

# ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញៈ **នយោបាយ ប្រាក់កាស និង ការភ័យខ្លាច គ្រប់គ្រង** ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ដោយរបៀបណា

របាយការណ៍ លីកាដូ
ខែឧសភា ២០០៨


លីកាដូ
សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE OF HUMAN RIGHTS
LICADHO

# ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ៖
## នយោបាយ ប្រាក់កាស និង ការភ័យខ្លាច គ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ដោយរបៀបណា

របាយការណ៍ លីកាដូ

ខែឧសភា ២០០៨


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួន ក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈ កម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំងប្រាំមួយរបស់ខ្លួនដូចខាងក្រោមៈ**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារ និងវិភាគឱ្យបានឆាប់រហ័ស។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយ ឱ្យពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារ នៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រនិងជួយបញ្ជូនជនរងគ្រោះ ដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទំនាក់ទំនង:**

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥)២៣ ៣៦០ ៩៦៥/៣៦៤ ៩០១

ទូរសារ: (៨៥៥)៣៦០ ៩៦៥/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: www.licadho.org

**ឧបត្ថមគាំទ្រពីស្ថានទូតអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ**

ដោយប្រើប្រាស់មូលនិធិកម្មវិធីយុទ្ធសាស្ត្ររបស់ FCO

# មាតិការឿង

សេចក្តីសង្ខេប ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ i

បុព្វកថា~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១

ភាគ ១: ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤

ប្រវត្តិសាស្រ្ត ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤

មុនឆ្នាំ១៩៥៣: សម័យអាណានិគមចាប់ផ្តើម ------------------------------------------- ៤

ឆ្នាំ១៩៥៣-១៩៧០: ការគ្រប់គ្រងសារព័ត៌មាន ------------------------------------------ ៥

ឆ្នាំ១៩៧០-១៩៧៥ : ការត្រួតពិនិត្យជាផ្លូវការ ------------------------------------------ ៧

ឆ្នាំ១៩៧៥-១៩៧៩ ( ឆ្នាំ សូន្យ) -------------------------------------------------------- ៨

ឆ្នាំ១៩៧៩-១៩៩៣: ក្រោមការត្រួតត្រារបស់កុម្មុយនីស្ត ---------------------------------- ៩

ឆ្នាំ១៩៩១-១៩៩៣ :សម័យអ៊ុនតាក់ ---------------------------------------------------- ១០

ឆ្នាំ ១៩៩៣- ២០០៨ : ការរីកចម្រើនយ៉ាងលឿន និងធ្វើទុក្ខបុកម្នេញ ------------------------ ១០

អ្នកស្តាប់/ទស្សនិកជន~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៤

ទស្សនៈនៃព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៧

សារព័ត៌មាន------------------------------------------------------------------------ ១៨

វិទ្យុ ------------------------------------------------------------------------------ ២៤

ទូរទស្សន៍ -------------------------------------------------------------------------- ២៧

អ៊ីនធឺណេត ------------------------------------------------------------------------ ៣១

សមាគមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៣

សមាគមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា--------------------------------------------- ៣៣

សមាគមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ ------------------------------------------- ៣៧

អំពើពុករលួយ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៩

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា និងច្បាប់ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤៣

កតិ្តកាសញ្ញាអន្តរជាតិ----------------------------------------------------------------- ៤៣

រដ្ឋធម្មនុញ្ញជាតិ------------------------------------------------------------------- ៤៤

ច្បាប់ជាតិ ----------------------------------------------------------------------- ៤៤

អ្នកសារព័ត៌មាន ជាអ្នកការពារសិទ្ធិមនុស្ស ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤៧

ភាគ ២៖ សេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបាន ព័ត៌មាន ~~~~~~~~~~~~~~~~~~៥០
ភាពជាម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មាន អាជ្ញាប័ណ្ណ និងភាពលំអៀង ខាងនយោបាយ ~~~៥០
តួនាទីរបស់រដ្ឋាភិបាល ------------------------------------------------------------------------៥២
ទូរទស្សន៍ ------------------------------------------------------------------------------------- ៥៤
វិទ្យុ ---------------------------------------------------------------------------------------- ៦៤
សារព័ត៌មាន-----------------------------------------------------------------------------------៧៤
សារព័ត៌មានភាសាបរទេស -----------------------------------------------------------------៨១
ការត្រួតពិនិត្យ និងការត្រួតពិនិត្យខ្លួនឯង ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~៨៤
ការត្រួតពិនិត្យ ------------------------------------------------------------------------------ ៨៤
ការត្រួតពិនិត្យខ្លួនឯង -----------------------------------------------------------------------៨៧
ការផ្អាក -----------------------------------------------------------------------------------------៨៨
ការរឹបអូស ----------------------------------------------------------------------------------- ៨៩
ការទទួលបានព័ត៌មាន~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៩១
ភាគ ៣៖ ការវាយប្រហារ ការគំរាមកំហែង និងការភ័យខ្លាច~~~~~~~~~~~~~~~~~~~~~~~~~ ៩៥
ការវាយប្រហារលើរូបរាងកាយ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~៩៥
ឃាតកម្ម----------------------------------------------------------------------------------------- ៩៦
ការបង្ករបួសស្នាម ----------------------------------------------------------------------------១០០
ការវាយប្រហារផ្នែកច្បាប់ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១០១
ការបំភិតបំភ័យ និងការភ័យខ្លាច~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១០៤
អនុសាសន៍ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១១០
ឧបសម្ព័ន្ធ ក៖ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~១១៤
ឧបសម្ព័ន្ធ ខ៖ វិធីសាស្ត្រនៃការស្រាវជ្រាវ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៣៦
ឧបសម្ព័ន្ធ គ៖ ឯកសារយោង ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៣៩

# សេចក្តីសង្ខេប

**សហព័ន្ធសារព័ត៌មានអន្តរជាតិ:** *"សារព័ត៌មានពុំអាចមានសេរីភាពទេ ប្រសិនបើអ្នកសារព័ត៌មានស្ថិតក្នុងស្ថានភាពពុករលួយ ក្រីក្រ ឬការភ័យខ្លាច"* ។

ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាច្រើនតែត្រូវបានគេពិពណ៌នាថា "ជាប្រព័ន្ធផ្សាយព័ត៌មានមួយដែលមានសេរីភាពជាងគេបំផុតនៅក្នុងតំបន់ ដោយគ្មានការត្រួតពិនិត្យជាផ្លូវការ និងសារព័ត៌មានមួយ" ដ៏ជឿនលឿន" ។

ប៉ុន្តែ ប្រសិនបើពិនិត្យមើលឱ្យឆ្ងាយហួសពីបរិមាណនៃសារព័ត៌មាន និងទស្សនាវដ្តី ព្រមទាំងស្តាប់អ្នកសារព័ត៌មាន និងបណ្ណាធិការរៀបរាប់អំពីបរិយាកាសការងាររបស់ពួកគេវិញ នោះយើងនឹងឃើញថា ប្រព័ន្ធផ្សាយព័ត៌មានត្រូវបានគ្រប់គ្រងយ៉ាងខ្លាំងដោយនយោបាយ ប្រាក់កាស និងការភ័យខ្លាច ។

ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាភាគច្រើនមានសម្ព័ន្ធភាពជាមួយគណបក្សនយោបាយ ដែលភាគច្រើនលំអៀងទៅគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច ។ លក្ខណៈបែបនេះប្រែប្រួលទៅតាមប្រព័ន្ធផ្សាយព័ត៌មាន ទូរទស្សន៍ ដែលម្ចាស់ ឬគ្រប់គ្រងដោយរដ្ឋាភិបាល ឬគណបក្សកាន់អំណាច ។

ស្ថានីយវិទ្យុមួយចំនួនតូចមានសម្ព័ន្ធភាពជាមួយគណបក្សជំទាស់ ហើយក៏មានសម្លេងឯករាជ្យសំខាន់ខ្លះដែរ ចំណែកសារព័ត៌មានភាគច្រើនដើរតួជាឧបករណ៍បញ្ចេញសម្លេងសំរាប់គណបក្សមួយ ឬគណបក្សដទៃទៀត លើកលែងតែសារព័ត៌មានជាភាសាបរទេស ។

ម្ចាស់ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា បង្កឱ្យមានការលំអៀងនយោបាយនៅក្នុងសេចក្តីរាយការណ៍សារព័ត៌មាន។ ភាពលំអៀងនេះ ត្រូវបានពង្រឹងថែមទៀតដោយវប្បធម៌ពុករលួយ ដែលអ្នកសារព័ត៌មានមួយចំនួនត្រូវបានទទួលប្រាក់កាសឱ្យចូលរួមក្នុងឱកាសសន្និសីទសារព័ត៌មាន និងថតរូបនានាជាការអនុវត្តន៍ទូទៅ ហើយសូម្បីតែអ្នកសារព័ត៌មានកម្ពុជាភាគច្រើនបានគិតថា នេះពុំមែនជាអំពើពុករលួយទេ។ ជាលទ្ធផលព័ត៌មាន គឺមានលក្ខណៈលំអៀងយ៉ាងខ្លាំងទៅខាងណាដែលមានលទ្ធភាពចំណាយថវិកាដូចជា រដ្ឋាភិបាល និងគណបក្សកាន់អំណាចជាដើម ។

ជាប្រវត្តិសាស្ត្រ កម្ពុជាមានប្រពៃណីសារព័ត៌មានសេរី និងឯករាជ្យតិចតួច។ កិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានចែងជាលើកដំបូងអំពីសេរីភាពប្រព័ន្ធផ្សាយព័ត៌មានដែលយ៉ាងតិចណាស់ក៏មាននៅក្នុងទ្រឹស្តីដែរ។ មន្ត្រីរដ្ឋាភិបាលដែលមិនទុកចិត្តនរណាទាំងអស់បានខិតខំប្រឹងប្រែងដោយលំបាកវេកវិធីត្រួតត្រាលើវិស័យប្រព័ន្ធផ្សាយព័ត៌មាន ដែលទើបតែដុះដាលឡើង ហើយនិងឥទ្ធិពលប្រព័ន្ធផ្សាយព័ត៌មានទៅលើមតិប្រជាពលរដ្ឋ។ ហើយពេលហ្នឹង អ្នកសារព័ត៌មានក៏ខិតខំស្វែងរក និងបំពេញតួនាទីរបស់ខ្លួនជាអ្នកសង្កេតការណ៍សំរាប់សាធារណៈជនទូទៅដែរ។

ការរីកចម្រើនប្រព័ន្ធផ្សាយព័ត៌មានយ៉ាងលឿន គឺក្នុងចំណោមសារព័ត៌មានទាំងឡាយ ហើយសារព័ត៌មានថ្មីៗជាច្រើនក៏ត្រូវបានបង្កើតឡើងដែរ។ ភាគច្រើននៃទំព័រសារព័ត៌មានទាំងនោះ បានឃោសនាសម្រាប់គណបក្សមួយ ឬ គណបក្សដទៃទៀត ហើយស្ថានភាពបែបនេះត្រូវបានបន្សល់ទុកមករហូតដល់សព្វថ្ងៃនេះ។ សារព័ត៌មានទាំងឡាយ (គ្រប់និន្នាការនយោបាយទាំងអស់) បានបោះពុម្ពជាច្រើន ព្រមទាំងធ្វើការរិះគន់ និងចោទប្រកាន់ខ្លាំងៗ ដោយពុំសូវមានភស្តុតាងគ្រប់គ្រាន់ទៅលើមេដឹកនាំដែលជំទាស់នឹងបក្សខ្លួន។ ជាលទ្ធផលគឺមានសារព័ត៌មានមួយដែលមានលក្ខណៈអ៊ូរអរ និងនាំឱ្យមានសភាពភ្ញាក់ផ្អើល ហើយយ៉ាងតិចណាស់ក៏បាននាំមកនូវទស្សនៈនយោបាយផ្សេងៗគ្នាដែរ បើទោះបីជាធម្មតា ពុំមែនជាសារព័ត៌មានដែលមានលក្ខណៈជាអាជីព ឬសមភាពក៏ដោយ។ បទដ្ឋានបណ្ណាធិការនៃសារព័ត៌មានទាំងនោះ ឃើញថាមានការប្រសើរជាងមុនចាប់តាំងពីឆ្នាំ១៩៩០ មក ក៏ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយដែរ។

ពុំមែនជាការចៃដន្យទេ ដែលរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានសារព័ត៌មានជាច្រើន តែការពិតមានឥទ្ធិពលតិចតួច ដោយសារតែពុំមានការចែកចាយឱ្យបានទូលំទូលាយ រួមជាមួយនឹងអត្រាអ្នកមិនចេះអក្សរខ្ពស់នៅកម្ពុជាផង។ ប៉ុន្តែបែរជាមានការរឹតត្បិតយ៉ាងតឹងរ៉ឹងចំពោះប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិចទៅវិញ។ រយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ជាទូទៅ រដ្ឋាភិបាលបានបដិសេធមិនផ្តល់អាជ្ញាប័ណ្ណវិទ្យុ និងទូរទស្សន៍ដល់អ្នកណាដែលរដ្ឋាភិបាលយល់ឃើញថាពុំមានអំណោយទានចំពោះគណបក្សកាន់អំណាច។ ទោះបីជាសម្ព័ន្ធភាពនៃគណបក្សជំទាស់ ឬអ្នកប្រតិបត្តិការឯករាជ្យបានទទួលអាជ្ញាប័ណ្ណវិទ្យុក៏ដោយ ក៏អាជ្ញាប័ណ្ណទូរទស្សន៍ធុនមធ្យមដែលមានកម្លាំងផ្សាយខ្លាំងជាងនេះមិនត្រូវបានអនុញ្ញាតទេ។

ទូរទស្សនិកជនដែលទស្សនាទូរទស្សន៍កម្ពុជា បានទទួលព័ត៌មានយ៉ាងច្រើនអំពីការឃោសនារបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាច។ ព័ត៌មានលំអៀងនេះ ពិសេសគឺការអវត្តមានអ្នកជំទាស់ ឬ សម្លេងឯករាជ្យណាមួយ រួមជាមួយនឹងការបញ្ចាំងរូបភាពនៃមន្ត្រីរដ្ឋាភិបាលសម្ភោធគម្រោងកសាងហេដ្ឋារចនា

សម្ព័ន្ធមិនចេះចប់ ឬ ប្រគល់ម្ហូបអាហារ ឬ ប្រាក់កាសដល់ប្រជាពលរដ្ឋ នោះជារូបភាពដែលអាចមានឥទ្ធិពល ដោយផ្ទាល់ទៅលើអ្នកបោះឆ្នោតកម្ពុជា។

ទោះបីគេតែងតែនិយមជឿថា មានសេរីភាពខាងប្រព័ន្ធផ្សាយព័ត៌មានក៏ដោយ ក៏ការត្រួតពិនិត្យពិតជាមាននៅកម្ពុជា។ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ទូរទស្សន៍ (ទទក) ព័ត៌មានណាដែលពាក់ព័ន្ធនយោបាយ និងរឿងវិវាទផ្សេងៗត្រូវឆ្លងកាត់ការត្រួតពិនិត្យពីសំណាក់មន្ត្រីជាន់ខ្ពស់នៃក្រសួងព័ត៌មាន ជាមុនសិន។ "ព័ត៌មានថ្មីៗហើយសំខាន់" ត្រូវបានហាមមិនឱ្យផ្សាយ ឬ ត្រូវកែសម្រួលធ្វើយ៉ាងណាឱ្យឆ្លុះបញ្ចាំងស្របតាមមាគ៌ារបស់រដ្ឋាភិបាល។

ប្រហែលជាអ្វីដែលសុសសាយជាងនេះទៅទៀត គឺការអនុវត្តន៍ដ៏ទូលំទូលាយនៃការត្រួតពិនិត្យខ្លួនឯង ដែលអាចជាបញ្ហាមួយធំជាងគេទាំងអស់សំរាប់សេរីភាពប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជា ដែលលាក់ទុករឿងរ៉ាវជាច្រើនពីសាធារណជន។ អ្នកសារព័ត៌មានបានដឹងឮអំពីរឿងដែលអាចនាំឱ្យមានបញ្ហាដល់ខ្លួនគេ ហើយបកស្រាយរឿងនោះដោយមានការប្រុងប្រយ័ត្នជាទីបំផុត ឬក៏បំភ្លេចចោល។

អ្នកសារព័ត៌មានជាច្រើនបានរិះគន់ចំពោះប្រព័ន្ធដែលពួកគេត្រូវបង្ខំឱ្យធ្វើការនៅក្នុងនោះ ជាពិសេសប្រាក់បៀវត្សរ៍ទាប ហើយមានអារម្មណ៍ថា ពួកគេត្រូវតែទ្រាំទ្រចំពោះស្ថានភាពបែបនេះ បើមិនដូច្នេះ ត្រូវប្រឈមមុខនឹងការបាត់បង់ការងារ ឬ ស្ថានភាពអាក្រក់ជាងនេះទៀត។

ការភ័យខ្លាចគឺជារឿងពិតនៃជីវិតរបស់អ្នកសារព័ត៌មានកម្ពុជាទាំងឡាយ។ នៅក្នុងការសិក្សាស្រាវជ្រាវមួយកាលពីឆ្នាំ២០០៧ ទៅលើអ្នកសារព័ត៌មានចំនួន ១៥០ នាក់ ដែលរៀបចំឡើងសម្រាប់របាយការណ៍នេះ ៦៥% នៃអ្នកសារព័ត៌មានទាំងនោះបាននិយាយថា ពួកគេមានការភ័យខ្លាចពីការវាយប្រហារលើរូបរាងកាយ ហើយ ៦២% ទៀតភ័យខ្លាចការប្រើប្រាស់វិធានការច្បាប់មកលើពួកគេ។ លើសពីនេះទៅទៀត មាន ៥៤% បាននិយាយថា ពួកគេធ្លាប់បានទទួលរងការគំរាមកំហែងធ្វើបាបលើរូបរាងកាយ ឬ ប្រើប្រាស់វិធានការច្បាប់។ យ៉ាងតិចណាស់អ្នកសារព័ត៌មាន ៩ នាក់ (ភាគច្រើនមកពីផ្នែកសារព័ត៌មាន) ជឿថាត្រូវបានគេសម្លាប់ដោយសារតែការងាររបស់ពួកគេ ចាប់តាំងពីកម្ពុជាមានរដ្ឋធម្មនុញ្ញថ្មី ឆ្នាំ១៩៩៣មក។ ពុំមានឃាតករណាម្នាក់ត្រូវបាននាំខ្លួនចូលតុលាការឡើយ ដែលនេះ គឺជាដំណឹងស្តីពីនិទ្ទណ្ឌភាពដ៏ខ្លាំងមួយសម្រាប់ពួកដែលចូលចិត្តវាយប្រហារទៅលើអ្នកសារព័ត៌មាន។

អ្នកសារព័ត៌មានខ្លះទៀតបានរងរបួសដោយការវាយដំ ឬរងការប៉ុនប៉ងធ្វើឃាតមិនបានសម្រេច ឬការិយាល័យរបស់ពួគេរងការលុកលុយចូលលួចសម្ភារៈដោយហ្វូងមនុស្សឥតសណ្ដាប់ធ្នាប់ ឬត្រូវទទួលរងការគប់គ្រាប់បែកចូលទៅក្នុងការិយាល័យរបស់ពួកគេ។ សំណាងដែរ ដែលអំពើឃាតកម្ម និងហិង្សាលើរាងកាយធ្ងន់ធ្ងរនានាមកលើប្រព័ន្ធផ្សាយព័ត៌មានបានថយចុះរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែការបង្ករបួសស្នាមតិចតួច និងការគំរាមកំហែងដល់អាយុជីវិតនៅតែបន្តមានដដែល។

ដូចគ្នានេះដែរ ចំពោះការវាយប្រហារតាមវិធីច្បាប់មកលើអ្នកសារព័ត៌មាននៅតែមាន។ ប៉ុន្មានឆ្នាំកន្លងទៅនេះ មានអ្នកសារព័ត៌មានច្រើនបានប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬគំរាមកំហែងមកលើពួកគេ ហើយមានអ្នកខ្លះជាប់ពន្ធនាគារផង។ ថ្មីៗកន្លងទៅនេះ ការចាប់ខ្លួនពួកអ្នករិះគន់ជាករណីដ៏ធំមួយរបស់ប្រមុខរដ្ឋាភិបាលដែលរួមមាន (ម្ចាស់ស្ថានីយ៍វិទ្យុផងដែរ) កាលពីខែធ្នូ ឆ្នាំ២០០៥ កន្លងទៅ ហើយក្រោយមកក៏មានមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលបានប្រើប្រាស់តុលាការ ឬការគំរាមប្រើប្រាស់វិធានការច្បាប់ដើម្បីដាក់ទណ្ឌកម្មពួកអ្នករិះគន់ ព្រមទាំងបំបិទមាត់ការតវ៉ា ។

តាមច្បាប់សារព័ត៌មានកម្ពុជាដែលមានលក្ខណៈរដ្ឋប្បវេណីឆ្នាំ១៩៩៥ បានចែងថា ជនណាដែលត្រូវបរិហារកេរ្តិ៍ដោយសារព័ត៌មានអាចស្វែងរកដំណោះស្រាយដើម្បីជួសជុលការខូចខាតតាមផ្លូវតុលាការ ដោយដំណោះស្រាយមានដូចជា ការស្នើឱ្យមានបញ្ចៅកែប្រែនៅក្នុងការផ្សាយ ឬទារសំណងជម្ងឺចិត្ត។ ប៉ុន្តែបណ្តឹង (រួមមានមន្ត្រីរដ្ឋាភិបាលផង) ច្រើនតែបំភ្លេចចោលនូវនីតិវិធីរដ្ឋប្បវេណីនេះហើយបែរជាប្តឹងដោយប្រើប្រាស់ក្រមព្រហ្មទណ្ឌកម្ពុជាទៅវិញ ដែលរួមមានបទល្មើសដូចជា បទបរិហារកេរ្តិ៍ ឬបង្ខូចកេរ្តិ៍ឈ្មោះ ការផ្សាយព័ត៌មានមិនពិត និងបទញុះញង់ជាដើម ។

ច្បាប់ស្តីពីសារព័ត៌មានបានចែងយ៉ាងច្បាស់ថា "គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដោយសារការបញ្ចេញមតិឡើយ" តែផ្ទុយទៅវិញ មាត្រានេះត្រូវបានរំលោភដដែលៗ។

ការកែប្រែច្បាប់ស្តីពីបទល្មើសបរិហារកេរ្តិ៍ និងបង្ខូចកេរ្តិ៍ឈ្មោះ កាលពីឆ្នាំ២០០៦ ត្រូវបានសហគមន៍អន្តរជាតិស្វាគមន៍យ៉ាងកក់ក្តៅ ប៉ុន្តែលទ្ធផលត្រឹមតែបានធ្វើឱ្យល្អមើលតែប៉ុណ្ណោះ។ អ្នកសារព័ត៌មាននៅតែប្រឈមមុខនឹងការជាប់ពន្ធនាគារតាមវិធីចោទប្រកាន់ផ្សេងទៀត ពីបទព្រហ្មទណ្ឌពីការផ្សព្វផ្សាយព័ត៌មានមិនពិត និងញុះញង់ជាដើម ឬប្រឈមមុខនឹងការពិន័យចំពោះបទបរិហារកេរ្តិ៍ដែលមានតម្លៃស្មើនឹងប្រាក់បៀវត្សរ៍ ១ឆ្នាំ ឬ ២ឆ្នាំ (ហើយអាចត្រូវបានឃុំខ្លួនជាកូនបំណុល ប្រសិនបើគ្មានប្រាក់បង់)។

ច្បាប់ស្តីពីសារព័ត៌មានបានផ្តល់អំណាចឱ្យរដ្ឋាភិបាលផ្អាកការផ្សាយរយៈពេល៣០ ថ្ងៃ ព្រមទាំងរឹបអូសសារព័ត៌មានច្បាប់ណាដែលចេញផ្សាយល្មើស ប្រសិនបើសារព័ត៌មាននោះផ្សាយព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ "ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ"។ ពាក្យពេចន៍ទាំងនេះពុំត្រូវបានកំណត់អត្ថន័យទេនៅក្នុងច្បាប់ ហើយបទបញ្ញត្តិនេះច្រើនតែត្រូវបានគេយកមកប្រើប្រាស់ខុស ដើម្បីបំបិទមាត់ពួកអ្នកជំទាស់ដាក់ទណ្ឌកម្មពួកអ្នកសរសេរបង្ខូចឈ្មោះ និងធ្វើការត្រួតពិនិត្យព័ត៌មានណាដែលនាំឱ្យខូចមុខមាត់របស់រដ្ឋាភិបាល។

ដូចគ្នាដែរ ចំពោះការភ័យខ្លាចពីការវាយប្រហារលើរូបរាងកាយ និងប្រើប្រាស់វិធានការច្បាប់ និងកង្វះឯករាជ្យភាពក្នុងការបញ្ចេញមតិដែលផ្តល់ឱ្យអ្នកសារព័ត៌មានដោយអ្នកគ្រប់គ្រងរបស់ខ្លួន។ អំពើពុករលួយខ្លះៗ នៅក្នុងប្រព័ន្ធផ្សាយព័ត៌មានក៏បានជម្រុញឱ្យមានសេចក្តីរាយការណ៍លំអៀង និងជ្រើសរើសចន្លោះៗ។ នៅក្នុងការសិក្សាដែលធ្វើឡើងសម្រាប់របាយការណ៍នេះបង្ហាញថា ២៥% នៃអ្នកឆ្លើយសំណួរសម្ភាសន៍បាននិយាយថា ពួកគេបានស្គាល់អ្នកសារព័ត៌មានដែលទទួលសំណូកដើម្បីផ្សាយព័ត៌មានតាមចិត្តអ្នកសូកចង់បាន ហើយ ៣៥% ទៀត មិនចង់ឆ្លើយសំណួរសម្ភាសន៍នេះ។ នៅមានអ្នកសារព័ត៌មានច្រើនទៀតគឺ ៣៤% និយាយថា ពួកគេធ្លាប់ស្គាល់សហការីរបស់ខ្លួនដែលទទួលសំណូកដើម្បីបំបិទព័ត៌មាន។

ប៉ុន្តែ នៅមានសង្ឃឹមលើក្រុមខ្លះដែរចំពោះប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា។

សេវាកម្មវិទ្យុឯករាជ្យផ្សាយសម្លេងអន្តរជាតិដូចជា វិទ្យុអាស៊ីសេរី វិទ្យុអន្តរជាតិបារាំង និងសម្លេងសហរដ្ឋអាមេរិកជាដើម ដែលផ្តល់នូវតុល្យភាពទល់នឹងព័ត៌មានវិទ្យុ-ទូរទស្សន៍លំអៀងយ៉ាងខ្លាំងទៅខាងគណបក្សកាន់អំណាច ហើយរាយការណ៍យ៉ាងសេរីអំពីនយោបាយ ការកាប់ឈើខុសច្បាប់ ការរំលោភដីធ្លី និងអំពើពុករលួយ។ តាមរបាយការណ៍ដែលថា មានអ្នកស្តាប់ព័ត៌មានពីវិទ្យុទាំងនេះជាច្រើនជាការបង្ហាញឱ្យឃើញថា ពលរដ្ឋកម្ពុជាជាច្រើនមានសេចក្តីស្រេកឃ្លានយ៉ាងខ្លាំងនូវព័ត៌មានឯករាជ្យ និងព័ត៌មានដែលចេញមកពីប្រភពមិនមែនរដ្ឋាភិបាល។ សូម្បីតែសារព័ត៌មានប្រកាន់បក្សពួក ដែលភាគច្រើនច្រើនតែជាសារព័ត៌មានខ្វះក្រមសីលធម៌ និងពោរពេញទៅដោយការឃោសនាក្តី យ៉ាងតិចណាស់ក៏គាំទ្រនយោបាយផ្សេងៗ ដែលអាចឮក្នុងទីផ្សារសារព័ត៌មានដ៏តូចចង្អៀតក្នុងទីក្រុងផងដែរ។

ក្នុងរង្វង់សហគមន៍អ្នកសារព័ត៌មានកម្ពុជា ក៏មានព័ត៌មានល្អៗជាច្រើនក្នុងចំណោមព័ត៌មានដែលមិនល្អផងដែរ។ ទន្ទឹមនឹងមានអ្នកយកព័ត៌មាន និងបណ្ណាធិការមួយចំនួនប្រឹងស្រែកឃោសនានយោបាយ

ដោយចេតនា ឬជម្រើតទារប្រាក់ ក៏នៅមានអ្នកសារព័ត៌មានមួយចំនួនយល់ពីការទទួលខុសត្រូវរបស់ខ្លួនដែលត្រូវផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋ និងរាយការណ៍ដោយស្មោះត្រង់។ អ្នកសារព័ត៌មានជាច្រើនទៀតបង្ហាញនូវបំណងធ្វើឱ្យមានការប្រសើរជាងនេះ ប្រសិនបើស្ថានភាពអំណោយផល។

ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា បានវិវត្តយ៉ាងលឿនទៅមុខចាប់តាំងពីប៉ុន្មានទសវត្សរកន្លងមកនេះ ជាមួយនឹងការកែលំអយ៉ាងប្រសើរ ពីសម័យកាលដ៏ខ្មៅងងឹតនៃការគ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មានទាំងស្រុងដោយខ្មែរក្រហម និងក្រោយមកដោយវៀតណាម។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តីក៏ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាកំពុងស្ថិតនៅឆ្ងាយពីសេរីភាពផងដែរ។ តាមរយៈវិធីសាស្ត្រនានា ជាពិសេស ពួកម្ចាស់ប្រព័ន្ធផ្សាយព័ត៌មានបានបង្កើតឱ្យមានលំអៀង នយោបាយ និងការភ័យខ្លាច គណបក្សកាន់អំណាចបានត្រួតពិនិត្យយ៉ាងហ្មត់ចត់លើអ្នកសារព័ត៌មាន និងវិធីដែលពួកនោះរាយការណ៍ព័ត៌មាន។

# បុព្វកថា

អ្នកស្រី Jennifer Windson, នាយកប្រតិបត្តិរបស់អង្គការ "ផ្ទះសេរីភាព" ក្នុងការស្រាវជ្រាវជាសកលមួយទៅលើឯកភាពនៃប្រព័ន្ធផ្សាយព័ត៌មាន នៅថ្ងៃទី២ ឧសភា ២០០៧ បានមានសរសេរថាៈ "*សេរីភាពសារព័ត៌មានគឺប្រៀបដូចជាសត្វចាបមួយនៅក្នុងរ៉ែថ្យូង... បើមានការរំលោភលើប្រព័ន្ធផ្សាយព័ត៌មាននៅពេលបន្តទៀត មិនអាចចៀសផុតពីការរំលោភលើស្ថាប័នប្រជាធិបតេយ្យទេ*" ។

របាយការណ៍នេះផ្តោតទៅលើប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាប៉ុណ្ណោះ ដោយរួមមានស្ថានីយ៍ទូរទស្សន៍ និងវិទ្យុ សារព័ត៌មាន ព្រមទាំងផ្តោតខ្លះៗទៅលើអ៊ីនធឺណេត។ របាយការណ៍នេះនឹងពិនិត្យមើលពីប្រព័ន្ធផ្សាយព័ត៌មាន ពីទស្សនៈសិទ្ធិមនុស្ស ពិនិត្យមើលលក្ខណៈនៃសេរីភាពសារព័ត៌មាន ការទទួលបានព័ត៌មាន ការវាយប្រហារ និងការគំរាមកំហែងលើអ្នកសារព័ត៌មាន។ របាយការណ៍នេះផ្អែកទៅលើឯកសារស្រាវជ្រាវ ការសម្ភាសន៍ដ៏ស៊ីជម្រៅ និងការសិក្សាស្រាវជ្រាវទៅលើអ្នកសារព័ត៌មានកម្ពុជា ១៥០ នាក់ ។

លទ្ធផលនៃការស្រាវជ្រាវនេះ អាចធ្វើឱ្យមានការភ្ញាក់ផ្អើលខ្លះអំពីប្រព័ន្ធផ្សាយព័ត៌មាន ដែលគេច្រើនតែលើកឡើងថា ជាប្រព័ន្ធផ្សាយព័ត៌មានមួយដែលមានសេរីភាពជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍។

ប្រព័ន្ធផ្សាយព័ត៌មានដ៏រឹងប៉ឹងមួយ ត្រូវបានមនុស្សគ្រប់គ្នាទទួលស្គាល់តាំងពីយូរលង់មកហើយថា ជាផ្នែកមួយសំខាន់ណាស់នៃលទ្ធិប្រជាធិបតេយ្យដែលរឹងមាំ។ ក្នុងឱកាសដ៏ល្អបំផុត ប្រព័ន្ធផ្សាយព័ត៌មាន គឺជាប្រភពនៃព័ត៌មានសម្រាប់សាធារណជនទូទៅអំពីសង្គម និងរដ្ឋាភិបាលរបស់ពួកគេ។ ជាពិសេស ព័ត៌មានកាន់តែសំខាន់ណាស់នៅពេលមានការបោះឆ្នោត និងការពិភាក្សានានាអំពីនយោបាយ។ ឱកាសដ៏អ័ព្ទអួរបំផុតប្រព័ន្ធផ្សាយព័ត៌មានអាចក្លាយទៅជាឧបករណ៍មួយសម្រាប់ផ្សព្វផ្សាយដំណឹងមិនពិត និងការឃោសនា។

ផ្តើមចេញពីទស្សនៈសិទ្ធិមនុស្ស មុខងាររបស់ប្រព័ន្ធផ្សាយព័ត៌មានគឺផ្សារភ្ជាប់ជាមួយសិទ្ធិជាមូលដ្ឋានពីរសំខាន់ៗនោះគឺ សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី និងសិទ្ធិក្នុងការទទួលបានព័ត៌មាន។ សិទ្ធិទាំងនេះត្រូវបានការពារដោយៈ អនុសញ្ញាអន្តរជាតិជាច្រើន ដែលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន រដ្ឋធម្មនុញ្ញកម្ពុជា និងភាគខ្លះនៃច្បាប់កម្ពុជាមួយចំនួនទៀត។

សិទ្ធិក្នុងការស្វែងរកព័ត៌មាន និងទំនាក់ទំនងព័ត៌មាន ព្រមទាំងទស្សនៈ គឺជាសិទ្ធិដែលពលរដ្ឋកម្ពុជាគ្រប់រូបត្រូវបានអនុញ្ញាតតាមច្បាប់កំណត់ ប៉ុន្តែម្ចាស់ប្រព័ន្ធផ្សាយព័ត៌មាន និងរដ្ឋាភិបាល ព្រមទាំងតុលាការបានរួមគ្នារឹតត្បិតកំណត់ព្រំដែនចំពោះការអនុញ្ញាតនេះទៅវិញ។

អ្នកសារព័ត៌មានដែលបានអនុវត្តសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួននៅកម្ពុជា ជួនកាលត្រូវរងការវាយប្រហារទៅវិញទាំងផ្នែករាងកាយ និងវិធានការច្បាប់។ បើគិតពីតួនាទីដ៏សំខាន់ណាស់នៃប្រព័ន្ធផ្សាយព័ត៌មានក្នុងលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដ ការវាយប្រហាររបៀបនេះគឺគេចាត់ទុកថាជាការគំរាមកំហែងលើអ្នកសារព័ត៌មានដែលជាអ្នកការពារសិទ្ធិមនុស្ស។

អ្នកការពារសិទ្ធិមនុស្ស គឺជាមនុស្សណាម្នាក់ដែលដើរតួតែម្នាក់ឯង ឬជាមួយអ្នកដទៃដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាមូលដ្ឋានតាមវិធីអហិង្សា។ អ្នកសារព័ត៌មានគឺជាមនុស្សដែលដើរតួជាអ្នកការពាសិទ្ធិមនុស្សនេះតាមរយៈការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស ជួយសម្លេងគាំទ្រដល់ជនរងគ្រោះ និងជម្រុញឱ្យមានយុត្តិធម៌។ ជាទស្សនៈដ៏ទូលំទូលាយ ពួកអ្នកសារព័ត៌មានក៏ជាអ្នកការពារសិទ្ធិមនុស្សដែរ តាមរយៈការផ្សព្វផ្សាយ និងលាតត្រដាងនូវព័ត៌មានពាក់ព័ន្ធដល់សង្គមកម្ពុជា ហើយនឹងធាតុពិតនៃនយោបាយតាមរយៈការអនុវត្តសិទ្ធិក្នុងការទទួលបានព័ត៌មានសាធារណៈ។

របាយការណ៍នេះ មានគោលបំណងពីរ ទី១ គឺដើម្បីពិនិត្យមើលបរិយាកាសប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាបច្ចុប្បន្ន អំពីបញ្ហាសេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន និងទី២ គឺពិនិត្យមើលការវាយប្រហារមកលើអ្នកសារព័ត៌មាន។

ចំណុចសំខាន់គឺដើម្បីរកគុណវិបត្តិរបស់សារព័ត៌មានខ្មែរ (ព្រមទាំងភាពខ្លាំងខ្លះៗផងដែរ) និងវិធីសាស្ត្រត្រួតត្រានានា ដែលជាធម្មតា អ្នកអាន អ្នកស្តាប់ និងអ្នកតាមដានមើល មិនអាចមើលឃើញនូវបញ្ហាទាំងនោះឡើយ។

របាយការណ៍នេះក៏ជាផ្នែកមួយនៃគម្រោងបង្កើនការយល់ដឹងដ៏ទូលំទូលាយអំពីតួនាទីរបស់អ្នកសារព័ត៌មាន ដែលអាចដើរតួនាទីជាអ្នកការពារសិទ្ធិមនុស្ស ជាតួនាទីដែលផ្តល់ផលប្រយោជន៍ដល់សាធារណៈជន សង្គមស៊ីវិល និងលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដ។ គម្រោងនេះក៏មានគោលបំណងដើម្បីបង្កើនសមត្ថភាពអ្នកសារព័ត៌មានដើម្បីការពារខ្លួនគេ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា និងអង្គការផ្សេងទៀតឱ្យតស៊ូមតិក្នុងការបញ្ចេញមតិនៅកម្ពុជាឱ្យបានស្របតាមបទដ្ឋានអន្តរជាតិ។

## សេចក្តីថ្លែងអំណរគុណ និងកំណត់សម្គាល់អំពីវិធីសាស្ត្រ

ព័ត៌មាននានានៅក្នុងរបាយការណ៍នេះបានមកពីប្រភពធំៗ ៣ គឺ :

- ការសិក្សាស្រាវជ្រាវប្រព័ន្ធផ្សាយព័ត៌មានលើអ្នកយកព័ត៌មាន ១៤១ នាក់ដែលជាអ្នកសារព័ត៌មាន បណ្ណាធិការ អ្នកថតរូប និងអ្នកថតវីដេអូបុរស/ស្ត្រីនៅភ្នំពេញ និងទីរួមខេត្ត ១២ ខេត្ត។
- បទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធប្រព័ន្ធផ្សាយព័ត៌មានសំខាន់នានា
- សៀវភៅរបាយការណ៍ និងអត្ថបទនានា

លទ្ធផលពិស្តារនៃការសិក្សាស្រាវជ្រាវនេះ និងការពិពណ៌នាពិស្តារនៃវិធីសាស្ត្រដែលលើកយកមកប្រើត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ។

មនុស្សភាគច្រើននៃផ្នែកប្រព័ន្ធផ្សាយព័ត៌មាន ដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះត្រូវបានសន្យាថា ឈ្មោះ និងមុខងាររបស់ពួកគេមិនត្រូវបានប្រើទេ។ ប៉ុន្តែអាចប្រើបាននូវតួនាទីទូទៅ (ឧ. អ្នកយកព័ត៌មានជើងចាស់) អាចប្រើបានដើម្បីបង្ហាញនូវជំនាញ ឬទស្សនៈរបស់ពួកគេ។ ភាពអនាមឹកនេះត្រូវបានចាត់ទុកថាជាផ្នែកមួយចាំបាច់ដើម្បីឱ្យប្រភពផ្តល់ព័ត៌មានទាំងនោះហ៊ាននិយាយអំពីបញ្ហាចម្បងៗដោយពុំមានការភ័យខ្លាចអំពីការផ្តន្ទាទោសឡើយ។

សូមមើលឯកសារយោងនៅទំព័រ (ឧបសម្ព័ន្ធ) ខាងក្រោម ចំពោះប្រភពឯកសារសំខាន់ៗដែលលើកឡើងក្នុងរបាយការណ៍នេះ។

អ្នកសរសេររបាយការណ៍ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមផ្តល់បទសម្ភាសន៍ទាំងអស់ដែលបានចំណាយពេលវេលា និងសន្តានចិត្ត។ អរគុណចំពោះអ្នកសារព័ត៌មានជាច្រើនដែលបានចំណាយពេលវេលាដើម្បីបំពេញបញ្ជីសំណួរនានា ជាពិសេសអរគុណចំពោះអ្នកដែលហ៊ានឆ្លើយនូវសំណួរលំបាកៗជាច្រើនដោយស្មោះត្រង់។ អវសាន្ត អរគុណដល់បុគ្គលិកលីកាដូតាមបណ្តាខេត្តដែលបានចែកចាយ និងប្រមូលបញ្ជីសំណួរនៅក្នុងខេត្តរបស់ខ្លួន។

# ភាគ ១: ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

## ប្រវត្តិសាស្ត្រ

ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជាបច្ចុប្បន្ន គួរពិនិត្យមើលនៅក្នុងបរិបទនៃប្រវត្តិសាស្ត្រ និងការវិវត្ត។ តាំងពីដើមមក នៅកម្ពុជាឃើញមានសេរីភាពប្រពន្ធ័ផ្សព្វផ្សាយព័ត៌មានតិចតួច។ របបថ្មីដែលបន្តពីរបបមុនៗបានមើលឃើញថា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគឺជាឧបករណ៍មួយដើម្បីធ្វើការឃោសនា ឬពេលដែលអ្នកសារព័ត៌មានព្យាយាមរុញច្រានដែនកំណត់នៃសេរីភាពក្នុងការបញ្ចេញមតិ នោះវាជាគោលដៅសម្រាប់ការគាបសង្កត់។ តាំងពីសម័យអាណានិគមបារាំងរហូតមកដល់របបប្រល័យពូជសាសន៍ខ្មែរក្រហមក្នុងទសវត្សឆ្នាំ១៩៧០ និងរបបកុម្មុយនីស្តដែលគាំទ្រដោយវៀតណាមដែលកាន់អំណាចបន្តបន្ទាប់មកអំណាចប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវបានគាបជាប់។

មកដល់សករាជថ្មីនៃសេរីភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន យ៉ាងតិចណាស់ក៏នៅក្នុងទ្រឹស្តីដែរ ត្រូវបានបង្ហាញទិសដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ក្នុងការបោះឆ្នោតជាតិដែលត្រួតពិនិត្យដោយអង្គការសហប្រជាជាតិនៅពេលក្រោយមក និងរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជាឆ្នាំ១៩៩៣។ ពេលនោះបានបង្ហាញឡើងនូវការរីកចម្រើនដែលភាគច្រើនជាសារព័ត៌មាន បន្តបន្ទាប់មកមានចំនួនតិចជាងគឺប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិច។ មន្ត្រីរដ្ឋាភិបាលដែលមិនទុកចិត្តនរណាទាំងអស់បានខំប្រឹងប្រែងដោយលំបាករកវិធីដើម្បីត្រួតត្រាប្រពន្ធ័ផ្សព្វផ្សាយព័ត៌មាន ហើយក៏រិតនូវឥទ្ធិពលរបស់ប្រពន្ធ័ផ្សព្វផ្សាយព័ត៌មានដែលមាននៅលើមតិសាធារណៈ។ ចំណែកអ្នកសារព័ត៌មានខ្លួនឯង (នៅក្នុងប្រទេសមួយដែលមានប្រពៃណី ឯករាជ្យ និងវិជ្ជាជីវៈខាងសារព័ត៌មានតិចតួច) បានខិតខំតស៊ូដើម្បីស្វែងរក និងបំពេញតួនាទីរបស់ខ្លួនជាអ្នកឃ្លាំមើលសម្រាប់សាធារណៈ។

### *មុនឆ្នាំ១៩៥៣: សម័យអាណានិគមចាប់ផ្តើម*

ក្នុងកំឡុងឆ្នាំ១៩២០ ប្រទេសកម្ពុជាមានសារព័ត៌មាន ៣ គឺ L’ Echo du Cambodge and L’Impartial de Phnom Penh ជាភាសាបារាំង និងសារព័ត៌មានភាសាវៀតណាមឈ្មោះ Cao-mien

Huong-truyen[1] ។ ព្រឹត្តិប័ត្រព័ត៌មានប្រចាំខែសរសេរដោយដៃហៅថា កម្ពុជាសូរិយា ចេញផ្សាយដោយពុទ្ធសាសនបណ្ឌិត ប៉ុន្តែផ្សាយអំពីកិច្ចការសាសនា និងអក្សរសាស្ត្រតែប៉ុណ្ណោះ[២] ។

សារព័ត៌មានជាភាសាខ្មែរដំបូងបង្អស់ឈ្មោះ នគរវត្ត ចេញផ្សាយក្នុងឆ្នាំ១៩៣៦ ខណៈដែលប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមនិយមបារាំង។ សារព័ត៌មាន នគរវត្ត ចេញផ្សាយពីរដងក្នុងមួយសប្តាហ៍ ហើយមិនយូរប៉ុន្មានលក់អស់ ៥.000 ច្បាប់ចេញផ្សាយម្តងៗ[៣] ។ សារព័ត៌មាននោះគឺជាសារព័ត៌មានជាតិនិយមប្រឆាំងវៀតណាម ហើយដល់ដើមទសវត្សរ៍ឆ្នាំ១៩៤០ ជាសារព័ត៌មានរិះគន់បារាំង។ សារព័ត៌មាននោះត្រូវបានបិទទៅវិញ ក្រោយពីបណ្ណាធិការម្នាក់នៃសារព័ត៌មាននោះបានដឹកនាំបាតុកម្មប្រឆាំងបារាំងក្នុងឆ្នាំ១៩៤២[៤] ។

បណ្តាញផ្សាយព័ត៌មានរបស់រដ្ឋតាមវិទ្យុជាតិត្រូវបានបើកឡើងនៅឆ្នាំ១៩៤៧ ក្រោមការគ្រប់គ្រងរបស់ក្រសួងឃោសនាការ[៥] ។

ឆ្នាំ១៩៥២ បណ្ណាធិការនៃសារព័ត៌មាន នគរវត្តម្នាក់ ឈ្មោះសឺង ង៉ុកថាញ់ ត្រឡប់ពីនិរទេសខ្លួនវិញបានចាប់ផ្តើមបើកសារព័ត៌មានមួយឈ្មោះថា "*ខ្មែរក្រោក*" ចំណងជើងបង្ហាញនូវទំនាក់ទំនងរវាងប្រព័ន្ធផ្សាយព័ត៌មាន និងការកើនឡើងនៃអត្តសញ្ញាណជាតិ[៦] ។

## ឆ្នាំ១៩៥៣_១៩៧០: ការគ្រប់គ្រងសារព័ត៌មាន

មកដល់ពាក់កណ្តាលឆ្នាំ១៩៦០ មានសារព័ត៌មានចេញផ្សាយប្រចាំថ្ងៃច្រើនរហូត១៣ សារព័ត៌មាន ២ចេញផ្សាយមួយសប្តាហ៍ម្តង ៣ចេញផ្សាយមួយខែម្តង ព្រមទាំងចេញផ្សាយ បន្ថែមនៅថ្ងៃអាទិត្យ និងសារព័ត៌មានខ្លីៗប្រចាំថ្ងៃ បោះពុម្ពដោយម៉ាស៊ីនរ៉ូណេអូ។ ប៉ុន្តែយោងតាមអ្នកនិពន្ធខ្លះ សារព័ត៌មានជាច្រើនដើរតួជា"ឧបករណ៍ឃោសនា" និងជួយ "កសាងនូវប្រជាភិថុត" តែប៉ុណ្ណោះ[៧] ។

---

[១] ឡោ ច័ន្ទដារ៉ា : សារព័ត៌មានកម្ពុជាបានលេចឡើងនូវលទ្ធិប្រជាធិប្បតេយ្យ។ ឯកសារដាក់ជូនសិក្ខាសាលាសារព័ត៌មាន ថ្នាក់តំបន់ឆ្នាំ២០០៣ ។

[២] Harish C.Mehta: ភាពស្ងប់ស្ងាត់កម្ពុជា-សារព័ត៌មានក្រោម ៦ របប។ ទំ. ២៨ ។

[៣] Davide P. Chandler ប្រវត្តិសាស្ត្រកម្ពុជា (បោះពុម្ពលើកទី ២) ១៩៩៣ ទំ. ១៥៩ ។

[៤] Davide P. Chandler ប្រវត្តិសាស្ត្រកម្ពុជា ទំ. ១៦៦ ដល់ ១៦៨ ។

[៥] ពុយ គា: ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ឆ្នាំ ២០០៧ ។

[៦] Davide P. Chandler ប្រវត្តិសាស្ត្រកម្ពុជា ទំ. ១៦៤ ។

[៧] Harish C. Mehta. ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ៣៧ ។

ពីឆ្នាំ១៩៤១-១៩៧០[៨] សារព័ត៌មានច្រើនតែត្រូវបានត្រួតពិនិត្យ អ្នកសារព័ត៌មានត្រូវជាប់ពន្ធនាគារ ហើយសារព័ត៌មានត្រូវបានបិទជាញឹកញាប់ដើម្បីបំបិទសម្លេងពួកប្រឆាំង។ បញ្ហានេះបានបណ្តាលឱ្យប្រព័ន្ធផ្សាយព័ត៌មានធ្វើការត្រួតពិនិត្យដោយខ្លួនឯង[៩]។

បណ្ណាធិការសារព័ត៌មានម្នាក់ ឈ្មោះ សាឡុត ឆាយ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៥៥ បុរសនោះត្រូវជាបងរបស់ សាឡុត ស (គេស្គាល់ឈ្មោះ ប៉ុល ពត ច្រើនជាង ដែលក្រោយមកក្លាយជាមេដឹកនាំខ្មែរក្រហម)[១០]។ លោក ខៀវ សំផន ដែលក្រោយមកក្លាយជាប្រមុខរដ្ឋនៃរបបខ្មែរក្រហមត្រូវបានវាយដំស្រាតខោ ដោះអាវ ហើយថតរូបដោយនគរបាលស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលដោយសារតែគាត់បានសរសេរនៅក្នុងសារព័ត៌មានប្រចាំសប្តាហ៍ "L'Observateur អ្នកសង្កេតការណ៍របស់គាត់"[១១] ។

សម្តេចសីហនុច្រើនតែជំរុញឱ្យអ្នកសារព័ត៌មានបរទេសតបតគ្នាទៅវិញទៅមក បោះពុម្ពសារឡើងវិញនូវរឿងដែលព្រះអង្គគាប់ព្រះទ័យនៅក្នុងទស្សនាវដ្តី កាំបូហ្សា របស់ព្រះអង្គ ហើយប្រើប្រាស់រឿងរ៉ាវទាំងនោះដើម្បីឆ្លើយតបទៅអ្នករិះគន់ព្រះអង្គ។ ក្នុងឆ្នាំ១៩៦៤ សម្តេចសីហនុ បានប្រកាសថាព្រះអង្គនឹងបង្កើត "វិចិត្រសាលពាល" មួយកន្លែងដើម្បីតាំងរូបថតពួកអ្នកសារព័តមានណាដែលពូកែរិះគន់ដើម្បីបង្ហាញជាសាធារណៈ។ នៅឆ្នាំក្រោយ១មក ព្រះអង្គបានហាមប្រាមអ្នកសារព័ត៌មានបស្ចឹមប្រទេសទាំងអស់ ហើយបានចោទប្រកាន់លោក បែរណា គ្រីស័រ នៃ Newsweek ដែលក្រោយមកជាស្ថាបនិកនៃសារព័ត៌មាន (ឌឹ ឃែមបូឌាដេលី) ថាបានប្រមាថមើលងាយព្រះមហាក្សត្រិយានី។ ការហាមប្រាមនោះ ត្រូវបានជ្រើសរើសមកអនុវត្តបានខ្លះៗ[១២] ។

ក្នុងឆ្នាំ១៩៦០ ប្រទេសចិនបានប្រគល់ស្ថានីយវិទ្យុ AM ទី ២ ឱ្យកម្ពុជាជាផ្លូវការ ដែលមានឈ្មោះថា វិទ្យុសម្លេងកម្ពុជា ដែលនោះក៏ជាឧបករណ៏សម្រាប់ឃោសនាផងដែរ[១៣] ។

មកដល់ ខែកុម្ភៈ ឆ្នាំ១៩៦៦ ទូរទស្សន៍កម្ពុជាបានចាប់ផ្តើមផ្សាយ ជាទូរទស្សន៍ ស-ខ្មៅ ។

---

[៨] ចំពោះផ្នែកខ្លះនៃសម័យនោះ សម្តេច សីហនុពេលខ្លះ ព្រះអង្គពុំមែនជាព្រះរាជាទេ។ ទ្រង់គ្រងរាជសម្បត្តិពីឆ្នាំ ១៩៤១ ដល់ ១៩៥៥ ក្រោយទ្រង់បានដាក់រាជដើរតួជាអ្នកនយោបាយដ៏សំខាន់ ហើយជាប្រមុខរដ្ឋពីឆ្នាំ១៩៦០ ដល់ ១៩៧០។

[៩] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ៣៨ ។

[១០] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ៤០ ។

[១១] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ៤១ ។

[១២] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ៧០-៨៦ ។

[១៣] ពុយ គា ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ។

## ឆ្នាំ១៩៧០_១៩៧៥ : ការត្រួតពិនិត្យជាផ្លូវការ

នៅពេលដែល លន់ នល់ ទម្លាក់សម្ដេច សីហនុ នៅថ្ងៃទី១៨ មិនា ១៩៧០ សារព័ត៌មានដ៏ធំជាងគេនៅក្នុងប្រទេសគឺ កោះសន្តិភាព រង់ចាំមួយថ្ងៃដើម្បីកំណត់លទ្ធផលនយោបាយ នៃចលនាហើយក្រោយមកក៏បានប្តូរគោលនយោបាយរបស់ខ្លួនបែរមកគាំទ្រ លន់ នល់ វិញ។ សារព័ត៌មានប្រចាំថ្ងៃធំៗពីរទៀតគឺ នគរធំ និងខ្មែរឯករាជ្យក៏បានប្តូរទិសដៅដូចគ្នាដែរ ដើម្បីជៀសវាងពីការផ្ដន្ទាទោសដាក់ពន្ធនាគារ[១៤]។

លន់ នល់ បានណែនាំឱ្យមានការត្រួតពិនិត្យសារព័ត៌មានទាំងអស់ជាផ្លូវការ ដោយក្រសួងព័ត៌មាន ប៉ុន្តែក្រោយមកក៏បានផ្អាកទៅវិញនៅខែសីហា ឆ្នាំ១៩៧០។ ជាដំបូង កោះសន្តិភាព បានតវ៉ាជំទាស់ ដោយបានបោះពុម្ពពណ៌-សសុទ្ធនៅលើទំព័រសារព័ត៌មាន ដោយលុបចោលនូវអត្ថបទទាំងឡាយ ដែលត្រូវបានត្រួតពិនិត្យ ប៉ុន្តែក្រោយៗមក សារព័ត៌មាននោះក៏ឈប់សរសេរអត្ថបទរិះគន់ទៅ[១៥]។

នៅឆ្នាំ១៩៧២ លន់ នល់ បានចេញច្បាប់សារព័ត៌មានមួយយ៉ាងតឹងរឹងដែលហាមមិនឱ្យបង្ខូច "កិត្តិយសរបស់បុគ្គលណាម្នាក់" ហើយដូច្នេះបានបណ្តាលឱ្យមានរឿងស្ងប់ស្ងាត់អំពីអំពើពុករលួយ និងការរំលោភបំពានផ្សេងៗទៀត។

រោងចក្រផលិតក្រដាសកម្ពុជាតែមួយគត់នៅខេត្តក្រចេះ ត្រូវកងទ័ពខ្មែរក្រហមវាយដណ្ដើមបាន ដែលជាការបង្កើនតម្លៃបោះពុម្ពសារព័ត៌មាន ដែលកំពុងតែថ្លៃខ្ពស់ស្រាប់ទៅហើយ។ យោងតាមប្រភពព័ត៌មានមួយបានឱ្យដឹងថា មានបទបញ្ញត្តិថ្មីមួយដែលតម្រូវឱ្យបង់ប្រាក់១.៦លានរៀលដើម្បីសុំអាជ្ញាប័ណ្ណសារព័ត៌មានដែលបញ្ហានេះបានធ្វើឱ្យកាន់តែលំបាកឡើងក្នុងការបន្តអាជីវកម្មរបស់ខ្លួន ហើយនៅពេលដែលរដ្ឋាភិបាល លន់ នល់ ចាប់ផ្តើម គេឃើញមានសារព័ត៌មានចំនួន ២០ ហើយចំនួននេះបានថយមកនៅត្រឹម ៤ ឬ ៥ សារព័ត៌មានប៉ុណ្ណោះមកដល់ឆ្នាំ១៩៧៥[១៦]។

នៅចន្លោះឆ្នាំ១៩៧៣ និងមកដល់ពេលដួលរលំនៃរបប លន់ នល់ ឆ្នាំ១៩៧៥ វិទ្យុជាតិកម្ពុជា បានឈប់ផលិតអត្ថបទថ្មីៗ ហើយចាក់ផ្សាយតែបទចម្រៀង ល្ខោន និងមហោស្រពដដែលៗ[១៧]។

---

[១៤] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ២១។

[១៥] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ២១, ១០០ ។

[១៦] Harish C. Mehta ភាពស្ងប់ស្ងាត់កម្ពុជា ទំ. ១០២ និង ១០៥។ ឆ្នាំដែលកងទ័ពខ្មែរក្រហមដណ្ដើមបានរោងចក្រក្រដាស មិនមែននិយាយទេ។

[១៧] ពុយ គា: ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា។

## *ឆ្នាំ១៩៧៥-១៩៧៩ (ឆ្នាំ សូន្យ)*

អ្នកសារព័ត៌មានត្រូវបានចាត់ទុកថា ជាធាតុមួយនៃសង្គម "ពួកចក្រពត្តិ" ដែលខ្មែរក្រហមត្រូវបោសសំអាត ហើយអ្នកសារព័ត៌មានកម្ពុជាស្ទើរតែទាំងអស់បានស្លាប់នៅចន្លោះឆ្នាំ១៩៧៥ -១៩៧៩[១៨] ។

ប៉ុន្តែ "ផែនការ៤ឆ្នាំ" ដែលរៀបចំឡើងដោយរបបនោះក្នុងខែកក្កដា និងសីហា ឆ្នាំ១៩៧៦ រួមមានសេចក្ដីណែនាំដើម្បីបង្កើតឧបករណ៍ឃោសនាដូចជា វិទ្យុ ភាពយន្ត សិល្បៈ និងសារព័ត៌មានជាដើម។ ផែនការក៏បានលើកឡើងអំពីការបោះពុម្ពជាភាសាបរទេស (ជាពិសេសភាសាអង់គ្លេស) ពីឆ្នាំ១៩៧៧ តទៅ។ បញ្ហានេះក៏ដូចជាទិដ្ឋភាពផ្សេងៗជាច្រើនទៀតនៃផែនការដែរមិនត្រូវបានអនុវត្តទេ។

រដ្ឋាភិបាលខ្មែរក្រហម បានបោះពុម្ពទស្សនាវដ្ដីប្រចាំខែចំនួន ៣ ដើម្បីចែកផ្សាយដល់សមាជិកគណបក្សរបស់ខ្លួន។ មុនពេលដែលពួកខ្មែរក្រហមដណ្ដើមបានអំណាចខែមេសា ឆ្នាំ១៩៧៥ ការបោះពុម្ពផ្សាយនេះត្រូវបានសរសេរដោយដៃ ហើយក្រោយមកចម្លង និងក្រោយមកទៀតពួកគេបានប្រើរោងពុម្ពសំរាប់បោះពុម្ពសារព័ត៌មាន[១៩] ។

ទស្សនាវដ្ដី *យុវជន និងយុវនារីបដិវត្ត* ត្រូវបានបោះពុម្ពផ្សាយចាប់ពីខែមករា ឆ្នាំ១៩៧៤ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨។ *ទស្សនាវដ្ដី ទង់បដិវត្ត* ត្រូវបានបោះពុម្ពផ្សាយពីឆ្នាំ១៩៧៥ រហូតដល់យ៉ាងតិចណាស់ត្រឹមខែកញ្ញា ១៩៧៨។ ពួកខ្មែរក្រហមក៏បានបោះពុម្ពផ្សាយទស្សនាវដ្ដីមួយឈ្មោះ *រណសិរ្សកម្ពុជា*[២០] ។ ទស្សនាវដ្ដីទាំងនោះពោរពេញទៅដោយការឃោសនាបដិវត្តិ។

វិទ្យុជាតិកម្ពុជាបានបន្តផ្សាយ ៣ ដងក្នុង ១ ថ្ងៃ ដែល ១ ម៉ោងសម្រាប់ផ្សាយគោលនយោបាយបក្សកុម្មុយនីស្តដែលបានថតទុកជាស្រេច សកម្មភាពកសិករ និងចម្រៀងកសិករ[២១] ។ ការផ្សាយត្រូវជួប

---

[១៨] រដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កញ្ញារីទ្ធិ ប៉ាន់ស្មានថា អ្នកសាព័ត៌មាន ៩៥% ត្រូវពួកខ្មែរក្រហមសម្លាប់ (សម្ភាសន៍ជាមួយ ខៀវ កញ្ញារីទ្ធិ ។ ដឹកនាំអភិវឌ្ឍន៏ព័ត៌មានបោះឆ្នោតដោយសេរី និងទទួលខុសត្រូវៈ ទស្សនកាណាដា ស្ដីពី ទំហំព័ត៌មានស្ដីពីការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០០៣) ។

[១៩] George Chigas & Dmitri Mosyakov, អក្សរសាស្ត្រ និងការអប់រំក្នុងរបបខ្មែរក្រហម-សាកលវិទ្យាល័យ យែល។

[២០] George Chigas & Dmitri Mosyakov, អក្សរសាស្ត្រ និងការអប់រំក្នុងរបបខ្មែរក្រហម- សាកលវិទ្យាល័យ យែល។

[២១] ពុយ គា : ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា។

ការលំបាកដោយខ្វះខាតឧបករណ៍បម្រើការងារ ចំណែកឯ "ធនធានមនុស្សក៏ពុំមានគ្រប់គ្រាន់ដែរ អាស្រ័យដោយរបបប្រល័យពូជសាសន៍ ជាពិសេសអ្នកមានជំនាញត្រូវសម្លាប់ចោលអស់"[២២] ។

ដោយមានការលើកលែងខ្លះៗ ប្រទេសកម្ពុជាត្រូវបានបិទមិនឱ្យមានប្រពន្ធ័ផ្សាយព័ត៌មានអន្តរជាតិទេ។

## ឆ្នាំ១៩៧៩-១៩៩៣: ក្រោមការត្រួតត្រារបស់កុម្មុយនិស្ត

បន្ទាប់ពីការឈ្លានពានរបស់វៀតណាម ដែលបានផ្តួលរំលំរបបខ្មែរក្រហមក្នុងខែមករា ឆ្នាំ១៩៧៩ វិទ្យុជាតិត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលថ្មីសាធារណរដ្ឋប្រជាមានិតកម្ពុជា។ វិទ្យុនេះបានចាក់ផ្សាយព័ត៌មាន ការអប់រំ និងព័ត៌មាននយោបាយហើយច្រើនបញ្ចូលព័ត៌មានវាយប្រហារលើពួកឧទ្ទាមខ្មែរក្រហម។ ការផ្សាយពាណិជ្ជកម្មត្រូវបានហាមឃាត់។

រដ្ឋាភិបាលដែលគាំទ្រដោយវៀតណាម បានបើកទីភ្នាក់ងារសារព័ត៌មានរដ្ឋមួយឈ្មោះ សារព័ត៌មានកម្ពុជា ហៅកាត់ថា (SPK) ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា បានបោះពុម្ពសារព័ត៌មាន ដែលជាឧបករណ៍បំពងសម្លេងរបស់ខ្លួន ហៅថា "**កម្ពុជា**" ចំនួន ៥០.០០០ ច្បាប់ហើយចែកផ្សាយដោយឥតគិតថ្លៃ។ បណ្ណាធិការនៃសារព័ត៌មានកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩មក គឺលោក ខៀវ កញ្ញារីទ្ធិ ដែលក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងព័ត៌មាន។

ប្រពន្ធ័ផ្សាយព័ត៌មានបរទេសត្រូវបានហាមឃាត់ពីឆ្នាំ១៩៨០ ដល់ ១៩៨៦ ។

ក្រុមឧទ្ទាមខ្មែរក្រហម ហ៊្វុនស៊ីនប៉ិច និងរណសិរ្សរំដោះប្រជាជាតិខ្មែរបានបង្កើតវិទ្យុលួចលាក់ចាក់ផ្សាយពីតំបន់ព្រំដែនកម្ពុជា-ថៃ។

នៅឆ្នាំ១៩៨៦ ទូរទស្សន៍ជាតិបានចាប់ផ្តើមចេញផ្សាយទូរទស្សន៍ពណ៌។

នៅឆ្នាំ១៩៨៧ សម្តេចនាយករដ្ឋមន្ត្រី ដែលកាលនោះជា(ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី) បានប្រកាសអនុញ្ញាតឱ្យមានការផ្សាយពាណិជ្ជកម្មតាមវិទ្យុ[២៣] ។

---

[២២] ពុយ គា : ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ទំ. ១២ ។

## ឆ្នាំ១៩៩១-១៩៩៣ :សម័យអ៊ុនតាក់

បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៃកម្ពុជា (អ៊ុនតាក់) បង្ហាញទិសក្នុងសម័យថ្មីនៃសេរីភាពប្រព័ន្ធផ្សាយព័ត៌មាន។

វិទ្យុរបស់អ៊ុនតាក់ (AM 918 KHz) ចាប់ផ្តើមចេញផ្សាយដំបូងនៅខែវិច្ឆិកា ១៩៩២ ក្នុងកិច្ចប្រឹងប្រែងដើម្បីជួយគាំទ្រដល់ដំណើរការសន្តិភាព និងពន្យល់អំពីការបោះឆ្នោតដែលជិតមកដល់។ អ៊ុនតាក់បានចែកវិទ្យុដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃចំនួន ៣៤៦.០០០ គ្រឿង។ វិទ្យុត្រូវបានចាត់ទុកជាឧបករណ៍ដ៏មានប្រសិទ្ធិភាពបំផុតដែលអ៊ុនតាក់បានប្រើដើម្បីបញ្ចុះបញ្ចូលសាធារណជន ដែលមិនបានយល់ច្បាស់លាស់អំពីការបោះឆ្នោត ថាការបោះឆ្នោតរបស់ពួកគេគឺជាការសម្ងាត់។ ដោយមានការពន្យល់តាមវិទ្យុនេះហើយ បានជាប្រជាពលរដ្ឋចំនួន ៩០% មានការបោះឆ្នោតដោយមានភាពជឿជាក់[២៤]។

នៅឆ្នាំ១៩៩៣ វិទ្យុអ៊ុនតាក់បានចប់អាណត្តិហើយប្រគល់ឧបករណ៍ទាំងអស់ឱ្យក្រសួងព័ត៌មានដែលមានតម្លៃជាទឹកប្រាក់សរុប ៤ លានដុល្លា។ ឧបករណ៍ភាគច្រើនបានបាត់អស់ ប៉ុន្តែឧបករណ៍ខ្លះត្រូវបានប្រគល់ឱ្យវិទ្យុជាតិដែលកំពុងប្រើប្រាស់រហូតដល់សព្វថ្ងៃ[២៥]។

## ឆ្នាំ ១៩៩៣- ២០០៨ : ការរីកចម្រើនយ៉ាងលឿន និងធ្វើទុក្ខបុកម្នេញ

កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានផ្តល់នូវមូលដ្ឋានច្បាប់សម្រាប់សេរីភាពក្នុងការបញ្ចេញមតិ និងការរីកចម្រើនវិស័យប្រព័ន្ធផ្សាយព័ត៌មានថ្មី។

សារព័ត៌មានរីកដុះដាលដូចផ្សិត។ យោងតាមការប៉ាន់ស្មានមួយនៅឆ្នាំ១៩៩៣ កម្ពុជាមានសារព័ត៌មានប្រហែល ៣០ ហើយឆ្នាំក្រោយៗមកទៀតមានប្រហែល ៤៥ ហើយមកដល់ឆ្នាំ១៩៩៥ មានប្រហែល ៩០។

---

[២៣] ពុយ គា : ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ទំ. ១៣។

[២៤] ពុយ គា : ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ទំ. ១៦។

[២៥] ពុយ គា : ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ទំ. ១៧។

វិទ្យុ FM ដែលមានសម្លេងច្បាស់ និងស្រួលស្តាប់ កាន់តែមានប្រជាប្រិយភាពជាងវិទ្យុ AM ហើយស្ថានីយវិទ្យុថ្មីៗជាច្រើនត្រូវបានបើកឡើង។

ក្លឹបសារព័ត៌មានដំបូងបង្អស់ និងសមាគមអ្នកសារព័ត៌មានខ្មែរត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩៣។ ក្នុងកំឡុងពេល២ឆ្នាំ ក្លឹបសារព័ត៌មាន និងសមាគមអ្នកសារព័ត៌មានខ្មែរនេះ កាន់តែក្លាយជាអ្នកតស៊ូមតិក្នុងការទាមទារសេរីភាពសារព័ត៌មានខ្លាំងឡើងៗ។ ដូច្នេះសារព័ត៌មានដែលគាំទ្ររដ្ឋាភិបាលបានបំបែកខ្លួនចេញពីក្លឹបសារព័ត៌មាន និងសមាគមអ្នកសារព័ត៌មានខ្មែរដើម្បីបង្កើតសមាគមមួយផ្សេងទៀតរបស់ខ្លួនឯង។ បញ្ហានេះ បានបណ្តាលឱ្យសមាគមអ្នកសារព័ត៌មានខ្មែរចុះទន់ខ្សោយបន្តិចម្តងៗជាលំដាប់។

ក្នុងឆ្នាំ១៩៩៤ អ្នកសារព័ត៌មាន ៣ នាក់ ត្រូវបានសម្លាប់ដោយសារតែការងាររបស់ពួកគេ។ នៅក្នុងឆ្នាំនោះ រដ្ឋាភិបាលបានបិទ ឬ គំរាមឱ្យបិទយ៉ាងតិចសារព័ត៌មានចំនួន ៩ ។

លោក ងួន ញន់ ជាសមាជិកគណៈបក្សហ៊្វុនស៊ិនប៉ិច និងជាបណ្ណាធិការសារព័ត៌មាន *ដំណឹងពេលព្រឹក* ជាអ្នកសារព័ត៌មានដំបូងបង្អស់ដែលត្រូវបានជាប់ពន្ធនាគារចាប់តាំងពីសម័យបេសកកម្ម អ៊ុនតាក់ និងការបោះឆ្នោតជាតិ។ នៅខែមេសា ឆ្នាំ១៩៩៤ លោក ងួន ញន់ ត្រូវចាប់ខ្លួនហើយជាប់ឃុំឃាំងរយៈពេល ២ ថ្ងៃ ដោយគាត់បានសរសេរអត្ថបទចោទប្រកាន់អភិបាលខេត្តម្នាក់ពាក់ព័ន្ធអំពើពុករលួយ។ នៅខែកក្កដា គាត់ត្រូវបានចាប់ដាក់ពន្ធនាគារអស់រយៈពេល ១ ខែទៀត ដោយបានសរសេរអត្ថបទស័កសៀតពាក្យសម្តីថាមន្ត្រីគណបក្សប្រជាជនកម្ពុជាមួយចំនួនជាប់ពាក់ព័ន្ធនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារ។

ច្បាប់ស្តីពីសារព័ត៌មានត្រូវបានអនុម័តនៅឆ្នាំ១៩៩៥ក្រោយពីការបញ្ចុះបញ្ចូលយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិ និងសង្គមស៊ីវិលដើម្បីស្នើសុំរដ្ឋាភិបាលលប់ចោលនូវបទបញ្ញត្តិព្រហ្មទណ្ឌ រួមទាំងការផ្តន្ទាទោសដាក់ពន្ធនាគារមួយចំនួនចេញពីច្បាប់។

នៅខែតុលា ឆ្នាំ១៩៩៥ មានប្រជាពលរដ្ឋប្រមាណ ១៥០ នាក់មកពីខេត្តកណ្តាល ដោយមានការខឹងសម្បារនឹងសារព័ត៌មាន *សេរីភាពថ្មី* បានសម្រុកចូលទីស្នាក់ការសារព័ត៌មាននេះនៅភ្នំពេញ លួច និងបំផ្លិចបំផ្លាញសម្ភារៈនានា ព្រមទាំងវាយដំបុគ្គលិក ដែលជាការឆ្លើយតបទៅនឹងអត្ថបទរិះគន់មួយមានចំណងជើងថា គម្រោងអភិវឌ្ឍន៍ដែលគាំទ្រដោយសម្តេចនាយករដ្ឋមន្ត្រី នៅក្នុងឃុំរបស់ពួកគេ។ មួយសប្តាហ៍ក្រោយមក សម្តេច នាយករដ្ឋមន្ត្រី បាននិយាយនៅក្នុងឃុំដោយបានការពារសកម្មភាពប្រជាពលរដ្ឋទាំងនោះថាជាអំពើ "មិនខុស" ទេ ។

ក្នុងឆ្នាំ១៩៩៦ អ្នកសារព័ត៌មានម្នាក់ ត្រូវបានគេធ្វើឃាតដោយសារការងាររបស់គាត់។ ម្នាក់ទៀត គឺជាអ្នកផ្សាយវិទ្យុហ្វ៊ុនស៊ីនប៉ិច ដ៏ល្បីឈ្មោះត្រូវបានគេបាញ់បណ្តាលឱ្យរបួសយ៉ាងធ្ងន់ធ្ងរ។

ក្នុងឆ្នាំ១៩៩៦ ដដែល តុលាការកំពូលបានតំកល់សាលក្រមពីរករណីផ្សេងពីគ្នា ១ គឺបទបរិហារកេរ្តិ៍ ឬផ្សព្វផ្សាយព័ត៌មានមិនពិតចោទប្រកាន់បណ្ណាធិការសារព័ត៌មានម្នាក់ឈ្មោះ ច័ន្ទ រតនា និងករណីទី២ គឺបណ្ណាធិការសារព័ត៌មានម្នាក់ទៀតឈ្មោះ ហែន វិភាគ ថាបានសរសេរអត្ថបទប្រមាថមើលងាយសម្តេចក្រុមព្រះ និងសម្តេច នាយករដ្ឋមន្ត្រី។ អ្នកសារព័ត៌មានទាំងពីរនាក់នេះ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ ហើយនេះ គឺជាការផ្តន្ទាទោស និងការឃុំឃាំងលើកទី១ ចាប់តាំងពីសម័យអ៊ុនតាក់ ប៉ុន្តែបុរសទាំងពីរនាក់នេះត្រូវបានដោះលែងមួយសប្តាហ៍ក្រោយ ដោយព្រះមហាក្សត្រទ្រង់ព្រះរាជទានទោស។

ក្នុងខែមិនា ឆ្នាំ១៩៩៦ បណ្ណាធិការនៃសារព័ត៌មានភាសាវៀតណាមប្រឆាំងនឹងកុម្មុយនីស្តត្រូវបានចាប់ខ្លួនតាមអំពើចិត្ត និងបញ្ជូនទៅវៀតណាមដែលជាកន្លែងគាត់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ។

វិទ្យុ FM របស់រដ្ឋ និងដំបូងគេតែមួយគត់គឺវិទ្យុជាតិ FM ៩៦ បានចាប់ផ្តើមផ្សាយនៅក្នុងខែមិនា ឆ្នាំ១៩៩៩ ដែលមិនមែនជាឧបករណ៍ថ្មីទេមានតម្លៃសរុបត្រឹម៩០០ ដុល្លាអាមេរិក ។

ឆ្នាំ១៩៩៧ អ្នកសារព័ត៌មាន៤នាក់ត្រូវបានគេធ្វើឃាត។ នៅក្នុងការវាយប្រហារដោយគ្រាប់បែកដៃមួយទៅលើការប្រជុំនៃក្រុមនយោបាយមួយ យ៉ាងតិចមានអ្នកសារពតិមាន២២នាក់ ត្រូវរងរបួសហើយម្នាក់ទៀតបានស្លាប់។

នៅក្នុងទិន្នាការមួយដែលបន្តរហូតមកដល់សព្វថ្ងៃ វិទ្យុ និងទូរទស្សន៍ជាតិ បានផ្តោតតែទៅលើសកម្មភាពព្រះមហាក្សត្រ សម្តេច នាយករដ្ឋមន្ត្រី (រួមទាំងការចាក់ផ្សាយឡើងវិញនូវសុន្ទរកថាទាំងស្រុង) និងសកម្មភាពរបស់មន្ត្រីនានា។ វិទ្យុ និងទូរទស្សន៍ជាតិ ក៏ចាក់ផ្សាយចម្រៀង និងកម្មវិធីកំសាន្តផងដែរ។

ក្នុងខែឧសភា ឆ្នាំ១៩៩៧ ស្ថានីយទូរទស្សន៍ជាតិ នៅក្រុងព្រះសីហនុត្រូវបានវាយប្រហារបណ្តាលឱ្យអ្នកបច្ចេកទេសម្នាក់បាត់បង់ជីវិត ក្រោយពី (ស្ថានីយដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា) បដិសេធមិនព្រមចាក់ផ្សាយសន្ទរកថានយោបាយរបស់មេដឹកនាំហ្វ៊ុនស៊ីនប៉ិច។

ក្នុងកំឡុងពេលព្រឹត្តការណ៍ ខែកក្កដា ឆ្នាំ១៩៩៧ គណបក្សប្រជាជនកម្ពុជា បានរឹបអូសស្ថានីយវិទ្យុ និងទូរទស្សន៍របស់គណបក្សហ៊្វុនស៊ិនប៉ិច[២៦] ។

ក្នុងឆ្នាំ២០០៣ អ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់បម្រើការនៅស្ថានីយវិទ្យុគណបក្សហ៊្វុនស៊ិនប៉ិច ត្រូវបានបាញ់សម្លាប់ ៤ថ្ងៃក្រោយពីនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់ការផ្សាយរបស់ស្ថានីយជាសាធារណៈ ។

ក្នុងឆ្នាំ២០០៦ ផ្នែកខ្លះនៃបទបរិហារកេរ្តិ៍ត្រូវបានកែប្រែ ប៉ុន្តែនៅតែជាបទល្មើសព្រហ្មទណ្ឌដដែល គ្រាន់តែគេមិនកាត់ទោសដាក់ពន្ធនាគារ ។

[២៦] ឃ្លាំមើលសិទ្ធិមនុស្ស អាស៊ី -របាយការណ៍ពិភពលោក ១៩៩៨ http://www.hrw.org/worldreport/Asia-02.htm

## អ្នកស្តាប់/ទស្សនិកជន

មុននឹងក្រឡេកទៅមើលប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា និងបញ្ហាមួយចំនួនដែលប្រព័ន្ធផ្សាយសារព័ត៌មាននេះប្រឈមមុខ ចំណុចសំខាន់ត្រូវយល់អំពីវិធីដែលពលរដ្ឋកម្ពុជាទទួលព័ត៌មានជាមុនសិន ។

នៅទូទាំងប្រទេស ពលរដ្ឋទទួលបានព័ត៌មាន និងការកំសាន្តរបស់ពួកគេភាគច្រើនពីការចាក់ផ្សាយនៃប្រព័ន្ធផ្សាយព័ត៌មាន ។ ការសិក្សាមួយធ្វើឡើងកាលពីឆ្នាំ២០០៣ បានបង្ហាញឱ្យឃើញថា ៥២% នៃអ្នកដែលត្រូវបានសាកសួរនោះ បានមើលទូរទស្សន៍លើសពី ៣ ដង ក្នុងសប្តាហ៍កន្លងទៅ ហើយ៣៨% ទៀតបានស្តាប់វិទ្យុលើសពី ៣ ដងក្នុងកំឡុងពេលដូចគ្នា[២៧] ។

ការសិក្សាបានសន្និដ្ឋានថា "ទូរទស្សន៍នៅតែបន្តជាមធ្យោបាយដ៏សំខាន់បំផុត" ក្នុងការផ្សាយទៅដល់ប្រជាពលរដ្ឋទូទៅ ប៉ុន្តែ បញ្ហានេះក៏នៅតែបើកចំហរឱ្យមានការពិភាក្សានៅឡើយ[២៨] ។ មានអ្នកខ្លះលើកឡើងថា ទូរទស្សន៍ត្រូវបានទស្សនាដើម្បីកំសាន្តតែប៉ុណ្ណោះ ចំណែកឯវិទ្យុវិញប្រជាពលរដ្ឋប្រើសម្រាប់ស្តាប់ព័ត៌មានដែលបញ្ហានេះមានន័យថា វិទ្យុមានឥទ្ធិពលលើមតិសាធារណជនខ្លាំងជាង ។

អ្នកសារព័ត៌មាន បណ្ណាធិការ និងផលិតករជាច្រើន ដែលបានសម្ភាសន៍ដើម្បីសរសេររបាយការណ៍នេះបានគាំទ្រទស្សនៈនេះដោយនិយាយថា វិទ្យុជាព័ត៌មានដែលសំខាន់ជាងគេបំផុតនៃប្រព័ន្ធផ្សាយព័ត៌មានពីព្រោះម្យ៉ាង គឺវាថោកនៅពេលទិញ ពេលប្រើក៏មិនចំណាយច្រើនដែរ ហើយម្យ៉ាងទៀត អ្នកស្តាប់អាចបើកស្តាប់កម្មវិធីអន្តរជាតិណាមួយ ក្នុងចំណោមកម្មវិធីជាច្រើនដែលមើលទៅហាក់ដូចជាប្រភពមួយមិនលំអៀង ។

យើងមិនត្រូវគិតថា វិទ្យុ ឬ ទូរទស្សន៍ណាមួយមានឥទ្ធិពលជាងទេ តាមពិតវាច្បាស់ណាស់ថាទាំងពីរនេះបានផ្សាយទៅដល់ប្រជាពលរដ្ឋច្រើនជាងសារព័ត៌មាន ឬអ៊ីនធឺណែតឆ្ងាយណាស់ ។

***អ្នកសារព័ត៌មានជើងចាស់ម្នាក់បាននិយាយថា "ពេលអ្នកនិយាយពីជនបទ គឺនិយាយពីវិទ្យុ" ។***

---

២៧ មូលនិធិអាស៊ី : លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា-២០០៣: ការសិក្សាស្តីពីអ្នកបោះឆ្នោតនៅកម្ពុជា ។ តួលេខនេះ ដកស្រង់ចេញពីសេចក្តីព្រៀងចុះថ្ងៃទី១៦ ឧសភា ២០០៣ ។ សូមមើលវែបសាយ : http://www.asiafoundation.org/pdf/Democracyin Cambodia.pdf. ទំហំប៉ាន់គំរូនៃការសិក្សានេះ គឺ ១.០០៨ នាក់ ក្នុង២៤ ខេត្ត/ក្រុង ។

២៨ មូលនិធិអាស៊ី : លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ទំ. ៩០ ។

អ្នកសារព័ត៌មានជើងចាស់ម្នាក់បាននិយាយថា "ពេលអ្នកនិយាយពីជនបទ គឺនិយាយពីវិទ្យុ"[២៩] ។

ការសិក្សាឆ្នាំ២០០៣ បានបង្ហាញឱ្យឃើញថា មានតែ៩%នៃអ្នកផ្តល់សម្ភាសន៍ប៉ុណ្ណោះ អានសារព័ត៌មានជាប្រចាំ។ មូលហេតុមួយចំពោះបញ្ហានេះ គឺអត្រាអក្ខរភាពនៅកម្ពុជាទាបនៅឡើយដោយគេបានប៉ាន់ប្រមាណថាត្រឹម៧៣.៦០%នៃពលរដ្ឋកម្ពុជាប៉ុណ្ណោះជាអក្ខរជន (ចេះអានអក្សរ) ប៉ុន្តែវាអាចនៅទាបជាងនេះទៅទៀតប្រសិនបើ "អក្ខរភាព" គេកំណត់ថាត្រឹមចេះអានសារព័ត៌មានបានពុំមែនគ្រាន់តែចេះអានពីរ-បីពាក្យប៉ុណ្ណោះទេ[៣០] ។ បញ្ហាសំខាន់មួយទៀតដែរ គឺការខ្វះខាតការចែកចាយសារព័ត៌មាននៅជនបទ និងទីរួមខេត្តមួយចំនួន។ កន្លងមកក៏ឃើញមានសារព័ត៌មានខេត្តខ្លះៗដែរ ប៉ុន្តែសារព័ត៌មានទាំងនោះភាគច្រើនគឺជាសារព័ត៌មានមិនសូវចេញផ្សាយជាប់ជាប្រចាំទេ ឬគ្រាន់តែជាឧបករណ៍សម្រាប់គំរាមកំហែងតែប៉ុណ្ណោះ (នឹងពិភាក្សាពិស្តារនៅពេលក្រោយ)។ សារព័ត៌មានធំៗមួយចំនួននៅភ្នំពេញ បានបញ្ជូនសារព័ត៌មានដែលបានបោះពុម្ពរបស់ខ្លួនបន្តិចបន្តួចទៅលក់នៅតាមបណ្តាខេត្ត (ភាគច្រើនតាមរថយន្តតាក់ស៊ី) ដូចជា សៀមរាប និងក្រុងព្រះសីហនុជាដើម ប៉ុន្តែចំពោះប្រជាពលរដ្ឋកម្ពុជាភាគច្រើនប្រហែល ៨៥% ដែលរស់នៅតាមជនបទមិនអាចរកទិញសារព័ត៌មានអានបានទេ។

ប៉ុន្តែ ទោះបីជាសារព័ត៌មានមិនទាន់បានផ្សាយទូលំទូលាយក៏ដោយ ក៏ប៉ុន្តែសារព័ត៌មាននៅតែជាវេទិកាមួយយ៉ាងសំខាន់សម្រាប់ព័ត៌មាននយោបាយ ការមានមតិ និងការខ្សឹបខ្សៀវ ហេតុដូច្នេះហើយបានជាសារព័ត៌មាននៅតែជាគោលដៅសំរាប់ការវាយប្រហារទៅលើប្រព័ន្ធផ្សាយព័ត៌មាន។

ឥទ្ធិពលរបស់អ៊ីនធឺណេតនៅមានកំរិតទាបនៅឡើយ។ គេបានប៉ាន់ប្រមាណថា មានអ្នកប្រើប្រាស់អ៊ីនធឺណេតប្រមាណ ៤៤.០០០ នាក់ នៅកម្ពុជា ឬប្រហែលស្មើ ០.៣% នៃចំនួនប្រជាពលរដ្ឋសរុប[៣១] ។ ចំពោះហេតុផលដែលនាំឱ្យមានអត្រាទាបនេះ រួមមានកង្វះការអប់រំជំនាញភាសា និងជំនាញកុំព្យូទ័រ តម្លៃកុំព្យូទ័រខ្ពស់ កង្វះអគ្គិសនី និងសេវាកម្មអ៊ីនធឺណេត។ ប៉ុន្តែអ៊ីនធឺណេតជាវិស័យមួយដែលលូតលាស់យ៉ាងឆាប់រហ័សលឿនជាងគេ ជាពិសេសក្នុងចំណោមសិស្ស-និស្សិត ហើយនិស្សិតខ្លះប្រើអ៊ីនធឺណេតដើម្បីស្រាវ

---

[២៩] សម្ភាសន៍ជាមួយអ្នកសារព័ត៌មានម្នាក់ ថ្ងៃទី ២៣ សីហា ២០០៧ ។

[៣០] ស្ថិតិដកស្រង់ពីវិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជាឆ្នាំ២០០៤ដែលកំណត់ន័យអក្ខរភាពថាៈ "ជនណាដែលចេះអាន និងសរសេរនូវពាក្យពេចន៍សាមញ្ញៗ" ។

[៣១] ស្ថិតិនេះត្រូវបានប្រើយ៉ាងទូលំទូលាយ ហើយមានប្រភពចេញពីសហព័ន្ធទូរគមនាគមន៍អន្តរជាតិនៃអង្គការសហប្រជាជាតិ ប៉ុន្តែមិនច្បាស់ថាគេគណនារបៀបណាទេ។

ជ្រាវព័ត៌មានមួយចំនួន (ដូចជារបាយការណ៍ដែលគេហាមឃាត់ស្តីពីការរកស៊ីឈើខុសច្បាប់ និងអំពើពុករលួយជាដើម) ដែលរដ្ឋាភិបាលតែងតែហាមឃាត់មិនឱ្យចេញផ្សាយ។ ដូចជាសារព័ត៌មានដែរ លក្ខណៈទូទៅនៃអ៊ីនធឺណេត គឺភាគច្រើនប្រើប្រាស់តែក្នុងចំណោមអ្នកចេះដឹងនៅទីក្រុងតិចតួចតែប៉ុណ្ណោះ។

មធ្យោបាយដែលបានរៀបរាប់មកខាងលើនេះ គឺជាវិធីដែលពលរដ្ឋកម្ពុជាទទួលបានព័ត៌មាន។ ឧទាហរណ៍ នៅពេលដែលអង្គការមូលនិធិអាស៊ីចុះសួរប្រជាពលរដ្ឋកម្ពុជានៅឆ្នាំ២០០៣ ថាតើពួកគេចង់ឮព័ត៌មានពាក់ព័ន្ធការបោះឆ្នោតពីអ្នកណា? នោះចម្លើយរួមមាន: ពីមេភូមិ (៧៤%) មេឃុំ (៦១%) កិច្ចប្រជុំសាធារណៈ (៥៩%) ទូរទស្សន៍ (៥៨%) ប្រធានក្រុម (៥៧%) មិត្តភ័ក្ត/បងប្អូន (៤៦%) និងវិទ្យុ (៤១%)[៣២]។ មានតែអ្នកចូលរួមសម្ភាសន៍ ១៥% ប៉ុណ្ណោះនិយាយថាចង់ឮតាមកាសែត ចូលចិត្តសៀវភៅកំប្លែង (៣៣%) ហើយតាមការសម្តែងល្ខោន (២៥%)។

បញ្ហានេះបញ្ជាក់ឱ្យឃើញថា សង្គមមួយនៅវិលវល់ត្រឹមតែជុំវិញភូមិ និងឃុំប៉ុណ្ណោះ ជាមួយអ្នកមេដឹកនាំនៅតាមមូលដ្ឋានដើរតួយ៉ាងសំខាន់។ ការចាក់ផ្សាយរបស់ប្រពន្ធ័ផ្សាយសារព័ត៌មានបានជ្រៀតចូលយ៉ាងជ្រៅ ដូច្នេះវាជាសក្តានុពលនៃការផ្សព្វផ្សាយព័ត៌មាន និងមានឥទ្ធិពលទៅលើមតិ ប៉ុន្តែវាជាវិធីតែមួយប៉ុណ្ណោះដែលពលរដ្ឋកម្ពុជាទទួលបានព័ត៌មាន។

ដូច្នេះ ប្រសិនបើយើងយល់នូវបរិយាកាសប្រព័ន្ធផ្សាយព័ត៌មានទូទាំងប្រទេស នោះយើងនឹងឃើញថា អ្នកភាគច្រើននៅតាមជនបទ គឺជាមនុស្សដែលចូលចិត្តស្តាប់វិទ្យុ និងទស្សនាទូរទស្សន៍ច្រើន ចំណែកឯសារព័ត៌មាន និងអ៊ីនធឺណេតវិញ គឺភាគច្រើនប្រើប្រាស់តែនៅរង្វង់ទីក្រុងភ្នំពេញ និងទីរួមខេត្តប៉ុណ្ណោះ។

---

[៣២] មូលនិធិអាស៊ី : លទ្ធិប្រជាធិតេយ្យនៅកម្ពុជា ទំ. ៩១ ។ គួរកត់សំគាល់ផងដែរថា ៩៨% នៃមេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ គឺជាសមាជិកគណបក្សប្រជាជនកម្ពុជា ជាបក្សកាន់អំណាច) (៧០.៤% គឺជាមេភូមិ) ដែលជ្រើសរើសដោយគណបក្សប្រជាជនកម្ពុជា។

ការប្រើប្រាស់ប្រព័ន្ធសារព័តិមាននៅកម្ពុជា




ប្រភព: លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ឆ្នាំ២00៣: ការស្ទង់មតិអ្នកបោះឆ្នោតនៅកម្ពុជា។ មូលនិធិអាស៊ី។

## ទស្សនៈនៃព័ត៌មានរបស់ប្រព័ន្ធផ្សាយព័ត៌មាន

នៅក្នុងផ្នែកនេះរបស់របាយការណ៍នឹងផ្តល់ជាសេចក្តីផ្តើមដល់ស្ថានភាពបច្ចុប្បន្ននៃព័តិមានសំខាន់ៗ របស់ប្រព័ន្ធផ្សាយព័តិមាន (សារព័តិមាន វិទ្យុ និងទូរទស្សន៍) ជាដើម ព្រមទាំងបញ្ហាការលំបាកសំខាន់ៗ និងការហាមប្រាមដែលប្រឈមមុខនៅក្នុងវិស័យនេះ។ ព័តិមានពិស្តារបន្ថែមអំពីកម្មសិទ្ធិ និងភាពលំអៀងផ្នែកនយោបាយនៃប្រព័ន្ធផ្សាយព័តិមានពិសេស នឹងត្រូវលើកយកមកពិភាក្សាជូននៅផ្នែកខាងក្រោមនៃរបាយការណ៍នេះនៅក្នុងផ្នែកស្តីពីកម្មសិទ្ធិប្រព័ន្ធផ្សាយព័តិមាន និងលំអៀងនយោបាយ។

## សារព័ត៌មាន

មន្ត្រីរដ្ឋាភិបាល និងអ្នកធ្វើអត្ថាធិប្បាយប្រព័ន្ធផ្សាយព័ត៌មានច្រើនអះអាងថា ការរីកចម្រើនផ្នែក "សារព័ត៌មាន" កម្ពុជា គឺដោយសារចំនួនបោះពុម្ពផ្សាយពិតរបស់វា និងទស្សនៈប្រឆាំងនយោបាយនេះ ហើយជាភស្តុតាងនៃបរិយាកាសសេរីភាពប្រព័ន្ធផ្សាយព័ត៌មាន។ ធាតុពិតសារព័ត៌មានភាសាខ្មែរភាគច្រើន ត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយគណបក្សនយោបាយ ឬបុគ្គលដែលមានឥទ្ធិពលដែលប្រើប្រាស់សារព័ត៌មាន សម្រាប់ការឃោសនាឱ្យខ្លួន ចំណែកឯសារព័ត៌មានខ្លះទៀត គឺគ្រាន់តែជាឧបករណ៍សម្រាប់ប្រមូលប្រាក់កាសប៉ុណ្ណោះ។ សារព័ត៌មានអាចមានសេរីភាពខ្លះដែរបើនិយាយពីបរិមាណនៃការចេញផ្សាយ ប៉ុន្តែបើនិយាយពីគុណភាព និងឯករាជ្យភាពវិញពុំមានសេរីភាពទេ។

ចាប់តាំងពីដើមឆ្នាំ១៩៩០ រដ្ឋាភិបាលបានបន្ធូរបន្ថយលើការបោះពុម្ពផ្សាយ នៃប្រព័ន្ធផ្សាយព័ត៌មាន ជាពិសេសការអនុញ្ញាតឱ្យបង្កើតការបោះពុម្ពថ្មីៗជាច្រើនជាងការអនុញ្ញាតនៃប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិច។ ជាការពិតប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិចដោយសារតែអាចផ្សព្វផ្សាយបានយ៉ាងទូលំទូលាយ ហើយនឹងមានលទ្ធភាពក្នុងការផ្តល់ព័ត៌មាន ព្រមទាំងមានឥទ្ធិពលទៅលើទស្សនៈរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើន ហេតុដូច្នេះហើយបានជាពុំត្រូវបានអនុញ្ញាតឱ្យមានសេរីភាពស្មើនឹងព័ត៌មានបោះពុម្ពឡើយ។



ក្រសួងព័ត៌មាន មានបញ្ជីជាផ្លូវការសរុបចំនួន ៣០៣ សារព័ត៌មាន ព្រឹត្តិប័ត្រសារព័ត៌មាន៣២ ទស្សនាវដ្តីចំនួន៩៨ ប្រព័ន្ធផ្សាយព័ត៌មានអន្តរជាតិចំនួន ៤២ និងសារព័ត៌មានដែលនាំចូលពីក្រៅចំនួន ៩ [៣៣]។ ប៉ុន្តែនេះ គ្រាន់តែជាចំនួនបូកសរុបដែលបានទទួលចុះបញ្ជីក្នុងប៉ុន្មានឆ្នាំកន្លងមកតែប៉ុណ្ណោះ ហើយមិនបានឆ្លុះបញ្ចាំងនូវចំនួនពិត ដែលមាននៅតាមតូបលក់សារព័ត៌មានឡើយ។ ការបោះពុម្ពផ្សាយមួយចំនួនត្រូវចុះបញ្ជីលើសពីមួយដង ហើយខ្លះទៀតមានតែនៅលើក្រដាសតែប៉ុណ្ណោះ តាមពិតការបោះពុម្ពផ្សាយទាំងនោះបានដួលរលំ ឬម្ចាស់ស្លាប់បាត់អស់ទៅហើយ។

---

[៣៣] បញ្ជីឈ្មោះសាព័ត៌មានបោះពុម្ពរបស់ក្រសួងព័ត៌មាន ខែមិថុនា ២០០៧។

ធាតុពិត មានត្រឹមតែ១៥ ទៅ២០ សារព័ត៌មានប៉ុណ្ណោះដែលចេញផ្សាយជាប្រចាំ[៣៤]។

សារព័ត៌មានប្រចាំថ្ងៃ កោះសន្តិភាព រស្មីកម្ពុជា និងកម្ពុជាថ្មី ចាត់ទុកថាជាសារព័ត៌មាន ៣ ដែលលក់ដាច់ជាងគេបំផុតដែលមានលក់លើទីផ្សារប្រហែល ២០.០០០ ទៅ ២៥.០០០ ច្បាប់។ សារព័ត៌មានតូចៗភាគច្រើន បោះពុម្ពពីរ-បីពាន់ច្បាប់ ប៉ុន្តែចំនួនមានការឡើង ចុះទៅតាមព័ត៌មានប្រចាំថ្ងៃ និងការចេញផ្សាយក្នុង១ថ្ងៃៗអាចកើនឡើងខ្ពស់ក្នុងឱកាស ពិសេសៗ ដូចជាកំឡុងពេលបោះឆ្នោត ឬពេលមានការតស៊ូផ្នែកនយោបាយ[៣៥]។

សារព័ត៌មានប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ភាគច្រើនចុះផ្សាយព័ត៌មានទូទៅ និងនយោបាយព្រមទាំងកីឡា ពាណិជ្ជកម្ម និងអត្ថបទដកស្រង់ពីសៀវភៅ។ សារព័ត៌មានដែលលក់ដាច់ជាងគេប្រកួតប្រជែងដណ្តើមអតិថិជន តាមរយៈការចុះផ្សាយចំណងជើងដែលធ្វើឱ្យមានការភ្ញាក់ផ្អើល នៅទំព័រមុខ និងរូបថតមានឈាមរបស់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម ឬជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរដែលត្រូវបានប្រើដើម្បីទាក់ទាញការចាប់អារម្មណ៍។ នេះគឺជាកត្តាសំខាន់ដោយសារតែសារព័ត៌មានមួយចំនួនតូចទេដែលមានប្រព័ន្ធសំរាប់ជាវតាមផ្លូវការ ចំណែកចំនួនធំលក់តាមចិញ្ចើមផ្លូវ ឬតាមតូបនៅក្នុងផ្សារ។ ជម្រើសរបស់អ្នកអានអាចអាស្រ័យទៅតាមទំនោរផ្នែកនយោបាយរបស់គេ (ឧ.គេអាចចង់អានសារព័ត៌មានគាំទ្ររដ្ឋាភិបាល ឬសារព័ត៌មានប្រឆាំង) ប៉ុន្តែ បណ្ណាធិការនិយាយថាអ្នកអានមានភក្តីភាពចំពោះសញ្ញាសំគាល់សារព័ត៌មានតិចតួចណាស់។ ជារឿយៗអ្នកដែលចង់ទិញសារព័ត៌មាន មើលត្រួសៗនៅតាមតូបលក់សារព័ត៌មាន ហើយជ្រើសរើសសារព័ត៌មានណាដែលខ្លួនឯងចាប់អារម្មណ៍ជាងគេនៅទំព័រមុខគេ ធ្វើដូច្នេះហើយដែលអាចធ្វើឱ្យមានការលើកទឹកចិត្ត "ការប្រណាំងប្រជែងគ្នាពីរឿងដែលធ្វើឱ្យស្ញុកស្ញាញ" មិនគិតដល់គុណភាព និងបទដ្ឋានរបស់បណ្ណាធិការសារព័ត៌មានឡើយ ដោយសារតែសារព័ត៌មាននេះមានការប្រកួតប្រជែងគ្នាដើម្បីទាក់ទាញអ្នកអាន[៣៦]។

គ្មានសារព័ត៌មានភាសាខ្មែរធំណាមួយ អាចចាត់ទុកថាជាសារព័ត៌មានអព្យាក្រិត្យផ្នែកនយោបាយឡើយ។ តាមពិតស្ទើរតែគ្រប់សារព័ត៌មានទាំងអស់ ទាំងតូចទាំងធំជាកម្មសិទ្ធិ ឬក៏ជាសារព័ត៌មានដែល

[៣៤] ចំនួននេះរួមមាន: រស្មីកម្ពុជា កោះសន្តិភាព កម្ពុជាថ្មី សម្លេងយុវជនខ្មែរ មនសិការខ្មែរ ដើមអំពិល អរិយធម៌ ចក្រវាល ស្រឡាញ់ខ្មែរ ខ្មែរអមតៈ ស និង ខ្មៅ រស្មីអង្គរ ទស្សនៈខ្មែរ ខ្មែរម្ចាស់ស្រុក ស្នាដៃក្មេងវត្ត ខ្មែរមេគង្គ សាព័ត៌មានសាកល និងមេគង្គកម្ពុជា។

[៣៥] ពុំមានសវនកម្មឯករាជ្យទេ ចំពោះការធ្វើចរាចរសារព័ត៌មាននៅកម្ពុជា។

[៣៦] ការវិភាគអំពីទម្លាប់ការទិញនេះ គឺផ្អែកលើការសម្ភាសន៍ជាមួយអ្នកឃ្លាំមើលសារព័ត៌មាន និងអ្នកសារព័ត៌មាន។

គាំទ្រដោយអ្នកនយោបាយដែលមានអំណាច ឬពាណិជ្ជករ ហើយវាឆ្លុះបញ្ចាំងឱ្យឃើញនូវភាពលំអៀងនយោបាយចំពោះចៅហ្វាយខ្លួននៅក្នុងខ្លឹមសារវិចារណកថារបស់សារព័ត៌មាននោះ។ ចំពោះការបោះពុម្ពសារព័ត៌មានតូចៗ ចៅហ្វាយ និងអ្នកសរសេរវិចារណកថារបស់គេអាចនឹងមានការផ្លាស់ប្តូរជាច្រើនដង។ អំឡុងឆ្នាំ២០០០ តម្លៃត្រឹមតែ ៤០០ ដុល្លា ប៉ុណ្ណោះក្នុង១ខែដើម្បីទិញទឹកចិត្តសារព័ត៌មានមួយដែលចេញផ្សាយពីរ-បីដងក្នុងមួយសប្តាហ៍ ប៉ុន្តែបច្ចុប្បន្ន មិនច្បាស់ថា "វាឡើងដល់ថ្លៃប៉ុន្មាន" ទេ[៣៧]។ (ចំពោះព័ត៌មានបន្ថែមអំពីបញ្ហាពាក់ព័ន្ធគ្នាទៅវិញទៅមករបស់កម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មាន និងសុន្ទរកថាលំអៀង សូមអានផ្នែកស្តីពីកម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មាន អាជ្ញាប័ណ្ណ និងលំអៀងផ្នែកនយោបាយ)។

អ្នកសារព័ត៌មានកម្ពុជា ជាធម្មតាបែងចែកសារព័ត៌មានចេញជា ៣ ប្រភេទៈ សារព័ត៌មានគាំទ្ររដ្ឋាភិបាល សារព័ត៌មានប្រឆាំង និងសារព័ត៌មានអន្តរជាតិ។ ពាក្យថា សារព័ត៌មានអន្តរជាតិ គេច្រើនតែនិយាយសំដៅ ឌឹខែមបូឌាដេលី ភ្នំពេញប៉ុស្តិ៍ កាំបូដស័រ និងថ្មីៗនេះ កាសែតទើបបើកថ្មីមួយឈ្មោះមេគង្គថែម ប៉ុន្តែក៏នៅមានប្រភេទសារព័ត៌មានភាសាចិនច្រើនប្រភេទទៀតដែរ ដែលផ្តោតទៅលើតែព័ត៌មានពាណិជ្ជកម្មប៉ុណ្ណោះ។ ប្រព័ន្ធផ្សាយព័ត៌មានអន្តរជាតិ ជាទូទៅត្រូវគេចាត់ទុកថាជាឯករាជ្យ ទោះបីជាព្រឹត្តិការណ៍ខ្លះថ្មីៗនេះបានបង្កឱ្យមានការលំបាកក្នុងការជឿថាជាប្រព័ន្ធផ្សាយឯករាជ្យក៏ដោយ ហើយអ្នកសារព័ត៌មានកម្ពុជាជាច្រើនចង់បានសេរីភាព និងកិច្ចការពារខ្លះៗ (ព្រមទាំងប្រាក់បៀវត្សរ៍ច្រើនជាង) ដែលបុគ្គលិកធ្វើការនៅក្នុងសារព័ត៌មានអន្តរជាតិទាំងនោះបានទទួល។

សារព័ត៌មានគាំទ្រ និងសារព័ត៌មានប្រឆាំងរដ្ឋាភិបាលប្រើប្រាស់ទំព័ររបស់ខ្លួនដើម្បីផ្សព្វផ្សាយគណបក្សរបស់គេរៀងៗខ្លួន និងបើកការវាយប្រហារលើគូបដិបក្ខ។ សារព័ត៌មានគាំទ្ររដ្ឋាភិបាលច្រើនតែងតែបំភ្លេចចោលនូវព័ត៌មានព្រឹត្តិការណ៍សំខាន់ៗ ប្រសិនបើព្រឹត្តិការណ៍ទាំងនោះមើលទៅហាក់ដូចជាធ្វើឱ្យខ្វល់ខ្វាយ និងអាចប៉ះពាល់ដល់អំណាច ឬមួយក៏គេចុះផ្សាយដោយប្រុងប្រយ័ត្ននូវពាក្យពេចន៍ដែលរដ្ឋាភិបាលជាអ្នកកំណត់ឱ្យ។ ចំណែកឯសារព័ត៌មានប្រឆាំងវិញ បច្ចុប្បន្ននេះធ្វើការចោទប្រកាន់ជារឿយៗ ដែលពេលខ្លះមានការពិតតិចតួចដើម្បីគាំទ្រការចោទប្រកាន់លើមន្ត្រីរដ្ឋាភិបាល និងបក្សពួករបស់មន្ត្រីទាំងនោះ។

[៣៧] Britt-Loise Edman ជាប់គាំងក្នុងអតីតកាល ស្វែងរកអនាគត : ការសិក្សាអំពីផ្នែកសារព័ត៌មានកម្ពុជា ផ្តល់ដោយ Sida និង Forum Syd ថ្ងៃទី១២ ឧសភា ឆ្នាំ២០០០ ទំ. ១៨ ។

អ្នកយកព័ត៌មានក្នុងស្រុកម្នាក់បាននិយាយថា "ប្រសិនបើយើងក្រឡេកមើលសារព័ត៌មានទាំង ២ ក្រុមនេះ គឺជាឧបករណ៍សម្រាប់គណបក្ស និងតែងតែវាយប្រហារគ្នាទៅវិញទៅមក ដូច្នេះសារព័ត៌មានទាំងនោះពុំមានឱកាសដើម្បីគោរពក្រមសីលធម៌ទេ"[៣៨] ។

ជារឿយៗពុំមានភាពខុសគ្នាទេរវាងព័ត៌មាន និងសុន្ទរកថា ជាមួយនឹងទស្សនៈរបស់អ្នកនិពន្ធ (បណ្ណាធិការ ឬអ្នកបោះពុម្ពផ្សាយ) ក្នុងការអនុញ្ញាតសេចក្តីរាយការណ៍សារព័ត៌មាន ព្រមទាំងបទដ្ឋានកិត្តិវិជ្ជាជីវៈផ្សេងៗទៀតមានកិត្តិទាបនៅឡើយ ។ អ្នកសារព័ត៌មានក្នុងស្រុកជាច្រើនដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះបានត្អូញត្អែរអំពីកង្វះគុណភាពនៅក្នុងសារព័ត៌មានខ្មែរនានា បញ្ជាក់ច្បាស់អំពីករណីចម្លងអាចខុសការពិត លំអៀងផ្នែកនយោបាយ ការសរសេរបង្ខូចកេរ្តិ៍ឈ្មោះ ការដកស្រង់សម្តីដែលគ្មានប្រភព ឬមិនច្បាស់លាស់ និងការរៀបចំទំព័រពុំបានសមរម្យជាដើម ។

ប៉ុន្តែខ្លះទៀតបានកត់សម្គាល់ឃើញថាមានការកែលំអប្រសើរជាងមុន ។ ចន្លោះឆ្នាំ១៩៩៦ និង ១៩៩៨ ការឃ្លាំមើលដោយអង្គការមួយពីប្រព័ន្ធផ្សាយព័ត៌មានបានសង្កេតឃើញថា មួយភាគបួននៃអត្ថបទដែលបោះពុម្ពផ្សាយទាំងអស់អំពីស្ត្រី គឺជារឿងអាសអាភាស[៣៩] ។ តូបលក់សារព័ត៌មាន នៅតែបន្តធ្វើពាណិជ្ជកម្មកូនសៀវភៅ "រឿងភេទ" ដដែល ។ រូបភាពស្ត្រីនៅលើទំព័រសារព័ត៌មានត្រូវបានកែលំអដែលភាគច្រើនអាស្រ័យដោយការអប់រំ និងតស៊ូមតិរបស់មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

សារព័ត៌មានសំខាន់ៗចំនួនពី១៥-២០ សារព័ត៌មានក៏ដូច្នេះដែរមានចំណងជើងផ្សេងៗជាច្រើនដែលហាក់ដូចជាសរសេរឡើងក្នុងគោលបំណងជម្រិតទារប្រាក់ដោយចេញផ្សាយតែពេលណា ដែលគម្រោងរកប្រាក់កំពុងដំណើរការ ។ សារព័ត៌មានទាំងនោះមានពីរប្រភេទដែលគេស្គាល់ថា "សារព័ត៌មានជូនពរ" ឬ "សារព័ត៌មានដែលរាំងខ្ទប់ព័ត៌មានមិនឱ្យចេញផ្សាយ" ។

សារព័ត៌មានដែលរាំងខ្ទប់ព័ត៌មានមិនឱ្យចេញផ្សាយគឺប្រើការគំរាម ដើម្បីជម្រិតទារប្រាក់ពីមនុស្សសំខាន់ៗ ឬពាណិជ្ជករមិនមែនជាសារព័ត៌មានផ្សាយអត្ថបទរឿងទេ ជាពិសេសនៅពេលដែលមានការកាប់ឈើខុសច្បាប់ ការរត់ពន្ធ អំពើពុករលួយ ឬរឿងស្នេហាក៏មានពាក់ព័ន្ធដែរ ។ ចំពោះរឿងអាស្រូវសំខាន់ៗ សំណូកអាចច្រើនរហូតដល់ទៅ ១,០០០ ដុល្លា សម្រាប់បិទបាំងរឿងមួយ នេះបើតាមសម្តីរបស់បណ្ណាធិការ

---

[៣៨] សម្ភាសន៍ជាមួយអ្នកយកព័ត៌មានម្នាក់ នៅថ្ងៃទី១១ កញ្ញា ឆ្នាំ២០០៧ ។

[៣៩] ទីវ សារាយេត: នាយិកាមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា-បទពិសោធន៍ការកែទម្រង់សារព័ត៌មាននៅកម្ពុជា- ឯកសារដាក់ជូនវេទិការឆ្នាំ២០០២

ជាន់ខ្ពស់ម្នាក់។ អ្នកសារព័ត៌មានក្លែងក្លាយមួយចំនួនអាចបោះពុម្ពតែពីរ-បីច្បាប់ទេ អំពីរឿងនៅលើទំព័រសារព័ត៌មានដើម្បីបង្ហាញឱ្យច្បាស់នូវរឿងអាស្រូវ។ អ្នកខ្លះទទួលសំណូកដើម្បីបិទភ្នែកធ្វើអំពើអាក្រក់។ ចំពោះអ្នកខ្លះទៀតនេះវាជាអាជីវកម្ម។

បណ្ណាធិការជាន់ខ្ពស់ម្នាក់និយាយថា "ជួនកាលអ្នកអាចជួបអ្នកសារព័ត៌មានជាច្រើននៅច្រកព្រំដែនប៉ោយប៉ែត ពួកគេធ្វើការដូចជា "*អាជ្ញាធរនៅទីនោះ*" នេះបើនិយាយអំពីការជម្រិតទារប្រាក់ពីអ្នករត់ពន្ធនៅច្រកព្រំដែនកម្ពុជា-ថៃ "[៤០]។

រឿងដែលកើតឡើងជាធម្មតាមួយទៀតគឺ "សារព័ត៌មានជូនពរ"។ រឿងនេះ សារព័ត៌មានបោះពុម្ពនូវសារជូនពរ ខួបកំណើត (ឬ ពេលឡើងបុណ្យសក្តិ អាពាហ៍ពិពាហ៍ជាដើម) របស់អ្នកនយោបាយជាន់ខ្ពស់ និងភ្ជាប់ការឧបត្ថម្ភផ្សាយទៅនឹងឈ្មោះមន្ត្រីថ្នាក់កណ្តាល ឬពាណិជ្ជករណាម្នាក់ ជួនកាលអ្នកដែលមានឈ្មោះនោះពុំបានដឹងផង ឬពុំមានការយល់ព្រមផងក៏មាន។ អ្នកបោះពុម្ពផ្សាយទាក់ទងជាមួយមន្ត្រីថ្នាក់កណ្តាល នោះដើម្បីទារថ្លៃចុះផ្សាយដែលចាត់ទុកថាជាការវិនិយោគដើម្បីផ្គាប់ផ្គុនមន្ត្រីជាន់ខ្ពស់។

មានករណីខ្លះសារព័ត៌មានជូនពរនេះ បានអនុញ្ញាតឱ្យអ្នកល្បីល្បាញមកទិញកិត្តិនាមតាមរយៈការចុះផ្សាយ។ យោងតាមបណ្ណាធិការជាន់ខ្ពស់ម្នាក់បាននិយាយថា អ្នកចម្រៀងវ័យក្មេង ឬតារាត្រូវចំណាយថវិកាដើម្បីមានរូបនៅលើក្របទស្សនាវដ្តីរលោង។ ថវិកាបែបនេះអាចចំណាយទាបត្រឹម១០០ដុល្លាអាមេរិកក៏បាន។ ដូចគ្នានេះដែរ ចំពោះការពង្រីកអាជីព បណ្ណាធិការរូបនោះបានបន្តទៀតថាការចុះផ្សាយរូបថតលើគំរបទស្សនាវដ្តីនេះក៏ធ្លាប់ត្រូវបានប្រើ ដើម្បីសុំទិដ្ឋាការទៅសហរដ្ឋអាមេរិកដែរដោយកត្តានេះអាចបញ្ជាក់ថាអ្នកសុំទិដ្ឋាការនេះទំនងជានឹងវិលត្រឡប់មកកម្ពុជាវិញអាស្រ័យកិត្តិសព្ទ និងទ្រព្យសម្បត្តិរបស់គេ ក៏ប៉ុន្តែពួកគេភាគច្រើនបែរមិនត្រលប់មកវិញហើយរស់នៅ "អាមេរិក" តែម្តង បណ្ណាធិការនោះបន្ថែម[៤១]។

ចំណុចសំខាន់មានសារព័ត៌មានមួយចំនួនដែលត្រូវបានបោះពុម្ពច្រើនតែកើននៅមុនពេល បោះឆ្នោត និងនៅពេលដែលមានការចោទប្រកាន់ផ្នែកនយោបាយ។ នេះអាចបង្ហាញថាជាភស្តុតាងជាក់ស្តែងអំពីកំណើននៃតម្រូវការព័ត៌មាន និងតម្រូវឱ្យសារព័ត៌មាន មានការឆ្លើយតប ប៉ុន្តែវាទំនងជាអ្នកនយោបាយ

[៤០] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ នៅថ្ងៃទី១២ កញ្ញា ២០០៧ ។

[៤១] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ នៅថ្ងៃទី១២ កញ្ញា ២០០៧ ។

មួយចំនួនចូលចិត្តបង្ក និងគាំទ្រការបោះពុម្ពផ្សាយនៅក្នុងកំឡុងពេលនោះដូចជាការសរសេរិរះគន់មួយប្រាវ អ្នកនយោបាយចំណាយប្រាក់ដើម្បីឱ្យសាររបស់ពួកគេចេញលក់នៅតាមតូបសារព័ត៌មាន។

សារព័ត៌មានកម្ពុជាត្រូវបានគេពិពណ៌នាថាពុំមែនជា "អ្នកសង្កេតការណ៍ទេ ប៉ុន្តែជាអ្នកមានបញ្ហា"[៤២]។ ជាពិសេសផ្នែកសារព័ត៌មានដែលមានឈ្មោះថា "អ្នកចោទប្រកាន់ដ៏កំណាច" ដែលច្រើនតែពុំមានភស្តុតាងជាក់ស្តែង[៤៣]។ ការចោទប្រកាន់ភាគច្រើន គឺជារឿងនយោបាយ ហើយបើនៅប្រទេសដែលមានប្រព័ន្ធច្បាប់រឹងមាំ អ្នកសារព័ត៌មានខ្លះអាចនឹងទទួលនូវការចោទប្រកាន់ខាងរដ្ឋប្បវេណីពីបទបរិហាកេរ្តិ៍ ឬបង្ខូចកេរ្តិ៍ឈ្មោះ ថ្វីត្បិតតែអត់មានទោសប្រហារជីវិត ឬជាប់ពន្ធនាគារ ដូចជាករណីនៅកម្ពុជា។ ហេតុនេះសេរីភាពបោះពុម្ពផ្សាយ ជួនកាលពុំមានតុល្យភាពជាមួយការទទួលខុសត្រូវសំរាប់បោះពុម្ពផ្សាយត្រឹមត្រូវយុត្តិធមិ និងឯករាជ្យទេ។ អ្នកសង្កេតការណ៍មួយចំនួននិយាយថា គុណភាពនៃសារព័ត៌មានកម្ពុជា មានការកែលំអប្រសើរជាងមុនខ្លះៗចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ប៉ុន្តែអ្នកខ្លះទៀតនិយាយថានៅតែមានស្ថានភាពដដែល ។

ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាដែលបោះពុម្ពផ្សាយ មានសេរីភាពច្រើនជាងគេបំផុតក្នុងចំណោមប្រព័ន្ធដែលធ្លាប់បានប្រើប្រាស់ពីមុនៗមក ប៉ុន្តែវាមិនមែនជាសេរីភាពជាក់លាក់ទេ។ ការបោះពុម្ពផ្សាយភាគច្រើន គឺជាឧបករណ៍បំពងសម្លេងជំនួសគេ ឬត្រូវបានប្រើប្រាស់ដើម្បីជាការជម្រិតទារប្រាក់ទៅវិញ។ ទំនោរសេរីភាពដែលសារព័ត៌មានទទួលបាននោះ គឺជាអាវុធមុខពីរ។ អាស្រ័យដោយបទវិចារណកថានយោបាយ និងការចោទប្រកាន់រកឃើញនៅក្នុងអត្ថបទបោះពុម្ពរបស់ប្រព័ន្ធផ្សាយពតិមាន អ្នកសារព័ត៌មានច្រើនតែជាគោលដៅទទួលរងការវាយប្រហារលើរូបរាងកាយ បណ្តឹងផ្នែកផ្លូវច្បាប់ និងការគំរាមកំហែងរហូតដល់ឃាតកម្មផង។ ទោះបីជាយ៉ាងណាក្តី រឿងនេះវានៅមានកំរិតមួយឃ្លាតឆ្ងាយពីភាពជាអ្នកកីឡាក្នុងទីលានប្រកួត។ អ្នកសារព័ត៌មានដែលមាននិន្នាការនយោបាយខ្លះដូចជា សារព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជា ជាធម្មតាមានសេរីភាពក្នុងការបរិហារកេរ្តិ៍ និយាយពាក្យមិនពិត និងឃោសនានៅលើទំព័រសារព័ត៌មានរបស់ពួកគេបានដោយគ្មានទោសទណ្ឌ(និទ្ទណ្ឌភាព) អ្វីសោះ។ ប៉ុន្តែ អ្នកសារព័ត៌មានទាំងឡាយដែលពុំមែនជាសារព័ត៌មានគាំទ្រអ្នកកាន់អំណាច ច្រើនតែប្រឈមមុខទៅនឹងផលវិបាកធ្ងន់ធ្ងរចំពោះការផ្សព្វផ្សាយដូចគ្នានូវអ្វីដូចបានពោលខាងលើនេះ។

---

[៤២] Chris Tenove សារព័ត៌មានកម្ពុជា "ឆ្កែឆ្កួត" ពុំមែនជាអ្នកសង្កេតការណ៍ទេ" ការត្រួតពិនិត្យសារព័ត៌មាន UBC។ មេសា ២០០១។

[៤៣] អ្នកអត្ថាធិប្បាយសារព័ត៌មានអន្តរជាតិ-សម្ភាសន៍ថ្ងៃទី ២៤ សីហា ២០០៧។

## *វិទ្យុ*

ជោគជ័យនៃវិទ្យុអ៊ុនតាក់ និងការចែកចាយវិទ្យុចំនួន ៣៤៦.០០០ គ្រឿង ដោយឥតគិតថ្លៃរបស់អង្គការសហប្រជាជាតិនៅដើមទសវត្សរ៍១៩៩០ គឺជាការចាប់ផ្តើមធ្វើឱ្យវិទ្យុមានប្រជាប្រិយភាពយ៉ាងលឿននៅកម្ពុជា។ វិទ្យុត្រង់ស៊ីស្ទ័រ ខ្នាតតូច ជាប្រភេទវិទ្យុដែលមានតម្លៃថោក និងងាយស្រួលក្នុងការប្រើប្រាស់ ទោះបីជានៅតំបន់នោះពុំមានអគ្គិសនីក៏ដោយ។ លើសពីនេះទៀត វាងាយស្រួលក្នុងការដាក់តាមខ្លួន និងមានសារៈសំខាន់សំរាប់ស្តាប់នៅជុំវិញផ្ទះ ឬយកទៅតាមខ្លួនទៅស្រែចំការដែលត្រូវបានបង្កើននូវប្រជាប្រិយភាពនៅតាមតំបន់ជនបទ។

នៅកម្ពុជា មានស្ថានីយវិទ្យុផ្សាយសម្លេងចំនួន ៥៣ ដែលបានចុះបញ្ជីនៅក្រសួងព័ត៌មានរហូតមកដល់ខែមិថុនា ឆ្នាំ២០០៧។ ក្នុងចំណោមស្ថានីយទាំងនេះមាន២២ស្ថានីយ បោះទីតាំងនៅរាជធានីភ្នំពេញ និង៣១ស្ថានីយ នៅតាមបណ្តាខេត្តនានា ប៉ុន្តែចំនួននេះ រួមទាំងស្ថានីយផ្សាយបន្តផង។ ជាក់ស្តែង ស្ថានីយទាំងអស់គឺជាស្ថានីយវិទ្យុប្រេកង់ FM មានតែស្ថានីយវិទ្យុជាតិរបស់រដ្ឋប៉ុណ្ណោះ ដែលជាវិទ្យុប្រេកង់ AM ។

ស្ថានីយវិទ្យុភាគច្រើនប្រើឧបករណ៍ផ្សាយសម្លេងកម្លាំង ១០ គីឡូវ៉ាត់ ដែលអាចផ្សាយបានចម្ងាយប្រមាណ ១៥០ គីឡូម៉ែត្រ អាស្រ័យដោយកម្ពស់អង់តែន និងលក្ខណៈភូមិសាស្រ្ត។ លើកលែងតែវិទ្យុជាតិ ដែលមានឧបករណ៍ផ្សាយសម្លេងកម្លាំង ២២០ គីឡូវ៉ាត់ សម្រាប់ផ្សាយប្រេកង់ AM និង ឧបករណ៍កម្លាំង ២០ គីឡូវ៉ាត់សម្រាប់ផ្សាយប្រេកង់ FM ។ ម្ចាស់ស្ថានីយវិទ្យុឯកជនម្នាក់បាននិយាយថា មានការកំណត់ក្រៅផ្លូវការអំពីទំហំឧបករណ៍ផ្សាយរបស់វិទ្យុដែលពុំមែនជារបស់រដ្ឋាភិបាល[៤៤] ។

ចំនួនស្ថានីយវិទ្យុ ពុំមែនជាការឆ្លុះបញ្ចាំងឱ្យឃើញថាមានសេរីភាពក្នុងការផ្សព្វផ្សាយតាមរលកធាតុអាកាសទេ។ ការហាមប្រាមរបស់រដ្ឋាភិបាល ចំពោះការផ្តល់អាជ្ញាប័ណ្ណឱ្យស្ថានីយវិទ្យុបានធានាថា ស្ថានីយវិទ្យុភាគច្រើន ទោះបីជាមិនទាំងអស់ក៏ដោយ ប៉ុន្តែភាគច្រើន គឺជាវិទ្យុដែលគាំទ្ររដ្ឋាភិបាលចំពោះអ្វីដែលគេត្រូវផ្សព្វផ្សាយ។ រដ្ឋាភិបាលគឺជាម្ចាស់ផ្ទាល់ ឬមួយផ្នែកលើស្ថានីយវិទ្យុចំនួន ៥ ហើយស្ថានីយវិទ្យុឯកជនច្រើនមួយចំនួនទៀតជាកម្មសិទ្ធរបស់មន្ត្រីរដ្ឋាភិបាល។ លើសពីនេះទៀត ស្ថានីយវិទ្យុបាយ័ន

[៤៤] សម្ភាសន៍ជាមួយម្ចាស់ស្ថានីយវិទ្យុម្នាក់នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧។

និងអប្សារា (ជាសាខាស្ថានីយទូរទស្សន៍បាយ័ន និងអប្សារា) ហើយ គឺជាស្ថានីយសម្រាប់បម្រើជាឧបករណ៍បំពងសម្លេងរបស់គណបក្សប្រជាជនកម្ពុជាជាចំហរ។ គណបក្សប្រឆាំង និងបុគ្គលណាដែលទំនងជាមិនយោគយល់ដល់រដ្ឋាភិបាល (និងជាពិសេសគណបក្សប្រជាជនកម្ពុជា) តែងតែត្រូវបានបដិសេធមិនផ្តល់អាជ្ញាប័ណ្ណឱ្យទេនៅក្នុងរយៈពេលកន្លងមកនេះ។

ថ្វីត្បិតបើរដ្ឋាភិបាលគ្រប់គ្រងការផ្សព្វផ្សាយតាមរលកធាតុអាកាស(វិទ្យុ)ក៏ដោយ ក៏មានការលើកលែងចំពោះស្ថានីយ ឯករាជ្យខ្លះៗបានលេចចេញឡើងប្រៀបបានដូចជាសត្វខ្ទួតស៊ីទំលុះជញ្ជាំងដ៏រឹងមាំដែលជាសម្លេងឯករាជ្យមួយ ឬយ៉ាងតិចណាស់ក៏ជាសំលេងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ មានស្ថានីយវិទ្យុមួយចំនួនដែលគេនិយាយថា ជាស្ថានីយដែលត្រូវបានគាំទ្រដោយ ឬលំអៀងទៅខាងបក្សជំទាស់ហើយមានស្ថានីយពីរទៀតដែលគេចាត់ទុកថាជាស្ថានីយឯករាជ្យ។ ករណីទាំងអស់នេះ វាហាក់ដូចជាការផ្តល់អាជ្ញាប័ណ្ណស្ថានីយវិទ្យុគឺអាស្រ័យទៅដោយយុទ្ធសាស្ត្រ នយោបាយនៅពេល ស្នើសុំអាជ្ញាប័ណ្ណ ឬក៏មានទំនាក់ទំនងល្អជាបុគ្គលជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ឬ ការលក់ ឬ ផ្ទេរនូវអាជ្ញាប័ណ្ណ ដែលមានស្រាប់។ (ចំពោះព័ត៌មានបន្ថែមស្តីពីអាជ្ញាប័ណ្ណវិទ្យុ និងកម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មាន សូមអានត្រង់ចំណុចកម្មសិទ្ធិប្រព័ន្ធព័ត៌មានអាជ្ញាប័ណ្ណ និងលំអៀងខាងនយោបាយក្នុងរបាយការណ៍នេះ)។

មានស្ថានីយវិទ្យុពីរ ដែលគ្រប់គ្នានិយាយថាជាស្ថានីយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកនយោបាយ គឺវិទ្យុសម្បុកឃ្មុំ (FM 105) និងស្ថានីយវិទ្យុមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM 102)។ ស្ថានីយវិទ្យុមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជាគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលមានឈ្មោះដូចគ្នាភាគច្រើនផ្តោតទៅលើបញ្ហាសង្គមដែលប៉ះពាល់ដល់បញ្ហាស្ត្រី ហើយជាឧបករណ៍សំរាប់លើកកំពស់ការយល់ដឹងលើប្រធានបទទាំងអស់នេះ។ វិទ្យុនេះពុំមានការវិវាទផ្នែកនយោបាយទេ ហើយគេជឿជាក់ជាទូទៅថាជាវិទ្យុដែលមិនផ្សាយរិះគន់ខ្លាំងៗដល់រដ្ឋាភិបាលទេ។

ចំណែកឯវិទ្យុសម្បុកឃ្មុំវិញ មិនដែលឃ្លាតចាកពីជំហរត្រង់ៗរបស់គាត់ឡើយ ហើយគេជឿជាក់ថាជាវិទ្យុដែលមានប្រជាប្រិយភាពជាងគេ និងគេស្គាល់ថាជាវិទ្យុដែលផ្សាយនូវទស្សនៈជំទាស់ ហើយធ្លាប់ត្រូវបានរដ្ឋាភិបាលបញ្ជាឱ្យបិទពីរបីដង ហើយម្ចាស់វិទ្យុនេះធ្លាប់ជាប់ពន្ធនាគារអស់ ២ដងផងដែរ។

គេនិយាយថា វិទ្យុសម្បុកឃ្មុំគ្របដណ្តប់ការផ្សព្វផ្សាយដល់ទៅ ២ ភាគ ៣ នៃទូទាំងប្រទេសហើយបានផ្តល់ជាប្រចាំនូវវេទិការដ៏កម្រសម្រាប់ព័ត៌មានឯករាជ្យ និងសម្លេងរិះគន់។ វិធីមួយដែលវិទ្យុ

នេះបានធ្វើនោះ គឺការជួលម៉ោងផ្សាយឱ្យទៅគណបក្សជំទាស់ ដែលមិនអាចសុំអាជ្ញាប័ណ្ណវិទ្យុខ្លួនឯងបាន ដើម្បីផ្សព្វផ្សាយទស្សនៈ និងកម្មវិធីនយោបាយរបស់គេ។

សំខាន់បំផុត វិទ្យុសម្បុកឃ្មុំ តាំងពីឆ្នាំ១៩៩៩ បានជួលម៉ោងផ្សាយទៅឱ្យវិទ្យុអាស៊ីសេរី ដែលជាវិទ្យុផ្សាយសម្លេងអន្តរជាតិផ្តល់មូលនិធិដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក (RFA) និងវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA)។ ប៉ុន្មានឆ្នាំថ្មីៗនេះ ក៏បានជួលម៉ោងផ្សាយទៅសម្លេងប្រជាធិបតេយ្យ (VOD) ដែលពីមុនជាផ្នែកមួយនៃអង្គការសិទ្ធិមនុស្ស បង្កើតឡើងដោយលោក កឹម សុខា ដែលក្រោយមកបានចាកចេញពីអង្គការនោះ ហើយមកបង្កើតគណបក្សសិទ្ធិមនុស្ស។ រដ្ឋាភិបាលតែងតែបដិសេធមិនផ្តល់អាជ្ញាប័ណ្ណឱ្យវិទ្យុអាស៊ីសេរី សម្លេងសហរដ្ឋអាមេរិក និងសម្លេងប្រជាធិបតេយ្យទេ។

ព្រឹត្តិប័ត្រសារព័ត៌មានជាភាសាខ្មែរ កម្មវិធីពិភាក្សាតាមទូរស័ព្ទ និងវេទិកានានារបស់វិទ្យុអាស៊ីសេរី សម្លេងសហរដ្ឋអាមេរិក និងសម្លេងប្រជាធិតេយ្យ ព្រមទាំងវិទ្យុអន្តរជាតិបារាំង (ដែលមានស្ថានីយផ្ទាល់ខ្លួន) ជឿថា ជាកម្មវិធីមានប្រជាប្រិយភាព ហើយជាពិសេសចំពោះអ្នកស្តាប់នៅភ្នំពេញ[៤៥]។ ទាំងអស់គ្នា គេបានផ្តល់នូវសេចក្តីរាយការណ៍ និងវិចារណកថាយ៉ាងម៉ឺងម៉ាត់ និងឯករាជ្យតាមរលកធាតុអាកាសដែលជាការទប់ទល់យ៉ាងសំខាន់ទៅនឹងវិទ្យុរដ្ឋាភិបាលដែលគ្របដណ្តប់លើសលប់លើគេ។

មិនបាច់ងឿងឆ្ងល់ទេ អ្នកសារព័ត៌មានទាំងអស់នេះ ហើយជាពិសេសពួកដែលបម្រើការងារនៅវិទ្យុអាស៊ីសេរីដែលល្បីខាងរាយការណ៍ពីមូលដ្ឋាន និងគាស់កកាយបញ្ហាការកាប់ឈើខុសច្បាប់ និងអំពើពុករលួយតែងតែប្រឈមមុខជាមួយនឹងការគំរាមកំហែង និងបំភិតបំភ័យ។ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីមួយចំនួនបានចាកចេញពីប្រទេសដោយសារតែមានការគំរាមកំហែងដល់អាយុជីវិត។

ជើងឯកក្នុងការផ្សាយព្រឹត្តិប័ត្រសារព័ត៌មាន វិទ្យុអាស៊ីសេរី និងសម្លេងសហរដ្ឋអាមេរិកដែលចាក់ផ្សាយតាមរយៈវិទ្យុសម្បុកឃ្មុំ(ដែលពីដើមគ្រាន់តែផ្សាយចូលមកកម្ពុជាតាមរលកធាតុអាកាសខ្លីពីបរទេសប៉ុណ្ណោះ) បានធ្វើឱ្យគេអាចផ្សាយដល់អ្នកស្តាប់ដែលគេមិនធ្លាប់បានផ្សាយទៅដល់កាលពីមុន។ ព្យាករណ៍មើលទៅ (អាចទាយទុកមុនបាន) រដ្ឋាភិបាលបានជំទាស់នឹងបញ្ហានេះ ហើយធ្លាប់បង្ខំឱ្យវិទ្យុសម្បុកឃ្មុំផ្អាក

---

[៤៥] ចំពោះវិទ្យុអាស៊ីសេរី តាមការសិក្សាមួយបានឱ្យដឹងថា ជាង ៣១%នៃប្រជាពលរដ្ឋទូទាំងប្រទេស និង ៥៦% នៃប្រជាពលរដ្ឋដែលរស់នៅក្នុងរង្វង់ ៨0 គីឡូម៉ែត្រពីភ្នំពេញ ស្តាប់វិទ្យុអាស៊ីសេរី ជាប្រចាំ ។ Shawn W. Crispen។ សមរភូមិអ្នកផ្សាយសម្លេងកម្ពុជា-គណៈកម្មការដើម្បីការពារអ្នកសារព័ត៌មាន-ខែតុលា ២00៧ ។ [http://.cpj.org/cambodiabroatcasters/index.html](http://.cpj.org/cambodiabroatcasters/index.html)

ការផ្សាយរបស់សម្លេងសហរដ្ឋអាមេរិក និងអាស៊ីសេរីជាច្រើនដងរួចហើយ ។ ទោះបីជា រដ្ឋាភិបាលបដិសេធមិនព្រមផ្តល់អាជ្ញាប័ណ្ណឱ្យអាស៊ីសេរី និងសម្លេងសហរដ្ឋអាមេរិក និងថ្មីៗនេះមិនផ្តល់ឱ្យ សម្លេងប្រជាធិប-តេយ្យក៏ដោយ ក៏រដ្ឋាភិបាលហាក់ដូចជាឈប់បង្ខំ (យ៉ាងតិចណាស់សម្រាប់បច្ចុប្បន្ន) ឱ្យវិទ្យុសម្បុកឃ្មុំផ្អាកការផ្សាយកម្មវិធីរបស់វិទ្យុទាំងបីនោះដែរ ។

ស្ថានីយវិទ្យុខ្លះទៀតដូចជា មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM ១០២ បច្ចុប្បន្ននេះក៏ផ្សាយកម្មវិធីសម្លេងសហរដ្ឋអាមេរិក អាស៊ីសេរី ឬសម្លេងប្រជាធិបតេយ្យដែរ ។

ការអភិវឌ្ឍន៍ថ្មីៗក្នុងវិស័យវិទ្យុ គឺកាលពីខែឧសភា ២០០៧ កន្លងទៅនេះ មានការបង្កើតសមាគមផ្សាយសម្លេងកម្ពុជាក្រោមការដឹកនាំរបស់អគ្គនាយកទូរទស្សន៍ និងវិទ្យុអប្សារា ឈ្មោះ សុខ ឦសាន្តជាសមាជិកគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា ។ ភ្លាមៗនោះសមាគមបានកើនសមាជិករហូតដល់ ៣០ ស្ថានីយវិទ្យុ ហើយបានប្រារព្ធកិច្ចប្រជុំប្រចាំខែរបស់ខ្លួននៅក្នុងទីស្នាក់ការគណបក្សប្រជាជនកម្ពុជាភ្នំពេញ ។ ត្រង់ចំណុចនេះ នៅមិនទាន់ច្បាស់ថាសមាគមដើរតួនាទីអ្វីនោះទេ[៤៦] ។

ប្រព័ន្ធផ្សាយព័ត៌មានវិទ្យុកម្ពុជាគឺជាថង់ចម្រុះមួយ ។នៅពេលដែលមានស្ថានីយភាគច្រើនគ្រប់គ្រងដោយគណបក្សនយោបាយ ជាពិសេសគឺគណបក្សប្រជាជនកម្ពុជាក៏នៅមានជំហរដ៏រឹងមាំរបស់វិទ្យុសម្បុកឃ្មុំ ដែលបានអនុញ្ញាតឱ្យវិជ្ជាជីវៈខាងសារព័ត៌មានការស៊ើបអង្កេត និងធ្វើសេចក្តីរាយការណ៍នានាក្នុងការរិះគន់រដ្ឋាភិបាលបានផ្សាយទៅដល់មហាជន ។

## ទូរទស្សន៍

យើងអាចនិយាយថាទូរទស្សន៍ គឺជាប្រព័ន្ធផ្សាយព័ត៌មាន ដ៏មានប្រជាប្រិយភាពជាងគេបង្អស់នៅកម្ពុជា ហើយដោយសារតែការផ្សាយបានយ៉ាងទូលំទូលាយរបស់វា និងឥទ្ធិពលនៃរូបភាពមានចលនាបានក្លាយជាប្រព័ន្ធផ្សាយព័ត៌មានមួយដែលត្រូវបានគេរិតត្បិតជាងគេបំផុតក្នុងចំណោមប្រព័ន្ធផ្សាយព័ត៌មានទាំងអស់ ។ គ្រប់ស្ថានីយទូរទស្សន៍ទាំងអស់ក្នុងចំណោមស្ថានីយចំនួន ៧ នៅកម្ពុជា[៤៧] សុទ្ធតែជាស្ថានីយដែលជា

[៤៦] ឆ្លើយឆ្លងជាមួយប្រធានកម្មវិធីវិទ្យុកាលពី ថ្ងៃទី២០ វិច្ឆិកា ២០០៧ ។

[៤៧] ប៉ុស្តិ៍លេខ ៣ លេខ ៥ ទទក លេខ ៩ អប្សារា ស៊ីធីអិន និងប៉ុស្តិ៍បាយ័ន ។ មានទូរទស្សន៍ខ្សែរកាបពីរទៀត ដែលផ្សាយប៉ុស្តិ៍ក្នុងស្រុក និងអន្តរជាតិ ។

របស់រដ្ឋាភិបាល ឬជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាល ហើយជាពិសេសជិតដិតជាមួយគណបក្សប្រជាជនកម្ពុជា។ ព័ត៌មានណាដែលមានលក្ខណៈជំទាស់នឹងរដ្ឋាភិបាល គឺអាចត្រូវបានត្រួតពិនិត្យដោយរដ្ឋាភិបាល ឬ ដោយអ្នកសារព័ត៌មានផ្ទាល់ខ្លួន និងដោយអ្នកផលិតកម្មវិធីនោះ។ អ្នកយកព័ត៌មានទូរទស្សន៍ម្នាក់បាននិយាយថា "ខ្ញុំគិតថានៅគ្រប់ទីកន្លែងណាក៏ដោយ ក៏មានការត្រួតពិនិត្យដែរ" [៤៨] ។

*"ខ្ញុំគិតថានៅគ្រប់ទីកន្លែងណាក៏ដោយ ក៏មានការត្រួតពិនិត្យដែរ" អ្នកយកព័ត៌មានទូរទស្សន៍ម្នាក់បាននិយាយ។*

ស្ថានីយទូរទស្សន៍ ៣ ទូរទស្សន៍កម្ពុជា បាយ័ន ស៊ីធីអិន ស្ទើរតែគ្របដណ្តប់លើទូទាំងប្រទេស។ ការ គ្របដណ្តប់របស់ស្ថានីយ៍ទូរទស្សន៍ផ្សេងទៀតអាស្រ័យទៅដោយស្ថានីយផ្សាយបន្តរបស់ខ្លួន។ កន្លងមកពុំធ្លាប់មានការស្រាវជ្រាវឯករាជ្យណាមួយដែលទូលំទូលាយ ដើម្បីឱ្យដឹងថាស្ថានីយទូរទស្សន៍ណាមួយមានអ្នកមើលច្រើនជាងគេទេ។

កម្មវិធីកំសាន្តជាអ្នកនាំមុខគេនៅទូរទស្សន៍កម្ពុជា។ រឿងល្ខោនភាគផលិតក្នុងប្រទេស ការប្រគុំតន្ត្រី ល្បែងកំសាន្ត និងរឿងកំប្លែងលើឆាក ទាំងអស់នេះសំខាន់ជាងគេ។ រឿងថៃធ្លាប់មានប្រជាប្រិយភាព ប៉ុន្តែ ក្រោយមកត្រូវបានហាមឃាត់ដោយរដ្ឋាភិបាល ក្រោយពីមានកុប្បកម្មប្រឆាំងថៃ កាលពីខែមករា ២០០៣ កន្លងមក។ ឃើញមានរឿងល្ខោន និងភាពយន្តបរទេសខ្លះដែរ ដែលត្រូវបានបញ្ចូលសម្លេងជាភាសាខ្មែរ។ រឿងខ្មោចចិន និងភាពយន្តគំនូរជីវចល ក៏មានប្រជាប្រិយ ដូចគ្នានឹងកីឡាបោកចំបាប់អាមេរិកដែរ។

ប្រជាពលរដ្ឋកម្ពុជា ដែលពុំមានលទ្ធភាពទិញទូរទស្សន៍ដោយខ្លួនឯងបាន ហើយចង់មើលនោះ ត្រូវទៅហាងកាហ្វេណាមួយ ដែលចំណាយត្រឹមតែថ្លៃកាហ្វេ ក៏អាចមើលទូរទស្សន៍បានដែរ។

ដោយទូរទស្សន៍នីមួយៗអាចប្រឹងប្រកួតប្រជែងគ្នាដើម្បីទាក់ទាញទូរទស្សនិកជនស្ថានីយ៍ទូរទស្សន៍ទាំង ៧ បញ្ចាំងកម្មវិធីព័ត៌មានដូចគ្នាបេះបិទ គ្មានស្ថានីយណាមួយមានលក្ខណៈអព្យាក្រឹត្យផ្នែកនយោបាយបន្តិចទាល់តែសោះ។ នេះជាបញ្ហាមួយអាចព្យាករណ៍បានដោយគ្រាន់តែពិនិត្យមើលម្ចាស់ស្ថានីយតែប៉ុណ្ណោះ។ ទូរទស្សន៍របស់រដ្ឋ ទទក គឺស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងព័ត៌មាន ហើយស្ថានីយពីរទៀត គឺជាស្ថានីយដែលរដ្ឋាភិបាលមានភាគហ៊ុននៅក្នុងនោះដែរ។ ស្ថានីយពីរទៀត គឺអប្សរា

[៤៨] សម្ភាសន៍ជាមួយអ្នកយកព័ត៌មានទូរទស្សន៍ម្នាក់កាលពី ថ្ងៃទី១១ កញ្ញា ២០០៧។

និងបាយ័ន (ដែលមានស្ថានីយវិទ្យុផងដែរ) ត្រូវបានគេជឿជាក់ជាទូទៅថា ជារបស់គណបក្សប្រជាជនកម្ពុជា និងជារបស់គ្រួសារប្រមុខរដ្ឋាភិបាល។ ស្ថានីយទី៦ គឺមានសម្ព័ន្ធភាពជាមួយគណបក្សហ៊្វុនស៊ីនប៉ិច ហើយជារបស់ ឬ ផ្តល់អាជ្ញាប័ណ្ណឱ្យរដ្ឋមន្ត្រីម្នាក់ដែលមកពីគណបក្សនោះ ប៉ុន្តែធាតុពិត ក៏ជាទូរទស្សន៍គាំទ្ររដ្ឋាភិបាលដែរ ហើយមិនដែលរិះគន់គណបក្សប្រជាជនកម្ពុជាទេ។ ស្ថានីយក្រោយគេបង្អស់ និងថ្មីជាងគេ គឺជារបស់ពាណិជ្ជករដែលជាមហាសេដ្ឋីម្នាក់ដែលគេជឿជាក់ថា ជិតស្និទ្ធជាមួយគណបក្សប្រជាជនកម្ពុជា ។

ស្ថានីយនីមួយៗមានទំនាក់ទំនងជាមួយរដ្ឋាភិបាល និងគណបក្សកាន់អំណាច ហើយបានបង្កឱ្យមានភាពលំអៀងផ្នែកនយោបាយ ដែលនឹងលើកយកមកពិភាក្សាពិស្តារនៅក្នុងភាគខាងក្រោមនៃរបាយការណ៍នេះ។ ប៉ុន្តែនិយាយឱ្យខ្លី ព័ត៌មានទូរទស្សន៍កម្ពុជា គឺជាមធ្យោបាយគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នសម្រាប់ឃោសនាឱ្យរដ្ឋាភិបាល។

ព័ត៌មានពេលយប់ភាគច្រើនផ្សាយខ្លីៗ អំពីសកម្មភាពរបស់អ្នកមានបណ្តាស័ក្តិនានានៃរដ្ឋាភិបាល (ជាធម្មតាគណបក្សប្រជាជនកម្ពុជា) ចែកអំណោយ ប្រាក់កាស និងសម្ភារៈផ្សេងៗដល់អ្នកក្រីក្រ សកម្មភាពចុះពិនិត្យមើលផ្លូវ និងប្រព័ន្ធធារាសាស្ត្រដែលទើបកសាងរួច ឬ រៀបចំសិក្ខាសាលា និងសន្និសីទនានា។ ហើយមន្ត្រីដដែលនេះត្រូវបានបញ្ចាំងសារឡើងវិញម្តងហើយម្តងទៀត ចំណែកអ្នកនយោបាយបក្សប្រឆាំង និងសម្លេងប្រឆាំងវិញកម្របានឃើញណាស់។ បញ្ហាសំខាន់ៗ និងព្រឹត្តិការណ៍ព័ត៌មានដែលគេចាត់ទុកថាជាព័ត៌មានស្មុគស្មាញ ដូចជាការជម្លៀសប្រជាពលរដ្ឋជាដើម ដូច្នេះគេតែងតែបំភ្លេចចោល។

ប្រធានស្ថានីយទូរទស្សន៍ មិនដែលសុំទោសទូរទស្សន៍និកជន ពីរឿងឃោសនាដដែលៗដែលបានផ្តល់ ឱ្យទូរទស្សនិកជនរបស់ខ្លួនម្តងណាឡើយ។

នៅពេលដែលសួរអំពីមាតិកា ដែលគាំទ្ររដ្ឋាភិបាលហួសហេតុនោះ នាយកស្ថានីយទូរទស្សន៍អប្សរាបានពន្យល់ថា *"ការផ្សាយរបស់ទូរទស្សន៍យើងគឺជាការបង្ហាញនូវភារកិច្ច និងសមត្ថភាពរបស់រដ្ឋាភិបាល ប្រសិនបើយើងមិនគាំទ្ររដ្ឋាភិបាលទេ តើអ្នកណាជាអ្នកគាំទ្រ?"* ។

សូម្បីតែស្ថានីយទូរទស្សន៍ ស៊ីធីអិន ជាស្ថានីយថ្មីជាងគេបង្អស់ដែលបង្ហាញនូវមុខមាត់ពេញនិយម និងទាន់សម័យ ហើយផ្តោតទៅលើយុវវ័យក៏គ្មានអ្វីខុសពីគូប្រកួតចាស់ៗរបស់ខ្លួនដែរ នៅពេលនិយាយអំពី

*"ប្រសិនបើយើងមិនគាំទ្ររដ្ឋាភិបាលទេ តើអ្នកណាជាអ្នកគាំទ្រ?"នាយកស្ថានីយទូរទស្សន៍អប្សរាបានពន្យល់*

ព័ត៌មាននយោបាយ។ ស្ថានីយនេះផ្សាយវីដេអូខ្លីៗស្តីពីសកម្មភាពនាយក រដ្ឋមន្ត្រី និងមេដឹកនាំរដ្ឋាភិបាលផ្សេងៗចុះពិនិត្យមើលការងារសាធារណៈ និងចែកអំណោយរយៈពេលពីរ បីនាទី ហើយកម្មវិធី "វិភាគ" ព័ត៌មានវិញផ្សាយគាំទ្រមាគ៌ាគណបក្សប្រជាជនកម្ពុជាដោយត្រង់ៗ និងអាចព្យាករណ៍បាន។

ការត្រួតពិនិត្យព័ត៌មានដ៏តឹតលាក់លៀមបំផុត គឺនៅក្នុងស្ថានីយទូរទស្សន៍ជាតិកម្ពុជា (ទទក)។ គ្រប់តួអក្សរក្នុងសារព័ត៌មានត្រូវបានពិនិត្យពិច័យដោយអគ្គនាយកស្ថានីយ ជាមួយនឹងសេចក្តីរាយការណ៍ព័ត៌មានណាដែលមានលក្ខណៈនយោបាយត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងព័ត៌មានត្រួតពិនិត្យ នេះបើតាមការរៀបរាប់របស់អ្នកយកព័ត៌មានម្នាក់ អំពីដំណើរការនៃការត្រួតពិនិត្យ[៤៩]។

រឿងខ្លីៗ ជាភស្តុតាងបង្ហាញឱ្យឃើញនូវការហាមប្រាមស្រដៀងគ្នា នៅគ្រប់ស្ថានីយទាំងអស់ ប៉ុន្តែប្រហែលជាធ្វើការត្រួតពិនិត្យដោយខ្លួនឯងច្រើនជាងការពិនិត្យមុនការផ្សាយដូចជាទូរទស្សន៍ជាតិជាដើម។

សមាគមទូរទស្សន៍កម្ពុជាដែលបានប្រារព្ធកិច្ចប្រជុំប្រចាំខែរបស់ខ្លួនជាមួយនាយកស្ថានីយទូរទស្សន៍ទាំងអស់ ដើរតួជាខ្សែបណ្តាញរវាងស្ថានីយ និងក្រសួងព័ត៌មាន (ដែលផ្តល់អាជ្ញាប័ណ្ណ)។ ប្រធានសមាគមលោក ម៉ៅ អាយុទ្ធ ជាអតីតនាយកស្ថានីយទូរទស្សន៍ជាតិ (ទទក) បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាសមាជិកគណៈកម្មការកណ្តាលនៃគណបក្សកាន់អំណាចគណបក្សប្រជាជនកម្ពុជា។ នៅក្នុងកិច្ចប្រជុំ គេច្រើនពិភាក្សាអំពីបញ្ហាកំប៉ិកកំប៉ុកដូចជា តួសំដែងស្លៀកពាក់សម្លៀកបំពាក់ខ្លី អង្គប្រជុំក៏បាននិយាយជាមួយនាយកអំពីមាតិកានយោបាយដែរ។

លោក ជុំ កុសល ដែលបានចែកពេលខ្លះធ្វើជាអ្នកអានព័ត៌មាននៅស្ថានីយទូរទស្សន៍ ស៊ីធីអិន និងជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី បាននិយាយថា ប្រសិនបើស្ថានីយទូរទស្សន៍ណាមួយនិយាយអ្វីមិនច្បាស់វាអាចនាំឱ្យមានការប៉ះពាល់។

ជារួម ទូរទស្សន៍កម្ពុជាទទួលបានប្រជាប្រិយភាព សម្រាប់កម្មវិធីកំសាន្ត ប៉ុន្តែមាតិកាព័ត៌មានរបស់ទូរទស្សន៍ត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹង។

---

[៤៩] សម្ភាសន៍ជាមួយអ្នកយកព័ត៌មានម្នាក់នៅថ្ងៃទី ១១ កញ្ញា ២០០៧ ។ តាមច្បាប់ស្តីពីសារព័ត៌មានចែងថា ការត្រួតពិនិត្យមុនការផ្សាយគឺជាអំពើខុសច្បាប់ ប៉ុន្តែពុំមានច្បាប់ណាគ្របដណ្តប់លើសារព័ត៌មាននេះទេ។

## *អ៊ីនធឺណេត*

អ៊ីនធឺណេតមានឥទ្ធិពលនៅកម្ពុជា នៅមានកំរិតនៅឡើយ ប៉ុន្តែរីកចម្រើនទៅមុខ។

ការប្រើប្រាស់អ៊ីនធឺណេត ត្រូវបានរារាំងដោយតម្លៃខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធនៅមានកំរិត កង្វះជំនាញផ្នែកកុំព្យូទ័រព្រមទាំងការលំបាកក្នុងការបង្កើតអក្សរខ្មែរឱ្យបានតាមបទដ្ឋាន។ ប៉ុន្តែ បច្ចេកទេសទំនើប និងការបង្កើតឡើងនូវយូនីកូដ ជាវិធីមួយដើម្បីរៀបចំអក្សរខ្មែរឱ្យស្របតាមបទដ្ឋានអាចជួយនាំមកនូវការរីកចម្រើននៅក្នុងរង្វង់អ៊ីនធឺណែតកម្ពុជា[៥០] ។

នៅកម្ពុជា យ៉ាងតិចក៏មានក្រុមហ៊ុនផ្ដល់សេវាកម្មអ៊ីនធឺណេតចំនួន ១០ ដូចជា Cashin.net, Camintel, Cogetel's Online (ពីដើម Bigpond), Mobitel's Everyday សេវារបស់រដ្ឋ Camnet Services[៥១] ។

តាមការប៉ាន់ស្មាននៅកម្ពុជាមានអ្នកប្រើអ៊ីនធឺណេតចំនួន ៤៤.០០០ នាក់ នៅទូទាំងប្រទេស[៥២] ។ ភាគច្រើនគេប្រើនៅតាមអ៊ីនធឺណេតកាហ្វេ មិនសូវមានអ្នកមានកុំព្យូទ័រអ៊ីនធឺណេតផ្ទាល់ខ្លួន ឬអ៊ីនធឺណេតប្រើប្រាស់ទេ។

ការធ្វើ "ប្លុក" (គេហទំព័រ) កាន់តែមានប្រជាប្រិយភាពក្នុងចំណោមនិស្សិតកម្ពុជា។ ប៉ុន្តែអ្នកដែលផលិតប្លុកដែលល្បីឈ្មោះជាងគេ គឺអតីតព្រះមហាក្សត្រនរោត្តមសីហនុ ដែលធ្លាប់សកម្មជាច្រើនឆ្នាំមកហើយ[៥៣] ។

---

[៥០] រហូតមកដល់ពេលថ្មីៗនេះ អក្សរខ្មែរច្រើនប្រភេទត្រូវបានប្រើ ហើយមិនស្របគ្នាឡើយ។ នៅឆ្នាំ ២០០៤ សង្គមបើកចំហកម្ពុជា បានចេញផ្សាយយូនីកូដ ដែលប្ដូរអក្សរខ្មែរចំនួន ២០ ផ្សេងៗគ្នា។ ចាប់តាំងពីពេលនោះមក គេបានចេញផ្សាយការប្រើប្រាស់ Software ដំបូង យ៉ាងពេញលេញ ហើយកត់ត្រាជាភាសាខ្មែរ។

[៥១] តាមវែបសាយៈ ទ្រង់ទ្រាយវប្បធម៌ៈ កម្ពុជា ។ http://www.culturalprofiles.net/Cambodia/Directories/Cambodia_Cultural_Profile/-176.html

[៥២] ស្ថិតិនេះត្រូវបានគេប្រើប្រាស់ជាទូទៅ ហើយមានប្រភពមកពីសហព័ន្ធទូរគមនាគមន៍អន្តរជាតិរបស់អង្គការសហប្រជាជាតិ ប៉ុន្តែមិនច្បាស់ថា គេគណនាដោយរបៀបណាទេ។

[៥៣] វែបសាយរបស់អតីតព្រះមហាក្សត្រគឺ www.norodomsihanouk.info ។ ធ្លាប់មានមនុស្សបើកមើលជាង ១.៣ លាននាក់ យោងតាមការរាប់របស់វែបសាយ កាលពីថ្ងៃទី២១ តុលា ២០០៧។

សារព័ត៌មានភាសាខ្មែរមួយចំនួនក៏មាន "វែបសាយ" (គេហទំព័រ)ដូចសារព័ត៌មានភាសាបរទេសដែរ ដូចជាភ្នំពេញប៉ុស្តិ៍ជាដើម ។

វែបសាយព័ត៌មានដែលគួរឱ្យកត់សម្គាល់មួយគឺ KI Media ដែលមានពាក្យស្លោកថា "ផ្សាយតែព័ត៌មានក្តៅគគុកអំពីកម្ពុជា" ។ ព័ត៌មាននោះធ្វើដូចនេះមែន ប្រមូលប្រព័ន្ធផ្សាយព័ត៌មានតាមអ៊ីនធឺណេតនូវរឿងរ៉ាវដែលពាក់ព័ន្ធនឹងកម្ពុជា ហើយក៏បានចុះផ្សាយនូវរឿងបកប្រែពីភាសាខ្មែរមកជាភាសាអង់គ្លេសដែលយើងមិនស្វែងរកជាភាសាអង់គ្លេសបានទេនៅកន្លែងផ្សេងៗ ។ មាតិការបស់វែបសាយ គឺមានលក្ខណៈគាំទ្រគណបក្សប្រឆាំង សម រង្ស៊ី ហើយអ្នកសង្កេតការណ៍ជាច្រើនជឿជាក់ថា វែបសាយនេះ បង្កើតឡើងដោយគណបក្ស ឬ អ្នកគាំទ្រគណបក្សនេះ ។

អ៊ីនធឺណេតក៏បានផ្តល់នូវប្រភពនៃព័ត៌មានក្តៅគគុកក្នុងពេលរដ្ឋាភិបាលបង្ក្រាបដែរ ។ នៅខែមិថុនា ឆ្នាំ២០០៧ របាយការណ៍មួយរបស់ក្លូបបលវិតណេស (Global Witness) ស្តីពីការកាប់ឈើខុសច្បាប់ និងអំពើពុករលួយត្រូវបានរដ្ឋាភិបាលហាមឃាត់ ប៉ុន្តែអាចចម្លងពីវែបសាយបាន ។ ស្រដៀងគ្នា នេះដែរ ឯកសារមួយ ដែលផលិតដោយផលិតករភាពយន្តជនជាតិអាមេរិកម្នាក់ឈ្មោះ ប្រាដលី ខក់ (Bradley Cox) ស្តីពីឃាតកម្មមេដឹកនាំសហជីពសេរីកម្មករឈ្មោះ ជា វិជ្ជា ក៏ត្រូវបានរដ្ឋាភិបាលហាមឃាត់ដែរប៉ុន្តែក៏នៅតែអាចអានបានតាមវែបសាយ ។

តួនាទីរបស់អ៊ីនធឺណេតនៅក្នុងបរិយាកាសប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ត្រូវតែតាមដានមើលនៅពេលអនាគត ។

## សមាគមប្រព័ន្ធផ្សាយព័ត៌មាន

### *សមាគមប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា*

ក្លឹបអ្នកសារព័ត៌មានកម្ពុជាដំបូងបង្អស់ គឺសមាគមអ្នកសារព័ត៌មានកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣[៥៤] ហើយជាដំបូងត្រូវបានគាំទ្រដោយអ្នកសារព័ត៌មាន សឹងតែទាំងអស់នៃសារព័ត៌មានសំខាន់ៗ។ ក្រោមការដឹកនាំរបស់ប្រធានដំបូង លោក ពិន សំខុន សមាគមនេះបានប្រឆាំងនឹងការចាប់ និងការឃុំខ្លួនរបស់អ្នកសារព័ត៌មាន ហើយតស៊ូមតិជំទាស់នឹងច្បាប់សារព័ត៌មានដ៏តឹងរឹង ដែលត្រូវបានធ្វើសេចក្ដីព្រាង ដោយរដ្ឋាភិបាល។ នៅពេលដែលសមាគមនេះកាន់តែសកម្មឡើងដូចជាការធ្វើការស្ទង់មតិស្ដីពីប្រជាប្រិយ ភាពរបស់អ្នកនយោបាយ វាបានក្លាយជាសមាគមមួយដែលលែងមានប្រជាប្រិយភាពជាមួយរដ្ឋាភិបាល។ បណ្ណាធិការសារព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជាដូចជា លោក ប៉ែន សមិទ្ធិ នៅសារព័ត៌មានរស្មីកម្ពុជា បានជំទាស់ជំហររបស់សមាគមអ្នកសារព័ត៌មានអំពីច្បាប់ស្ដីពីសារព័ត៌មាន និងការស្ទង់មតិ ហើយក៏បានដកសមាជិកភាពចេញពីសមាគមនេះទៅ។

កំឡុងពេល ២ឆ្នាំ ដែលបានបង្កើតឡើង មានសារព័ត៌មានមួយក្រុមដែលគាំទ្ររដ្ឋាភិបាល (ដោយមានការគាំទ្រជាចំហរពីសំណាក់ សម្ដេច ហ៊ុន សែន និងសម្ដេច ក្រុមព្រះ) បានបំបែកខ្លួនចេញពីសមាគមអ្នកសារព័ត៌មានកម្ពុជាដើម្បីបង្កើតសមាគមរបស់គេផ្ទាល់ ដែលមានឈ្មោះថាសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (LCJ) ភ្លាមៗនោះដែរ មានជម្លោះផ្ទៃក្នុងដណ្ដើមតំណែងប្រធាននៅក្នុងសមាគមអ្នកសារព័ត៌មានកម្ពុជាបានលេចឡើងរវាង លោក ពិន សំខុន និងបណ្ណាធិការម្នាក់មកពីសារព័ត៌មានកម្ពុជាដែលជាសារព័ត៌មានរបស់រដ្ឋ។ បណ្ណាធិការនេះត្រូវបានគាំទ្រដោយអ្នកសារព័ត៌មានដែលគាំទ្ររដ្ឋាភិបាល ហើយមិនយូរប៉ុន្មានទេ សមាគមអ្នកសារព័ត៌មានកម្ពុជានោះក៏បានស្ងប់ស្ងាត់គ្មានសកម្មភាព ហើយស្ងាត់តែម្ដង។

បទពិសោធន៍របស់សមាគមអ្នកសារព័ត៌មានកម្ពុជា គឺជាសញ្ញាដែលអ្វីមួយនឹងមកដល់ដោយការរួបរួមរបស់អ្នកសារព័ត៌មានកម្ពុជាមានអាយុកាលខ្លី និងក្លាយជារឿងនយោបាយ ហើយការបែកបាក់ជាក្រុមផ្សេងៗគ្នាគឺជារឿងធម្មតាទៅហើយ។

---

[៥៤] ប៉ុន្តែ យោងតាមបញ្ជីរបស់ក្រសួងព័ត៌មាន សមាគមនេះមិនទាន់បានចុះបញ្ជីទេ រហូតដល់ឆ្នាំ ១៩៩៤។

បច្ចុប្បន្នមានក្លឹបនិងសមាគមអ្នកសារព័ត៌មានកម្ពុជាចំនួន១៥ ដែលបានចុះបញ្ជីនៅក្រសួងព័ត៌មាន។ ខាងក្រោមនេះគឺជាបញ្ជីសមាគម និងក្លឹបៈ

| **ឈ្មោះក្លឹប/សមាគម** | **កាលបរិច្ឆេទបង្កើត** |
|---|---|
| សមាគមអ្នកសារព័ត៌មានខ្មែរ | ២៨ កក្កដា ១៩៩៤ |
| សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា | ១៣ កក្កដា ១៩៩៩ [៥៥] |
| សហជីពអ្នកសារព័ត៌មានឯករាជ្យ | ១១ កញ្ញា ២០០០ |
| ក្លឹបអ្នកសារព័ត៌មានកម្ពុជា | ១១ កញ្ញា ២០០០ |
| សមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មាន | ៦ តុលា ២០០០ |
| សមាគមអ្នកសារព័ត៌មានកម្ពុជា | ២១ មិថុនា ២០០២ |
| វេទិកាប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាស្តីពីបរិស្ថាន | ២៦ មិថុនា ២០០២ |
| សមាគមអ្នកសារព័ត៌មានអាព្យាក្រិត្យ | ០២ កក្កដា ២០០៣ |
| អ្នកសារព័ត៌មានប្រជាធិតេយ្យខ្មែរ | ២៦ វិច្ឆិកា ២០០៣ |
| សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា | ២៦ វិច្ឆិកា ២០០៣ |
| សមាគមសារព័ត៌មានកម្ពុជា ដើម្បីសេរីភាព | ២៦ មេសា ២០០៥ |
| មិត្តភាពអ្នកសារព័ត៌មានខ្មែរ | ១៨ សីហា ២០០៥ |
| អង្គការសារព័ត៌មានឯករាជ្យ | ២៨ វិច្ឆិកា ២០០៥ |
| សមាគមអ្នកសារព័ត៌មានជាតិឯករាជ្យកម្ពុជា | ១៧ មិនា ២០០៦ |
| សមាគមអ្នកចែកចាយសារព័ត៌មាន | ១៦ សីហា ២០០៦ |

យោងតាមអ្នកសង្កេតការណ៍ សង្កេតឃើញមានមូលហេតុសំខាន់ៗពីរដែលបណ្តាលឱ្យមានក្រុមអ្នកសារព័ត៌មានផ្សេងៗគ្នាច្រើនដូច្នេះ។ ទីមួយ គឺការបែកជាក្រុមតាមគន្លងនយោបាយ។ មូលហេតុមួយ

[៥៥] ធាតុពិត ក្លឹបនេះត្រូវបានបង្កើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៩៥ នៅពេលដែលសមាជិកសមាគមអ្នកសារព័ត៌មានកម្ពុជាបែកចេញដើម្បីបង្កើតសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ដោយមានការគាំទ្រពីសំណាក់សម្តេចនាយករដ្ឋមន្ត្រី សូមអានត្រង់ចំណុច "សម្តេច នាយកចូលរួមជាមួយក្លឹបអ្នកសារព័ត៌មានថ្មី។ ភ្នំពេញប៉ុស្តិ៍ ១៤ -២៧ កក្កដា ១៩៩៥ ។

ទៀត គឺជាប្រពៃណីរបស់បណ្ណាធិការសារព័តិមានក្នុងការបង្កើតសមាគមអ្នកសារព័តិមានដើម្បីបង្កើនឥទ្ធិពលយកការណ៍របស់ខ្លួននៅក្នុងសហគមន៍។ យោងតាមសម្តីរបស់សមាជិក ក្រុមប្រឹក្សាភិបាលនៃក្លឹបអ្នកសារព័តិមានកម្ពុជាម្នាក់និយាយថា "នរណាក៏ចង់ក្លាយជាប្រធានធំដែរ"[៥៦] ។

ក្នុងចំណោមសមាគមទាំង ១៥ មានពីរលេចធ្លោ ។

**ក្លឹបអ្នកសារព័តិមានកម្ពុជា** (CCJ) បង្កើតឡើងក្នុងឆ្នាំ២០០០។ ក្លឹបនេះមានសមាជិកប្រហែល ១៣០ នាក់ ដែលសមាជិកទាំងនោះត្រូវមានបទពិសោធន៍ ២ ឆ្នាំ ហើយត្រូវបង់ប្រាក់ប្រចាំខែ ៥,០០០ រៀលដល់សមាគម។ សមាជិកទាំង ៩ នាក់ នៃក្រុមប្រឹក្សាភិបាលរួមមានបណ្ណាធិការ និងអ្នកយកព័តិមានដែលមានឥទ្ធិពលនៅក្នុងប្រព័ន្ធផ្សាយព័តិមានកម្ពុជា។ ក្លឹបនេះមានលោក ប៉ែន សមិទ្ធិ ជាប្រធានដែលជាបណ្ណាធិការនៃសារព័តិមានរស្មីកម្ពុជា។ ក្លឹបអ្នកសារព័តិមានកម្ពុជានេះឃ្លាំមើលការវាយប្រហារលើប្រព័ន្ធផ្សាយសារព័តិមាន *(លើរូបរាងកាយ និងប្រើប្រាស់ច្បាប់)* ក៏ប៉ុន្តែមិនសូវនិយាយផ្សាយជាសាធារណៈអំពីបញ្ហានេះទេ "ចូលចិត្តវិធីត្រជាក់"[៥៧] ។ ក្លឹបអ្នកសារព័តិមានកម្ពុជាក៏រៀបចំវេទិកា និងបញ្ជូនតំណាងទៅចូលរួមសន្និសីទប្រព័ន្ធផ្សាយព័តិមានបរទេសផងដែរ។ ថ្មីៗនេះក្លឹបនេះ បានប្រកាសអំពីការប្រកួតរង្វាន់សារព័តិមានស៊ើបអង្កេតដែលមានរង្វាន់ជាទឹកប្រាក់ដែលផ្តល់ដោយស្ថានទូតសហរដ្ឋអាមេរិក។

សមាគមកម្ពុជាដើម្បីការពារអ្នកសារព័តិមាន (CAPJ) ដឹកនាំដោយ លោក អ៊ុំ សារិន អ្នកយកព័តិមានវិទ្យុអាស៊ីសេរី ហើយអះអាងថា មានសមាជិកជាង ២០០ នាក់។ សមាគមនេះមានសកម្មភាពច្រើនជាងក្លឹបអ្នកសារព័តិមានកម្ពុជា ក្នុងការចេញសេចក្តីថ្លែងការណ៍ថ្កោលទោស ការវាយប្រហារលើសារព័តិមានដែលត្រូវចែកចាយទូទាំងពិភពលោកដោយក្រុមដូចជា "សហព័ន្ធអ្នកសារព័តិមានអន្តរជាតិ" និង "សេរីភាពអន្តរជាតិនៃការផ្លាស់ប្តូរការបញ្ចេញមតិ" ។ ដោយសារធ្វើរបៀបនេះហើយ សមាគមកម្ពុជាដើម្បីការពារអ្នកសារព័តិមាន ផ្តល់នូវទំនាក់ទំនងរវាងមូលដ្ឋាននៃធាតុពិតដែលអ្នកសារព័តិមានកម្ពុជាកំពុងប្រឈមមុខ និងការតស៊ូមតិអន្តរជាតិ។

---

[៥៦] សម្ភាសន៍ជាមួយសមាជិកគណៈកម្មាធិការនាយកនៃក្លឹបអ្នកសារព័តិមានកម្ពុជា ថ្ងៃទី១៦ សីហា ២០០៧ ។

[៥៧] សម្ភាសន៍ជាមួយសមាជិកគណៈកម្មាធិការនាយកនៃ ក្លឹបអ្នកសារព័តិមានកម្ពុជា ថ្ងៃទី១៦ សីហា ២០០៧។

នៅក្នុងខែកក្កដា ឆ្នាំ២០០៧ សមាគមប្រព័ន្ធផ្សាយព័ត៌មានចំនួន ១១ រួមគ្នាដើម្បីបង្កើតក្រុមប្រឹក្សាជាតិសារព័ត៌មាន[៥៨] រួមមានអ្នកដើរតួសំខាន់មួយគឺសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មានប៉ុន្តែមិនមែនជាក្លឹបអ្នកសារព័ត៌មានកម្ពុជាទេ។ សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្លឹបអ្នកសារព័ត៌មានកម្ពុជាបានចូលរួមពិភាក្សាពីដើមដំបូងដែរស្តីពីការបង្កើតក្រុមប្រឹក្សាជាតិសារព័ត៌មាន ប៉ុន្តែនៅទីបំផុតសម្រេចចិត្តមិនចូលរួមវិញ។

យោងតាមលោក អ៊ុំ សារិន ប្រធានក្រុមប្រឹក្សាជាតិសារព័ត៌មាន (និងជាប្រធានសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មាន) និយាយថាក្រុមប្រឹក្សាត្រូវបានបង្កើតឡើងដោយសារអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានាមានការភ័ន្តច្រឡំអំពីកិច្ចការ ថាតើពួកគេគួរទាក់ទងជាមួយអ្នកណាអំពីបញ្ហាប្រព័ន្ធផ្សាយព័ត៌មាននេះ។ លោក អ៊ុំ សារិន មានប្រសាសន៍ថាក្រុមប្រឹក្សាសារព័ត៌មាន "រួមគ្នាមួយ" អាចផ្តល់នូវ "សម្លេងខ្លាំង" ទាំងក្នុង និងក្រៅកម្ពុជា។ លោកបន្តថាក្រុមប្រឹក្សាជាតិសារព័ត៌មាននឹងព្យាយាមធ្វើការសម្របសម្រួលរវាងសមាជិករបស់ខ្លួនដើម្បីពិភាក្សាអំពីបញ្ហាដូចជា សេរីភាពសារព័ត៌មាន ក្រមសីលធម៌ និងប្រកាសឱ្យគេដឹងឮនៅពេលដែលមានការគំរាមកំហែង ឬការវាយប្រហារកើតឡើង[៥៩]។

អ្វីដែលកើតឡើង ដែលជាលទ្ធផលនៃការបញ្ចូលចូលគ្នានេះមិនទាន់ដឹងនៅឡើយទេ។ សមាជិកក្រុមប្រឹក្សាភិបាលនៃក្លឹបអ្នកសារព័ត៌មានខ្មែរម្នាក់អះអាងថា ខណៈដែលក្លឹបអ្នកសារព័ត៌មានអាចចុះបញ្ជីនៅក្រសួងព័ត៌មាន ក្រុមប្រឹក្សាជាតិសារព័ត៌មានត្រូវសុំការយល់ព្រមពីក្រសួងមហាផ្ទៃ ឬនាយករដ្ឋមន្ត្រី។ នីតិវិធីសុំច្បាប់អាស្រ័យលើៈ ថាតើក្រុមប្រឹក្សាជាតិសារព័ត៌មាននេះគេត្រូវទុកជាក្លឹបរបស់ប្រព័ន្ធផ្សាយព័ត៌មាន ឬក៏ជាអង្គការមិនមែនរដ្ឋាភិបាល។

ប៉ុន្តែនៅក្នុងសញ្ញាមួយដែលរដ្ឋាភិបាលអាចពេញចិត្តរដ្ឋមន្ត្រីក្រសួងព័ត៌មានថ្មីៗនេះបានផ្តល់យោបល់ឱ្យប្រធានក្លឹបអ្នកសារព័ត៌មានខ្មែរ លោក ប៉ែន សមិទ្ធិ ធ្វើជាតំណាងកម្ពុជានៃ "សម្ព័ន្ធភាពសារព័ត៌មាន

[៥៨] យោងតាមសេចក្តីថ្លែងការណ៍ គ្មានកាលបរិច្ឆេទមួយ អ្នកគាំទ្ររបស់ខ្លួនមាន ៖ សមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មានខ្មែរមិត្តភាព អ្នកសារព័ត៌មានខ្មែរ វេទិកាសារព័ត៌មានកម្ពុជាស្តីពីបរិស្ថាន អ្នកសារព័ត៌មានប្រជាធិតេយ្យខ្មែរ អ្នកសារព័ត៌មានជាតិកម្ពុជា ដើម្បីសេរីភាព (ឈីវ៉ាន់ សាលីដេត ) អ្នកសារព័ត៌មានជាតិកម្ពុជាដើម្បីសេរីភាព (ប៉ាន វុធថា) សហជីពអ្នកសារព័ត៌មានឯករាជ្យ សមាគមអ្នកសារព័ត៌មានជាតិឯករាជកម្ពុជា សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា សមាគមអ្នកសារព័ត៌មានដើម្បីសេរីភាព អង្គការក្រុមប្រឹក្សាសារព័ត៌មានកម្ពុជា ។ គួរកត់សំគាល់ថាក្លឹប២ ក្នុងចំណោមក្លឹបទាំងនេះ ទាំងពីរជាបក្សពួករបស់អ្នកសារព័ត៌មានជាតិកម្ពុជាដើម្បីសេរីភាព ពុំមានចុះបញ្ជីនៅក្រសួងព័ត៌មានទេ ប៉ុន្តែ មេដឹកនាំរបស់ក្លឹបនោះមានឈ្មោះនៅក្នុងបញ្ជីក្រសួង ថាបានចាប់ផ្តើមបើកក្លឹបផ្សេងទៀត។

[៥៩] សម្ភាសន៍ជាមួយ អ៊ុំ សារិន ថ្ងៃទី ២៧ សីហា ២០០៧ ។

អាស៊ីអាគ្នេយ៍" ដែលជាអង្គការឃ្លាំមើលសេរីភាពសារព័តិមានឯករាជ្យមួយ[៦០] ។ បែបនេះបង្ហាញថា រដ្ឋាភិបាលនឹងគាំទ្រក្លឹបអ្នកសារព័តិមានកម្ពុជាឱ្យទៅជា "សម្លេង" របស់ប្រព័ន្ធផ្សាយព័តិមានកម្ពុជា ជាង ក្រុមប្រឹក្សាជាតិសារព័តិមាន ។

## *សមាគមប្រព័ន្ធផ្សាយព័ត៌មានអន្តរជាតិ*

ដូចគ្នានឹងក្លឹបសារព័តិមានក្នុងស្រុកដែរ មានអង្គការប្រព័ន្ធផ្សាយព័តិមានអន្តរជាតិមួយចំនួនដែល ធ្វើការលើបញ្ហានានានៃប្រព័ន្ធផ្សាយព័តិមានកម្ពុជារួមមានៈ

**អ្នកយកព័តិមានគ្មានព្រំដែន**ប្រហែលជាមានការទទួលស្គាល់ថាជាអង្គការនៃសេរីភាពសារព័តិមាន ដែលគេទទួលស្គាល់ជាងគេបង្អស់នៅលើពិភពលោក។ មានមូលដ្ឋាននៅប្រទេសបារាំងនិងមានការិយាល័យ មួយនៅទីក្រុងបាងកក។ អង្គការនេះផ្សាយចេញសេចក្តីថ្លែងការណ៍អំពីបញ្ហាជាក់លាក់មួយចំនួនពាក់ព័ន្ធ នឹងការវាយប្រហារ គំរាមកំហែង ឬបញ្ហាសេរីភាពសារព័តិមាន។ អង្គការនេះធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីសេរីភាពសារព័តិមានលើពិភពលោក រួមទាំងកម្ពុជា សន្ទស្សន៍សេរីភាពសារព័តិមានពិភពលោក និង បញ្ជីសេរីភាពសារព័តិមាននៃមនុស្សប្រព្រឹត្តអំពើខុសឆ្គង។

**គណៈកម្មការដើម្បីការពារអ្នកសារព័តិមាន** មានមូលដ្ឋាននៅទីក្រុង ញូយ៉ក ចេញផ្សាយនូវសេចក្តី ប្រកាសចំពោះការវាយប្រហារលើអ្នកសារព័តិមានព្រមទាំងលក្ខណៈពិសេស១ និងរាយការណ៍អំពីបញ្ហា សេរីភាពនៃសារព័តិមាន។ ទីប្រឹក្សាកម្មវិធីដែលមានមូលដ្ឋាននៅទីក្រុងបាងកករបស់ "គណៈកម្មការដើម្បី ការពារអ្នកសារព័តិមាន" នេះ រាយការណ៍អំពីការលំបាកក្នុងការទទួលព័តិមានត្រឹមត្រូវពីក្រុមសារព័តិមាន ក្នុងស្រុកនៅកម្ពុជា។ គណៈកម្មការដើម្បីការពារអ្នកសារព័តិមាននេះ មានកម្មវិធីដែលអាចជួយអ្នកយក ព័តិមានណាដែលភាសន៍ខ្លួនដោយសារតែការគំរាមកំហែង ឬត្រូវការជំនួយផ្នែកពេទ្យ ក្រោយពីមានការ វាយប្រហារលើរាងកាយ។

[៦០] ចំណុចនេះមិនច្បាស់ទេ ហេតុអ្វីបានជារដ្ឋមន្ត្រីនិយាយថា ឱ្យអ្នកណាតំណាងអ្នកសារព័តិមាននៅក្នុងអង្គការ ដែលមានចក្ខុវិស័យ "ដើម្បីឱ្យតំបន់ អាស៊ីអាគ្នេយ៍ជាតំបន់មានសេរីភាពក្នុងការបញ្ចេញមតិ និងឯករាជ្យ និងសារព័តិមានទទួលខុសត្រូវក្នុងការផ្សព្វផ្សាយព័តិមាន និងផ្តល់ចំណេះ ដឹងដល់សង្គមប្រកបដោយតម្លាភាព និងពហុនិយមជាបទដ្ឋាន។

**សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ** គឺជាអង្គការអ្នកសារព័ត៌មានធំជាងគេបំផុតលើពិភពលោក ដែលមានសមាជិកប្រហែល ៥០០.០០០នាក់ នៅក្នុងប្រទេសជាង ១០០។ សហព័ន្ធនេះចេញផ្សាយនូវសេចក្តីប្រកាសព័ត៌មានអំពីការវាយប្រហារលើអ្នកសារព័ត៌មាន និងបញ្ហាផ្សេងៗទៀតនៃប្រព័ន្ធផ្សាយព័ត៌មាន។ សមាគមអ្នកសារព័ត៌មានកម្ពុជាមួយ គឺសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មានជាសមាជិករបស់សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ។

**សម្ព័ន្ធភាពសារព័ត៌មានអាស៊ីអាគ្នេយ៍** ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៨ គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើយុទ្ធនាការអំពីសេរីភាពសារព័ត៌មាននៅក្នុងតំបន់។ សម្ព័ន្ធភាពនេះចេញផ្សាយនូវសេចក្តីប្រកាសនិងវិចារណកថាអំពីការវាយប្រហារលើប្រព័ន្ធផ្សាយព័ត៌មាននិងបញ្ហាសេរីភាពសារព័ត៌មាន

**សេរីភាពអន្តរជាតិក្នុងផ្លាស់ប្តូរការបញ្ចេញមតិ** គឺជាគ្រឹះស្ថានត្រួសត្រាយសម្រាប់ប្រកាស និងចែកចាយព័ត៌មានអំពីការវាយប្រហារលើអ្នកសារព័ត៌មាន ឬសេរីភាពនៃការបញ្ចេញមតិ។ សេចក្តីប្រកាសនេះ ច្រើនតែមានដាក់បញ្ចូលនូវការអំពាវនាវឱ្យមានការសរសេរលិខិតផ្ញើទៅរដ្ឋាភិបាលផងដែរ។

អង្គការនេះបោះពុម្ពផ្សាយនូវសេចក្តីថ្លែងការណ៍ និងប្រកាសដែលចេញដោយអ្នកសារព័ត៌មានគ្មានព្រំដែន និងសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មានព្រមទាំងចេញដោយអង្គការសិទ្ធិមនុស្សនានា និងក្រុមអ្នកសារព័ត៌មានធ្វើឱ្យវាក្លាយទៅជាកន្លែងមួយដ៏ល្អដើម្បីមើលរូបភាពពិត នៃបញ្ហាសេរីភាពសារព័ត៌មាននៅកម្ពុជា។

**អន្តរសារព័ត៌មាន** គឺជាអង្គការហ្វឹកហ្វឺនជាបឋមមានគោលបំណងដើម្បីកែលំអការទទួលបានព័ត៌មាន និងលើកកម្ពស់ប្រព័ន្ធផ្សាយព័ត៌មានឯករាជ្យ។ នៅកម្ពុជាអន្តរសារព័ត៌មានបានរៀបចំវគ្គហ្វឹកហ្វឺនអំពីសារព័ត៌មានស៊ើបអង្កេតសាលាក្តីខ្មែរក្រហម និងជម្ងឺអេដស៍។

## អំពើពុករលួយ

អំពើពុករលួយរាលដាលពាសពេញក្នុងចំណោមសារព័ត៌មានកម្ពុជា មានតាំងពីការបង់ប្រាក់ម្តងចំណាយរាប់រយដុល្លា រហូតដល់ការអនុវត្តជាទូទៅដោយចំណាយថវិកាបន្តិចបន្តួចឱ្យអ្នកសារព័ត៌មាន ដើម្បីចូលរួមក្នុងសន្និសីទសារព័ត៌មាន។

ធាតុពិតនៃអំពើពុករលួយ គឺជាការពិបាកណាស់ក្នុងការរាប់បរិមាណឱ្យបានសុក្រិត្យត្រឹមត្រូវ។ ប៉ុន្តែនៅក្នុងការសិក្សាស្រាវជ្រាវមួយក្នុងចំណោមអ្នកសារព័ត៌មានខ្មែរ១៤១នាក់ ដែលធ្វើឡើងសម្រាប់សរសេររបាយការណ៍នេះ ២៥%នៃអ្នកឆ្លើយសម្ភាសន៏បាននិយាយថាពួកគេបានស្គាល់អ្នកសារព័ត៌មានដែលទទួលសំណូកជាការប្តូរនឹងការសរសេរសេចក្តីរាយការណ៍គាប់ចិត្តគេ ហើយ៣៥%ទៀតមិនចង់ឆ្លើយសំណួរនេះទេ[៦១]។ រហូតដល់មានអ្នកឆ្លើយសំណួរខ្លះទៀត ៣៤% និយាយថាគេធ្លាប់បានស្គាល់សហការីរបស់គេទទួលសំណូកដើម្បីមិនសរសេរសេចក្តីរាយការណ៍ទៀតផង។

តាមពិតទៅ នៅពេលដែលអ្នកសារព័ត៌មានត្រូវបានសួរថាតើអ្នកធ្លាប់ទទួលសំណូកដែរឬទេ? មានតែ ១៣% ប៉ុណ្ណោះដែលសារភាពថាធ្លាប់ទទួលសំណូក។ ប៉ុន្តែនៅពេលដែលសួរថា តើអ្នកធ្លាប់ទទួលប្រាក់ឬក៏អំណោយដើម្បីចូលរួមសន្និសីទសារព័ត៌មានឬទេ ? មួយភាគបីនៃអ្នកសារព័ត៌មានដែលបានសម្ភាសន៏បានទទួលស្គាល់ថា ធ្លាប់បានទទួល ហើយ១៣%ទៀត មិនចង់និយាយអំពីបញ្ហានេះទេ។

នេះគឺជាបាតុភូតគួរឱ្យបារម្ភក្នុងប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា។ ជាទូទៅអ្នកសារព័ត៌មានមិនចាត់ទុកថាជាអំពើពុករលួយទេ ដូចជាការទទួលស្រោមសំបុត្រ ដែលមានប្រាក់កាសពីអ្នកនយោបាយ ពាណិជ្ជករ ឬសូម្បីតែអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងសន្និសីទសារព័ត៌មាន។ ក្នុងពេលសម្ភាសន៏ អ្នកសារព័ត៌មានមួយចំនួនបានការពារនូវការអនុវត្តនឹបែបនេះ ដោយនិយាយថាគេទទួលប្រាក់កាស ដើម្បីបន្ថែមទៅលើប្រាក់បៀវត្សទាបរបស់ពួកគេ ហើយថែមទាំងអះអាងថាវាពុំមានឥទ្ធិពលលើការសរសេរអត្ថបទរបស់ពួកគេឡើយ។

---

[៦១] សំណួរសួរអ្នកសារព័ត៌មានថា : តើអ្នកធ្លាប់ស្គាល់អ្នកសារព័ត៌មានណាដែលទទួលប្រាក់កាស ឬ អំណោយជាការប្តូរនឹងសេចក្តីរាយការណ៏ដែលគាប់ចិត្តគេដែរឬទេ ? ហើយចម្លើយត្រូវបានផ្តល់នូវជម្រើស បាទ ទេ ឬ មិនចង់ឆ្លើយ។ ២៥% ឆ្លើយ បាទ - ២៧% ឆ្លើយថា ទេ-៣៥% ជ្រើសចម្លើយ មិនចង់ឆ្លើយ នៅសល់ ១៣% មិនឆ្លើយសំណួរសោះ។ សូមអានឧបសម្ព័ន្ធសារព័តមាន សំណួរ ៣១ និង សំណួរ ៣២ -៣៤ ។

អ្នកគ្រប់គ្រងជាន់ខ្ពស់នៃស្ថានីយ៍វិទ្យុមួយបាននិយាយថា "នៅពេលដែលយើងទទួលស្រោមសំបុត្រ យើងមិនលំអៀងទេ" ប៉ុន្តែ "សម្លេងរបស់អ្នកឱ្យស្រោមសំបុត្រគឺវែងជាងបន្តិច" ។

"ស្រោមសំបុត្រ" ដែលឃើញមាននៅគ្រប់ទីកន្លែងដែលត្រូវបានប្រើដោយអ្នកសារព័ត៌មានជំនួសឱ្យពាក្យ "សំណូក" វាជាការកើតឡើងរាល់ថ្ងៃ។ នៅក្នុងសភាពការណ៍នេះ ជាពិសេសក្នុងពេលដែលមានការអញ្ជើញឱ្យចូលរួមក្នុងសន្និសីទសារព័ត៌មាន ហើយពួកអ្នកសារព័ត៌មានដែលបានមកចូលរួមសរសេរឈ្មោះរបស់ពួកគេនិងអង្គការរបស់ខ្លួននៅក្នុងសៀវភៅកត់ត្រាមួយដែលវាជារឿងធម្មតាណាស់ទៅហើយ ។ ប៉ុន្តែ សៀវភៅនេះក្រោយមកគឺត្រូវបានប្រើដើម្បីបែងចែកការចំណាយជាធម្មតាប្រហែលពី ១.២៥ ទៅ ៥ ដុល្លា ចំពោះព្រឹត្តិការណ៍តូចតាច ហើយពី១០ ទៅ ២០ ដុល្លា ចំពោះព្រឹត្តិការណ៍ធំជាង។ អ្នកសារព័ត៌មានទូរទស្សន៍ម្នាក់បានអួតអំពីការទទួលបាន៥០ ដុល្លា ជាប្រចាំពីគណបក្សកាន់អំណាចនៅពេលដែលចូលរួមព្រឹត្តិការណ៍អ្វីមួយនៅតាមខេត្ត ដោយពន្យល់ថា ារធ្វើដំណើរក៏ត្រូវតែគេចំណាយឱ្យដែរ[៦២] ។

វាជារឿងខុសឆ្គងដែលអង្គការមួយចំនួនចំណាយប្រាក់កាស ឱ្យប្រព័ន្ធផ្សាយព័ត៌មានដើម្បីឱ្យគេចូលរួមក្នុងព្រឹត្តិការណ៍ណាមួយ។ ការធ្វើបែបនេះ ជាការជម្រុញ និងពង្រឹងបញ្ហាសំខាន់ក្នុងបញ្ហានានានៃប្រព័ន្ធផ្សាយព័ត៌មាន-អ្នកសារព័ត៌មានរកចំណូល ឬសង្ឃឹមថានឹងបានទទួលប្រាក់កាសដើម្បីចុះផ្សាយ (ឬមិនចុះផ្សាយ) អត្ថបទមួយ។ មិនមានភាពខុសគ្នាច្រើនពេកទេ រវាងអង្គការមិនមែនរដ្ឋាភិបាលចំណាយប្រាក់កាសឱ្យអ្នកសារព័ត៌មានដើម្បីចូលរួម និងរាយការណ៍ពីសន្និសីទសារព័ត៌មាន និងអ្នកនយោបាយចំណាយប្រាក់កាសដើម្បីឱ្យអ្នកសារព័ត៌មានសរសេរវិចារណកថាសរសើរអំពីអ្នកនយោបាយនោះ ។

អ្នកនយោបាយជាន់ខ្ពស់ និងពាណិជ្ជករដែលមានមុខមាត់ ដែលផ្ដល់ការសម្ភាសន៍មួយទល់មួយដល់អ្នកសារព័ត៌មានអាចផ្ដល់លុយឱ្យពួកគេរហូតដល់រាប់រយដុល្លា។ អ្នកសារព័ត៌មាន ២ នាក់ បានពិពណ៌នាអំពីការធ្វើបែបនេះថាជាទម្រង់នៃ "ការគំរាមកំហែងដោយសន្តិវិធី" ដើម្បីធ្វើឱ្យមានសេចក្ដីរាយការណ៍វិជ្ជមាន ឬធ្វើឱ្យអ្នកសារព័ត៌មានស្ងៀមស្ងាត់អំពីបញ្ហាស្មុកស្មាញមួយចំនួន[៦៣] ។

---

[៦២] សម្ភាសន៍ជាមួយអ្នកសារព័ត៌មាន ទូរទស្សន៍ម្នាក់ នៅថ្ងៃទី ២៨ សីហា ២០០៧ ។

[៦៣] ការសម្ភាសន៍ដោយឡែកមួយជាមួយអ្នកសារព័ត៌មាននៅថ្ងៃទី ២៣ និង ២៧ សីហា ២០០៧ ។

ដូចដែលបានពិភាក្សារួចពីខាងលើ នៅក្នុងផ្នែកសារព័ត៌មាន "សារព័ត៌មានជូនពរ" និង "សារព័ត៌មានដែលរាំងខ្ទប់ព័ត៌មានមិនឱ្យចេញផ្សាយ" នោះគឺជារឿងពីរដែលបង្កើតឡើងដើម្បីរកផលចំណេញពីការបោះពុម្ពផ្សាយ ។

សំខាន់ជាងនេះទៅទៀត ហេតុផលមួយដែលអ្នកសារព័ត៌មានមួយចំនួនជាពិសេសអ្នកសារព័ត៌មានណា ដែលមិនមានកិច្ចសន្យាការងារជាមួយស្ថានប័នជាក់លាក់ណាមួយ (freelancers) គឺឆាប់រក និងទទួលសំណូកនោះ គឺដោយសារតែពួកអ្នកទាំងនោះក៏ត្រូវបង់ប្រាក់កាសឱ្យទៅបណ្ណាធិការដើម្បីចុះផ្សាយអត្ថបទរបស់ពួកអ្នកទាំងនោះដែរ ។ ជាធម្មតា គឺអ្នកសារព័ត៌មានដែលពុំមែនជាបុគ្គលិកអាចបង់ឱ្យបណ្ណាធិការម្នាក់ចន្លោះពី ២០ ទៅ ៦០ ដុល្លា ដើម្បីចុះផ្សាយអត្ថបទ ហើយអត្ថបទនោះអាចធ្វើឱ្យមានចំណូលបានច្រើនជាងនេះទៅទៀត[៦៤] ។

បណ្ណាធិការជាន់ខ្ពស់ម្នាក់បាននិយាយថា "ប្រសិនបើមិនបង់ប្រាក់កាសឱ្យបណ្ណាធិការ នោះអត្ថបទនឹងមិនត្រូវបានចុះផ្សាយទេ"[៦៥] ។

អ្នកសារព័ត៌មានភាគច្រើន ដែលបានសម្ភាសន៍បានភ្ជាប់អំពើពុករលួយទៅនឹងប្រាក់បៀវត្សរ៍ទាបនៅក្នុងវិស័យប្រព័ន្ធផ្សាយព័ត៌មាន។ ប្រាក់បៀវត្សរ៍មធ្យមរបស់អ្នកសារព័ត៌មានគឺចន្លោះពី៥០ ដុល្លា និង ២០០ ដុល្លា ក្នុងមួយខែ ហើយ៨៧%នៃអ្នកសារព័ត៌មានដែលបានសម្ភាសន៍ និយាយថាប្រាក់បៀវត្សរ៍របស់ពួកគេ គឺមិនគ្រប់គ្រាន់ដើម្បីឧបត្ថម្ភខ្លួន និងគ្រួសាររបស់គេទេ[៦៦] ។ ហេតុនេះហើយ អ្នកទាំងអស់នោះបានអះអាងថាអ្នកសារព័ត៌មានត្រូវបង្ខំចិត្តទទួលសំណូក ។

ជាការពិតណាស់ ដោយសារប្រាក់បៀវត្សរ៍ទាបនេះជាកត្តាមួយក្នុងការប្រព្រឹត្តិអំពើពុករលួយ ក៏ប៉ុន្តែ បញ្ហានេះគឺជាវិធីដោះសារទេ។ សូម្បីតែអ្នកសារព័ត៌មានខ្លះដែលមានប្រាក់បៀវត្សរ៍ខ្ពស់ជាងនេះក៏នៅតែទទួលសំណូកដែរ ។

---

[៦៤] អ្នកសារព័ត៌មាននៅថ្ងៃទី ២៧ សីហា ២០០៧ ។

[៦៥] សម្ភាសន៍បណ្ណាធិការជាន់ខ្ពស់ម្នាក់នៅថ្ងៃទី ១២ កញ្ញា ២០០៧ ។

[៦៦] សូមអានការសិក្សាសារព័ត៌មាននៅ ឧបសម្ព័ន្ធ សំណួរ ១០ ចំពោះប្រាក់បៀវត្សរ៍ និងសំណួរ ១១ ចំពោះ ការគ្រប់គ្រាន់ ឬ មិនគ្រប់គ្រាន់សម្រាប់តម្រូវការ ។

អំពើពុករលួយដែលរាលដាលទូទៅនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាន បានធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងអំពីបញ្ហាថាតើអ្នកសារព័ត៌មានអាចដើរតួជាអ្នកឃ្លាំមើលក្នុងការបើកកកាយអំពើពុករលួយ និងការរំលោភផ្សេងៗប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល ឬបុគ្គលមានអំណាចដែរ ឬអត់? ករណីដ៏សំខាន់មួយក្នុងចំណុចនេះគឺការប្រកួតប្រជែងថ្មីៗដែលផ្តល់មូលនិធិដោយស្ថានទូតអាមេរិក ហើយចាត់ចែងដោយក្លឹបអ្នកសារព័ត៌មានកម្ពុជាដើម្បីផ្តល់រង្វាន់ដល់អត្ថបទណាដែលលាតត្រដាងអំពើពុករលួយនៅក្នុងសង្គម ។

អំពើពុករលួយនៅក្នុងប្រព័ន្ធផ្សាយព័ត៌មានបានឆ្លុះបញ្ចាំងនូវធាតុពិត នៃសង្គមកម្ពុជាមួយយ៉ាងធំក៏ប៉ុន្តែចំណុចនេះ វាជាបញ្ហាមួយចំពោះវិស័យប្រព័ន្ធផ្សាយព័ត៌មានដែលយើងរំពឹងថាផ្អែកលើ សុក្រិត្យភាពយុត្តិធម៌ និងឯករាជ្យ ។ នៅពេលដែលមូលដ្ឋានគ្រឹះនៃក្រមសីលធម៌សារព័ត៌មាន អាចត្រូវគេទិញបានក្នុងតម្លៃថោកៗ តួនាទីដ៏សំខាន់របស់ប្រព័ន្ធផ្សាយព័ត៌មាននៅក្នុងសង្គម គឺប្រាកដជាមានការស្មុកស្មាញ ។

**ករណីសិក្សា : ការកំណត់ថវិកាដើម្បីសូក**

*វាជារឿងធម្មតាទៅហើយចំពោះអ្នកសារព័ត៌មាន ដែលទទួលស្រោមសំបុត្រប្រាក់កាសជាថ្នូរនឹងការចូលរួមសន្និសីទសារព័ត៌មាន និងព្រឹត្តិការណ៍ណាមួយ ។*

*ប៉ុន្តែ សួរថាតើថវិកាទាំងនេះបានមកពីណា?*

*នៅពេលក្រសួងណាមួយជាប់ពាក់ព័ន្ធ នោះថវិកា គឺបានមកពីនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនោះ ដូចមានបង្ហាញដោយឯកសារគណនេយ្យដែលផ្តល់ដោយអ្នកសារព័ត៌មានម្នាក់ក្នុងល័ក្ខខ័ណសុំមិនបញ្ចេញឈ្មោះក្រសួង ។*

*នេះគឺជាឯកសារដែលធ្លាយចេញមកខាងក្រៅយើងបានឃើញការចំណាយសម្រាប់ព្រឹត្តិការណ៍មួយផ្សព្វផ្សាយអនុក្រិត្យថ្មី (សេចក្តីណែនាំអំពីរបៀបអនុវត្តច្បាប់) ។ ជាមួយនឹងការចំណាយធម្មតាឯកសារបង្ហាញថា អ្នកសារព័ត៌មាន ១៥ នាក់ដែលម្នាក់ៗទទួលបាន ១០ ដុល្លាចំពោះការចូលរួម ។ ក្រោយមកទៀត នៅក្នុងបន្ទាត់ថវិកា ១២០ ដុល្លាទៀតត្រូវបានចំណាយសម្រាប់អ្នកសារព័ត៌មាន ១២ នាក់ ។*

*ការចំណាយសរុប ២៧០ ដុល្លា ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារមួយផ្សេងទៀតដែលកត់ត្រាសំណូកថាជា "ការចំណាយ និងឧបត្ថម្ភដល់អ្នកសារព័ត៌មាន" ។*

# ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា និងច្បាប់

តាមទ្រឹស្តី អ្នកសារព័ត៌មានកម្ពុជាត្រូវបានការពារដោយបទបញ្ញត្តិច្បាប់នៅ៣ថ្នាក់ គឺកតិ្តកាសញ្ញាអន្តរជាតិ រដ្ឋធម្មនុញ្ញជាតិ និងច្បាប់ជាតិ។ ប៉ុន្តែ ធាតុពិតហាក់ដូចជាកិច្ចការពារផ្នែកច្បាប់ដ៏រឹងមាំដល់អ្នកសារព័ត៌មានត្រូវបានកាត់បន្ថយដោយតុលាការ និងនគរបាលកម្ពុជាដ៏ល្បីល្បាញ ខាងពុករលួយ និងលំអៀងដែលជារឿយៗគាំទ្រផលប្រយោជន៍របស់អ្នកមានអំណាច ហើយពុំបានលើកកម្ពស់ច្បាប់ឱ្យមានយុត្តិធម៌ និងឯករាជ្យទេ។

## *កតិ្តកាសញ្ញាអន្តរជាតិ*

**សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស** (១៩៤៨) កំណត់សម្លេងឱ្យនីតិកម្មសិទ្ធិមនុស្សអន្តរជាតិ។ មាត្រា ១៩ សេចក្តីប្រកាសចែងថា :

> មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសំដែងមតិ។ សិទ្ធិនោះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទឹកដី ទោះតាមរយៈមធ្យោបាយប្រព័ន្ធផ្សាយព័ត៌មានណាមួយក៏ដោយ។

**កតិ្តកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**[៦៧] (១៩៦៦) បានចែងលំអិតអំពីសិទ្ធិនេះ។ មាត្រា ១៩ នៃកតិ្តកាសញ្ញានេះបានចែងថា:

១. មនុស្សគ្រប់រូបមានសិទ្ធិក្នុងការប្រកាន់យកមតិយោបល់ដោយពុំមានការជ្រៀតជ្រែកឡើយ។

២. មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែនដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬ ក៏តាមមធ្យោបាយប្រព័ន្ធផ្សាយព័ត៌មានដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។

[៦៧] កម្ពុជា បានចុះហត្ថលេខាកតិ្តកាសញ្ញានេះនៅឆ្នាំ ១៩៨០ ហើយបានផ្តល់សច្ចាប័ននៅឆ្នាំ ១៩៩២។

## *រដ្ឋធម្មនុញ្ញជាតិ*

កាតព្វកិច្ចអន្តរជាតិនេះ ត្រូវបានទទួលស្គាល់ដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា :

"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិ្តកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" ។

ជាក់លាក់ជាងនេះទៀត គឺមាត្រា ៤១ ចែងថា:
"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ " ។

"របបសារព័ត៌មានត្រូវរៀបចំដោយច្បាប់ " ។

## *ច្បាប់ជាតិ*

មានច្បាប់ជាតិមួយចំនួន ដែលជាធម្មតាប៉ះពាល់ដល់ប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា ។

**ច្បាប់សារព័ត៌មាន** ឆ្នាំ១៩៩៥ ជាច្បាប់រដ្ឋប្បវេណីបានកំហិតដល់ការបោះពុម្ពផ្សាយ[៦៨] ។ ច្បាប់នេះមានកិច្ចការពារខ្លាំងៗដល់អ្នកសារព័តមាន ដូចជាការហាមប្រាមមិនឱ្យមានការត្រួតពិនិត្យមុនការផ្សាយ និងសិទ្ធិក្នុងការមិនផ្តល់ប្រភពព័ត៌មានដែលសំងាត់ជាដើម ។

ក៏ប៉ុន្តែ ច្បាប់សារព័ត៌មានក៏មានមាត្រា ដែលមានពាក្យពេចន៍មិនច្បាស់លាស់ដែលគេអាចយកមកប្រើប្រាស់ដើម្បីព្យាបាទអ្នកសារព័ត៌មាន[៦៩] ដូចជា:

"សារព័ត៌មានមិនត្រូវផ្សាយ ឬ ផលិតព័ត៌មានណា ដែលអាចនាំឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ" ។ (មាត្រា ១២)

---

[៦៨] ពុំមានច្បាប់ណាមួយជាក់លាក់ដែលគ្របដណ្តប់លើសារព័ត៌មានផ្សាយសម្លេង ឬ ការផ្សាយអ៊ីនធឺណេតទេ ។

[៦៩] សេចក្តីព្រាងដើមនៃច្បាប់សារព័ត៌មាន គឺមានលក្ខណៈហាមប្រាមខ្លាំងណាស់ ប៉ុន្តែក្រោយមកត្រូវបានបន្ធូរមកវិញដោយសារមានការរិះគន់ខ្លាំងៗពេកដោយសារព័ត៌មាន និងក្រុមសិទ្ធិមនុស្សនានា ។

ចំពោះការរំលោភមាត្រានេះ ការបោះពុម្ពផ្សាយអាចប្រឈមមុខនឹងការផាកពិន័យ (រហូតដល់ ៣,៧៥០ ដុល្លា) ព្រមទាំងត្រូវអាជ្ញាធររឹបអូសសារព័ត៌មានដែលសរសេរល្មើស និងត្រូវផ្អាកអាជ្ញាប័ណ្ណរហូតដល់ ១ ខែ។ ប៉ុន្តែ ជាសំខាន់ "សន្តិសុខជាតិ" និង "ស្ថិរភាពនយោបាយ" មិនត្រូវបានកំណត់និយមន័យឱ្យបានច្បាស់នៅក្នុងច្បាប់ទេ។ តួនាទីមួយផ្នែកទៀតរបស់ប្រព័ន្ធផ្សាយសារព័ត៌មាននៅក្នុងរបបលទ្ធិប្រជាធិបតេយ្យរឹងមាំពិតប្រាកដ គឺត្រូវសួរ និងស៊ើបអង្កេត និងរិះគន់ស្ថាប័នជាតិ អ្នកដឹកនាំ និងគោលនយោបាយជាតិ ហើយមិនអាចនិយាយថាជាការប៉ះពាល់ដល់ស្ថិរភាពនយោបាយ និងសន្តិសុខជាតិបានទេ។

លើសពីនេះទៅទៀត ច្បាប់សារព័ត៌មាន បានហាមប្រាមប្រព័ន្ធផ្សាយសារព័ត៌មានបោះពុម្ពពីការផ្សាយព័ត៌មានមិនពិតដែលអាចធ្វើឱ្យខូច "កិត្តិយស ឬ សេចក្តីថ្លៃថ្នូរ" (ដែលពុំមាននិយមន័យ) របស់នរណាម្នាក់ ហើយអនុញ្ញាតឱ្យតុលាការចេញបញ្ជាផាកពិន័យ និងទារសំណងជម្ងឺចិត្តពីជនល្មើស។

ប៉ុន្តែបញ្ហាចម្បងជាមួយនឹងច្បាប់សារព័ត៌មានគឺថា ជាធម្មតាច្បាប់នេះបានបំភ្លេចចោល ហើយបានយកបទបញ្ញត្តិផ្សេងៗនៅក្នុងច្បាប់ព្រហ្មទណ្ឌមកប្រើវិញ ដូចជាបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងបទញុះញង់ជាដើម។ ច្បាប់សារព័ត៌មានមិនសូវច្បាស់លាស់ទេ និងមានលក្ខណៈផ្ទុយគ្នា ថាតើពេលណាអាចចោទជាបទព្រហ្មទណ្ឌបាន ឬ ក៏មិនបាន? (ដូចមានចែងក្នុងមាត្រា ២០ របស់ច្បាប់នេះ) ថា: "អំពើណាដែលប្រព្រឹត្តដោយនិយោជក បណ្ណាធិការ ឬ អ្នកសារព័ត៌មានដែលរំលោភច្បាប់ព្រហ្មទណ្ឌនឹងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ពុំមាននរណាម្នាក់នឹងត្រូវចាប់ខ្លួន ឬ ត្រូវចោទប្រកាន់ជាបទព្រហ្មទណ្ឌដោយសារតែការបញ្ចេញយោបល់ទេ"។

ធាតុពិត គឺថាអ្នកសារព័ត៌មានជាច្រើនដែលបានបោះពុម្ពក្នុងឆ្នាំកន្លងមកបានប្រឈមមុខនឹងការចោទប្រកាន់ក្នុងបទព្រហ្មទណ្ឌចំពោះ "ការបញ្ចេញយោបល់"។ មន្ត្រីរដ្ឋាភិបាល និងបុគ្គលមានឥទ្ធិពលមួយចំនួនធ្លាប់បានប្តឹងអ្នកសារព័ត៌មាន និងម្ចាស់ប្រព័ន្ធផ្សាយព័ត៌មាននានាតាមមាត្រាព្រហ្មទណ្ឌ បរិហារកេរ្តិ៍ និងបង្ខូចកេរ្តិ៍ឈ្មោះ ដែលមានចែងនៅក្នុងមាត្រា ៦៣ នៃច្បាប់ក្រមព្រហ្មទណ្ឌអន្តរកាល[៧០]។

កាលពីខែឧសភា ឆ្នាំ២០០៦ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្ម ដើម្បីលុបចោលនូវទោសជាប់ពន្ធនាគារចំពោះបទបរិហារកេរ្តិ៍ និងបង្ខូចកេរ្តិ៍ឈ្មោះ ដោយទុកត្រឹមតែបទផាកពិន័យប៉ុណ្ណោះ។ ប៉ុន្តែវានៅ

---

[៧០] ច្បាប់នេះត្រូវបានសរសេរដោយអង្គការសហប្រជាជាតិ ក្នុងសម័យអ៊ុនតាក់ ។ វាគ្រាន់តែជាច្បាប់បណ្តោះអាសន្នតែប៉ុណ្ណោះ ប៉ុន្តែនៅជាធរមាននៅឡើយ។ ក្រមព្រហ្មទណ្ឌថ្មីត្រូវបានធ្វើសេចក្តីព្រៀងឡើងអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែមិនទាន់ទៅដល់រដ្ឋសភានៅឡើយទេ។

តែជាបទល្មើសព្រហ្មទណ្ឌដដែល។ លើសពីនេះទៀតនោះ អ្នកសារព័ត៌មានណាដែលត្រូវបានផ្តន្ទាទោសពីបទបរិហារកេរ្តិ៍អាចត្រូវជាប់ពន្ធនាគារ ប្រសិនបើគាត់មិនមានលទ្ធភាពបង់ការពិន័យដែលមានតម្លៃចន្លោះពី២៥០ ទៅដល់ ២៥០០ ដុល្លា។

ការចោទប្រកាន់មួយទៀតដែលជាធម្មតា មកលើអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាន (នៅតែអនុវត្តទោសជាប់ពន្ធនាគារដដែល) គឺការ ***ផ្សាយព័ត៌មានមិនពិត*** ដែលមានចែងនៅក្នុងមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌអន្តរកាល។ តាមបទបញ្ញត្តិនេះ អ្នកសារព័ត៌មាន បណ្ណាធិការ ឬ ម្ចាស់ប្រព័ន្ធផ្សាយព័ត៌មានអាចជាប់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ ចំពោះការចែកចាយព័ត៌មានដែល "មិនពិត ប្រឌិត ក្លែងក្លាយ ឬភ្ជាប់ព័ត៌មានមិនពិតទៅមនុស្សទីពណាម្នាក់ទៀត" និយាយថា គេបានធ្វើបែបនេះមែន "ដោយបំណងអាក្រក់ និងមានចេតនាព្យាបាទគេ" ហើយនាំឱ្យ "រំខាន ឬ ទំនងជាធ្វើឱ្យរំខានដល់សន្តិសុខសាធារណៈ"[៧១]។ លក្ខខណ្ឌក្រោយនេះ ប្រសិនបើការផ្សាយនេះអាចត្រូវរកឃើញថាមានចេតនាព្យាបាទ ហើយវាបានបណ្តាលឱ្យមានការគំរាមកំហែងពិតៗដល់ "សន្តិសុខសាធារណៈ" នោះនឹងអាចត្រូវផ្តន្ទាទោសក្នុងករិតធ្ងន់ប៉ុន្តែធាតុពិតវាផ្ទុយទៅវិញ។ អ្នកសារព័ត៌មានជាច្រើន និងអ្នកឯទៀតដូចជា មេដឹកនាំអង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តន្ទាទោសដោយគ្មានភស្តុតាងបន្តិចទាល់តែសោះដែលអំពើរបស់ពួកគេជាការព្យាបាទ ឬ គំរាមដល់សន្តិសុខសាធារណៈនោះ។

ក្រុមអង្គការសិទ្ធិមនុស្សនានាបានអះអាងថាច្បាប់ស្តីពីការផ្សាយព័ត៌មានមិនពិតជាការផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិ។ គេក៏បានកត់សម្គាល់ថែមទៀតថា "នៅក្នុងប្រទេសលទ្ធិប្រជាធិបតេយ្យដែលមានមូលដ្ឋានគ្រឹះរឹងមាំ បទបញ្ញត្តិច្បាប់ស្តីពីការ**ផ្សាយព័ត៌មានមិនពិត** ឬ **ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ** ពុំមានទេ"[៧២]។

មាត្រាផ្សេងទៀតនៃក្រមព្រហ្មទណ្ឌអន្តរកាល ដែលត្រូវបានប្រើមកលើអ្នកសារព័ត៌មានគឺ **បទញុះញង់** (មាត្រា ៥៩-៦០)។ ហើយនេះក៏ជាមាត្រាដែលប្រើពាក្យពេចន៍មិនច្បាស់មួយទៀតដែរនៅក្នុងច្បាប់នេះដែលជាការបើកផ្លូវឱ្យមានការរំលោភ។ ជាការគ្រោះថ្នាក់បំផុតនោះគឺអ្នកសារព័ត៌មាន ឬ អ្នកឯទៀតអាចត្រូវបានចោទពីបទញុះញង់ឱ្យមានការប្រព្រឹត្តបទល្មើស ***ទោះបីជាបទល្មើសនោះមិនកើតឡើងពិតមែនក៏ដោយ*** ។

---

[៧១] មាត្រា ៦២ ក្រមព្រហ្មទណ្ឌ សម័យអន្តរកាល ១៩៩២ ។

[៧២] សេចក្តីថ្លែងការណ៍របស់សម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា ១២ តុលា ២០០៦។

នៅពេលដែលមានការរិះគន់ទៅលើបទបញ្ញត្តិទាំងនេះ រដ្ឋាភិបាលច្រើនតែចង្អុលបង្ហាញភ្លាមថា នោះគឺអង្គការសហប្រជាជាតិ (ក្នុងសម័យអ៊ុនតាក់មកកម្ពុជា) ដែលជាអ្នកសរសេរច្បាប់នោះ។ ជាការឆ្លើយតប មន្ត្រីអង្គការសហប្រជាជាតិម្នាក់បានបញ្ជាក់ថា "ច្បាប់នេះគឺត្រូវអនុម័តជាវិធានការបណ្ដោះអាសន្ន ហើយស្ថិតក្នុងកាលៈទេសៈពិសេសមួយដែលមិនឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៅកម្ពុជាទេ" ដូច្នេះនៅពេលក្រោយមក ច្បាប់នេះមិនស្របជាមួយនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទេ ហើយច្បាប់នេះក៏ផ្ទុយនឹងកត្តិកាសញ្ញាអន្តរជាតិស្ដីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលរដ្ឋាភិបាលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នតាំងពីឆ្នាំ១៩៩២ មកម្ល៉េះ[៧៣] ។

## អ្នកសារព័ត៌មាន ជាអ្នកការពារសិទ្ធិមនុស្ស

របាយការណ៍នេះ គឺជាផ្នែកមួយនៃគម្រោងដ៏ធំ ដែលមានគោលបំណងការពារអ្នកសារព័ត៌មានពីការគំរាមកំហែង និងជួយអ្នកសារព័ត៌មានទាំងនោះឱ្យទៅជាអ្នកការពារសិទ្ធិមនុស្ស ។

ប៉ុន្តែ តើអ្នកសារព័ត៌មានបានមើលឃើញខ្លួនគេថាជាអ្នកកាពារសិទ្ធិមនុស្សដែរឬទេ ?

តាមការវិនិច្ឆ័យពីការសិក្សាលើអ្នកធ្វើការក្នុងប្រព័ន្ធផ្សាយព័ត៌មានចំនួន ១៤១ នាក់ ចម្លើយជាច្រើនលើសលប់ឆ្លើយថាគឺជា*អ្នកការពារសិទ្ធិមនុស្ស* ។ តាមពិត ៨៥% បាននិយាយថា គេចាត់ទុកខ្លួនគេថាជាអ្នកការពារសិទ្ធិមនុស្ស។ អ្នកទាំងនោះបានផ្ដល់ហេតុផលជាច្រើនថា ហេតុអ្វីបានជាអ្នកទាំងអស់នោះជឿជាក់ថាពួកគេជាអ្នកការពារសិទ្ធិមនុស្ស: អ្នកសារព័ត៌មានជាច្រើនមើលឃើញថាខ្លួនគេជាអ្នកដែលជួយ និងគាំទ្រជនរងគ្រោះច្រើន ឬ ជួយនិងគាំទ្រមនុស្សណាដែលអាចងាយរងគ្រោះ។

ប៉ុន្តែ រូបភាពរបស់អ្នកសារព័ត៌មាន និងបណ្ណាធិការកម្ពុជាមួយចំនួន គឺដូចជាមានភាពផ្ទុយពីអ្វីដែលតែងតែឃើញនៅតាមតូបលក់សារព័ត៌មាន និងនៅតាមរលកធាតុអាកាសទៅវិញ។ ធាតុពិត សារព័ត៌មានខ្លះតែងតែចាប់អារម្មណ៍លើរឿងហិង្សារំលោភលើភាពឯកជនរបស់ជនរងគ្រោះដោយឃាតកម្ម ឬ រំលោភបំពាននានា ហើយជួនកាលផ្សាយអ្វីៗទៅជាលំអៀងខាងជនមុខសញ្ញាទៅវិញជាជាងជនរងគ្រោះ។

[៧៣] សេចក្ដីប្រកាសព័ត៌មានរបស់តំណាងពិសេស នៃអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ២៧ ធ្នូ ២០០៥។

លើសពីនេះទៅទៀត ការភ័យខ្លាច និងការត្រួតពិនិត្យខ្លួនឯង និងការកង្វះសេរីភាព ដែលនិយោជកបានផ្តល់ឱ្យសារព័ត៌មានជាច្រើន ដើម្បីសរសេរឱ្យចំៗ និងត្រឹមត្រូវបានបណ្តាលឱ្យប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាមិនសូវមានឱកាសរិះគន់ទេ។ មានអត្ថបទខ្លះដែលត្រូវសរសេរអំពីករណីរំលោភសិទ្ធិមនុស្សដោយនគរបាល យោធា ឬ មន្ត្រីនានា នេះជារឿងមួយ "ក្តៅៗ" ដែលអ្នកសារព័ត៌មានជាច្រើនមិនអាចប៉ះបានទេ។

ដោយសារតែករណីរំលោភសិទ្ធិមនុស្សជាច្រើនជាប់ពាក់ព័ន្ធជាមួយនឹងមន្ត្រីរាជការ ការផ្សាយអំពីបញ្ហាលើសិទ្ធិមនុស្សច្រើនតែត្រូវគេចោទថាជាផ្នែកមួយនៃសារព័ត៌មាន ដែលមានសម្ព័ន្ធភាពជាមួយគណបក្សជំទាស់ ហើយភាគច្រើនប្រព័ន្ធផ្សាយព័ត៌មានដែលគាំទ្ររដ្ឋាភិបាលច្រើនបំភ្លេចរឿងនោះចោល។ អត្ថបទណាដែលធ្វើឱ្យខូចឈ្មោះរដ្ឋាភិបាល ឬ គណបក្សកាន់អំណាចគឺត្រូវបានមន្ត្រីបដិសេធចោលថាជារឿងភូតកុហក ឬ បំផ្លើសដោយគណបក្សជំទាស់ជាជាងការដោះស្រាយអំពីបញ្ហាសិទ្ធិមនុស្ស។

អ្នកសារព័ត៌មាន និងសកម្មជនសិទ្ធិមនុស្សមានទំនាក់ទំនងជិតស្និទនៅកម្ពុជា។ អ្នកយកព័ត៌មានត្រូវការប្រភពដើម្បីរាយការណ៍ប្រាប់ពួកគេអំពីការរំលោភនានា[៧៤] ហើយសកម្មជនសិទ្ធិមនុស្សពឹងផ្អែកទៅលើអ្នកសារព័ត៌មានដើម្បីតស៊ូមតិជាសាធារណៈ។ ជារឿយៗ នេះគឺជាទំនាក់ទំនងដែលផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ជួនកាលក៏មានភាពតានតឹងដែរ។

អ្នកសារព័ត៌មានក៏អាចដើរតួជាអ្នកការពារសិទ្ធិមនុស្សបានដែរ ប៉ុន្តែតួនាទីចម្បងរបស់អ្នកទាំងអស់នោះគឺជាអ្នកសារព័ត៌មានទេ។ យើងមិនត្រូវសង្ឃឹមថាអ្នកយកព័ត៌មាន ចេះតែដាក់បញ្ហាសិទ្ធិមនុស្សជាចម្បងនៅក្នុងសារព័ត៌មានទេ ហើយសហគមន៍សិទ្ធិមនុស្សគួរតែយល់ពីការលំបាករបស់ប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជា។

មានសំណួរពិបាកមួយចំនួនដែលត្រូវតែយកមកពិចារណា ។

ប្រាកដជាមានអ្នកយកព័ត៌មាន និងបណ្ណាធិការកម្ពុជាមួយចំនួនដែលដើរតួជាអ្នកការពារសិទ្ធិមនុស្សពិតមែន។ អ្នកទាំងនោះដើរតួបែបនេះដោយសារការរាយការណ៍ត្រឹមត្រូវយុត្តិធម៌ និងឯករាជ្យ។

[៧៤] នៅពេលសួរអ្នកសារព័ត៌មាន និងបណ្ណាធិការថា " តើអ្វីខ្លះគឺជាប្រភពព័ត៌មាន ៣ សំខាន់ៗជាងគេ សម្រាប់អត្ថបទរបស់អ្នក ? ចម្លើយដែលច្រើនទី ២ គឺ បន្ទាប់ពីជនរងគ្រោះគឺអង្គការមិនមែនរដ្ឋាភិបាល ។ សូមអានការសិក្សាស្រាវជ្រាវសារព័ត៌មាន សំណួរ ២១ ។

ពួកគេបានផ្តល់នូវសម្លេងឱ្យជនដែលអាចងាយរងគ្រោះនៅពេលមួយដែលសមរម្យ ហើយអ្នកទាំងនោះការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។ ដើម្បីប្រើឃ្លាមួយដែលអ្នកសារព័តិមានច្រើនតែប្រើៈ "គេរាយការណ៍ដោយពុំមានការភ័យខ្លាច ឬ បំពេញផលប្រយោជន៍" ឡើយ។ ប៉ុន្តែ តើ ៨៥% នៃអ្នកសារព័តិមានកម្ពុជាបានស្ថិតនៅក្នុងប្រភេទនេះដែរឬទេ ?

តើអ្នកសារព័តិមានអាចជាអ្នកការពារសិទ្ធិមនុស្សបានទេ បើអ្នកទាំងនោះទទួលសំណូក? តើសហគមន៍សិទ្ធិមនុស្សសង្ឃឹមខ្លាំងលើអ្នកសារព័តិមានម្នាក់ៗ ដែលធ្វើការនៅក្នុងប្រពន្ធ័ផ្សព្វផ្សាយព័តិមានមួយដែលមានបរិយាកាសផ្អែកលើការត្រួតពិនិត្យដោយខ្លួនឯង អំពើពុករលួយ និងការភ័យខ្លាចបានដែរឬទេ ?

តើអ្នកសារព័តិមានដើរតួជាអ្នកការពារសិទ្ធិមនុស្សដោយរបៀបណាពិតប្រាកដ? តើដោយគ្រាន់តែបំពេញការងាររបស់គាត់តាមក្រមសីលធម៌? ឬ មានអ្វីលើសពីនេះទៅទៀតទេ ?

# ភាគ ២: សេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន

## ភាពជាម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មាន អាជ្ញាប័ណ្ណ និង ភាពលំអៀងខាងនយោបាយ

ភាពជាម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សាយព័ត៌មានកម្ពុជានានា គឺជាវិធីមួយក្នុងចំណោមវិធីសំខាន់ៗមួយចំនួនដែលរដ្ឋាភិបាល និងគណបក្សនយោបាយគ្រប់គ្រងព័ត៌មាន និងទស្សនៈនានា។ ភាពជាម្ចាស់កម្មសិទ្ធិមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការផ្តល់អាជ្ញាប័ណ្ណរបស់ប្រព័ន្ធផ្សាយព័ត៌មាន គ្រប់គ្រងដោយរដ្ឋាភិបាល ហើយដែលធ្វើឱ្យមានស្ថាប័នលំអៀងផ្នែកនយោបាយនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននានា។

កំរិតនៃការត្រួតពិនិត្យគឺពុំមានលក្ខណៈទូទៅ ឬ ស្មើគ្នាទេ។ ជាក់ស្តែងប្រព័ន្ធផ្សាយព័ត៌មានខាងផ្នែកបោះពុម្ពមានការត្រួតពិនិត្យតិចតួចជាងគេបំផុត ដោយសារតែមានផលប៉ះពាល់តិច និងមិនសូវផ្សាយបានឆ្ងាយក្នុងចំណោមប្រព័ន្ធផ្សាយព័ត៌មានឯទៀត។ តាំងពីដើមទសវត្ស ១៩៩០ មក ក្រោយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្រោមឥទ្ធិពលរបស់អង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយទាំងឡាយដែលបានសន្យានាំមកនូវលទ្ធិប្រជាធិបតេយ្យ សេរី និងសិទ្ធិមនុស្សមកកម្ពុជា។ ពេលនោះ រដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការបោះពុម្ពសារព័ត៌មានរាប់សិប។ ជាលទ្ធផលគឺថា ប្រព័ន្ធផ្សាយព័ត៌មានបោះពុម្ពប្លែកៗ និងសំបូរបែបបានធ្វើឱ្យមានវេទិកាសម្លេងខុសៗគ្នា ទោះបីជាមិនសូវឯករាជ្យ និងមិនសូវមានលក្ខណៈអាជីពក៏ដោយ។ ទាមរយៈភាពជាម្ចាស់កម្មសិទ្ធិ (ទាំងម្ចាស់គាំទ្ររដ្ឋាភិបាល ឬ គាំទ្រគណបក្សជំទាស់) គឺភាគច្រើនជាសារព័ត៌មានឃោសនាសម្រាប់ម្ខាង ឬ ម្ខាងទៀត។

រដ្ឋាភិបាលបានកាន់កាប់ប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិចយ៉ាងណែន ជាការកំហិតដល់សម្លេងឯករាជ្យ ឬ សម្លេងមិនមែនរដ្ឋាភិបាលនៅតាមរលកធាតុអាកាសហើយនៅតែគាបទូរទស្សន៍ជាប់ដដែល។ ការហាមប្រាមតាមអំពើចិត្តក្នុងការផ្តល់អាជ្ញាប័ណ្ណប្រព័ន្ធផ្សាយព័ត៌មាន (សូមអានផ្នែកខាងក្រោម) គឺជាឧបករណ៍សំខាន់ដើម្បីសម្រេចបានបញ្ហានេះ។

ភាពជាកម្មសិទ្ធិរបស់ប្រព័ន្ធផ្សាយព័ត៌មាន មានឥទ្ធិពលប៉ះពាល់ទៅលើអ្នកសារព័ត៌មាន។ នៅពេលសួរអ្នកសារព័ត៌មាននៅក្នុងការសិក្សាមួយសម្រាប់របាយការណ៍នេះ ថាតើម្ចាស់កម្មសិទ្ធិរបស់ប្រព័ន្ធ

ផ្សាយព័ត៌មាន មានអនុភាពលើការសរសេរសេចក្តីរាយការណ៍របស់អ្នកសារព័ត៌មានដែរឬទេ ? ២៩% បាននិយាយថា "ជួនកាល" ហើយ ៣២% បានិយាយថា "ញឹកញាប់" ឬ "ជានិច្ចកាល"[៧៥] ។ (ផ្ទុយទៅវិញ នៅពេលដែលសួរដោយពិតប្រាកដ ថាតើបណ្ណាធិការធ្លាប់សុំឱ្យអ្នកសរសេរបំពេញបំណងអ្នកនយោបាយណាម្នាក់ ឬ គណបក្សណាមួយដែរឬទេ? មានសរុបត្រឹមតែ ១៥% ប៉ុណ្ណោះដែលឆ្លើយថា "ជួនកាល" "ជាញយៗ" ឬ "ជានិច្ចកាល" ហើយ ៦៨% បាននិយាយាថា បណ្ណាធិការ "មិនដែល" ជ្រៀតជ្រែកទេ[៧៦] ។)

ធាតុពិតនៃការឃោសនារបស់ផ្នែកចែកចាយនៃប្រព័ន្ធផ្សាយព័ត៌មានជាច្រើន ពុំមែនចេះតែជាកំហុសរបស់អ្នកយកព័ត៌មាន ឬ បណ្ណាធិការទេ ប៉ុន្តែគ្រាន់តែជាការឆ្លុះបញ្ចាំងឱ្យឃើញនូវបរិយាកាសមួយដែលពួកទាំងអស់នោះត្រូវតែធ្វើ ហើយបរិយាកាសនេះអាចមានឥទ្ធិពលខ្លាំងណាស់ ។ បញ្ហានេះ ប្រហែលជាអាចប្រទះឃើញយ៉ាងច្រើននៅក្នុងទូរទស្សន៍ ប្រព័ន្ធផ្សាយព័ត៌មានដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា និងឃើញមានតិចតួចនៅតាមស្ថានីយ៍វិទ្យុនានា។ ការផ្សព្វផ្សាយព័ត៌មានតែម្ខាង (ឬការផ្សព្វផ្សាយតែមួយជ្រុង) នៃបញ្ហានយោបាយ និងព្រឹត្តិការណ៍នានា ការមិនអនុញ្ញាតឱ្យមានសម្លេងនយោបាយប្រឆាំងតាមរលកធាតុអាកាស និងរូបភាពរបស់មន្ត្រីរដ្ឋាភិបាលធំៗ អង្គុយធ្វើជាអធិបតីក្នុងពិធីសម្ពោធការដ្ឋានគម្រោងហេដ្ឋារចនាសម្ព័ន្ធដដែលៗ ទាំងអស់នេះទំនងជាអាចមានឥទ្ធិពលមកលើអ្នកបោះឆ្នោតកម្ពុជាជាច្រើន។

---

[៧៥] សូមអានផ្នែកសិក្សាស្រាវជ្រាវលើសារព័ត៌មាន សំណួ ២៧ ។ សំណួរសួរថា : តើម្ចាស់កម្មសិទ្ធិសារព័ត៌មានរបស់អ្នក មានឥទ្ធិពលលើព័ត៌មានរបស់អ្នកដែរឬទេ?

[៧៦] សូមអានផ្នែក សិក្សាស្រាវជ្រាវលើសារព័ត៌មាន សំណួរ ២៨ ។ សំណួរពិតប្រាកដសួរថា: តើបណ្ណាធិការ/ផលិតករ ធ្លាប់សុំឱ្យអ្នកសរសេរអត្ថបទណាមួយដើម្បីបំពេញបំណងគណបក្ស ឬអ្នកនយោបាយណាមួយដែរឬទេ ?




## *តួនាទីរបស់រដ្ឋាភិបាល*

រដ្ឋាភិបាល តាមរយៈការប្រើប្រាស់ខុសតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់អាជ្ញាប័ណ្ណ និងធ្វើបទបញ្ញត្តិ ព្រមទាំងភាពជាម្ចាស់នៃសារព័ត៌មានរដ្ឋបានដើរតួនាទីនាំមុខគេជាអ្នកត្រួតពិនិត្យលើប្រព័ន្ធផ្សាយព័ត៌មាននៅក្នុងប្រទេស។ អំណាចនេះ ត្រូវបានពង្រឹងថែមទៀតដោយរដ្ឋាភិបាល ឬ មន្ត្រីធំៗដែលច្រើនតែដើរតួជាដើមបណ្តឹងនៅក្នុងតុលាការចំពោះករណីទាំងឡាយប្តឹងមកលើអ្នកសារព័ត៌មាន។

រដ្ឋាភិបាល គឺជាម្ចាស់ផ្ទាល់ និងជាប្រតិបត្តិករ (Operator) នៃទូរទស្សន៍កម្ពុជា ស្ថានីយវិទ្យុពីរ (មួយ AM និងមួយទៀត FM) និងជាម្ចាស់នៃទីភ្នាក់ងារសារព័ត៌មានមួយហៅថា ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)។ ទាំងអស់នេះ សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងព័ត៌មាន ហើយសុទ្ធតែគាំទ្ររដ្ឋាភិបាល (ជាពិសេសគឺគាំទ្រគណបក្សប្រជាជនកម្ពុជាតែម្តង)។ រដ្ឋាភិបាលក៏មានភាគហ៊ុននៅក្នុងស្ថានីយទូរទស្សន៍ និងវិទ្យុមួយចំនួនទៀតដែរ។

ក្រសួងព័ត៌មានបានផ្តល់អាជ្ញាប័ណ្ណឱ្យទូរទស្សន៍ វិទ្យុ និងសារព័ត៌មាននានា។ ដំណើរការនៃការផ្តល់នោះគឺប្រែប្រួលទៅតាមផ្នែកនីមួយៗ នៃប្រព័ន្ធផ្សាយព័ត៌មាន។ ការផ្តល់អាជ្ញាប័ណ្ណឱ្យសារព័ត៌មានដែលជាការបង្គ្រប់កិច្ចត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥។ ច្បាប់នេះបានផ្តល់អំណាចឱ្យក្រសួងបិទ ឬ ផ្អាកការផ្សាយសារព័ត៌មានបានដូចធ្លាប់កើតមានច្រើនដងក្នុងកំឡុងពេលច្រើនឆ្នាំកន្លងមកហើយ។ ក្រសួងក៏មានអំណាចរឹបអូសច្បាប់សារព័ត៌មាននានាដែលបានចេញផ្សាយផងដែរ។

តាមច្បាប់ស្តីពីសារព័ត៌មាន អំណាចនេះអាចត្រូវបានប្រើ ប្រសិនបើការផ្សាយនោះជាការរំលោភលើ "សន្តិសុខជាតិ និងស្ថិរភាពនយោបាយ"។ ប៉ុន្តែដូចដែលយើងនឹងលើកមកពិភាក្សាលំអិតជាងនេះនៅផ្នែកខាងក្រោយនៃរបាយការណ៍នេះ ក្រសួងតែងតែបានប្រើអំណាចខុសដោយបានប្រើ ដើម្បីបិទមាត់ពួកជំទាស់ ដាក់ទណ្ឌកម្មចំពោះអត្ថបទដែលសរសេរបង្ខូចឈ្មោះ និងត្រួតពិនិត្យព័ត៌មានណាដែលធ្វើឱ្យខូចមុខមាត់រដ្ឋាភិបាល។

ពុំមានច្បាប់ណាចែងអំពីការត្រួតពិនិត្យទូរទស្សន៍ និងវិទ្យុទេ ដូចដែលអ្នកសង្កេតការណ៍ម្នាក់បានលើកឡើងថា "រឿងនេះស្រេចតែលើរដ្ឋាភិបាលទឹកឃើញ"[៧៧]។ ទូរទស្សន៍គឺជាស្ថានីយ៍មួយដែលត្រូវគ្រប់គ្រងណែនជាងគេ មានតែស្ថានីយ៍គាំទ្ររដ្ឋាភិបាលទេដែលត្រូវផ្តល់អាជ្ញាប័ណ្ណឱ្យ។ គណបក្ស សម រង្ស៊ី ដែលជាគណបក្សជំទាស់បានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិទ្យុ និងទូរទស្សន៍ជាច្រើនដង ប៉ុន្តែត្រូវបានបដិសេធជានិច្ច ហើយអង្គការមិនមែនរដ្ឋាភិបាល ក៏បានប្រឈមមុខនឹងការបដិសេធនេះដែរនៅពេលដែលពួកគេស្នើសុំអាជ្ញាប័ណ្ណវិទ្យុ។ អស់រយៈពេលជាច្រើនឆ្នាំ ក្រសួងព័ត៌មានបានប្រើប្រាស់ការដោះសាររបៀបនេះដែរដើម្បីបដិសេធពាក្យសុំអាជ្ញាប័ណ្ណវិទ្យុថាអស់ប្រេកង់សម្រាប់វិទ្យុហើយនៅលើរលកធាតុអាកាសកម្ពុជា[៧៨]។ ក្នុងពេលជាមួយគ្នានោះដែរ គេបានសង្កេតឃើញមានការផ្តល់អាជ្ញាប័ណ្ណឱ្យទៅអ្នកដែលគាំទ្រ។ វិទ្យុសម្លេងប្រជាធិបតេយ្យ ដែលបង្កើតឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាតាំងពីឆ្នាំ២០០៣ បានស្នើសុំអាជ្ញាប័ណ្ណហើយត្រូវបានបដិសេធជានិច្ច ចំពោះហេតុផលដ៏ច្បាស់លាស់នេះ។ ប៉ុន្តែ មួយខែមុនការបដិសេធ

[៧៧] Kate Evans " ជេរណាម្នាក់ គឺដូចជាជេរខ្លួនឯង: ទស្សនៈអាស៊ីចំពោះសារព័ត៌មានកម្ពុជា" សម្លេងថ្មីក្នុងការ ស្រាវជ្រាវសារព័ត៌មាន។ www.arts.usyd.edu.au/departs/media/newvoices/Kae%20Evans.pdf ។

[៧៨] ពុយ គា ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ២០០៧។ ជាពិសេសសូមអានសេចក្តីប្រកាសដែលចេញផ្សាយដោយក្រសួងព័ត៌មានកាលពីថ្ងៃទី ២០ មេសា ២០០៥ ចុះហត្ថលេខាដោយខៀវ កញ្ញារីទ្ធ។

ចុងក្រោយបង្អស់របស់ខ្លួន នៅក្នុងខែកញ្ញា ២០០៧ ក្រសួងបានរកហ្រ្វេកង់ (FM 106) ផ្តល់ជូនរដ្ឋលេខាធិការក្រសួងការបរទេស មកពីគណបក្សប្រជាជនឈ្មោះ កៅ គឹមហួន[៧៩] ។

ដើម្បីព្យាយាមបិទចន្លោះមួយនៃការគ្រប់គ្រងរបស់ខ្លួនលើសារព័ត៌មានអេឡិចត្រូនិច នៅក្នុងខែកុម្ភៈ ក្រសួងបានចេញបញ្ជាស្ថានីយទូរទស្សន៍ និងវិទ្យុទាំងអស់មិនឱ្យផ្ទេរ ឬលក់អាជ្ញាប័ណ្ណទេប្រសិនបើមិនអាចបន្តដំណើរការបាន ហើយស្នើឱ្យប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ។

លើសពីនេះទៅទៀត រដ្ឋាភិបាលបានបិទស្ថានីយវិទ្យុ និងទូរទស្សន៍ជាច្រើនដងតាមអំពើចិត្ត ដោយគ្មានហេតុផលដែលមានមូលដ្ឋានច្បាប់ច្បាស់លាស់ឡើយ ឬ មិនដូច្នេះទេ បានក៏រិតនូវការហាមប្រាមលើការផ្សាយរបស់ស្ថានីយទាំងនោះ។

ជាទីបញ្ចប់ អាជ្ញាធររដ្ឋាភិបាល ឬ អ្នកដឹកនាំរដ្ឋាភិបាលជាន់ខ្ពស់នានា (ច្រើនដើរតួជាពលរដ្ឋម្នាក់ប្តឹងអ្នកសារព័ត៌មាន)។ កង្វះឯករាជភាពរបស់តុលាការពីសំណាក់រដ្ឋាភិបាល ស្ទើរតែគ្រប់ពេលដែលបានធ្វើឱ្យអ្នកសារព័តមានចាញ់ក្តីក្នុងតុលាការ ដោយមិនបាច់គិតអំពីផលល្អរបស់គេឡើយ។ ករណីខ្លះ គឺជាករណីព្យាបាទផ្លូវច្បាប់ច្បាស់ក្រឡែត ដោយគ្មានភស្តុតាងបង្ហាញសោះ និងជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ក្រាបសេរីភាពសារព័ត៌មាននៅកម្ពុជាផង។

ខាងក្រោមនេះគឺជាការពិនិត្យមើលយ៉ាងលំអិតអំពីភាពជាម្ចាស់កម្មសិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណដល់សារព័ត៌មាន វិទ្យុផ្សាយបន្ត និងទូរទស្សន៍ និងការលំអៀងដែលកើតឡើង[៨០] ។

## *ទូរទស្សន៍*

គ្រប់ស្ថានីយ៍ទូរទស្សន៍ទាំង ៧ នៅកម្ពុជាសុទ្ធតែគ្រប់គ្រងដោយផ្ទាល់ ឬ ក្រោមឥទ្ធិពលរបស់រដ្ឋាភិបាល/គណបក្សប្រជាជនកម្ពុជា។ ស្ថានីយ៍ទាំងនោះគឺ :

---

[៧៩] កៅ គឹមហួន ក៏ជាប្រធានសកលវិទ្យាល័យកម្ពុជាផងដែរ ហើយថ្មីៗនេះថែមទាំងបានបើកសារព័ត៌មានប្រចាំសប្តាហ៍មួយ ហើយពួគេថាកំពុងស្នើសុំអាជ្ញាប័ណ្ណទូរទស្សន៍ទៀតផង ។

[៨០] ដើម្បីបញ្ជាក់ឱ្យប្រាកដថា អ្នកណាជាម្ចាស់សារព័ត៌មានកម្ពុជាអាចជាការលំបាកពីព្រោះមានស្ថានខ្លះប្រើ "អ្នកឈរឈ្មោះជំនួស" ដើម្បីលាក់អត្តសញ្ញាណរបស់ម្ចាស់ពិត។ បើមិនដូច្នេះទេ មានបញ្ជាក់ថាម្ចាស់កម្មសិទ្ធិសារព័ត៌មានត្រូវបានបញ្ជាក់តាមលទ្ធភាពដែលអាចធ្វើបានតាមរយៈឯកសារ ឬ ប្រភពដែលអាចទុកចិត្តបាន។

| ស្ថានីយ | ម្ចាស់កម្មសិទ្ធិ/អ្នកគ្រប់គ្រង | ព័ត៌មានបន្ថែម |
|---|---|---|
| ស្ថានីយទូរទស្សន៍អប្សរា | ▪ តាមផ្លូវការជារបស់ក្រុមហ៊ុនសារព័ត៌មានអប្សរា ទោះបីជានាយកក្រុមហ៊ុននេះ មិនចេញមុខថាជានរណាក៏ដោយ[៨១] ក៏ត្រូវបានគេរាយការណ៍ថា ជារបស់គណបក្សប្រជាជនកម្ពុជា។<br>▪ អគ្គនាយកឈ្មោះ លោក សុខ ឦសាន្ត ជាសមាជិកគណៈកម្មាធិការកណ្តាល ដែលចាត់ទុកថាជា "ភារកិច្ចរបស់ប្រជាពលរដ្ឋ" គឺលើកកម្ពស់រដ្ឋាភិបាល[៨២]។ | ▪ ក្នុងឆ្នាំ២០០៦ ស្ថានីយនេះបានរួមជាដៃគូជាមួយ ក្រុមហ៊ុនបារាំង មួយឈ្មោះសូឡារីអន្តរជាតិ ដើម្បីកែលំអរបច្ចេកវិទ្យា មាតិកាកម្មវិធី និងកម្លាំងផ្សាយ។<br>▪ ទូទស្សន៍អប្សរា ក៏មានស្ថានីយវិទ្យុផងដែរ ។ |
| ស្ថានីយទូរទស្សន៍បាយ័ន | ▪ ត្រូវបានគេដឹងជាទូទៅថាជារបស់គ្រួសារសម្តេចនាយករដ្ឋមន្ត្រីហើយបច្ចុប្បន្ននេះគ្រប់គ្រងដោយកូនស្រីសម្តេច។ | ▪ បានបង្កើតឡើងនៅឆ្នាំ ១៩៩៨<br>▪ អស់រយៈពេលជាច្រើនឆ្នាំ អង់តែនទូរទស្សន៍បាយ័នស្ថិតនៅក្នុងរង្វង់ទីតាំងការពាររបស់សម្តេចនាយករដ្ឋមន្ត្រី ដែលនៅជាយក្រុងភ្នំពេញ។<br>▪ សម្តេចនាយករដ្ឋមន្ត្រី និងភរិយារបស់សម្តេចបានកាត់ខ្សែបូរណិដើម្បីសម្ពោធកន្លែងថ្មីរបស់ស្ថានីយបាយ័ន កាលពីខែមិនា ២០០៧ កន្លងទៅនេះ។ ដូចទូរទស្សន៍អប្សរា |

[៨១] អគ្គនាយកទូរទស្សន៍អប្សរា ឈ្មោះ សុខ ឦសាន្ត ដែលបានបដិសេធមិនព្រមបកស្រាយថា អ្នកណាជាម្ចាស់សារព័ត៌មានអប្សរា ឬ អ្នកណាជាម្ចាស់ដីដែលកសាងស្ថានីយទូរទស្សន៍នោះ។

[៨២] នៅក្នុងការសម្ភាសន៍មួយកាលពីថ្ងៃទី១០ សីហា ២០០៧ លោក សុខ ឦសាន្តបានផ្តល់ឱ្យអ្នកស្រាវជ្រាវនូវទស្សនាវដ្តី ២ច្បាប់ ដែលជាការបោះពុម្ពផ្សាយរបស់គណបក្សប្រជាជនកម្ពុជា គឺទស្សនាវដ្តីប្រជាជនដែលគាត់និយាយថា បានផ្តល់ជាអំណោយ ១០០ ចំពោះការផ្សាយលេខ ៧១ ខែមេសា ២០០៧។

| | | |
|---|---|---|
| | | ទូទស្សន៍បាយ័នក៏មានស្ថានីយ វិទ្យុផងដែរ ។ |
| បណ្តាញស្ថានីយ ទូរទស្សន៍កម្ពុជា (ស៊ីធីអិន) | ▪ ជារបស់ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប គ្រប់គ្រងដោយមហាសេដ្ឋីខ្មែរ-អូស្ត្រាលី លោក គិត ម៉េង[៨៣] និងជាប្រធានសភាពាណិជ្ជកម្មជាតិដែលគេស្គាល់ជាទូទៅថា មនុស្ស ជិតស្និទជាមួយរដ្ឋាភិបាល[៨៤] ។ | ▪ បណ្តាញទូរទស្សន៍កម្ពុជា (ស៊ីធីអិន) ជាស្ថានីយថ្មី និង ទំនើបជាងគេបង្អស់ក្នុងចំណោមស្ថានីយទាំងឡាយ<br>▪ ស្ថានីយទូរទស្សន៍នេះ គឺជាស្ថានីយ ដែលគាំទ្រគណបក្សប្រជាជនកម្ពុជា |
| ស្ថានីយផ្សាយរបស់រដ្ឋ **ទទក** | ▪ ត្រូវបានគ្រប់គ្រងដោយក្រសួង ព័ត៌មាន ។ | ▪ មានការត្រួតពិនិត្យយ៉ាងតឹងរឹងមុន នឹងចេញផ្សាយបញ្ហាស្មុកស្មាញ ។ |
| ស្ថានីយទូរទស្សន៍ប៉ុស្តិ៍ លេខ ៣ | ▪ ម្ចាស់ភាគហ៊ុនគឺមន្ទីរព័ត៌មាន រាជធានីភ្នំពេញ និងក្រុមហ៊ុន ថៃឈ្មោះ KCS Cambodia ។<br>▪ អគ្គនាយកទូរទស្សន៍ប៉ុស្តិ៍លេខ ៣ ឈ្មោះលោក ខាំពូន កែវម៉ានី គឺជាទីប្រឹក្សាសម្តេចប្រធាន | ▪ មន្ទីរព័ត៌មានរាជធានីភ្នំពេញ មាន ភាគហ៊ុនមួយផ្នែក ដែលមានមន្ទីរ ព័ត៌មានរាជធានីភ្នំពេញ និងក្រសួង ព័ត៌មានជាម្ចាស់កម្មសិទ្ធិនៃស្ថានីយ[៨៥] |

[៨៣] ក្រុមហ៊ុន រ៉ូយាល់គ្រុបរបស់ លោក គិត ម៉េង ក៏ជាម្ចាស់លើក្រុមហ៊ុនម៉ូប៊ីតែល ដែលជាក្រុមហ៊ុនទូរស័ព្ទធំជាងគេ ភ្នាក់ងារល្បែងស៊ីសងដែលមានអាជ្ញាប័ណ្ណ ជាម្ចាស់ពាក់កណ្តាលលើធនាគារ ANZ Royal ។ គិត ម៉េង គឺជាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

[៨៤] គិត ម៉េង ជាមនុស្សដែលគ្មានតំណែងនៅក្នុងរដ្ឋាភិបាលឡើយ ប៉ុន្តែគេជឿជាក់ថា គាត់ចូលជួបនាយករដ្ឋមន្ត្រីបានយ៉ាងងាយ ហើយអ្នកសារព័ត៌មានទូរទស្សន៍ ស៊ីធីអិន ក៏ដូច្នេះដែរ (អ្នកសារព័ត៌មានម្នាក់គឺជា ទីប្រឹក្សានាយករដ្ឋមន្ត្រី) ។ គិត ម៉េង ក៏មនុស្សដែលគេប្រើប្រាស់ជាឧបករណ៍សម្រាប់សម្របសម្រួលក្នុងការចរចាររវាង ហ៊ុន សែន និងសម រង្ស៊ីផងដែរ ដែលក្រោយមកបានធ្វើឱ្យ លោក សម រង្ស៊ី ត្រឡប់ពីនិរទេសខ្លួនវិញនៅឆ្នាំ២០០៦ ។ ក្នុងនាមជាប្រធានសភាពាណិជ្ជកម្មគាត់ក៏បានធ្វើដំណើរទៅបរទេស ជាមួយ ហ៊ុន សែន ហើយដើរតួនាទីជាអ្នកផ្សព្វផ្សាយពាណិជ្ជកម្មកម្ពុជាក្នុងនាមរដ្ឋាភិបាល ។

[៨៥] មន្ទីរព័ត៌មានរាជធានីភ្នំពេញ ក៏ជាម្ចាស់ស្ថានីយ វិទ្យុ FM ១០៣ ស្ថានីយ៍វិទ្យុ (FM ៨៨) និង (FM ៩៧.៥ ) និងម្ចាស់ក្រុមហ៊ុនទូរទស្សន៍ខ្មែរកាបភ្នំពេញផងដែរ ។ http://www.culturalprofiles.net/cambodia/Units/1142.html ។

| | | |
|---|---|---|
| | ព្រឹទ្ធសភា ជា ស៊ីម ។ | |
| ស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ ៥ | ▪ ក្រសួងការពារជាតិមានភាគហ៊ុនមួយភាគ និងប្រព័ន្ធផ្សាយព័ត៌មាន MICA មួយភាគ។ អគ្គនាយកស្ថានីយនេះ ឈ្មោះលោកខៃម គុណវឌ្ឍន៍ សមាជិកគណៈកម្មាធិ ការកណ្តាលគណបក្សប្រជាជនកម្ពុជា[៨៦] ។ | |
| ទូរទស្សន៍ប៉ុស្តិ៍លេខ ៩ | ▪ បច្ចុប្បន្ននេះត្រូវបានគេអះអាងថា "បានទទួលអាជ្ញាប័ណ្ណជាក្រុមហ៊ុនឯកជន ១00%"[៨៧] ។ គេជឿជាក់ស្ថានីយនេះជារបស់គ្រួសារលោករដ្ឋមន្ត្រី ឃុន ហាំង រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា (ហ៊្វុនស៊ីនប៉ិច) ហើយគ្រប់គ្រងដោយ សាច់ញាតិគ្រួសាររបស់លោក។ | ▪ ស្ថាបនាឡើង ដោយគណបក្ស ហ៊្វុនស៊ីនប៉ិចកាលពីដើមទសវត្ស ១៩៩0 ▪ រហូតមកដល់ ១៩៩៧ វាជាស្ថានីយមួយដែលផ្សាយពីបញ្ហាមិនស្មុកស្មាញខាងវិស័យនយោបាយ ដោយគាំទ្រគណបក្សហ៊្វុនស៊ីនប៉ិច និងរដ្ឋាភិបាលចម្រុះ ជាមួយគណបក្សប្រជាជនកម្ពុជា។ ព្រឹត្តិការណ៍ឆ្នាំ១៩៩៧ ស្ថានីយទូរទស្សន៍ នេះផ្សព្វផ្សាយឱ្យគណបក្សហ៊្វុនស៊ីនប៉ិច ហើយតែងតែនិយាយជំទាស់នឹងគណបក្សប្រជាជនកម្ពុជា។ ទូរទស្សន៍ ប៉ុស្តិ៍លេខ ៩ (ជាមួយស្ថានីយវិទ្យុរបស់ហ៊្វុនស៊ីនប៉ិច) ត្រូវបានវាយប្រហារក្នុងពេលព្រឹត្តការណ៍នេះ ក្រោយមកត្រូវបាន |

[៨៦] ឯកសារផ្តល់ដោយអ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់។

[៨៧] ពីវែបសាយរបស់ទូរទស្សន៍ប៉ុស្តិ៍លេខ ៩ http://www.tv.9.com.kh/aboutus.html ។

| | | |
|---|---|---|
| | | គ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ។<br>▪ ក្រោយមកទើបប្រគល់ជូនវិញ ហើយបច្ចុប្បន្នស្ថានីយវិទ្យុនេះ ស្ថិតនៅក្នុងដៃលោករដ្ឋមន្ត្រីយុន ហាំង ដែលចាត់ទុកថាជាវិទ្យុគាំទ្ររដ្ឋាភិបាល ហើយសម្រុះសម្រួលជាមួយគណបក្សប្រជាជនកម្ពុជា ។ |

រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ជាក់ថា ឆាប់ៗនេះក្រសួងនឹងផ្តល់ជូនអាជ្ញាប័ណ្ណឱ្យស្ថានីយទូរទស្សន៍ថ្មីពីរទៀតគឺ ស៊ីធីអិន ប្លូស់ (ជារបស់ លោក គិត ម៉េង) និងទូរទស្សន៍អាស៊ីអាគ្នេយ៍ (ជារបស់លោករដ្ឋលេខាធិការ កៅ គឹមហួន)[៨៨] ។

មិនគួរឱ្យភ្ញាក់ផ្អើលទេ នៅពេលពិនិត្យមើលភាពជាម្ចាស់កម្មសិទ្ធិនៃស្ថានីយទូរទស្សន៍កម្ពុជាទាំងឡាយ គ្មានកន្លែងណាដែលអាចរកមើលសេរីភាពបញ្ចេញមតិ ឬ ព័ត៌មានដែលមិនលំអៀងឃើញឡើយ។ ដូចដែលបានលើកឡើងពីខាងលើ ក្នុងរបាយការណ៍នេះគ្រប់ស្ថានីយផ្សាយព័ត៌មានទាំងអស់សុទ្ធតែមានភាពលំអៀងផ្នែកនយោបាយទៅខាងរដ្ឋាភិបាល។ ឧទាហរណ៍របាយការណ៍ជាក់ស្តែងរួមមាន ការពិពណ៌នាអំពីមន្ត្រីរដ្ឋាភិបាល ឬ មន្ត្រីមួយក្រុម (ស្ទើរតែជាសមាជិកគណបក្សប្រជាជនកម្ពុជាទាំងអស់) ធ្វើដំណើរទៅតាមជនបទដើម្បីពិនិត្យមើលផ្លូវ ឬ ស្ពាន ឬ ចែកអំណោយជាចំណីអាហារ ឬ ប្រាក់កាសបន្តិចបន្តួច ឬ របស់របរផ្សេងៗដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន។

*សម្តេច ហេង សំរិន (ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា និងជាប្រធានរដ្ឋសភាជាតិ) មានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជា ជួនកាលជួលទូរទស្សន៍ឯកជនដូចជា ប៉ុស្តិ៍អប្សរា ឬ បាយ័ន ឱ្យចាក់ផ្សាយព្រឹត្តិការណ៍នានារបស់គណបក្សប្រជាជនកម្ពុជា ហើយមានតែទូរទស្សន៍*

[៨៨] កៅ គឹមហួន ក៏បើកសារព័ត៌មានមួយ និងស្ថានីយវិទ្យុមួយនៅក្នុងឆ្នាំ ២០០៧ ហើយក៏ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជាដែរ ។

*ជាតិកម្ពុជា ទទក តែប៉ុណ្ណោះ ដែលចាក់ផ្សាយសេចក្តីរាយការណ៍ព័ត៌មានស្តីពីសកម្មភាពរបស់រដ្ឋាភិបាល។*

សម្តេចបញ្ជាក់សារជាថ្មីម្តងទៀតថា: *"**ទទក** ផ្សាយសកម្មភាពរបស់រដ្ឋាភិបាលមិនមែនរបស់គណបក្សប្រជាជនកម្ពុជាទេ"*[៨៩] ។

តាមរបៀបនេះ ក្រសួងនានា ឬ មេដឹកនាំរបស់រដ្ឋាភិបាលស្ទើរឡើងរឿងមួយបង់ថ្លៃសម្រាប់សេចក្តីរាយការណ៍ ព្រមទាំងផ្តល់ការលើកទឹកចិត្តជាថវិកាដល់អ្នកយកព័ត៌មាន។ ទម្លាប់ក្នុងការហុចស្រោមសំបុត្រដែលមានប្រាក់កាសក្នុងពេលសន្និសីទសារព័ត៌មាន ឬ ឱកាសថតរូបសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគឺជារឿងធម្មតា។ អ្នកយកព័ត៌មានទូរទស្សន៍ជាតិម្នាក់និយាយអួតថាបានទទួល៥០ដុល្លារសហរដ្ឋអាមេរិក និងការធ្វើដំណើរដោយឥតគិតថ្លៃនៅពេលធ្វើសេចក្តីរាយការណ៍ពីសកម្មភាពរបស់រដ្ឋាភិបាល[៩០] ។

អ្នកសារព័ត៌មានម្នាក់ បានធ្វើការកត់សម្គាល់នូវការចំអកអំពីការបង្ខំឱ្យផ្សាយ "ពិធីបុណ្យចែកអំណោយ" ប៉ុន្តែមិនអនុញ្ញាតឱ្យរាយការណ៍ពីភាពក្រីក្រដោយជាក់ស្តែងដែលនៅពីខាងក្រោយឆាករបស់អ្នកដឹកនាំនយោបាយក្នុងការផ្តល់ប្រាក់កាសតិចតួច និងមីកញ្ចប់ដល់ពលរដ្ឋកម្ពុជាជនបទទេ[៩១] ។

ការផ្សាយព័ត៌មានទាំងនេះ ប្រហែលជារឿងគួរអោយធុញទ្រាន់ ប៉ុន្តែអាចជាឧបករណ៍នយោបាយមួយដ៏មានឥទ្ធិពល ។

ការសិក្សាថ្មី១មួយបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់សន្លឹកឆ្នោតមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការសាងសង់ហេដ្ឋារចនាសម្ព័ន្ធហើយភ្ជាប់វាទៅនឹងចំណូលចិត្តនៃការបោះឆ្នោត។ នៅពេលដែល " វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ " បានសួរពលរដ្ឋកម្ពុជាថាតើអ្វីដែលមានអនុភាពលើការបោះឆ្នោតរបស់ពួកគេកាលពីសម័យបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០០៧? ចម្លើយខ្ពស់ជាងគេបំផុត(៤៣%) គឺ "ហេដ្ឋារចនាសម្ព័ន្ធ"[៩២] ។ នៅពេលដែលសួរថាហេតុអ្វីបានជាពួកគាត់

---

[៨៩] គណបក្សប្រជាជនកម្ពុជាត្រួតត្រាព័ត៌មាន **ទទក** ក្នុងការផ្សាយមុនពេលបោះឆ្នោត។ សារព័ត៌មាន ឌឺ ឃែមបូឌា ដេលី ១២ ធ្នូ ២០០៦ ។

[៩០] សម្ភាសន៍ជាមួយអ្នកយកព័ត៌មាន ទទក ២៥ សីហា ២០០៧។

[៩១] សម្ភាសន៍ជាមួយអ្នកយកព័ត៌មានថ្ងៃទី១១ កញ្ញា ២០០៧។

[៩២] ការសិក្សាទូទាំងប្រទេសមួយចេញផ្សាយដោយវិទ្យាស្ថានសាធារណអន្តរជាតិ កាលពីខែមិថុនា ២០០៧ បានសួរមនុស្ស ២០០០ នាក់ (ដែលពីមុនបានឆ្លើយដោយសុទិដ្ឋិនិយមអំពីអនាគតរបស់ប្រទេសជាតិ)។ សំណួរ : ហេតុអ្វីបានជាអ្នកយល់ថាប្រទេសកម្ពុជាកំពុងដើរតាមទិសត្រឹមត្រូវ ?" អ្នកឆ្លើយដ៏លើសលប់ ៧៨% បញ្ជាក់ថា "ហេដ្ឋារចនាសម្ព័ន្ធ" គឺជាហេតុផលដ៏សំខាន់។ ស្រដៀងគ្នានេះដែរ នៅពេលដែលការសិក្សា ស្រាវជ្រាវសួរ

គិតថា ប្រទេសកម្ពុជាកំពុងធ្វើដំណើរតាមទិសត្រឹមត្រូវនោះ? ៧៨%នៃអ្នកឆ្លើយបានបញ្ជាក់ថា "ហេដ្ឋារចនាសម្ព័ន្ធ"។ គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចបានឈ្នះ៨៤% នៃតំណែងជាប្រធានក្រុមប្រឹក្សាឃុំ/ សង្កាត់[៩៣]។

លោក គល់ បញ្ញា នាយកអង្គការខុមហ្វ្រែល (គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា) បានមានប្រសាសន៍ថា "ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ជាពិសេសទូរទស្សន៍ដើរតួនាទីយ៉ាងសំខាន់សម្រាប់ប្រជាជនក្រីក្រ និងមិនចេះអក្សរ។ ពួកគេឃើញតែគណបក្សប្រជាជនកម្ពុជា ធ្វើកិច្ចការអភិវឌ្ឍន៍នានា"[៩៤]។

ខណៈដែលភាពលំអៀងផ្នែកនយោបាយ មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលដូចក្នុងករណី **ទទក**ដែលជាប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រងដោយរដ្ឋនោះ ស្ថានីយផ្សេងៗទៀតក៏អនុវត្តដូចគ្នាដែរ។ អ្នកសារព័ត៌មានខ្លះបានសារភាពជាចំហរថា តួនាទីរបស់ពួកគេហាក់បីដូចជានាយកដ្ឋានទំនាក់ទំនងសាធារណៈរបស់រដ្ឋាភិបាលអញ្ចឹងជាជាងជាអ្នកផ្តល់ដំណឹងបែបឯករាជ្យមួយ។

លោក សុខ ព្សិសាន្ត អគ្គនាយកទូរទស្សន៍អប្សរា និងជាសមាជិកគណៈកម្មការកណ្តាលនៃគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា "គ្រប់សង្គមទាំងអស់សុទ្ធតែមានចំណុចវិជ្ជមាន និងអវិជ្ជមាន ប៉ុន្តែយើងលើកទឹកចិត្តចំណុចវិជ្ជមាន និងកាត់បន្ថយចំណុចអវិជ្ជមានវិញនេះជាការបម្រើនូវផលប្រយោជន៍ប្រទេសជាតិ និងប្រជាពលរដ្ឋ។ មនុស្សគ្រប់រូបស្រឡាញ់រឿងដែលល្អ"[៩៥]។

នៅក្នុងព្រឹត្តិប័ត្រទូរទស្សន៍ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ អត្ថបទបែបដំណឹងចំនួន៨ក្នុងចំណោម១២ បានដើរតាមរូបមន្តនៃការពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធ ឬ ការចែកអំណោយដល់សហគមន៍

ថា "តើហេតុផលអ្វីខ្លះដែលគណបក្សមួយធ្វើឱ្យអ្នកពេញចិត្តនៅក្នុងការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០៧ ? ចម្លើយទទួលបានខ្ពស់បំផុតគឺ "ការកសាងហេដ្ឋារចនាសម្ព័ន្ធ" (៤៣%)។

http://www.iri.org/asia/cambodia/pdfs/2007-06- 12Cambodia.pdf ។

[៩៣] គណបក្សប្រជាជនកម្ពុជាឈ្នះបាន ១៥៩១ តំណែងមេឃុំ ប្រៀបធៀបជាមួយគណបក្ស សម រង្ស៊ី (២៨) ហើយហ្វ៊ុនស៊ិនប៉ិចបាន (២)។ http://necelect.org.kh/English/ElectionResult/2007/official%20results/Official%20Results(seat_e).pdf.

[៩៤] គណបក្សប្រជាជនកម្ពុជាត្រួតត្រាព័ត៌មាន **ទទក** ក្នុងការផ្សាយមុនពេលបោះឆ្នោត-សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី ១២ ធ្នូ ២០០៦។

[៩៥] សម្ភាសន៍ជាមួយលោក សុខ ព្សិសាន្ត ថ្ងៃទី១១ កញ្ញា ២០០៧ ។

ដោយឯកឧត្តមផ្សេងៗ[៥៦] ។ ពុំមានដំណឹងបែបរិះគន់ណាមួយឡើយ ។ សារបង្ហាញយ៉ាងច្បាស់ថា: រដ្ឋាភិបាលបានចុះជួយប្រជាពលរដ្ឋ រដ្ឋាភិបាលគឺទទួលខុសត្រូវក្នុងការសាងសង់ផ្លូវ និងស្ពាន (ទោះបីជាផ្លូវ និងស្ពានសឹងតែទាំងអស់ជាអំណោយរបស់ម្ចាស់ជំនួយអន្តរជាតិក៏ដោយ) ។ មានការនិយាយតិចតួច ដែលស្ទើរតែគ្មានសោះអំពីការប្រឆាំងនយោបាយ ឧក្រិដ្ឋកម្ម (ដូចជានិទ្ទណ្ឌភាពចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយនគរបាល យោធា ឬមន្ត្រីរដ្ឋាភិបាល) ឬ សង្កត់លើបញ្ហា ដូចជាភាពក្រីក្រ និងបញ្ហារំលោភដីធ្លីជាដើម ។

អគ្គនាយកទូរទស្សន៍ប៉ុស្តិ៍លេខ៥ ធ្លាប់បានមានប្រសាសន៍ថា ស្ថានីយរបស់លោកផ្សាយអំពី "ការងារសហគមន៍" ដែលអនុវត្តដោយរដ្ឋាភិបាល ។ លោក ខែម គុណវឌ្ឍ[៥៧] ក៏ជាសមាជិកគណៈកម្មការកណ្តាលនៃគណបក្សប្រជាជនកម្ពុជាដែរ បានមានប្រសាសន៍ថា "ខ្ញុំមិនដែលឃើញគណបក្ស សម រង្ស៊ីកសាងសាលារៀន ផ្លូវ និងវត្តទេ ។ មូលហេតុនេះហើយ បានជាយើងមិនដែលផ្សាយព័ត៌មានពីគណបក្សនេះ" ។

ភាពលំអៀងគាំទ្ររដ្ឋាភិបាលរបស់ស្ថានីយទូរទស្សន៍បាយ័ន ត្រូវបានផ្សាយពាណិជ្ជកម្មតាមវែបសាយរបស់ខ្លួនយ៉ាងច្បាស់ដែលនិយាយថា ដំណឹងក្នុងស្រុកមានបំណងបម្រើជា "ស្ពានដែលពាំនាំគោលនយោបាយរបស់រដ្ឋាភិបាលទៅដល់ប្រជាពលរដ្ឋ"[៥៨] ។ ចំណុចនេះពិតជាមិនសូវភ្ញាក់ផ្អើលប៉ុន្មានទេ ដោយពិចារណាត្រង់ថាស្ថានីយទូរទស្សន៍ គឺគ្រប់គ្រងដោយកូនស្រីរបស់សម្តេចនាយករដ្ឋមន្ត្រី ។

ស្ថានីយថ្មីជាងគេបំផុតគឺ ស៊ីធីអិន ដែលជាទូរទស្សន៍ទំនើបជាងគេបន្តិចនៅក្នុងការបង្ហាញរបស់ខ្លួន ហើយប្រហែលជាស្ថានីយដែលមានសេរីភាពជាងគេបំផុតក្នុងខ្លឹមសារមាតិកា ប៉ុន្តែ ក៏មិនមានអ្វីខុសពីគេច្រើនណាស់ណាដែរ ។ ដំណឹង និង "បទវិចារណកថា" របស់ទូរទស្សន៍នោះច្រើនតែបង្ហាញនូវការផ្តល់វេទិកាសម្រាប់មន្ត្រីគណបក្សប្រជាជនកម្ពុជា ដើម្បីនិយាយយ៉ាងវែងអំពីការងារដ៏ល្អរបស់គណបក្ស ហើយរិះគន់គណបក្សប្រឆាំង និងអង្គការមិនមែនរដ្ឋាភិបាលចំៗ ឬ បញ្ឆិតបញ្ឆៀង (ពិសេសគឺអង្គការសិទ្ធិ

---

[៥៦] នៅក្នុងទំនាក់ផលប្រយោជន៍ពិតៗមួយ អត្ថបទមួយ គឺជាសន្ទរកថារបស់លោក សុខ ព្សសាន្ត ដែលជាអគ្គនាយកស្ថានីយ ។ អត្ថបទផ្សេងៗទៀតដូចជាព្រះសង្ឃទទួលរង្វាន់ កិច្ចប្រជុំរវាងរដ្ឋមន្ត្រីការបរទេសជាមួយនឹងអ្នកមានបណ្ដាស័ក្តិកូរ៉េ សន្និសីទស្តីពីឥស្លាម និងការដុតបំផ្លាញស៊ុតដើម្បីទប់ស្កាត់ជម្ងឺផ្តាសាយបក្សី ។

[៥៧] គណបក្សប្រជាជនកម្ពុជាត្រួតត្រាព័ត៌មាន **ខខក** ក្នុងការផ្សាយមុនពេលបោះឆ្នោត សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី ១២ ធ្នូ ២០០ ៦ ។

[៥៨] http://www.bayontv.com.kh/localnews.html

មនុស្ស)។ ជួនកាលស្ថានីយនេះសាកល្បងផ្សាយវិស័យខ្លះដែលខ្លួនមិនគួរផ្សាយ ប៉ុន្តែបញ្ចប់ទៅវិញយ៉ាងលឿន។ ក្នុងករណីមួយដែលបានថ្លែងកាលពីខែសីហា ២០០៦ សម្តេចនាយករដ្ឋមន្ត្រីជំទាស់នឹងកម្មវិធីមួយដែលបានពិភាក្សាអំពីអំពើពុករលួយហើយស៊ីធីអ៊ិនបានបិទវេទិកានោះភ្លាមៗមិនអោយផ្សព្វផ្សាយ[៩៩]។

*"នៅពេលខ្ញុំដែលមានពេលទំនេរពី ស៊ីធីអិន ខ្ញុំត្រឡប់មកទីស្តីការគណៈរដ្ឋមន្ត្រី ហើយបំពេញការងាររបស់ខ្ញុំសម្រាប់សម្តេចនាយករដ្ឋមន្ត្រី"។ មន្ត្រីព័ត៌មាន លោក ជុំ កុសល់*

ក្រៅពីជាអ្នកអត្ថាធិប្បាយដ៏សំខាន់ម្នាក់របស់ទូរទស្សន៍ស៊ីធីអិន និងជា "ជាមន្ត្រីព័ត៌មាន" លោក ជុំ កុសល់ ក៏ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីផងដែរ។ តួនាទីរបស់លោកនៅក្នុងស្ថានីយស៊ីធីអិន គឺសម្ភាសន៍មន្ត្រីបណ្តាខេត្ត "ដើម្បីបង្ហាញនូវសមិទ្ធិផលរបស់មន្ត្រីទាំងនោះ" ប៉ុន្តែលោកពុំបានឃើញទំនាស់ផលប្រយោជន៍នៅក្នុងការងាររបស់លោកទេ។

លោកបានពន្យល់ថា "ខ្ញុំត្រូវបែងចែកពេលវេលារបស់ខ្ញុំ" នៅពេលខ្ញុំដែលមានពេលទំនេរពីស៊ីធីអិន ខ្ញុំត្រឡប់មកទីស្តីការគណៈរដ្ឋមន្ត្រី ហើយបំពេញការងាររបស់ខ្ញុំសម្រាប់សម្តេចនាយករដ្ឋមន្ត្រី"[១០០]។

ថ្វីត្បិតតែគណបក្សប្រជាជនកម្ពុជា គ្រប់គ្រងផ្តាច់មុខទៅលើទូរទស្សន៍យ៉ាងណាក៏ដោយ ក៏ប៉ុន្តែក៏នៅតែមានករណីលើកលែងដោយកម្រ និងមានកម្រិត គឺនៅក្នុងអំឡុងយុទ្ធនាការបោះឆ្នោត។ នៅពេលដែលកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ទិញកម្មវិធីក្នុងទូរទស្សន៍ **ទទក** ដែលជារបស់រដ្ឋ ដើម្បីចាក់ផ្សាយបទរាយការណ៍ព័ត៌មានអំពីគណបក្សនយោបាយនានា ហើយព័ត៌មាននោះមានតុល្យភាពជាងមុន[១០១]។ កម្មវិធីនេះមានការកើតឡើងដោយមានកិរិតតិចបំផុត ហើយគ្មានឥទ្ធិពលណា

---

[៩៩] សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី ១៦ សីហា ២០០៦។

[១០០] សម្ភាសន៍ជាមួយ ជុំ កុសល ថ្ងៃទី ១៣ កញ្ញា ២០០៧។

[១០១] កម្មវិធីមិនបានផ្តល់ការផ្សាយស្មើភាពគ្នាទេ ប៉ុន្តែ "មានសមធម៌" ចំពោះគណបក្សធំៗមួយចំនួន ជាមួយនឹងបរិមាណព័ត៌មានដែលផ្តល់ដល់គណបក្សនីមួយៗ ដោយយោងទៅតាមលក្ខខណ្ឌដែលគណបក្សនីមួយៗមានអសនៈនៅក្នុងរដ្ឋសភាជាតិ (ដូច្នេះ គណបក្សប្រជាជនកម្ពុជាបានទទួលការផ្សាយច្រើនជាងគេបង្អស់) នៅក្នុងកំឡុងពេលបោះឆ្នោតឃុំ/សង្កាត់ ២០០៧ កម្មវិធីត្រូវបានផ្សាយក្នុងរយៈពេល១៥នាទី បន្ទាប់ពីព័ត៌មានពេលយប់របស់ទូរទស្សន៍ ទទក ហើយរយៈពេលនៃការផ្សាយនោះមាន១៥ថ្ងៃ។ ការផ្សាយនេះមានរយៈពេល៤០នាទី ក្នុង១សប្តាហ៍សំរាប់បង្ហាញការងារថ្មីៗ ពីចន្លោះការបោះឆ្នោតឃុំ/សង្កាត់២០០៧ និងការបោះឆ្នោតជាតិ ២០០៨។ សូមមើលគេហទំព័រ http://www.equitycam.tv/

ដែលអាចមើលឃើញច្បាស់ទៅលើមាតិកានៃការផ្សព្វផ្សាយជាប្រក្រតីផ្សេងទៀតរបស់ **ទទក** នៅពេលវេលាសេសសល់តទៅទៀត។

ទោះបីជាទូរទស្សន៍ **ទទក** សំអាងថាមានសមភាពក៏ដោយ ក៏ទូរទស្សន៍នេះស្វែងរកវិធីដ៏ប៉ិនប្រសព្វជាងនេះ ដើម្បីធ្វើអោយទូរទស្សនិកជនដឹងអំពីភាពលំអៀងរបស់ខ្លួនផងដែរ។ ឧទាហរណ៍ នៅមុនពេលជិតបោះឆ្នោតជាតិឆ្នាំ២០០៣ **ទទក** បានបញ្ចាំងភាពយន្តមួយគឺ វាលពិឃាដជារៀងរាល់យប់ អស់រយះពេលមួយសប្តាហ៍ តាមមើលទៅនេះ គឺជាការខិតខំប្រឹងប្រែងដើម្បីរំឭកប្រជាពលរដ្ឋអំពីរបបប៉ុល ពត ដែលគណបក្សប្រជាជនកម្ពុជា (ឬអ្នកកាន់អំណាចមុន) អះអាងថាបានរំដោះប្រទេសជាតិចេញពីរបបនេះ[១០២]។

ស្ថានីយទូរទស្សន៍ "ឯកជន" ផ្សេងទៀត បានជំទាស់អស់រយៈពេលជាច្រើនឆ្នាំក្នុងការបង្ខំឱ្យលក់ម៉ោងផ្សាយទៅគណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយក្នុងអំឡុងយុទ្ធនាការរកសម្លេងឆ្នោតជាសកម្មភាពមួយ ដែលអាចនាំឱ្យខូចប្រយោជន៍ដល់គណបក្សដទៃច្រើនជាងគណបក្សប្រជាជនកម្ពុជា។ ហេតុផលដែលបានអះអាងចំពោះគោលនយោបាយនេះ គឺថាការផ្សព្វផ្សាយរបស់គណបក្សនយោបាយ គឺមិនសូវកាក់កបដូចការផ្សាយពាណិជ្ជកម្មធម្មតាទេ។ប៉ុន្តែឈានចូលមកដល់សម័យបោះឆ្នោតជាតិ២០០៣ ស្ថានីយទូរទស្សន៍ស្ទើរតែទាំងអស់លើកលែងតែស្ថានីយមួយ (ព្រមទាំង **ទទក** ផងដែរ) បានត្រៀមខ្លួនជាស្រេចដើម្បីផ្សាយការឃោសនាឱ្យគណបក្សប្រជាជនកម្ពុជាអំពី "ភាពយន្តឯកសារ" ក្នុងការការពារការផ្តួលរំលំគណបក្សហ៊ុនស៊ិនប៊ិចនៅក្នុងព្រឹត្តការណ៍មួយក្នុងឆ្នាំ១៩៩៧[១០៣]។

នៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ ២០០៧ ស្ថានីយទូរទស្សន៍ ស៊ីធីអិន បានផ្សព្វផ្សាយកម្មវិធីមួយដែលមានចំណងជើងថា "ទេពកោសល្យ និងសមិទ្ធផល" ដែលសម្ភាសន៍តែមេឃុំដែលជាសមាជិកគណបក្សប្រជាជនកម្ពុជា និងមន្ត្រីរដ្ឋាភិបាលនានានិយាយអំពីសមិទ្ធផលរបស់ខ្លួន។ សេចក្តី

[១០២] មាត្រា ១៩ អាដហុក និងមជ្ឈមណ្ឌលដើម្បីអប់រំច្បាប់ដល់សហគមន៍- សេរីភាពក្នុងការបញ្ចេញមតិ និងសារព័ត៌មាន ខែមិថុនា ២០០៦ ។

[១០៣] សេចក្តីថ្លែងការណ៍ដោយ Daniel Caligaert ជាសាស្ត្រាចារ្យការបោះឆ្នោតប្រជាធិបតេយ្យនៅកម្ពុជា នៃវិទ្យាស្ថានសាធារណអន្តរជាតិ នៅអនុគណៈកម្មការសភាអាមេរិក ស្តីពីអាស៊ី និង ប៉ាស៊ីហ្វិក-គណកម្មការទំនាក់ទំនងអន្តរជាតិនៃរដ្ឋសភា-ខែមិថុនា ២០០៣។ សូមអានផងដែរត្រង់ចំណុចរហូតមកដល់សម័យបោះឆ្នោត ជ្រើសរើសសភា ឆ្នាំ២០០៣ នៅកម្ពុជា: ការបញ្ចេញយោបល់នយោបាយ និងសេរីភាពក្នុងការប្រជុំក្រោមការវាយប្រហារ-អង្គការឃ្លាំមើលសិទ្ធិមនុស្ស-១២ មិថុនា ២០០៣ ។

វាយការណ៏នយោបាយរបស់ទូរទស្សន៍ស៊ីធីអិនជាទូទៅត្រូវបានពិពណ៌នាដោយក្រុមសង្កេតការណ៍បោះឆ្នោតមួយថា "មានភាពលំអៀងយ៉ាងខ្លាំង" ទៅខាងគណបក្សប្រជាជនកម្ពុជា[១០៤] ។

## វិទ្យុ

ម្ចាស់កម្មសិទ្ធិនៃស្ថានីយវិទ្យុ ក៏ត្រូវបានត្រួតត្រាដោយអ្នកដែលស្មោះត្រង់នឹងគណបក្សប្រជាជនកម្ពុជាផងដែរ ។ ប៉ុន្តែមានស្ថានីយវិទ្យុពីរដែលគេជឿជាក់ថាមានសម្ព័ន្ធភាពជាមួយគណបក្សប្រឆាំង សម រង្ស៊ី ហើយស្ថានីយពីរទៀតដែលមានម្ចាស់គ្រប់គ្រងមានភាពឯករាជ្យពីនយោបាយ ។

ខាងក្រោមនេះ គឺជាស្ថានីយជាតិសំខាន់ៗ ឬ មានមូលដ្ឋាននៅភ្នំពេញ (លើកលែងតែស្ថានីយតូចៗនៅតាមបណ្តាខេត្ត)៖

| ស្ថានីយ | រលកធាតុអាកាស (MHz) | ម្ចាស់/ ប្រធានគ្រប់គ្រង | ការមើលឃើញថាមានការលំអៀងផ្នែកនយោបាយ |
|---|---|---|---|
| **ស្ថានីយវិទ្យុAM** | | | |
| វិទ្យុជាតិ | AM 918 | ▪ វិទ្យុជាតិគ្រប់គ្រងដោយរដ្ឋ | គណបក្សប្រជាជនកម្ពុជា |
| **ស្ថានីយវិទ្យុ FM** | | | |
| Sweet FM 88 | FM 88 | ▪ លោក អេង សេដ្ឋា មូលី (សាច់ញាតិរបស់ អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក អៀងមូលី) ឬ សម្តេចនាយករដ្ឋមន្ត្រី/គណបក្សប្រជាជនកម្ពុជា[១០៥] ។ | គណបក្សប្រជាជនកម្ពុជា |
| សម្លេងជីវិតថ្មី FM | FM 89.5 | ▪ លោក តាំង វេកហុង | អាព្យាក្រិត្យភាព ក្នុងមាតិកា |

---

[១០៤] គណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ការវាយតម្លៃចុងក្រោយ និងរបាយការណ៍ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០០៧។

[១០៥] បច្ចុប្បន្ននេះមិនច្បាស់ថា នរណាជាម្ចាស់ទេ ។ ស្ថានីយនេះ ត្រូវបានស្ថាបនាដោយ អៀង មូលី ពេលគាត់ជារដ្ឋមន្ត្រីព័ត៌មាននៅទសវត្ស ១៩៩០ ហើយមានសម្ព័ន្ធភាពជាមួយនឹងគណបក្សប្រជាធិតេយ្យសេរីនិយមព្រះពុទ្ធសាសនា។ ឆ្នាំ២០០៣ ត្រូវបានរាយការណ៍ថាស្ថានីយនេះត្រូវបានលក់ឱ្យ ហ៊ុន សែន។ សូមអាន "ការលក់វិទ្យុត្រូវបានរឹតចំណងគណបក្សប្រជាជនកម្ពុជាកាន់កាប់រលកធាតុអាកាស" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ខែវិច្ឆិកា ៧-២០ ឆ្នាំ២០០៣។

| | | | |
|---|---|---|---|
| (វិទ្យុគ្រិស្តសាសនា) | | | |
| FM 90 | FM 90 | ▪ ហ៊្វុនស៊ិនប៉ិច | ហ៊្វុនស៊ិនប៉ិច |
| តាព្រហ្ម FM | FM 90.5 | ▪ ពីមុនឮថាចេញអាជ្ញាប័ណ្ណឱ្យសមាជិកសភាហ៊្វុនស៊ិនប៉ិច លោក អៀ លឹមសួរ [១០៦] | ហ៊្វុនស៊ិនប៉ិច |
| វិទ្យុបារាំងអន្តរជាតិ ស្ថានីយផ្សាយបន្ត | FM 92 | ▪ វិទ្យុបារាំងអន្តរជាតិ | អព្យាក្រិត្យ |
| FM 93.5 | FM 93.5 | ▪ អតីតសម្ព័ន្ធភាពគណបក្សប្រជាធិបតេយ្យសេរី និយមព្រះពុទ្ធសាសនា ម្ចាស់បច្ចុប្បន្នមិនច្បាស់ ប៉ុន្តែគេជឿជាក់ថាមានទំនោរទៅខាង សមរង្ស៊ី | គណបក្ស សម រង្ស៊ី |
| បាយ័ន FM | FM 95 | ▪ តាមរបាយការណ៍បានឱ្យដឹងថា (ជាមួយនឹងទូរទស្សន៍បាយ័ន) ហើយម្ចាស់គឺគ្រួសាររបស់សម្តេច នាយករដ្ឋមន្ត្រី។ អគ្គនាយក គឺកូនស្រីរបស់សម្តេច | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុជាតិ FM | FM 96 | ▪ វិទ្យុគ្រប់គ្រងដោយរដ្ឋ | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុអប្សរា FM | FM97 | ▪ មិនប្រាប់ឈ្មោះម្ចាស់ ប៉ុន្តែជាទូទៅគេជឿជាក់ថាជារបស់គណបក្សប្រជាជនកម្ពុជា។ គ្រប់គ្រងដោយ លោក សុខ ឮសាន្ត សមាជិកគណៈកម្មការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា | គណបក្សប្រជាជនកម្ពុជា |

[១០៦] ពីមុនស្ថានីយនេះត្រូវបានគ្រប់គ្រងដោយ ណូរ៉ាណារឹទ្ធ អាណាន់ដាយ៉ាត ដែលកាលនោះគឺជា សមាជិកគណៈកម្មការនាយក និងជាប្រធានខុទ្ទកាល័យសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ។ នៅពេលដែល នរោត្តម រណឫទ្ធិ ត្រូវបានទម្លាក់ពីតំណែងប្រធានគណបក្ស កាលពីខែតុលា ២០០៦ ក៏មានរដ្ឋប្រហារយ៉ាងមានប្រសិទ្ធិភាពនៅឯស្ថានីយនេះដែរ ហើយនៅតែស្ថិតក្នុងដៃគណបក្សហ៊្វុនស៊ិនប៉ិចដដែល ខណៈដែលទ្រង់ រណឫទ្ធិ ចាកចេញដើម្បីបង្កើតគណបក្សថ្មី។ សូមអានត្រង់ចំណុចសម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជាប្រកាសបន្ទាន់ ២៣ តុលា ២០០៦ ដែលមាននៅក្នុងវែបសាយ http://www.licadho.org/press/files/132AFECUAStaffremovalRadioTaProhm06.pdf

| | | | |
|---|---|---|---|
| វិទ្យុសេចក្តីស្រឡាញ់ FM (ស្ថានីយចម្រៀងប្រជាប្រិយ) | FM 97.5 | ▪ ម្ចាស់ពីរគឺសាលាក្រុងភ្នំពេញ និងក្រុមហ៊ុន KCS Cambodia | អព្យាក្រិត្យ |
| វិទ្យុ FM យោធា | FM 98 | ▪ ម្ចាស់ពីរគឺក្រសួងការពារជាតិ និងក្រុមហ៊ុនថៃ។ គ្រប់គ្រងដោយលោក អានុចា វ៉ាចារ៉ាត់ ថាងកា ។ | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុ FM 99 | FM 99 | ▪ អគ្គនាយកឈ្មោះលោក គឹម បឿន។ មិនច្បាស់ថា អ្នកណាជាម្ចាស់ពិតប្រាកដ[១០៧] ។ | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុគ្រួសារ FM | FM99.5 | ▪ ក្រុមហ៊ុនផ្សាយសម្លេងចុងបូព៌ា កម្ពុជា | វិទ្យុគ្រិស្តសាសនា (អព្យាក្រិត្យ) |
| ស្ថានីយផ្សាយបន្ត BBC | FM 100 | ▪ សារជីវកម្មផ្សាយសម្លេងអង់គ្លេស | អព្យាក្រិត្យ |
| ស្ថានីយផ្សាយបន្ត ABC | FM 101.5 | ▪ សារជីវកម្មផ្សាយសម្លេងអូស្ត្រាលី | អព្យាក្រិត្យ |
| វិទ្យុសម្លេងស្ត្រី FM | FM 102 | ▪ ម្ចាស់ និងគ្រប់គ្រងដោយអង្គការមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា | អព្យាក្រិត្យ |
| វិទ្យុភ្នំពេញ FM | FM 103 | ▪ ម្ចាស់ពីរគឺមន្ទីរព័ត៌មាននៃសាលាក្រុងភ្នំពេញ និងក្រុមហ៊ុន KCS Cambodia | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុសុវណ្ណភូមិ FM | FM 104 | ▪ មិនដឹង | គណបក្ស សម រង្ស៊ី |
| សម្បុកឃ្មុំ FM | FM 105 | ▪ លោក ម៉ម សូណង់ដូ | អព្យាក្រិត |
| វិទ្យុអាស៊ីអាគ្នេយ៍ FM | FM 106 | ▪ ឯកឧត្តម កៅ គឹមហួន រដ្ឋលេខាធិការគណបក្សប្រជាជនកម្ពុជា | គណបក្សប្រជាជនកម្ពុជា |
| វិទ្យុខ្មែរ | FM 107 | ▪ ឯកឧត្តម យុន ហាំង រដ្ឋមន្ត្រីក្រសួងធម្មការនិង សាសនា គ្រប់គ្រងដោយ | គណបក្សប្រជាជនកម្ពុជា និងហ៊ុនស៊ីនប៊ិច ។ |

---

[១០៧] ទំព័រលឿង កម្ពុជា អាសយដ្ឋានរបស់វិទ្យុ ៩៩ និងអាសយដ្ឋានរបស់វិទ្យុ និងទូរទស្សន៍អប្សរានៅជាមួយគ្នា។ សូមមើលវែបសាយ http://www.yellowpages-cambodia.com/media/television-and-radio-stations/

| | | | |
|---|---|---|---|
| | | យុន អេឡៃណា។ | |

ម្ចាស់ស្ថានីយវិទ្យុជាច្រើន មានសម្ព័ន្ធភាពជាមួយគណបក្សនយោបាយ ហើយការផ្សាយរបស់ពួកគេឆ្លុះបញ្ចាំងឱ្យឃើញនូវភាពលំអៀង។ ស្ថានីយវិទ្យុជាតិដែលជារបស់រដ្ឋ គាំទ្ររដ្ឋាភិបាល និងមាតិគណបក្សប្រជាជនកម្ពុជាដែលមានការផ្សាយទស្សនៈជំទាស់បានតិចតួច។ ស្ថានីយវិទ្យុបាយ័ន និងអប្សរាជាឧបករណ៍បំពងសម្លេងរបស់គណបក្សប្រជាជនកម្ពុជា នៅតាមរលកធាតុអាកាស ដូចជាដៃគូរបស់គេគឺទូរទស្សន៍បាយ័ន និងអប្សរាដែរ។ ស្ថានីយវិទ្យុខ្លះទៀតគឺមាន "ភាពអព្យាក្រិត្យ" ផ្នែកនយោបាយយ៉ាងធំធេងដោយចាក់ផ្សាយតែចម្រៀង ឬ កម្មវិធីកំសាន្តនានា ប៉ុន្តែស្ថានីយទាំងនោះ ក៏មានភក្តីភាពចំពោះគណបក្សប្រជាជនកម្ពុជាដែរ។ ស្ថានីយទាំងនេះប្រហែលជាមិនផ្សព្វផ្សាយពីការលើកតំកើង គណបក្សកាន់អំណាចទេ ក៏ប៉ុន្តែក៏មិនបានផ្តល់នូវវេទិកាសម្រាប់ព័ត៌មាន ឬ ទស្សនៈឯករាជ្យដែរ។

ទោះជាយ៉ាងណាក៏ដោយ ក៏មានទស្សនៈនយោបាយជាច្រើន ហើយមានព័ត៌មានឯករាជ្យខ្លះដែលអ្នកស្តាប់វិទ្យុអាចរកបាន។ បញ្ហានេះមិនបានឆ្លុះបញ្ចាំងនូវឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការបើករលកធាតុអាកាសអោយបានទូលាយទេ។ ជាការពិត រដ្ឋាភិបាលជានិច្ចកាលតែងតែរកមធ្យោបាយដើម្បីមិនចង់បើករលកធាតុអាកាសឱ្យបានទូលំទូលាយទេ ច្រើនតែបដិសេធមិនផ្តល់អាជ្ញាប័ណ្ណវិទ្យុទៅជនណាដែលរដ្ឋាភិបាលចាត់ទុកថាមិនគាំទ្រគណបក្សកាន់អំណាច ជាពិសេសគណបក្សប្រឆាំង និងអង្គការមិនមែនរដ្ឋាភិបាល។

ជាច្រើនដង ការគ្រប់គ្រងរលកធាតុអាកាសត្រូវបានកំណត់ឡើងតាមរយៈមធ្យោបាយដ៏ម៉ឺងម៉ាត់ជាងមុន។ នៅសម័យដែលមានភាពតានតឹងខ្លាំងផ្នែកនយោបាយ ស្ថានីយវិទ្យុដែលគ្រប់គ្រងដោយហ៊ុន-ស៊ីនប៊ុិចពីរត្រូវបានរឹបអូសយកដោយប្រើអាវុធ ហើយអ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់នៅក្នុងស្ថានីយមួយត្រូវបានធ្វើឃាដ ក្នុងករណីដែលគេជឿជាក់ជាទូទៅថា ជាការសម្លាប់ដែលមានការពាក់ព័ន្ធផ្នែកនយោបាយ (Political killing)។ វិទ្យុសម្បុកឃ្មុំដែលជាសម្លេងឯករាជ្យ និងឆ្នើមជាងគេបំផុតនៅលើរលកធាតុអាកាសកម្ពុជា ក៏ត្រូវបានបិទហើយម្ចាស់វិទ្យុនេះត្រូវបានជាប់ពន្ធនាគារពីរដង ។

ពីដើមហ៊ុនស៊ីនប៊ុិច ទទួលបានអាជ្ញាប័ណ្ណសម្រាប់ស្ថានីយវិទ្យុពីររបស់ខ្លួន (FM 90 និង FM 90.5 ក្រោយមកគេស្គាល់ថាជាវិទ្យុតាព្រហ្ម)[១០៨] តាមរយៈតំណែងជាដៃគូក្នុងរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជា។ ជាទំលាប់ស្ថានីយទាំងពីររបស់ហ៊ុនស៊ីនប៊ុិចក្លាយទៅជាអសកម្ម ហើយមានទំនោរទៅរក

[១០៨] គេជឿថា ការចេញអាជ្ញាប័ណ្ណ ស្ថានីយទាំងពីរនេះ គឺឱ្យទៅបុគ្គលជាម្ចាស់នៅក្នុងគណបក្សហ៊ុនស៊ីនប៊ុិច ពុំមែនអោយទៅគណបក្សទេ។

គណបក្សប្រជាជនកម្ពុជា លើកលែងតែក្នុងខណៈពេលដែលទំនាក់ទំនងរវាងគណបក្សទាំងពីរនេះបានកើតជាបញ្ហាធំៗជាមួយគ្នា ។

ស្ថានីយវិទ្យុ FM 90 ស្ថាបនាឡើងនៅដើមទសវត្ស១៩៩0 ពុំបានធ្វើការរិះគន់ដល់គណបក្សប្រជាជនកម្ពុជាទេ អស់រយៈពេលយ៉ាងយូរ ចាប់តាំងពីកកើតរបស់ខ្លួនមករហូតដល់មុនព្រឹត្តការណ៍ឆ្នាំ១៩៩៧។ ក្នុងអំឡុងព្រឹត្តការណ៍ ១៩៩៧ នេះ ស្ថានីយ៍ FM90 (ព្រមទាំងទូរទស្សន៍គណបក្សហ៊្វុនស៊ីនប៉ិចប៉ុស្តិ៍លេខ៩) ត្រូវបានរឹបអូស និងលួចយកទ្រព្យសម្បត្តិដោយកងកម្លាំងប្រដាប់អាវុធ[១០៩] ។ ត្រូវចំណាយពេលអស់ជាច្រើនខែមុននឹងប្រគល់មកឱ្យគណបក្សហ៊្វុនស៊ីនប៉ិច ធ្វើការគ្រប់គ្រង និងបន្តដំណើរការឡើងវិញ។ ស្ថានីយនេះនៅតែមិនប្រឈមមុខដាក់គណបក្សប្រជាជនកម្ពុជាដដែល បច្ចុប្បន្ននេះថ្វីត្បិតតែអ្នកខ្លះនិយាយថាការផ្សាយព័ត៌មានរបស់វិទ្យុនេះមានភាពតុល្យភាពជាងមុន និង បញ្ចូលទស្សនៈប្លែកៗជាច្រើនក៏ដោយ ។

ស្ថានីយវិទ្យុតាព្រហ្មដែលត្រូវបានស្ថាបនាឡើងប្រហែលក្នុងឆ្នាំ២00១ បន្ទាប់ពីស្ថានីយវិទ្យុFM 90 ក៏មានប្រវត្តិប្រហាក់ប្រហែលគ្នាដែរ ។ ក្នុងអំឡុងជាប់គាំងផ្នែកនយោបាយដ៏តានតឹងក្រោយការបោះឆ្នោតជាតិឆ្នាំ២00៣ ពេលដែលស្ថានីយនេះបានបើកយុទ្ធនាការផ្សាយប្រឆាំងជាមួយគណបក្សប្រជាជនកម្ពុជា និងមេដឹកនាំគណបក្សប្រជាជនកម្ពុជា បណ្ណាធិការជាន់ខ្ពស់ម្នាក់ លោក ជូ ជេដ្ឋារីទ្ធ ត្រូវបានធ្វើឃាដនៅខាងក្រៅការិយាល័យស្ថានីយវិទ្យុ ។ ក្រោយមក ស្ថានីយនេះត្រឡប់ទៅជាគាំទ្រមាគ៌ា នយោបាយរបស់រដ្ឋាភិបាលយ៉ាងសកម្ម ក្រោយពីហ៊្វុនស៊ីនប៉ិចចូលរួមក្នុងរដ្ឋាភិបាលចម្រុះជាថ្មីម្តងទៀតជាមួយគណបក្សប្រជាជនកម្ពុជា។

នៅចុងឆ្នាំ២00៦ ខណៈដែលទំនាក់ទំនងរវាងប្រធានគណបក្សសម្តេចក្រុមព្រះ និងសម្តេច នាយករដ្ឋមន្ត្រី បានប្រែក្លាយកាន់តែខ្លាំងឡើងម្តងទៀត ការផ្សាយរបស់ស្ថានីយវិទ្យុតាព្រហ្មក៏កាន់ តែប្រឆាំងគណបក្សប្រជាជនកម្ពុជាខ្លាំងឡើងៗដែរ ។ នៅខែតុលា គណបក្សហ៊្វុនស៊ីនប៉ិចត្រូវបែកបាក់ដោយជម្លោះផ្ទៃក្នុងដែលគេជឿជាក់ថាប្រហែលជាអាចត្រូវបានរៀបចំដោយគណបក្សប្រជាជនកម្ពុជាដែលនាំឱ្យមានការដកសម្តេចក្រុមព្រះពីតំណែងប្រធានគណបក្ស ។ នៅថ្ងៃដែលគេដកសម្តេចក្រុមព្រះចេញពីតំណែង កងអង្គរក្សប្រដាប់ដោយអាវុធរបស់អគ្គលេខាធិការរបស់គណបក្សហ៊្វុនស៊ីនប៉ិចបានត្រួតត្រាស្ថានីយនេះ ។ គេ

[១០៩] របាយការណ៍របស់តំណាងពិសេស នៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ស្តីការទទួលបានសារព័ត៌មាន ២៥ មិថុនា ១៩៩៨ http://cambodia.ohchr.org/download.aspx?ep_id=120 ។

បានចោទដោយគ្មានភស្តុតាងថា ពួកគេបានបង្ខំនាយកស្ថានីយដោយភ្ជង់កាំភ្លើង ជាមនុស្សដែលស្និទ្ធជាមួយនឹងសម្តេចក្រុមព្រះឈ្មោះ ណូរ៉ាណារីទ្ធ អាណាន់ដាយ៉ាត ឱ្យផ្សាយអំពីការទម្លាក់សម្តេចក្រុមព្រះ។ គាត់បានបដិសេធ ហើយបានគេចខ្លួនជាមួយបុគ្គលិកផ្សេងទៀតចេញពីស្ថានីយ[១១០] ។ បច្ចុប្បន្ននេះស្ថានីយនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកអគ្គលេខាធិការ និងគណបក្សហ៊្វុនស៊ីនប៉ិច ហើយទំនោរទៅរកគណបក្សប្រជាជនកម្ពុជា ។

អតីតគណបក្សប្រជាធិតេយ្យសេរីនិយមព្រះពុទ្ធសាសនា បានទទួលអាជ្ញាប័ណ្ណមួយសម្រាប់ស្ថានីយវិទ្យុ（FM 88）នៅដើមទសវត្ស ១៩៩០ នៅពេលដែលខ្លួនជាផ្នែកមួយនៃរដ្ឋាភិបាលចម្រុះ ហើយមន្ត្រីជាន់ខ្ពស់នៃគណបក្សនេះ លោក អៀង មូលី ជាអតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន។（អាជ្ញាប័ណ្ណនេះឮគេថាបានចេញឱ្យឈ្មោះបុគ្គលម្នាក់ដែលជាសាច់ញាតិរបស់លោក）ក្រោយពីលោក អៀង មូលី បានបំបែកខ្លួនចេញពីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនានៅឆ្នាំ១៩៩៥ ហើយបង្កើតគណបក្សមួយដែលជិតស្និទជាមួយនឹងគណបក្សប្រជាជនកម្ពុជា ពេលនោះការចំណាយរបស់ស្ថានីយវិទ្យុត្រូវបានសម្តេចនាយករដ្ឋមន្ត្រីជួយចេញមួយផ្នែក។ នៅឆ្នាំ២០០៣ គេបានរាយការណ៍ថាស្ថានីយនេះត្រូវបានលក់ឱ្យសម្តេចនាយករដ្ឋមន្ត្រីទាំងស្រុង[១១១] ។ សព្វថ្ងៃស្ថានីយនេះគាំទ្រគណបក្សប្រជាជនកម្ពុជា។

ក្រោយពីការបែកបាក់របស់គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ក្រុមសម្តេច ស៊ីន សាន បានចាប់ផ្តើមការផ្សាយស្ថានីយវិទ្យុមួយទៀតគឺ（FM 93.5）នៅដើមឆ្នាំ១៩៩៧ ទោះបីក្រសួងព័ត៌មានបានព្យាយាមបិទវិទ្យុនេះជាច្រើនលើកច្រើនសារក៏ដោយ។ ក្នុងអំឡុងព្រឹត្តការណ៍ឆ្នាំ១៩៩៧ ស្ថានីយវិទ្យុនេះ ក៏ដូចស្ថានីយវិទ្យុហ៊្វុនស៊ីនប៉ិចដែរត្រូវបានគេលួចប្លន់ទ្រព្យសម្បត្តិ។ ក្រោយមក ត្រូវបានផ្តល់អាជ្ញាប័ណ្ណមួយទៀតដោយដាក់ឈ្មោះបុគ្គលម្នាក់ជាសមាជិក ដែលមានទំនាក់ទំនងជាមួយគណបក្សប្រជាធិតេយ្យសេរីនិយមព្រះពុទ្ធសាសនា ប៉ុន្តែមិនបានបន្តការផ្សាយទេអាស្រ័យដោយកង្វះមូលនិធិ[១១២] ។

---

[១១០] សម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។ ការប្រកាសអាសន្ន ២៣ តុលា ២០០៦។ អាចរកមាននៅវែបសាយ http://www.licadho.org/press/files/132AFECUAStaffRemovalRadioTaProhm06.pdf

[១១១] សូមអាន "ការទិញអាជ្ញាប័ណ្ណវិទ្យុត្រូវបានរឹតបណ្តឹងគណបក្សប្រជាជនកម្ពុជាកាន់កាប់រលកធាតុអាកាស"។ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ៧ -២០ វិច្ឆិកា ២០០៣ ។

[១១២] របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ស្តីពីការទទួលបានព័ត៌មាន ២៥ មិថុនា ១៩៩៨ http://cambodia.ohchr.org/download.aspx?ep_id=120

គណបក្សប្រឆាំង សម រង្ស៊ី (និងគណបក្សមុនដែលមានឈ្មោះ គណបក្សជាតិខ្មែរ) ត្រូវបានបដិសេធជាច្រើនដងក្នុងការស្នើសុំអាជ្ញាប័ណ្ណស្ថានីយវិទ្យុតាំងពីឆ្នាំ១៩៩៦។ ប៉ុន្តែគណបក្សនេះ បានរកឃើញទីផ្សារវិទ្យុដើម្បីឱ្យស្ថានីយវិទ្យុ FM 93.5 រស់ឡើងវិញ ដែលពីមុនគឺជាស្ថានីយវិទ្យុរបស់មន្ត្រីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាដែលលែងមានទៀតហើយនៅឆ្នាំ២០០៣។ វានៅមិនច្បាស់ថាតើកិច្ចការនេះកើតឡើងដោយរបៀបណា ? ប៉ុន្តែតាមប្រភពខ្លះពន្យល់ថា អាជ្ញាប័ណ្ណស្ថានីយវិទ្យុនេះត្រូវបានលក់ ឬ ជួលឱ្យអ្នកគាំទ្រគណបក្ស សម រង្ស៊ី ដែលជាអតីតមន្ត្រីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា។ ស្ថានីយនេះក៏ត្រូវបានគេនិយាយថា បានទទួលផលចំណេញជាឧបករណ៍ និងធនធានផ្សេងទៀត ពីការហូរចូលនូវមូលនិធិពីវិទ្យាស្ថានសាធារណៈអន្តរជាតិដែលប្រភពមូលនិធិមកពីរដ្ឋាភិបាលសហរដ្ឋអាមេរិក។ ស្ថានីយវិទ្យុ FM 93.5 គឺជាស្ថានីយដែលគេជឿជាក់ថាមានទំនោរទៅរកគណបក្ស សម រង្ស៊ី ក្នុងមាតិការបស់ខ្លួន ទោះបីជាអ្នកសង្កេតការណ៍មួយចំនួននិយាយថា កាលពីដើមបានខិតខំធ្វើឱ្យមានតុល្យភាព ហើយមិនលំអៀងនៅក្នុងសេចក្តីរាយការណ៍ ព័ត៌មានរបស់ខ្លួនក៏ដោយ។ បច្ចុប្បន្ននេះ ស្ថានីយនេះមានព័ត៌មានខ្លួនឯងតិចតួច ហើយភាគច្រើនជួលម៉ោងផ្សាយឱ្យអង្គការមិនមែនរដ្ឋាភិបាល។ (ម្ចាស់វិទ្យុ FM 104 ដែលមានចំណែកទីតាំងនៅក្នុងស្ថានីយវិទ្យុ ៩៣.៥ ដែរ [១១៣] នេះគឺជាបញ្ហាមិនច្បាស់ ប៉ុន្តែគេក៏បានចាត់ទុកថាជាស្ថានីយមួយដែលគាំទ្រគណបក្ស សម រង្ស៊ី ដែរ)។

ដូចដែលបានធ្វើការកត់សម្គាល់មកពីខាងលើនៃរបាយការណ៍នេះ ដែលគេតែងតែនិយាយថា មានតែស្ថានីយវិទ្យុពីរទេ ដែលមានភាពជាឯករាជ្យ ស្ថានីយវិទ្យុពីរដែលកំពុងផ្សាយព័ត៌មានបែបដំណឹង និងយោបល់តែមួយគត់ក្នុងប្រទេសកម្ពុជានោះ គឺមានវិទ្យុ FM 102 គ្រប់គ្រងដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និង FM 105 ហៅថា វិទ្យុសម្បុកឃ្មុំ។

វិទ្យុFM102 ដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល បានចាប់ផ្តើមនៅឆ្នាំ១៩៩៩ ហើយភាគច្រើនទទួលបានប្រាក់ជំនួយបរទេសរួមមានពីសហរដ្ឋអាមេរិក អូស្ត្រាលី និងអង់គ្លេស។ ស្ថានីយវិទ្យុនេះផ្សាយជាសំខាន់អំពីឯកសារព័ត៌មាន និងបញ្ហាអប់រំអំពីបញ្ហាសង្គម ជាពិសេសបញ្ហានានាដែលប៉ះពាល់ដល់ស្ត្រី។ នេះគឺជាអង្គការមិនមែនរដ្ឋាភិបាលតែមួយគត់នៅកម្ពុជាដែលមានស្ថានីយវិទ្យុផ្ទាល់ខ្លួន ទោះបីស្ថានីយនេះ (ជាមួយនឹងស្ថានីយផ្សេងទៀត) បានជួលម៉ោងផ្សាយឱ្យអង្គការមិនមែនរដ្ឋាភិបាលនានាក៏ដោយ។ មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជាច្រើនផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូររបស់ស្ត្រីនៅក្នុង

[១១៣] FM 104 ចុះបញ្ជីនៅក្នុងទំព័រលឿងកម្ពុជា មានអាសយដ្ឋាននៅជាមួយ FM 93.5 ដែរ ។

សង្គមមិនមែននយោបាយទេ ពិតមែនហើយដែលបញ្ហាទាំងនេះបានជួយឱ្យអង្គការនេះទទួលអាជ្ញាប័ណ្ណស្ថានីយវិទ្យុ។ សហនាយកស្ថានីយនេះ ឈ្មោះលោកស្រី ទីវ សារ៉ាយ៉េត ដែលពីមុនធ្វើការនៅក្រសួងព័ត៌មាន និងជាមិត្តភក្ដិជាមួយរដ្ឋមន្ត្រីក្រសួងព័ត៌មាន ប្រហែលជាបានជួយក្នុងការទទួលបានអាជ្ញាប័ណ្ណផងដែរ។

វិទ្យុ FM105 ឬសម្បុកឃ្មុំ គឺជាស្ថានីយដែលស្គាល់ថាបានផ្សព្វផ្សាយទស្សនៈរិះគន់រដ្ឋាភិបាល។ ម្ចាស់វិទ្យុនេះឈ្មោះលោក ម៉ម សូណង់ដូ ជាពាណិជ្ជករខ្មែរ-បារាំងម្នាក់ ដែលធ្លាប់រស់នៅប្រទេសបារាំងអស់រយៈពេល៣០ឆ្នាំ ហើយធ្លាប់បើកហាងឱស្ថនៅក្រុងប៉ារីស គឺមិនទំនងជាបុគ្គលនៅក្នុងពិភពវិទ្យុកម្ពុជា។ លោកត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៩៤ ហើយ២ឆ្នាំក្រោយមកបានបង្កើតស្ថានីយវិទ្យុនេះ ហើយក្រោយមក លោកបានប្រើវិទ្យុនេះដើម្បីផ្សព្វផ្សាយគណបក្សរបស់លោកដែលឥឡូវលែងមានទៀតហើយ គឺគណបក្សសម្បុកឃ្មុំដែលធ្លាប់បានចូលរួមបោះឆ្នោតជាតិនៅឆ្នាំ១៩៩៨ ។ បច្ចុប្បន្ននេះ វិទ្យុសម្បុកឃ្មុំគឺជាស្ថានីយដែលចាត់ទុកថាគ្មានលំអៀងដោយមិនគាំទ្រគណបក្សនយោបាយណាមួយឡើយ។ ក៏ប៉ុន្តែ តាមទស្សនៈរដ្ឋាភិបាលវិទ្យុនេះគឺប្រឆាំងរដ្ឋាភិបាលទេ (ហើយប្រហែលជាអ្នកស្ដាប់ជាច្រើនបើកស្ដាប់ដោយសារហេតុផលនេះហើយមើលទៅ)។ លោក ម៉ម សូណង់ដូ ច្រើនតែឧទ្ទេសនាមខ្លួនលោកថាឯករាជ្យ ប៉ុន្តែមិនអព្យាក្រឹត្យពីព្រោះលោក "លំអៀង" ទៅខាងប្រជាជនកម្ពុជា។ អស់រយៈពេលជាច្រើនឆ្នាំ លោកគឺជាអ្នករិះគន់ដោយវោហាចំពោះគណបក្សកាន់អំណាច ហើយពេលខ្លះក៏រិះគន់គណបក្ស សម រង្ស៊ី និងគណបក្សដទៃៗទៀតផងដែរ។ ថ្មីៗនេះលោកបានព្យាយាមធ្វើយុទ្ធនាការ ដើម្បីប្រមូលគណបក្សនយោបាយទាំងឡាយ ក្រៅពីគណបក្សប្រជាជនកម្ពុជា ឱ្យរួមគ្នាទៅជាកម្លាំងប្រឆាំងតែមួយ ដើម្បីប្រកួតជាមួយគណបក្សប្រជាជនកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធិភាពនៅក្នុងការបោះឆ្នោតជាតិ ឆ្នាំ២០០៨ ខាងមុខនេះ។

តាមសាច់រឿងរបស់លោក លោក ម៉ម សូណង់ដូ ទទួលបានអាជ្ញាប័ណ្ណស្ថានីយវិទ្យុដោយសំណាងនិងទំនាក់ទំនងផ្ទាល់ខ្លួន។ អតីតរដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក អៀង មូលី មកពីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាគឺជាមិត្តភ័ក្តចាស់របស់ លោក ម៉ម សូណង់ដូ នៅប្រទេសបារាំង។ អាជ្ញាប័ណ្ណត្រូវបានចេញនៅឆ្នាំ១៩៩៥ ខណៈដែលលោក មូលី កំពុងតែបំបែកបក្សចេញពីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា



លោក ម៉ម សូណង់ដូ ត្រូវបាននាំខ្លួនទៅតុលាការក្នុងកំឡុងពេលឃុំខ្លួនលើកទី២

ដើម្បីបង្កើតគណបក្សដែលជាសម្ព័ន្ធមិត្តជាមួយគណបក្សប្រជាជនកម្ពុជា។ ហើយ "បញ្ហានេះត្រូវបានគេជឿជាក់ថា គណបក្សប្រជាជនកម្ពុជា ជាអ្នកផ្តល់អាជ្ញាប័ណ្ណឱ្យលោកសូណង់ដូ ក្នុងការស្មានមើលទៅថាលោកអាចគាំទ្រនូវបុព្វហេតុរបស់គណបក្សប្រជាជនកម្ពុជា"។ អាជ្ញាប័ណ្ណនេះ ជាដំបូង គឺផ្តល់ឱ្យសមាគមកម្ពុជាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលលោក សូណង់ដូ បានបង្កើតឡើង។ លោក សូណង់ដូ មានប្រសាសន៍ថា គោលបំណងរបស់លោកមុនដំបូងជាមួយនឹងស្ថានីយវិទ្យុគឺដើម្បីតែចាក់ផ្សាយបទចម្រៀងតែប៉ុណ្ណោះហើយ "នាំមកនូវការកំសាន្តដល់ប្រជាពលរដ្ឋកម្ពុជា" ប៉ុន្តែក្រោយមកចាប់ពីខែសីហា ឆ្នាំ១៩៩៦ លោកបានប្តូរសម្លេង[១១៤]។

នៅក្នុងខែឧសភា ១៩៩៧ សម្បុកឃ្មុំត្រូវបានគេរុះរកកាយ និងលួចយកទ្រព្យសម្បត្តិដោយហ្វូងមនុស្សស្លៀកពាក់ឯកសណ្ឋាន នគរបាល និងយោធា។ ក្នុងឆ្នាំ១៩៩៨ ចំពេលមានមហាបាតុកម្មក្រោយពីការបោះឆ្នោតជាតិដែលគណបក្សសម្បុកឃ្មុំរបស់លោក សូណង់ដូ មិនបានទទួលជោគជ័យនៅក្នុងការប្រកួត រដ្ឋាភិបាលបានផ្អាកអាជ្ញាប័ណ្ណរបស់សម្បុកឃ្មុំ ហើយលោក សូណង់ដូ បានគេចខ្លួនទៅប្រទេសថៃ។ ស្ថានីយនេះបានបន្តការផ្សាយឡើងវិញនៅឆ្នាំ១៩៩៩ ហើយលោក សូណង់ដូ ក៏បានបិទគណបក្សរបស់លោកចោលដើម្បីផ្តោតលើការផ្សាយតែមួយគត់។ លោក សូណង់ដូ ធ្លាប់បានជាប់ពន្ធនាគារពីរដង លើកទី១ ក្រោមការចោទប្រកាន់ ថាបានញុះញង់ឱ្យមានកុប្បកម្មប្រឆាំងថៃនៅទីក្រុងភ្នំពេញកាលពីឆ្នាំ២០០៣ ហើយលើកទីពីរ ក្នុងរយៈពេល២ឆ្នាំក្រោយមក ក្រោមការចោទប្រកាន់ថាបានផ្សាយការសម្ភាសន៍មួយជាមួយនឹងសកម្មជនដែលជាអ្នករិះគន់សន្ធិសញ្ញាព្រំដែនថ្មីរវាងកម្ពុជា និងវៀតណាម។ ក្នុងករណីទាំងពីរនេះគ្មានភស្តុតាងណាមួយ ដែលអាចគួរឱ្យជឿបានដើម្បីចោទប្រកាន់មកលើលោកឡើយ ហើយបទព្រហ្មទណ្ឌដែលចោទមកលើលោកត្រូវបានមតិរិះគន់ជាច្រើនថាជាការវាយប្រហាររបស់រដ្ឋាភិបាលទៅលើសេរីភាពក្នុងការបញ្ចេញមតិ។

បច្ចុប្បន្ននេះ តាមរបាយការណ៍បានឱ្យដឹងថា សម្បុកឃ្មុំគឺជាស្ថានីយវិទ្យុមួយដែលមានប្រជាប្រិយភាពខ្លាំងជាងគេក្នុងប្រទេស ហើយជាយន្តការមួយដ៏សំខាន់សម្រាប់ព័ត៌មានឯករាជ្យ និងការពិភាក្សានយោបាយ។ នៅក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតក្នុងខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះ លោកសូណង់ដូបានលក់ម៉ោងផ្សាយឱ្យទៅគណបក្សប្រឆាំងផ្សេងៗរួមមាន គណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តម រណឫទ្ធិ ដើម្បីផ្សាយកម្មវិធីរយៈពេលមួយម៉ោងរៀងរាល់ថ្ងៃអំពីកម្មវិធីរបស់គណបក្ស

[១១៤] ព័ត៌មានអំពីការស្ថាបនា និងអាជ្ញាប័ណ្ណរបស់វិទ្យុសម្បុកឃ្មុំបានដកស្រង់ចេញពីមាត្រា ១៩-អង្គការអាដហុក និងមជ្ឈមណ្ឌលកម្ពុជា ដើម្បីអប់រំច្បាប់ សេរីភាពក្នុងការបញ្ចេញមតិ និងសារព័ត៌មាន ខែមិថុនា ២០០៦ ។ " ឱស្ថរបស់ ម៉ម សូណង់ដូ- ភ្នំពេញប៉ុស្តិ៍ ២៩ មិថុនា ដល់ ១២ កក្កដា ២០០៧ ។ វែបសាយរបស់វិទ្យុសម្បុកឃ្មុំ (http://www.sbk.com.kh/pages/history.htm)

នោះផ្ទាល់។ នេះគឺជាគំនិតដើម្បីឱ្យគណបក្សទាំងនេះបានបង្ហាញនូវកម្មវិធីនយោបាយរបស់ពួកគេទោះបីនៅពេលខ្លះគណបក្សទាំងនោះបានប្រើប្រាស់រលកធាតុអាកាស ដើម្បីវាយប្រហារគ្នាទៅវិញទៅមកក៏ដោយ។ មានការត្រួតពិនិត្យមួយដែលកម្រនឹងធ្វើកាលពីខែតុលា ២០០៧ លោក សូណង់ដូ បានផ្អាកការផ្សាយរបស់គណបក្សនរោត្តម រណឫទ្ធិ អស់រយៈពេលបីថ្ងៃ ដោយយល់ថា មានមាតិកាបានវាយប្រហារលើសម្តេចនាយករដ្ឋមន្ត្រីខ្លាំងពេក។

ចំណុចសំខាន់ៗនៃវិទ្យុសម្បុកឃ្មុំផ្សេងទៀត គឺចាប់តាំងពីឆ្នាំ១៩៩៩ មក ក៏បានជួលម៉ោងផ្សាយឱ្យវិទ្យុអាស៊ីសេរី និងសម្លេងសហរដ្ឋអាមេរិក ដែលគាំទ្រមូលនិធិដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីផ្សាយព័ត៌មាន និងបទវិចារណកថាជាភាសាខ្មែររបស់ខ្លួន។ រដ្ឋាភិបាលបានបញ្ជា វិទ្យុសម្បុកឃ្មុំជាច្រើនសារឱ្យបញ្ឈប់ធ្វើដូច្នេះ ដោយលើកឡើងថាស្ថានីយនេះពុំមានសិទ្ធិក្នុងការផ្សាយព័ត៌មានអន្តរជាតិឡើយ ប៉ុន្តែការបញ្ជានេះក៏ត្រូវបានផ្អាកទៅវិញដោយសារតែមានការរិះគន់ច្រើនពេក។

ខណៈពេលដែលបដិសេធមិនព្រមផ្តល់អាជ្ញាប័ណ្ណឱ្យវិទ្យុសម្លេងសហរដ្ឋអាមេរិក និង អាស៊ីសេរី រដ្ឋាភិបាលបានផ្តល់អាជ្ញាប័ណ្ណឱ្យវិទ្យុបរទេសដទៃទៀត គឺវិទ្យុបារាំងអន្តរជាតិ (FM 92) និងសាជីវកម្មផ្សាយសម្លេងអង់គ្លេស ( FM 100) ព្រមទាំងសាជីវកម្មផ្សាយសម្លេងអូស្ត្រាលី ( FM 101.5)។ នៅឆ្នាំ២០០៥ ពេលដែលវិទ្យុបារាំងអន្តរជាតិត្រូវបានផ្តល់អាជ្ញាប័ណ្ណ ដើម្បីបើកស្ថានីយផ្ទាល់ខ្លួននោះ លោករដ្ឋមន្ត្រីក្រសួងព័ត៌មានបានពន្យល់ថា ចំពោះការមិនផ្តល់អាជ្ញាប័ណ្ណឱ្យវិទ្យុសម្លេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរីដោយវិទ្យុទាំងនោះ "បម្រើឱ្យរដ្ឋាភិបាលអាមេរិក" តែវិទ្យុបារាំង និងអង់គ្លេសមិនបានបម្រើឱ្យរដ្ឋាភិបាលបារាំង និងអង់គ្លេសឡើយ[១១៥]។

ស្រដៀងគ្នានេះដែរ មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ដែលផ្តល់មូលនិធិដោយសហរដ្ឋអាមេរិកក៏ត្រូវបានរដ្ឋាភិបាលបដិសេធមិនផ្តល់អាជ្ញាបណ្ណ័ឱ្យដែរ។ ផ្នែកវិទ្យុសម្លេងប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលបច្ចុប្បន្ននេះ បានផ្តាច់ខ្លួនចេញពីមជ្ឈមណ្ឌល ហើយក្លាយជារូបវ័ន្តបុគ្គលដាច់ដោយឡែកមួយ និងអាចត្រឹមតែជួលម៉ោងផ្សាយពីស្ថានីយ៍វិទ្យុសម្បុកឃ្មុំ និង FM ៩៣.៥ តែប៉ុណ្ណោះ ។

វិទ្យុអាស៊ីសេរី សម្លេងសហរដ្ឋអាមេរិក និងសម្លេងប្រជាធិបតេយ្យ ព្រមទាំងសារព័ត៌មានភាសាខ្មែររបស់វិទ្យុអន្តរជាតិបារាំង គឺជាវិទ្យុដែលតំណាងឱ្យភាពវិជ្ជមានមិនដូចជាបរិយាកាសនៃវិទ្យុកម្ពុជា ដែល

---

១១៥ http://www.voanews.com/khmer/archive/2005-102005-10-31-voa4.cfm

ស្ថិតក្រោមការគ្រប់គ្រងរបស់នយោបាយ និងសារព័ត៌មានត្រួតពិនិត្យខ្លួនឯង។ ប៉ុន្តែវិជ្ជាជីវៈ និងអព្យាក្រិត្យភាពរបស់អ្នកសារព័ត៌មានទាំងឡាយដែលបំរើការងារក្នុងស្ថាប័នទាំងនោះ អាចខុសគ្នា ថ្វីត្បិតតែរដ្ឋាភិបាលជួនកាលចោទប្រកាន់អ្នកទាំងនោះថាជាឧបករណ៍បំពងសម្លេងរបស់ពួកប្រឆាំងក៏ដោយ ក៏ពួកអ្នកទាំងអស់នោះនៅតែផ្សាយនូវសេចក្តីរាយការណ៍ដ៏ត្រឹមត្រូវ និងការពិភាក្សារំលែកពែ្ញកបញ្ហាទាំងអស់នោះដែលអ្នកឯទៀតកម្រនឹងធ្វើ។ ពួកទាំងអស់នោះផ្សាយព័ត៌មានស្តីពីការកាប់ឈើខុសច្បាប់ អំពើពុករលួយ និងរឿងស្មុកស្មាញឯទៀតដែលប្រព័ន្ធផ្សាយព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជា មិនធ្វើការផ្សព្វផ្សាយ។ ជាផលវិបាក អ្នកសារព័ត៌មាននៃស្ថានីយវិទ្យុទាំងអស់នោះ បានក្លាយជាគោលដៅនៃការគំរាមកំហែង និងការបំភិតបំភ័យក្នុងរយះពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ។

ជាទូទៅ ស្ថានីយវិទ្យុជាច្រើនបានដើរតួនាទីជាឧបករណ៍បំពងសម្លេងឱ្យគណបក្សនយោបាយណាដែលខ្លួនគាំទ្រ។ ប៉ុន្តែស្ថានីយឯករាជ្យទាំងឡាយ និងការផ្សាយបន្តពីអន្តរជាតិផ្តល់ឱ្យអ្នកស្តាប់នូវជម្រើសព័ត៌មានជាច្រើនដែលពុំមានផ្សាយនៅតាមស្ថានីយទូរទស្សន៍នានាទេ។

### ***សារព័ត៌មាន***

តូបលក់សារព័ត៌មាននៅកម្ពុជា បានដាក់តាំងលក់សារព័ត៌រាប់សិប ដែលមើលពីសំបកខាងក្រៅឃើញថា មានសេរីភាពខាងប្រព័ន្ធផ្សាយព័ត៌មាន និងមានការលូតលាស់ខ្លាំងណាស់ ខាងឧស្សាហកម្មព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានលើកឡើងពីខាងដើមក្នុងរបាយការណ៍នេះ ការបោះពុម្ពផ្សាយព័ត៌មានភាគច្រើនមានភាពលំអៀងផ្នែកនយោបាយ ស្ថាប័នមួយៗត្រូវបានកំណត់ដោយម្ចាស់ ឬចៅ-ហ្វាយរបស់ស្ថាប័ននោះ ហើយមានការខ្វះខាតអំពីអព្យាក្រិត្យភាព និងគោលដៅ។ ដោយមានភាពចំរុះគ្នានៃម្ចាស់កម្មសិទ្ធិសារព័ត៌មានច្រើនជាងវិទ្យុ និងទូរទស្សន៍ អ្នកអានកម្ពុជាភាគច្រើន ទិញសារព័ត៌មានដែលលំអៀងគាំទ្រខាងរដ្ឋាភិបាល។

គួរតែយើងចាប់អារម្មណ៍មើលឱ្យបានល្អិតល្អន់ថា អ្នកណាជាម្ចាស់សារព័ត៌មានទាំងបីដែលលក់ដាច់ជាងគេបំផុតនៅក្នុងប្រទេស :



ចាងហ្វាងកាសែតរស្មីកម្ពុជា លោក ថេង ប៊ុនម៉ា ត្រូវបានសម្ភាសន៍ក្នុងការផ្តល់ជំនួយដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន នាទសវត្សទី៩០។

**រស្មីកម្ពុជា** គឺជារបស់ក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ដែលម្ចាស់ឈ្មោះលោក ថេង ប៊ុនម៉ា។ លោក ប៊ុនម៉ា ធ្លាប់បានគេចាត់ទុកថា ជាអ្នកមានជាងគេនៅកម្ពុជា ហើយប្រហែលជា

ល្បីល្បាញដោយសារលោកបានបាញ់កង់យន្តហោះប្រភេទ Boeing737 របស់ក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា ពីព្រោះលោកបានយល់ថាបុគ្គលិកមិនគួរសមដាក់លោកនៅឆ្នាំ១៩៩៧។ មានពេលមួយ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រកាសថា "លោកមានពាក់ពន្ធ័បញ្ហាគ្រឿងញៀន"[១១៦] ។ លោក ប៊ុនម៉ា ធ្លាប់មានទំនាក់ទំនងជាមួយគណបក្សប្រជាជនកម្ពុជាយ៉ាងយូរ ហើយក៏ធ្លាប់ជាអ្នកផ្តល់ហិរញ្ញវត្ថុជូនសម្តេចនាយករដ្ឋមន្ត្រីផងដែរ។ លោកធ្លាប់ផ្តល់ថវិកាដល់គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលបើកឡើងដោយសម្តេចនាយករដ្ឋមន្ត្រី ហើយផ្តល់ថវិកាចំនួន ១លាន ដុល្លាសហរដ្ឋអាមេរិក ជូនសម្តេចក្រោយពីព្រឹត្តការណ៍ឆ្នាំ១៩៩៧[១១៧] ។ ប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ គេមិនសូវបានឮពីលោក ប៊ុនម៉ា ច្រើនទេក្រោយពីឮថាលោកមានជម្ងឺដាច់សរសៃឈាម។ បច្ចុប្បន្ននេះឮថា កូនលោក ប៊ុនម៉ា ឈ្មោះ ខូវ សម្បត្តិ ជាអ្នកគ្រប់គ្រងសារព័ត៌មាន។ បណ្ណាធិការសារព័ត៌មាននេះ ឈ្មោះលោក ប៉ែន សាមិទ្ធិ អតីតអ្នកសារព័ត៌មានរបស់រដ្ឋ "កម្ពុជា និងភ្នំពេញ" កាលពីទសវត្សរ៍ឆ្នាំ១៩៨0 ហើយក៏ជាប្រធានក្លឹបអ្នកសារព័ត៌មានកម្ពុជាផងដែរ។

**កោះសន្តិភាព:** ជារបស់លោក ថុង អ៊ុយប៉ាង ជាតួអង្គដែលមានវោហារ ដោយគេស្គាល់ដោយកាន់កាំភ្លើងខ្លីដែលមានភ្លើងឡាហ្សែ។ លោកមានហេតុផលដើម្បីធ្វើដូច្នេះ ដោយហេតុថាគេបានកំណត់គោលដៅដោយប្រើប្រាស់អំពើហិង្សាមកលើរូបលោកពីរដងកន្លងមកហើយៈ គ្រាប់បែកដៃត្រូវបានបោះចូលទៅក្នុងផ្ទះរបស់លោកកាលពីខែតុលា ១៩៩៧ ហើយលោកបានរួចជីវិតពីការបាញ់ ត្រូវពីរគ្រាប់ដោយឃាតករកាលពីខែមិថុនា ១៩៩៨។ ការវាយប្រហារនេះត្រូវបានគេជឿថា គឺជាលទ្ធផលនៃជម្លោះនៅក្នុងគណបក្សប្រជាជនកម្ពុជា[១១៨] ។ កោះសន្តិភាពត្រូវបានគេចាត់ទុកថា ជាសារព័ត៌មានដែលជានិច្ចកាលគាំទ្រគណបក្សប្រជាជនកម្ពុជា ហើយបណ្ណាធិការសារព័តមាននេះលោក ខៀវ ណារី ក៏នៅក្នុង "គណៈកម្មការអ្នកនិពន្ធ" របស់ការផ្សព្វផ្សាយសម្រាប់តែសមាជិករបស់គណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ គឺ "ទស្សនាវដ្តីប្រជា

---

[១១៦] Nicholas Burns ធ្វើការនៅក្រសួងការបរទេសអាមេរិកបាននិយាយនៅក្នុងសេចក្តីសង្ខេបសារព័ត៌មានប្រចាំថ្ងៃ កាលពីថ្ងៃទី២២ កក្កដា ១៩៩៧ ថា : "យើងមានរបាយការណ៍ដែលអាចជឿជាក់បានថា ថេង ប៊ុនម៉ា ពិតជាបានជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ និងយ៉ាងខ្លាំងជាមួយការជួញដូរគ្រឿងញៀននៅកម្ពុជា ។ http://www.hri.org/news/usa/std/1997/97-07-22.std.html

[១១៧] Far Eastern Economic Review ថ្ងៃទី២ ធ្នូ ១៩៩៨។ http://www.feer.com/breaking_news981202.html

[១១៨] លោក អ៊ុយ ប៉ាង បានចោទប្រកាន់ជាច្រើនដងថា លោក ហេង ពៅ ដែលកាលនោះជាបញ្ជាការនគរបាលប្រឆាំងគ្រឿងញៀន ជាសមាជិកគណបក្សប្រជាជនបាននៅពីក្រោយការប៉ុនប៉ងធ្វើឃាដគាត់កាលពីឆ្នាំ១៩៩៨។ ក្រៅពីការបោះគ្រាប់បែកដៃចូលទៅក្នុងផ្ទះ ឆ្នាំ១៩៩៧ លោក ប៉ាង និយាយថា "នៅពេលដែលខ្ញុំចាប់ផ្តើមសរសេរអត្ថបទរិះគន់លោក ជា ស៊ីម ហុក ឡុងឌី កូន ទា បាញ់ និង ថៃ ប៊ុន រ៉ុង ស្រាប់តែមាន គេចោលគ្រាប់បែកដៃពីរគ្រាប់ចូលក្នុងផ្ទះរបស់ខ្ញុំ" សូមអានអត្ថបទ "ការរិះគន់ពាក់ព័ន្ធនឹងគ្រប់បែក" ។ សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី ១៧ តុលា ១៩៩៧ ។

ជន"[១១៩]។ ប៉ុន្តែប្រហែលជាលើសពីការគាំទ្រមាគាំគណបក្សប្រជាជនកម្ពុជារបស់ខ្លួនថែមទៀត សារព័ត៌មាន នេះល្បីដោយសារតែស្ទីលមានរូបថតច្រើន និងរូបថតមានការភ្ញាក់ផ្អើល នៃព័ត៌មានបែបឧក្រិដ្ឋកម្ម។

បញ្ជីផ្លូវការរបស់ក្រសួងព័ត៌មានបញ្ជាក់ថា ម្ចាស់របស់**សារព័ត៌មានកម្ពុជាថ្មី** គឺលោក លី ហួ ប៉ុន្តែប្រភពមួយចំនួននិយាយថាអ្នកនៅពីក្រោយពិតប្រាកដគឺលោក លឹម ហ៊ុយឡេង គឺជាមហាសេដ្ឋីអចលនៈវត្ថុម្នាក់ និងជាប្រធានសភាពាណិជ្ជកម្មក្រុងព្រះសីហនុ។ សារព័ត៌មានកម្ពុជាថ្មី គឺជាសារព័ត៌មានមួយដែលគេចាត់ទុកផងដែរថាជាសារព័ត៌មានគាំទ្ររដ្ឋាភិបាល។

សារព័ត៌មានឯទៀតដែលតូច ចេញផ្សាយជាប្រចាំមានម្ចាស់ និងលំអៀងនយោបាយដូចខាងក្រោម[១២០]។

| **សារព័ត៌មាន** | **ម្ចាស់** | **លំអៀងនយោបាយ** |
|---|---|---|
| អរិយធម៌ | ▪ ស្ងួន និមល[១២១] | គណបក្សប្រជាជនកម្ពុជា |
| ស និង ខ្មៅ | ▪ ជិន ចាន់មុនី | អព្យាក្រិត្យ/គណបក្សប្រជាជនកម្ពុជា[១២២] |
| ចក្រវាលប្រចាំថ្ងៃ | ▪ កែវ សោភ័ណ ពាណិជ្ជករ | គណបក្សប្រជាជនកម្ពុជា |
| ដើមអំពិល | ▪ សយ សុភាព ធ្វើការនៅទូរទស្សន៍ស៊ីធីអិន ដែរ | គណបក្សប្រជាជនកម្ពុជា |
| ខ្មែរអមតៈ | ▪ ប៊ុន ថា ទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | គណបក្សនរោត្តម រណឫទ្ធិ |
| ខ្មែរម្ចាស់ស្រុក | ▪ ស្លេញ លុយ | គណបក្សសម រង្ស៊ី |
| ខ្មែរមេគង្គ | ▪ ទា ថេន រដ្ឋលេខាធិការ | ហ្វ៊ុនស៊ិនប៉ិច |

[១១៩] គណៈកម្មការនិពន្ធ គឺមានឈ្មោះនៅក្នុង ទំព័រទស្សនាវដ្តី។

[១២០] បញ្ជីម្ចាស់សារព័ត៌មាននេះ គឺផ្អែកលើបញ្ជីផ្លូវការរបស់ក្រសួងព័ត៌មាន និងការសម្ភាសន៍។ ទស្សនៈនយោបាយលំអៀងបានមកពីការសម្ភាសន៍ជាមួយអ្នកឃ្លាំមើលសារព័ត៌មាន អ្នកសារព័ត៌មាន និងបណ្ណាធិការ។

[១២១] ស្ងួន និមល គឺជាឈ្មោះនៅក្នុងបញ្ជីក្រសួងព័ត៌មាន ប៉ុន្តែ អ្នកសារព័ត៌មានជាន់ខ្ពស់ពីរនាក់ គិតថាសារព័ត៌មាននេះគ្រប់គ្រងដោយ ព្រុំ សាយ។

[១២២] មានយោបល់ខ្វែងគ្នាក្នុងចំណោមអ្នកសារព័ត៌មានជាន់ខ្ពស់ អំពីលំអៀងនយោបាយនៃសារព័ត៌មាន។

| | | |
|---|---|---|
| | ក្រសួងអប់រំ | |
| មេគង្គកម្ពុជា | ▪ គង់ យុទ្ធា | ហ៊ុនស៊ីនប៊ិច |
| មនៈសិការខ្មែរ | ▪ ដាំ សិទ្ធិ អគ្គលេខាធិការរងនៃគណបក្ស សម រង្ស៊ី | គណបក្សសម រង្ស៊ី |
| សម្លេងយុវជនខ្មែរ | ▪ កែវ សុធា | គណបក្សនរោត្តម រណឫទ្ធិ |
| ស្នាដៃក្មេងវត្ត | ▪ សំផន ណារីទ្ធិ | គណបក្សប្រជាជនកម្ពុជា |
| ស្រឡាញ់ខ្មែរ | ▪ ថាច់ កេត | គណបក្សប្រជាជនកម្ពុជា |
| រស្មីអង្គរ | ▪ អ៊ិន ចាន់ស៊ីវុត្ថា | គណបក្សប្រជាជនកម្ពុជា |
| ទស្សនៈខ្មែរ | ▪ សុវណ្ណ សុខា | ប្រឆាំង |

នៅក្នុងបរិយាកាសសារព័ត៌មាននយោបាយដ៏អ៊ូអររបស់កម្ពុជា ដែលស្ថាប័នផ្សព្វផ្សាយព័ត៌មានទាំងនោះត្រូវបានចាត់ចូលតាមប្រភេទថាជា "សារព័ត៌មានគាំទ្ររដ្ឋាភិបាល" "គាំទ្រគណបក្សប្រឆាំង" (និងការបែងចែកជាតូចៗតទៅទៀតរវាងគណបក្សនីមួយៗ) អ្នកយកព័ត៌មានត្រូវបានរំពឹងថាត្រូវតែប្រកាន់ខ្ជាប់នូវភាពលំអៀងនយោបាយខាងក្នុងគណបក្សរបស់អ្នកយកព័ត៌មាននេះ។

អ្នកយកព័ត៌មានជាន់ខ្ពស់ម្នាក់បានមានប្រសាសន៍ថា "ប្រសិនបើអ្នកសរសេរអោយហ៊ុនស៊ីនប៊ិចអ្នកអាចសរសេរផ្តាប់ផ្តន់គាំទ្រហ៊ុនស៊ីនប៊ិចតែប៉ុណ្ណោះ គឺគ្មានឯករាជ្យទេ អ្នកមិនអាចសរសេរអ្វីដែលអ្នកបានឃើញទេ"[១២៣]។

ភាពលំអៀងអាចកើតតាមវិធីផ្សេងៗ ប៉ុន្តែភាគច្រើនតាមការជ្រើសរើស ឬការលប់ចោលនូវអត្ថបទរឿងបែបព័ត៌មាន ការធ្វើបទវិចារណកថា ការជ្រើសរើសភាសា និងការប្រើប្រាស់រូបថត ឬ រូបថ្លុកនៅក្នុងបទវិចារណកថានោះ ។

ភាពលំអៀងនេះ ពុំបានក៏រិតទៅតាមអត្ថបទវិចារណកថា ឬ អត្ថបទអត្ថាធិប្បាយប៉ុណ្ណោះទេ តែផ្ទុយទៅវិញ សារព័ត៌មានភាគច្រើនពុំបានកំណត់ផ្នែកបញ្ចេញមតិអោយច្បាស់លាស់ទេ។ អត្ថបទដែលបង្ហាញជាសាច់រឿងបែបពត៌មាន ច្រើនតែបញ្ចូលបទវិចារណកថាយ៉ាងសន្ធឹកសន្ធាប់ ឬ ធ្វើការចោទប្រកាន់

[១២៣] សម្ភាសន៍ជាមួយអ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់ថ្ងៃទី១៤ កញ្ញា ២០០៧។

យ៉ាងខ្លាំងៗដោយគ្មានភស្តុតាង ឬ ការសំអាងអ្វីមួយ។ វាក៏ជារឿងធម្មតាផងដែរសម្រាប់សារព័ត៌មានខុសៗគ្នានៅពេលណា ដែលមានបញ្ហាស្មុគស្មាញមួយ គឺទាំងអស់គ្នាខ្វល់ខ្វាយតែពីការជម្លោះពាក្យសំដីដោយមិនខិតខំដើម្បីរៀបចំឱ្យមានការផ្សាយឱ្យមានតុល្យភាព ឬ មិនលំអៀងឡើយ។

ថ្វីត្បិតតែមិនមានក្រមសីលធម៌ និងគាំទ្រយ៉ាងខ្លាំងទៅលើគណបក្សកាន់អំណាចក៏ដោយ ក៏របាយការណ៍លំអៀងនេះ បានផ្តល់នូវវេទិកាមួយសម្រាប់សម្លេងនយោបាយខុសៗគ្នាបានពួ។ ការចោទប្រកាន់អំពីអំពើពុករលួយ និងសកម្មភាពខុសច្បាប់ផ្សេងៗទៀត ច្រើនតែលេចចេញពីសារព័ត៌មានប្រឆាំង ចំណែកឯសារព័ត៌មានគាំទ្ររដ្ឋាភិបាលវិញបោះពុម្ពផ្សាយតែរឿងរិះគន់អំពីគណបក្សជំទាស់ និងអ្នកដឹកនាំនេះតែប៉ុណ្ណោះ។ អ្នកអានសារព័ត៌មានដែលមានភក្តីភាពខ្លាំងខាងនយោបាយ នឹងជ្រើសរើសយកការបោះពុម្ពផ្សាយណា ដែលឆ្លុះបញ្ចាំងនូវភាពលំអៀងរបស់អ្នកអានសារព័ត៌មាននោះ ធ្វើដូច្នេះ សារព័ត៌មានពង្រឹងទស្សនៈខាងនយោបាយដែលអ្នកសារព័ត៌មានមានទុកជាមុនស្រាប់[១២៤]។

ឧស្សាហកម្មសារព័ត៌មាន មានការផ្លាស់ប្តូរយ៉ាងលឿន ពីព្រោះសារព័ត៌មានតូចៗមួយចំនួនបានបើកហើយរលំទៅវិញ ហើយម្យ៉ាងទៀតមានការផ្លាស់ប្តូរម្ចាស់ និងសេចក្តីស្មោះត្រង់។ ឧទាហរណ៍ សម្លេងយុវជនខ្មែរ ដែលធ្លាប់តែជាសារព័ត៌មានគាំទ្រគណបក្ស សម រង្ស៊ី អស់រយះពេលយ៉ាងយូរ ធ្លាប់មានរឿងក្តីជាច្រើន ហើយរហូតដល់មានការសម្លាប់បណ្ណាធិការម្នាក់ថែមទៀត។ ជាយថាហេតុ សារព័ត៌មាននេះក៏បែរជាប្តូរទៅហ៊្វុនស៊ិនប៉ិចទៅវិញ ហើយក្រោយមកទៀតគាំទ្រគណបក្សនរោត្តមរណឫទ្ធិ។ ឧទាហរណ៍មួយទៀតគឺសារព័ត៌មានស្រឡាញ់ខ្មែរ ពីមុនជាសារព័ត៌មានគាំទ្រគណបក្ស សម រង្ស៊ី ដែលប៉ុន្មានឆ្នាំថ្មីៗនេះបានធ្វើអោយមន្ត្រីរដ្ឋាភិបាលមានកំហឹងម្តងហើយម្តងទៀត។ កាលពីខែមិនា ២០០៨ ចំពេលកំពុងមានយុទ្ធនាការរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីបញ្ចុះបញ្ចូលមន្ត្រី សម រង្ស៊ី ឱ្យចូលរួមជាមួយគណបក្សកាន់អំណាច។ លោក ថាច់ កេត ដែលជាចាងហ្វាងសារព័ត៌មាននេះ និងជាសមាជិកគណៈកម្មការនាយកគណបក្សសម រង្ស៊ី ក៏បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។ ការបោះពុម្ពផ្សាយដំបូងនៃសារព័ត៌មានដែលមានរូបរាងថ្មីបានឆ្លុះបញ្ចាំងអោយឃើញនូវការផ្លាស់ប្តូរ ១៨០ អង្សាក្នុងមាតិកា ដោយមានអត្ថបទរិះគន់ដល់គណបក្សជំទាស់ទាំងបី ហើយសរសើរគណបក្សប្រជាជនកម្ពុជាយ៉ាងកក់ក្តៅ។

---

[១២៤] ប៉ុន្តែ ដូចដែលបានកត់សំគាល់រួចមកហើយនៅក្នុងរបាយការណ៍នេះ អ្នកទិញសារព័ត៌មានដែលគ្មាននិន្នាការនយោបាយ ជាច្រើនអាចមើលត្រួសៗ តាមតូបសារព័ត៌មានរកមើលទំព័រណាដែលចាប់អារម្មណ៍ជាងគេនៅលើទំព័រដំបូង ដែលលើកទឹកចិត្តឱ្យការធ្វើឱ្យមានការទាក់ទាញអារម្មណ៍ និង ក្រាហ្វិចនៅលើសារព័ត៌មាន។

ភាពខុសគ្នាមួយដ៏សំខាន់រវាងការវិភាគរបស់សារព័ត៌មាន "គាំទ្ររដ្ឋាភិបាល" ឬ "គាំទ្រគណបក្សជំទាស់" គឺថាភាពលំអៀងរបស់ពួកគេគឺមិនអាចកំណត់តែឯងក្នុងការគាំទ្រគណបក្សរបស់ខ្លួន ហើយវាយប្រហារ លើគណបក្សដែលមានជម្លោះតែប៉ុណ្ណោះទេ។ នៅក្នុងគណបក្សមួយ សារព័ត៌មានអាចលំអៀងទៅលើបុគ្គលណាម្នាក់ដែលពិសេស ឬ មនុស្សមួយក្រុមណាមួយ ជាពិសេសអ្នកណាដែលកាន់បញ្ជីប្រាក់ខែឱ្យសារព័ត៌មានជាជាងលំអៀងទៅរកគណបក្ស និងមន្ត្រីរបស់បក្សទាំងមូល។ ការផ្តល់ថវិកាឱ្យសារព័ត៌មានគឺជាវិធីតែមួយដ៏យូរអង្វែងដែលអ្នកនយោបាយ ធ្វើយ៉ាងណាធានាឱ្យមានការផ្សាយផ្គាប់ចិត្តដល់អ្នកនយោ-បាយនោះ ដើម្បីប្រជែងយកតំណែង ឬ ឥទ្ធិពលនៅក្នុងគណបក្សរបស់ខ្លួន ក៏ដូចជាប្រណាំងប្រជែងជាមួយអ្នកប្រឆាំងខាងក្រៅដែរ។

ដូច្នេះហើយ សារព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជា ឬ គាំទ្រគណបក្សសម រង្ស៊ី អាចរៀបចំផ្សព្វផ្សាយជូននូវសេចក្តីរាយការណ៍យ៉ាងមានខ្លឹមសារដល់មន្ត្រីនៅក្នុងបក្សរបស់គេរៀងៗខ្លួន ដែលមន្ត្រីនោះបានផ្តល់ហិរញ្ញវត្ថុសម្រាប់ការបោះពុម្ពផ្សាយ ប៉ុន្តែបែរជាមិនយកចិត្តទុកដាក់ មិនត្រឹមតែប៉ុណ្ណោះ អាចបោះពុម្ពផ្សាយការរិះគន់យ៉ាងខ្លាំងដល់មន្ត្រីផ្សេងទៀតនៅក្នុងបក្សជាមួយគ្នា។ ឧទាហរណ៍ ពេលដែលមានអំពើហិង្សាមកលើកោះសន្តិភាព កាលពីចុងទសវត្សរ៍១៩៩០ គេជឿជាទូទៅថាជាលទ្ធផលនៃការផ្លាស់ប្តូរភក្តីភាពនៅក្នុងគណបក្សប្រជាជនកម្ពុជា ដូច្នេះហើយ បានជាមានអត្ថបទរបស់សារព័ត៌មានរិះគន់មន្ត្រីខ្លះនៅក្នុងគណបក្សនោះ។

ក្នុងករណីខ្លះទៀតអ្នកសារព័ត៌មានមួយចំនួនអាចមិនយល់ព្រមជាមួយនឹងការពាក់ព័ន្ធភាពលំអៀងផ្នែកនយោបាយដែលពួកគេរក្សាមានជានិច្ច។ អ្នកយកព័ត៌មានជើងចាស់ម្នាក់បានរៀបរាប់អំពីរបៀប ដែលធ្វើការពាក់កណ្តាលម៉ោងជាមួយសារព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជា ហើយធ្វើពាក់កណ្តាលម៉ោងទៀតជាមួយសារព័ត៌មានគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច។ លោកនោះ បានប្រើឈ្មោះជាអ្នកសរសេរសម្រាប់ការងារទាំងពីរនេះ ហើយលោកបានប្រសាសន៍ថា "ខ្ញុំប្រមូលព័ត៌មាន ហើយសរសេរតាមទស្សនៈនយោបាយរបស់គណបក្សនីមួយៗដែលខ្ញុំធ្វើការជូន"។លោកបានបន្ថែមថា លោកបានស្គាល់អ្នកយកព័ត៌មានឯទៀតយ៉ាងតិច ១៥ នាក់ ដែលចែកពេលវេលាធ្វើការងារបែបនេះ។

នៅក្នុងបាតុភូតគួរអោយចាប់អារម្មណ៍មួយទៀត គឺការចែកចាយព័ត៌មានរវាងអ្នកសារព័ត៌មានដែលធ្វើការជាមួយសារព័ត៌មានសម្ព័ន្ធភាពគណបក្សខុសៗគ្នា។ នៅក្នុងករណីខ្លះ ប្រសិនបើអ្នកយកព័ត៌មានម្នាក់ទទួលបានព័ត៌មានដែលស្មុកស្មាញ ហើយផ្ទុយនឹងមានភាពលំអៀងក្នុងការផ្សព្វផ្សាយរបស់ខ្លួន នោះ

លោកអាចចែករំលែកឱ្យទៅមិត្តភ័ក្តរបស់លោក ដែលនៅសារព័ត៌មានផ្សេងទៀតឱ្យសរសេរដោយមិនបញ្ជាក់ពីប្រភពព័ត៌មានឡើយ។ ការធ្លាយព័ត៌មានបែបនេះ គឺច្រើនតែបានមកពីអ្នកសារព័ត៌មានដែលធ្វើការជាមួយសារព័ត៌មានសម្ព័ន្ធភាពគណបក្សប្រជាជនកម្ពុជា ដែលចង់ឱ្យការពិតត្រូវបានលាតត្រដាង ប៉ុន្តែដឹងថាវាអាចបាត់បង់ការងាររបស់ខ្លួន ឬធ្ងន់ជាងនេះទៅទៀតនេះ គឺជាការលើកឡើងរបស់អ្នកសារព័ត៌មានជាច្រើន។ អ្នកសារព័ត៌មានម្នាក់មានប្រសាសន៍ថា "ប្រសិនបើប្រធានរបស់គេដឹងនោះគេនឹងមានបញ្ហា" អ្នកសារព័ត៌មាននោះបានរៀបរាប់ថា ប្រភពដែលមកពីមិត្តភក្តិនោះគឺជា "ភ្នាក់ងារមុខពីរ" [១២៥] ។

ទោះជាអ្នកសារព័ត៌មានម្នាក់ៗមានជំនឿផ្ទាល់ខ្លួនអ្វីក៏ដោយ ហើយវិធីដែលពួកគេអាចព្យាយាមស្វែងរកជុំវិញការហាមប្រាម ម្នាក់ៗសុទ្ធតែដឹងថាគេត្រូវតែធ្វើតាមមាគ៌ានយោបាយរបស់ការបោះពុម្ពផ្សាយនីមួយៗ ដែលអ្នកសារព័ត៌មាននោះសរសេរឱ្យ។ នៅក្នុងប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យរឹងមាំ ក្លឹបអ្នកសារព័ត៌មានចាត់ទុកថាតុល្យភាព និងឯករាជ្យភាពរបស់វិចារណកថា ជាក្រមសីលធម៌ចាំបាច់សម្រាប់អ្នកសារព័ត៌មាន[១២៦] ។ ទោះបីយ៉ាងណាក៏ដោយ នៅកម្ពុជា ដោយសារព័ត៌មានភាគច្រើនជារបស់ ឬ ត្រូវបានគ្រប់គ្រងដោយកម្លាំងនយោបាយ អ្នកសារព័ត៌មានជាច្រើនពុំមានភាពឯករាជ្យក្នុងការធ្វើបទវិចារ- ណកថាទេ នេះពុំមែនជាអ្វីដែលអ្នកសារព័ត៌មានទាំងនោះត្រូវគេផ្តល់ឱកាសសំរាប់ឱ្យធ្វើទេ។

ថ្វីត្បិតតែអ្នកសារព័ត៌មានខ្លះសុខចិត្តទទួលយកទង្វើនេះ ក៏ប៉ុន្តែអ្នកទាំងអស់នោះភាគច្រើនចាត់ទុកទង្វើនេះជាឧបសគ្គមួយដែលធ្វើឱ្យមានការពិបាកចិត្តខ្លាំងណាស់។ អ្នកសារព័ត៌មានម្នាក់ បានមានប្រសាសន៍ថា "ជាការពិតណាស់ អ្នកសារព័ត៌មានទាំងអស់នោះចង់ធ្វើឱ្យមានវិជ្ជាជីវៈខាងសារព័ត៌មានណាស់ ចង់ប្រើប្រាស់បទពិសោធន៍ដែលបានរៀនពីខាងក្រៅ (ក្នុងវគ្គបណ្តុះបណ្តាល) ប៉ុន្តែអ្នកទាំងអស់នោះស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកដទៃ" [១២៧] ។

---

[១២៥] សម្ភាសន៍ជាមួយបណ្ណាធិការ ថ្ងៃទី១៣ កញ្ញា ២០០៧។

[១២៦] ច្បាប់សារព័ត៌មាននៅក្នុងសេចក្តីណែនាំរបស់ច្បាប់នេះចំពោះក្លឹបអ្នកសារព័ត៌មានបាននិយាយថា "អ្នកសារព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មានដោយស្មោះត្រង់ ហើយសរសេរបទវិចារណកថាត្រឹមត្រូវ ឬ រិះគន់ឱ្យស្របតាមន័យយុត្តិធម៌" ហើយក្លឹបអ្នកសារព័ត៌មានកម្ពុជាក៏មានក្រមសីលធម៌ដែលទាមទារឱ្យ "ស្មោះត្រង់ ថ្លៃថ្នូរ និងយុត្តិធម៌"។ ប៉ុន្តែតាមពិត ក្រមសីលធម៌ដែលមិនអាចអនុវត្តបាននេះត្រូវបានទុកចោល។

[១២៧] សម្ភាសន៍ជាមួយអ្នកសារព័ត៌មានម្នាក់ថ្ងៃទី១១ កញ្ញា ២០០៧។

រឿងពិតដ៏អកុសល្យនៃការគ្រប់គ្រងនយោបាយលើសារព័ត៌មាន (និងប្រព័ន្ធផ្សាយព័ត៌មានបែបព័ត៌មានផ្សេងៗទៀត ជាពិសេសទូរទស្សន៍) គឺជារឿងដែលលំបាកក្នុងការដោះស្រាយ តាមរយៈវគ្គបណ្តុះបណ្តាល។ ជាងមួយទសវត្សរ៍ហើយកម្មវិធីបណ្តុះបណ្តាលរាប់មិនអស់ត្រូវបានរៀបចំសម្រាប់អ្នកសារព័ត៌មានកម្ពុជា មានចាប់តាំងពីការសម្ភាសន៍ជាមូលដ្ឋាន និងជំនាញក្នុងការសរសេររឿងរហូតដល់ក្រមសីលធម៌ប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មាន។ ប៉ុន្តែបន្ទាប់ពីវគ្គនីមួយៗ អ្នកយកព័ត៌មានភាគច្រើនត្រឡប់ទៅស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិញដែលម្ចាស់ ឬចៅហ្វាយនាយបានផ្តល់ថវិកាឱ្យពួកគេធ្វើតាមបញ្ជាមាគ៌ានយោបាយជាក់លាក់ណាមួយ ដែលមិនមែនជាអ្នកសារព័ត៌មានអាព្យាក្រិត្យ និងប្រកបដោយវិជ្ជាជីវៈទេ។

បញ្ហាកាន់តែរីកធំឡើង ដោយសារកង្វះខាតជំនាញពាណិជ្ជកម្មក្នុងចំណោមអ្នកគ្រប់គ្រងសារព័ត៌មាន ហើយសារព័ត៌មានភាគច្រើនពុំបានធ្វើអាជីវកម្មប្រកបដោយនិរន្តភាពទេ (រកប្រាក់ចំណូលគ្រប់គ្រាន់ពីការផ្សាយពាណិជ្ជកម្ម និងលក់ដើម្បីទប់ទល់ប្រាក់ខែ និងការចំណាយប្រតិបត្តិការផ្សេងទៀត)។ តាមពិតដោយការអានសារព័ត៌មាននៅក្នុងប្រទេសកម្ពុជានៅមានកំរិតនៅឡើយនោះ ធាតុពិតគឺថាស្ថាប័នផ្សព្វផ្សាយព័ត៌មានជាច្រើនពុំអាចទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដោយខ្លួនឯងបាន ហេតុនេះហើយ ត្រូវពឹងផ្អែកលើការជួយឧបត្ថម្ភពីអ្នកនយោបាយ ឬមនុស្សដែលមានឥទ្ធិពលផ្សេងៗ។

សរុបសេចក្តីមក រឿងសារព័ត៌មានកម្ពុជាគឺជាបញ្ហានយោបាយមួយយ៉ាងខ្លាំងក្លាដែលការបោះពុម្ពភាគច្រើនជាឧបករណ៍បំពងសម្លេងសម្រាប់គណបក្សមួយ ឬ គណបក្សផ្សេងទៀត។ ក៏ប៉ុន្តែ នេះគឺអាចធ្វើឱ្យមានសម្លេងនយោបាយផ្សេងៗជាច្រើន ដែលអាចឮបានតាមរយៈសារព័ត៌មានជាតិ មិនដូចជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិកជាច្រើនទេ។

## *សារព័ត៌មានភាសាបរទេស*

ជាទូទៅ សារព័ត៌មានភាសាបរទេសនៅកម្ពុជា ជាយូរមកហើយមិនដែលត្រូវបានគេរិះគន់ថាលំអៀងផ្នែកនយោបាយ និងខ្វះឯករាជ្យភាពទេបើធៀបទៅនឹងសារព័ត៌មានកម្ពុជា។ ប៉ុន្តែព្រឹត្តិការណ៍ថ្មីៗនេះ រួមមានការបណ្តេញភ្លាមៗនៃបណ្ណាធិការម្នាក់នៅក្នុងសារព័ត៌មានមួយបានបង្កឡើងនូវការសង្ស័យខ្លះអំពីបញ្ហាថាតើម្ចាស់របស់គេអាចធានាបាននូវបទវិចារណកថាឯករាជ្យរបស់ពួកគេយ៉ាងណា។

ស្ថាប័នផ្សព្វផ្សាយព័ត៌មានភាសាបរទេសសំខាន់ៗ គឺភាសាអង់គ្លេសរួមមាន ឌឹ ឃែមបូឌា ដេលី ភ្នំពេញប៉ុស្តិ៍ កាសែតមេគង្គថៃម ដែលចាប់ផ្តើមថ្មីៗ និងសារព័ត៌មានភាសាបារាំងកាំបូដស័រ។ សារព័ត៌មានទាំងអស់សុទ្ធតែមានផ្នែកជាភាសាខ្មែរ លើកលែងតែភ្នំពេញប៉ុស្តិ៍ប៉ុណ្ណោះ។

សារព័ត៌មានដែលមានវ័យចំណាស់ជាងគេបង្អស់គឺសារព័ត៌មាន **ឌឹ ឃែមបូឌា ដេលី និងភ្នំពេញប៉ុស្តិ៍** សារព័ត៌មានទាំងពីរនេះគឺចាប់ផ្តើមបើកដោយជនជាតិអាមេរិកនៅដើមទសវត្សរ៍ ១៩៩០។ រយៈពេលជាច្រើនឆ្នាំកន្លងមកសារព័ត៌មានទាំងនេះគឺជាប្រភពដ៏សំខាន់នៃព័ត៌មាននិងការវិភាគឯករាជ្យដ៏ធំធេងសម្រាប់ពលរដ្ឋមកពីក្រៅប្រទេស និងសម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលមានការអប់រំកាន់តែច្រើនឡើងៗជាពិសេសនៅទីក្រុងភ្នំពេញ។

សារព័ត៌មានទាំងពីរបានបង្កកំហឹងម្តងហើយម្តងទៀតដល់រដ្ឋាភិបាល ឬមនុស្សដែលមានឥទ្ធិពលផ្សេងៗ ហើយសារព័ត៌មាន **ឌឹ ឃែមបូឌា ដេលី** ត្រូវបានមន្ត្រីរដ្ឋាភិបាលប្តឹងដោយជោគជ័យជាច្រើនដង (ប៉ុន្តែមនុស្សជាច្រើននិយាយថាមិនយុត្តិធម៌)។ ទោះជាយ៉ាងក្តីសារព័ត៌មានទាំងពីរបានព្យាយាមគេចពីអំពើហិង្សា ការផ្អាកអាជ្ញាប័ណ្ណ និងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរផ្សេងៗ ដូចដែលសារព័ត៌មានកម្ពុជាមួយចំនួនដែលជាមិត្តភក្តិធ្លាប់ប្រឈមមុខ។ ជាការពិត ថ្វីត្បិតតែសារព័ត៌មាននេះចុះផ្សាយការរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាចក៏ដោយ ក៏សារព័ត៌មាននេះមិនត្រូវបានមើលឃើញ ថាគាំទ្រគណបក្សជំទាស់ទេម្យ៉ាងទៀត ដោយសារការចែកចាយមានកំរិត ហើយសារព័ត៌មានទាំងពីរនេះផ្សព្វផ្សាយជាភាសាអង់គ្លេសទៀត (ទោះបីជាសារព័ត៌មាន ឌឹ ឃែមបូឌា ដេលី បានចេញផ្សាយជាភាសាខ្មែរ ជាច្រើនឆ្នាំកន្លងមកហើយក៏ដោយ) ដូច្នេះហើយបានជាអ្នកអានសារព័ត៌មាននេះនៅមានកំរិតនៅឡើយ ហើយម្ចាស់បរទេសរបស់សារព័ត៌មានទាំងពីរនេះអាចការពារអ្នកសារព័ត៌មានបានច្រើនជាងបន្តិច។

នៅដើមឆ្នាំ ២០០៨ ភាគហ៊ុនភាគជាច្រើនរបស់សារព័ត៌មានភ្នំពេញប៉ុស្តិ៍នេះ ត្រូវបានលក់ឱ្យពាណិជ្ជករបរទេសបីនាក់ ម្នាក់ជាថៅកែអណ្តូងរ៉ែប្រេង ម្ចាស់សារព័ត៌មានមីយ៉ាន់ម៉ា ថែម នៅភូមា និងជនជាតិបារាំងម្នាក់ទៀត ដែលជាមនុស្សមានបទពិសោធន៍ផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន នៅប្រទេសវៀតណាម និងប្រទេសថៃ។ ការលក់នេះបានធ្វើឱ្យមានការខ្វាយខ្វល់ខ្លះៗដែលថាសារព័ត៌មាន ភ្នំពេញប៉ុស្តិ៍នេះ អាចបន្ទន់សេចក្តីរាយការណ៍របស់ខ្លួនចំពោះរដ្ឋាភិបាល និងគណបក្សកាន់អំណាច បើប្រសិនណា

ម្ចាស់ថ្មីនេះ មានបំណងបន្តពាណិជ្ជកម្មផ្សេងទៀតនៅកម្ពុជា (ដូចជាសម្បទានរ៉ែ ឬ ប្រេងនៅកម្ពុជាជាដើម)[១២៨] ។

សារព័តិមានកាំបូឌស័រ ពេលនេះមានការគំរាមដោយផ្ទាល់មកលើឯករាជ្យភាពនៃវិចារណកថារបស់អ្នកសារព័តិមានក្នុងឆ្នាំ២០០៧។ ចាប់តាំងពីការចាប់ផ្តើមបើកដំបូងនៅពាក់កណ្តាលឆ្នាំ ១៩៩០ សារព័តិមានភាសាបារាំង (ដែលមានផ្នែកជាភាសាខ្មែរដែរ) បានដើរតាមគន្លងឯករាជ្យ និងការផ្សាយយ៉ាងមានតុល្យភាព។ ប៉ុន្តែនៅក្នុងខែមិថុនា ២០០៧ អ្នកគ្រប់គ្រងសារព័តិមាននោះ បានបណ្តេញបណ្ណាធិការម្នាក់ចេញពីការងារភ្លាមៗ គឺលោក សូវែន ស៊ីឡូវ ដោយគាត់បានចុះផ្សាយអត្ថបទមួយជារបាយការណ៍របស់អង្គការឃ្លាំមើលបរិស្ថានឈ្មោះ ក្លូបាលវិណេស (Global Witness) ដែលមានការចោទប្រកាន់អំពីអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីខ្ពស់មួយចំនួនថា បានពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់ និងបទឧក្រិដ្ឋផ្សេងៗទៀត។ ពេលបណ្តេញលោក ស៊ីឡូវ ចេញ បុគ្គលិកខ្មែរ និងបរទេសក៏បានធ្វើកូដកម្មតវ៉ាចំពោះបញ្ហានេះ ហើយការឆ្លើយតបរបស់អ្នកគ្រប់គ្រង គឺប្រកាសបិទសារព័តិមាននោះចោល ដោយទំនងជាបណ្តាលមកពីការក្ស័យធន។

បញ្ហានេះត្រូវគេដឹងថាម្ចាស់ភាគហ៊ុន/នាយកម្នាក់ នៃសារព័តិមាននេះគឺ លោក ភីលីព ម៉ូនីន ជនជាតិបារាំង គឺជាទីប្រឹក្សាក្រសួងកសិកម្ម (មូលនិធិភ្នាក់ងារអភិវឌ្ឍន៍បារាំងជាអ្នកបញ្ជូនមក) ហើយលោករដ្ឋមន្ត្រីក្រសួងកសិកម្ម ដែលក្លូវបាលវិណេស (Global Witness) ត្រូវចោទប្រកាន់ថាមានឈ្មោះពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់។ តាមសេចក្តីរាយការណ៍ លោក ម៉ូនីន បានប្រាប់លោក ស៊ីឡូវ ថាការផ្សាយរបាយការណ៍នេះនៅក្នុងកាំបូឌស័រធ្វើឱ្យរដ្ឋាភិបាលអន់ចិត្តជាខ្លាំង ហើយលោកក៏ស្ថិតក្នុងស្ថានភាពមួយលំបាកដែរ[១២៩] ។ លោកម៉ូនីន បានបដិសេធជាសាធារណៈមិននិយាយអ្វីទាំងអស់ក្រៅពីការឆ្លើយទៅនឹងសំណួរមួយថា "ហេតុអ្វីបានជាបុគ្គលិកខឹងធ្វើកូដកម្ម?" លោកក៏បានឆ្លើយថា "ពួកគេមិនបានមើលឃើញពីការអភិវឌ្ឍន៍ប្រទេសជាតិតាមវិធីដូចគ្នាទេ"[១៣០] ។

---

[១២៨] ម្ចាស់សារព័តិមានម្នាក់ ឈ្មោះ ប៊ីល ក្លូ ជាអភិជន ជាតិអូស្ត្រាលីម្នាក់ រកស៊ីខាង រ៉ែ និងប្រេងកាតដែលមានឥទ្ធិពល គឺជាភាគហ៊ុនមួយនៃសារព័តិមាន មីយ៉ាន់ម៉ា ថៃម នៅភូមា (ដែលមនុស្សជាច្រើនបានរិះគន់ថាជាឧបករណ៍បំពងសម្លេងរបស់របបជិះជាន់) ហើយក៏បានទទួលសម្បទានរុករកប្រេងពីរបបយោធាភូមាផង។

[១២៩] ការប្រកាសអាសន្នរបស់របស់អ្នកយកព័តិមានគ្មានព្រំដែន ១៥ មិថុនា ២០០០។ មាននៅក្នុងវែបសាយ hppt://www.ifex.org/alerts/content/view/full/84139

[១៣០] កម្ពុជាបានបាត់សម្លេងសារព័តិមានឯករាជ្យ "ខ្លូក្លា ជីលីសុន អ្នកឃ្លាំមើលអាស៊ី-មាននៅក្នុងវែបសាយ http://www.irrawaddy.org/print_article.php?art_id=7674

ពីរបីខែក្រោយមកសារព័ត៌មាននោះបានបើកឡើងវិញ ហើយអ្នកគ្រប់គ្រងមានលក្ខណៈទន់ភ្លន់ជាងមុនជាមួយរដ្ឋាភិបាល។ អតីតបុគ្គលិកជាច្រើនត្រឡប់ទៅធ្វើការវិញ ប៉ុន្តែខ្លះមិនទៅទេ ពីព្រោះពួកគាត់ជឿជាក់ថា ពុំមានការធានាគ្រប់គ្រាន់ដល់ឯករាជ្យភាព នៃការសរសេររបស់ពួកគាត់ទេ។ បុគ្គលិកខ្មែរ និងបរទេសមួយចំនួនដែលធ្លាប់ធ្វើការនៅក្នុងសារព័ត៌មាននោះ បានបើកសារព័ត៌មានតាមវែបសាយជាភាសាបារាំង និងខ្មែរដែលមានអាសយដ្ឋាន (www.ka-set.info)។

ការបន្ថែមចុងក្រោយបង្អស់ទៅលើសារព័ត៌មានភាសាបរទេស គឺមេគង្គថៃម ដែលបើកនៅពាក់កណ្តាលឆ្នាំ២០០៨។ សារព័ត៌មាននេះបោះពុម្ពផ្សាយជាភាសាអង់គ្លេស និងភាសាខ្មែរដែលជារបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍ប្រព័ន្ធផ្សាយព័ត៌មានមួយ។ មេគង្គថៃមជាសារព័ត៌មានឯករាជ្យ ដែលមានលក្ខណៈប្រុងប្រយ័ត្ន ប៉ុន្តែមិនផ្សាយរិះគន់ខ្លាំងៗផ្នែកនយោបាយទេ។

យើងកំពុងតែចាំមើលឃើញ ថាតើសារព័ត៌មានភាសាបរទេសនៅកម្ពុជានឹងរក្សាបាននូវកេរ្តិ៍ឈ្មោះដូចពីមុន ថាជាសារព័ត៌មានគំរូមួយឥតលំអៀង និងអាព្យាក្រិត្យនៅក្នុងប្រទេស ដែលធ្លាប់តែមានសារព័ត៌មានលំអៀងផ្នែកនយោបាយធ្ងន់ធ្ងរដែរឬទេ? ឬ ក៏បទពិសោធន៍របស់ សារព័ត៌មានកាំបូឌស័រ ឆ្នាំ២០០៧ ជាប្រផ្នូលមួយ ប្រាប់ឱ្យដឹងជាមុនថានឹងអាចមានកើតអ្វីៗទៀត នៅពេលអនាគត។

## ការត្រួតពិនិត្យ និងការត្រួតពិនិត្យខ្លួនឯង

ជាពិសេស ច្បាប់ស្តីពីសារព័ត៌មានបានហាមប្រាមមិនឱ្យមានការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយទេដែលបានគោរពដោយរដ្ឋាភិបាល។ ក៏ប៉ុន្តែច្បាប់នេះមិនបានគ្រប់គ្រងទៅលើប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិកទេ ហើយស្ថានីយទូរទស្សន៍ជាតិ **ទទក** បានដំណើរការផ្សាយក្រោមការត្រួតពិនិត្យមួយតឹងរឹងនូវព័ត៌មានដែលស្មុកស្មាញ។ អ្នកសារព័ត៌មានទូរទស្សន៍ និងវិទ្យុធ្លាប់ជួបប្រទះនូវការគាបសង្កត់ពីសំណាក់រដ្ឋាភិបាលតាមបែបផ្សេងៗគ្នា ហើយច្រើនតែអនុវត្តនូវការត្រួតពិនិត្យខ្លួនឯង។

### *ការត្រួតពិនិត្យ*

ការត្រួតពិនិត្យនៅកម្ពុជាដ៏តឹងរឹងជាងគេនៅក្នុងស្ថានីយទូរទស្សន៍ **ទទក** ។ រឿងស្តីពីបញ្ហានានាដូចជានយោបាយ អំពើពុករលួយ សិទ្ធិមនុស្ស ភាពក្រីក្រ និងអស្ថិរភាពសង្គមត្រូវទទួលការឯកភាព ហើយអាចត្រូវបានត្រួតពិនិត្យដោយអគ្គនាយក **ទទក** ជាមុនសិន។

អ្នកយកព័ត៌មានក្នុងស្រុកម្នាក់បានមានប្រសាសន៍ដោយមិនបញ្ចេញឈ្មោះថា "អគ្គនាយកពិនិត្យមើលគ្រប់ពាក្យទាំងអស់ដើម្បីរកមើលក្រែងលោមានពាក្យជាពាក្យរិះគន់ដល់រដ្ឋាភិបាល បុគ្គល ឬ ប៉ះពាល់ដល់សង្គម" [១៣១] ។

អ្នកយកព័ត៌មាននោះបានបន្ថែមទៀតថាប្រធានបទ "ក្តៅៗ" ទាំងនេះ ត្រូវបានដកចេញពីការផ្សាយ ហើយសម្លេងវិចារណកថាត្រូវតែសំរួលជាងមុន។ ក្នុងសម័យដែលស្ថានភាពនយោបាយរំជើបរំជួលដូចជាបញ្ហានយោបាយជាប់គាំងពេញមួយឆ្នាំ ក្រោយពីការបោះឆ្នោតជាតិឆ្នាំ២០០៣ បញ្ហាតានតឹងនានា ជាដំបូងត្រូវបានត្រួតពិនិត្យដោយមន្ត្រីជាន់ខ្ពស់នៅក្រសួងព័ត៌មាន ជាធម្មតា គឺលោករដ្ឋមន្ត្រី ខៀវ កញ្ញារីទ្ធិ។

អ្នកយកព័ត៌មានដដែលនោះក៏បានបន្តទៀតថា "រាល់ព័ត៌មានទាំងអស់ស្តីពីនយោបាយ ឬ សាលាក្តីខ្មែរក្រហមត្រូវតែឆ្លងកាត់លោករដ្ឋមន្ត្រីក្រសួងព័ត៌មានសិន លោកនាយកអត់ហ៊ានសម្រេចថាត្រូវផ្សព្វផ្សាយ ឬក៏មិនផ្សព្វផ្សាយទេពីព្រោះវាមានផលប៉ះពាល់យ៉ាងខ្លាំង"។

នីតិវិធីសំរាប់សរសេរវិចារណកថានៅស្ថានីយ៍ផ្សេងៗទៀតមិនសូវច្បាស់ទេ ប៉ុន្តែអ្នកយកព័ត៌មាននោះដែលបានរៀបរាប់អំពីរបបការត្រួតពិនិត្យនៅ **ទទក** បាននិយាយថា ភាពតឹងតែងមាននៅគ្រប់ទីកន្លែង ។

អ្នកយកព័ត៌មានដដែលនោះបានបន្តថា "ខ្ញុំមានមិត្តភ័ក្តច្រើនធ្វើការនៅស្ថានីយទូរទស្សន៍នានា ហើយពួកគេទាំងអស់មានពិធីការពួកគេមានសិទ្ធិផ្សាយរឿង ប៉ុន្តែគ្មានសិទ្ធិផ្សាយរឿងពិតទេ"។

មន្ត្រីជាន់ខ្ពស់ម្នាក់នៃស្ថានីយទូរទស្សន៍ឯកជនបាននិយាយប្រាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលកាលពីពីរបីឆ្នាំកន្លងទៅថា ប្រសិនបើគាត់មានចម្ងល់អំពីការផ្សាយរឿងអ្វីមួយ គាត់ត្រូវទូរស័ព្ទទៅសួរទីប្រឹក្សានាយករដ្ឋមន្ត្រីសិនដើម្បីទទួលការណែនាំ។

នៅ **ទទក** និងស្ថានីយផ្សេងៗទៀត ក៏មានគោលការណ៍មិនផ្សាយរឿងរបស់បុគ្គលិកមួយចំនួន (ដូចជាប្រធានអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ដែលចាត់ទុកថាមានលក្ខណៈរិះគន់ដល់រដ្ឋាភិបាល)

---

[១៣១] សម្ភាសន៍ជាមួយអ្នកយកព័ត៌មានម្នាក់ថ្ងៃទី១១ កញ្ញា ២០០៧។ អ្នកយកព័ត៌មាននោះបានផ្តល់បទសម្ភាសន៍ យ៉ាងពិស្តារអំពីការត្រួតពិនិត្យទទក និងការសម្ភាសន៍អ្នកសារព័ត៌មានផ្សេងៗទៀត បានបញ្ជាក់ជាទូទៅអំពីការត្រួតពិនិត្យមុនពេលផ្សាយនៅតាមស្ថានីយរបស់ពួកគេ។

មនុស្សប្រភេទនោះ គឺមិនសូវមានឃើញក្នុងកញ្ចក់ទូរទស្សន៍ទេ លើកលែងតែបុគ្គលនោះចូលរួមក្នុងព្រឹត្តិ-ការណ៍ណាមួយដែលរៀបចំដោយរដ្ឋាភិបាល ក្នុងករណីនេះគេបង្ហាញថាមានការគាំទ្ររដ្ឋាភិបាល។

នៅក្នុងករណីដោយឡែក ប្រសិនបើមានបញ្ហាដែលគេចាត់ទុកថាជាបញ្ហាស្មុគស្មាញនោះរដ្ឋាភិបាលនឹងចេញប្រកាសការហាមប្រាមដល់ប្រព័ន្ធផ្សាយព័ត៌មាននានាមិនឱ្យផ្សាយ។ ឧទាហរណ៍មួយ គឺភាពចម្រូងចម្រាសនៃសន្ធិសញ្ញាព្រំដែនរវាងកម្ពុជា និងវៀតណាមនៅចុងឆ្នាំ២០០៥។ រដ្ឋាភិបាលបានហាមឃាត់គ្រប់ប្រព័ន្ធផ្សាយព័ត៌មានទាំងអស់ថា បើអ្នកណាផ្សព្វផ្សាយពីសន្ធិសញ្ញានេះអាចនឹងប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍។ ប្រព័ន្ធផ្សាយព័ត៌មានគាំទ្ររដ្ឋាភិបាលជាច្រើន មិនបានរាយការណ៍អំពីបញ្ហានេះទេ ទោះបីជារឿងនេះមានសារៈសំខាន់សំរាប់ជាតិក៏ដោយ គឺគ្រាន់តែផ្សាយអំពីមាគ៌ារបស់រដ្ឋាភិបាលជាផ្លូវការតែប៉ុណ្ណោះ។ លោក ម៉ម សូណង់ដូ នាយកវិទ្យុសម្បុកឃ្មុំត្រូវបានចាប់ខ្លួន និងជាប់ពន្ធនាគារអស់រយៈពេល៣ខែ ក្រោយពីលោកបានផ្សាយការសម្ភាសន៍មួយជាមួយសកម្មជនដែលរិះគន់សន្ធិសញ្ញាព្រំដែន។

ការហាមប្រាមមួយទៀត គឺការផ្សាយរបាយការណ៍របស់អង្គការឃ្លាំមើលបរិស្ថានមួយឈ្មោះគ្លូបាលវិតណេស (Gobal Witness) ដែលបានសរសេរភ្ជាប់ការកាប់ឈើខុសច្បាប់ទៅនឹងមន្ត្រីរដ្ឋាភិបាលធំៗមួយចំនួន។ កាលពីថ្ងៃទី៣ ខែមិថុនា ២០០៧ ក្រសួងព័ត៌មានបានណែនាំក្រសួងមហាផ្ទៃហាមប្រាមកុំឱ្យមានការផ្សាយរបាយការណ៍នោះ។ នៅពេលដែលសារព័ត៌មានប្រឆាំងឈ្មោះ ស្រឡាញ់ខ្មែរ បានចុះផ្សាយទាំងស្រុងនូវរបាយការណ៍នោះសារព័ត៌មាននោះត្រូវបានបញ្ជាឱ្យឈប់ផ្សាយភ្លាមៗ ឬ បើមិនដូច្នេះទេនឹងត្រូវប្រឈមមុខនឹងច្បាប់។

លោករដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍កាលពីថ្ងៃទី៨ មិថុនា ថា "ប្រព័ន្ធផ្សាយព័ត៌មានបានផ្សាយមួយសប្តាហ៍រួចហើយ (អំពីរបាយការណ៍នេះ) ប៉ុណ្ណោះវាហួសពីគ្រប់គ្រាន់ណាស់ហើយ"។ សារព័ត៌មានអាចនិយាយពីរឿងនេះបាន ប៉ុន្តែកុំចុះផ្សាយដដែលៗ។ ប្រសិនបើមិនគោរពតាមការហាមប្រាមនេះទេយើងនឹងចាត់វិធានការតាមផ្លូវច្បាប់បើចាំបាច់[១៣២]។

ពុំមានមូលដ្ឋានច្បាប់ណា សម្រាប់ឱ្យរដ្ឋាភិបាលកំណត់ពេលវេលាឱ្យប្រពន្ធ័ផ្សាយព័ត៌មានចុះផ្សាយបញ្ហាណាមួយឡើយ ឬ ហាមប្រាមមិនឱ្យចុះផ្សាយនូវសេចក្តីដកស្រង់ពីរបាយការណ៍ណាមួយឡើយ។

---

[១៣២] អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីម្នាក់បានទទួលការគំរាមដល់អាយុជីវិត បន្ទាប់ពីបានរាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើ "សេចក្តីថ្លែងការណ៍របស់អ្នកយកព័ត៌មានគ្មានព្រំដែន" ថ្ងៃទី១៩ មិថុនា ២០០៧ http://www.ifex.org/en/content/view/full/84236

ស្រដៀងគ្នានេះដែរ ក្រសួងព័ត៌មានធ្លាប់ហាមស្ថានីយវិទ្យុ និងទូរទស្សន៍ជាច្រើនដងពីការផ្សាយបទអត្ថាធិប្បាយរបស់អត្ថបទសារព័ត៌មាននានា។ ជាការទំលាប់ ការអានអត្ថបទសារព័ត៌មានដោយមានការវិភាគ ឬ អត្ថាធិប្បាយបន្ថែម គឺជាការផ្សាយពិសេសមួយរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍ក្នុងពេលបច្ចុប្បន្ន។ ដោយសារតែសារព័ត៌មានជាអ្នកផ្សព្វផ្សាយបញ្ហាដែលស្មុកស្មាញ ហើយទូរទស្សន៍ដែលមិនជំទាស់មិនហ៊ានប៉ះពាល់ទេ ដូច្នេះការហាមប្រាមមានឥទ្ធិពលខ្ពស់ក្នុងការបញ្ឈប់ការពិភាក្សានយោបាយខ្លាំងៗ ហើយបិទនូវច្រកនៃការទទួលព័ត៌មានសំខាន់ៗ។

## ***ការត្រួតពិនិត្យខ្លួនឯង***

ការត្រួតពិនិត្យដោយខ្លួនឯង ប្រហែលអាចជាការហាមប្រាមដ៏តឹងតែងជាងគេចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា។ សេរីភាពសារព័ត៌មាននេះ គឺទាក់ទងទៅនឹងម្ចាស់នៃប្រព័ន្ធផ្សាយព័ត៌មាន និងការលំអៀងខាងនយោបាយ។ អ្នកសារព័ត៌មានកម្ពុជាមិនចាំបាច់គេប្រាប់ជារៀងរាល់ថ្ងៃ នូវអ្វីដែលត្រូវសរសេរ និងត្រូវសរសេរដូចម្តេចទេ។ អ្នកសារព័ត៌មានទាំងអស់នោះពិតជាដឹងនូវលទ្ធផល ដែលអ្នកទាំងនោះបានទទួលទោះជាការសរសេរនោះគាំទ្ររដ្ឋាភិបាល ឬ ការរិះគន់ធ្ងន់ៗក៏ដោយ ។

អ្នកសារព័ត៌មាន និងបណ្ណាធិការជាច្រើន ដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងអំពីព្រំដែននៃសេរីភាពសារព័ត៌មានរបស់ពួកអ្នកទាំងអស់នោះ ជាពិសេសចំពោះបញ្ហាស្មុកស្មាញ ឬ បញ្ហាចម្រូងចម្រាសនានា ដែលចាត់ទុកថាមិននៅក្នុងដែនកំណត់ ឬ យ៉ាងតិចក៏ជាកន្លែងគ្រោះថ្នាក់ដែរ។ បណ្ណាធិការជាន់ខ្ពស់ម្នាក់បានមានប្រសាសន៍ថា "៩០%នៃរឿងរ៉ាវទាំងឡាយ អ្នកអាចសរសេរបានដោយសេរី"។ ការលំបាកខ្លាំងនោះគឺពេលដែលសារព័ត៌មានត្រូវត្រួតពិនិត្យខ្លួនឯងនោះគឺ "រឿងណាដែលនិយាយអំពីអំពើពុករលួយ"[១៣៣] ។

លោក ពុយ គា អ្នកឆ្លើយឆ្លងព័ត៌មានទីភ្នាក់ងារសារព័ត៌មានជប៉ុន ក្យូដូ (Kyodo) និងជាអ្នកនិពន្ធកូនសៀវភៅផ្តត់អំពីវិទ្យុកម្ពុជាបានមានប្រសាសន៍ថា "ការត្រួតពិនិត្យខ្លួនឯងនៅក្នុងប្រព័ន្ធផ្សាយព័ត៌មានមាននៅក្នុងកម្ពុជា"។ បញ្ហានេះជាធម្មតាវាកើតឡើងនៅក្នុងគ្រប់ស្ថាប័នប្រពន្ធ័ផ្សាយព័ត៌មានទាំង

---

[១៣៣] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ ថ្ងៃទី១២ កញ្ញា ២០០៧។

ឡាយដែលគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច។ នោះមានទាំងទូរទស្សន៍ វិទ្យុ និងសារព័ត៌មាន" [១៣៤] ។

លោក ពុយ គា មានប្រសាសន៍បន្ថែមទៀតថា ការត្រួតពិនិត្យដោយខ្លួនឯងនេះ ផ្តើមចេញពីការណែនាំដល់ម្ចាស់ស្ថានីយវិទ្យុ និងនិពន្ធនាយកសារព័ត៌មាននានាឱ្យប្រុងប្រយ័ត្នអំពីការផ្សាយបញ្ហានយោបាយនានា ជាពិសេស រឿងណាដែលពាក់ព័ន្ធនឹងគណបក្សប្រជាជនកម្ពុជា។

លោក គង់ សុត្ថាណារីទ្ធ អ្នកសារព័ត៌មាននៃវិទ្យុអន្តរជាតិបារាំង មានទស្សនៈស្រដៀងគ្នានេះដែរ។ លោកមានប្រសាសន៍ថា "ស្ថានីយវិទ្យុណាមួយដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ឬ គណបក្សកាន់អំណាចត្រូវតែគោរពតាមមាគ៌ារបស់បក្សនូវគោលការណ៍ត្រួតពិនិត្យខ្លួនឯង" [១៣៥] ។

### *ការផ្អាក*

តាមច្បាប់ស្តីពីសារព័ត៌មាន ក្រសួងព័ត៌មានមានអំណាចផ្អាកការផ្សាយរបស់សារព័ត៌មានណា ដែលផ្សាយអត្ថបទនាំឱ្យប៉ះពាល់ដល់ "សន្តិសុខជាតិ និងស្ថិរភាពនយោបាយ" (ពុំមានចែងច្បាស់នៅក្នុងច្បាប់ទេ)។ ការផ្អាកអាចមានរយៈពេលរហូត ៣០ថ្ងៃ [១៣៦]។ បញ្ញត្តិនេះច្រើនតែត្រូវបានប្រើប្រាស់ខុសគោលដៅដើម្បីបិទមាត់ពួកប្រឆាំង ឬ ដាក់ទណ្ឌកម្មសេចក្តីរាយការណ៍ណាដែលប៉ះពាល់កេរ្តិ៍ឈ្មោះករណីភាគច្រើន គឺពុំឃើញមានការគំរាមកំហែងដល់ "សន្តិសុខជាតិ" សូម្បីតែបន្តិចទាល់តែសោះ។ គេអាចនិយាយថាពាក្យដែលមិនច្បាស់លាស់ "ស្ថិរភាពនយោបាយ" គឺឱ្យតែសារព័ត៌មានមានការចុះផ្សាយអ្វីដែលប៉ះពាល់តិចតួចបំផុតដល់រឿងនយោបាយ គឺអាចយកមកប្រើថាប៉ះពាល់ដល់ "ស្ថិរភាពនយោបាយ" ។

ច្រើនឆ្នាំកន្លងមកនេះ មានការផ្អាក និងការគំរាមកំហែងផ្អាកសារព័ត៌មានជាច្រើន។ សារព័ត៌មានខ្មែរអមតៈ គឺជាសារព័ត៌មានមួយដែលមានទំនាក់ទំនងជាមួយគណបក្ស នរោត្តម រណឫទ្ធិ ត្រូវបានក្រសួងព័ត៌មាន ផ្អាកនៅក្នុងខែតុលា ២០០៧ ថ្មីៗនេះ។ ការផ្អាកនេះ គឺជាវិធានការមួយក្នុងចំណោមវិធានការនានារបស់លោកអគ្គលេខាធិការគណបក្សហ្វ៊ុនស៊ិនប៉ិច និងជាឧបនាយករដ្ឋមន្ត្រី។ រឿងល្មើសនោះបានអះអាងថាលោកអគ្គលេខាធិការគណបក្សហ្វ៊ុនស៊ិនប៉ិច និងមេដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិចផ្សេងទៀត បានប្តូរឈ្មោះ

---

[១៣៤] ពុយ គា ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ២០០៧។

[១៣៥] ដកស្រង់ពី សៀវភៅរបស់ ពុយ គា អំពីវិទ្យុកម្ពុជា។

[១៣៦] មាត្រា ១២ នៃច្បាប់ស្តីពីសារព័ត៌មាន។

សាលាពីឈ្មោះ នរោត្តម រណឫទ្ធិ មកជាឈ្មោះ ញឹក ប៊ុនឆៃ វិញ។ លោកឧបនាយករដ្ឋមន្ត្រីរូបនេះ បានទាមទារឱ្យមានការកែតម្រូវ ប៉ុន្តែនិពន្ធនាយករបស់សារព័ត៌មានខ្មែរអមតៈបានអះអាងថា លោកមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្ររឿងនោះ ហើយបានស្នើសុំឱ្យដោះស្រាយតាមផ្លូវតុលាការ។ ក៏ប៉ុន្តែក្រសួងព័ត៌មានទៅជាផ្អាកអាជ្ញាប័ណ្ណ សារព័ត៌មានអស់រយៈពេល ១ ខែ នៅថ្ងៃទី៨ តុលា ទៅវិញ[១៣៧]។

## ការរឹបអូស

ការរឹបអូសនៃការបោះពុម្ពផ្សាយសារព័ត៌មាន ក៏ត្រូវបានអនុញ្ញាតតាមមាត្រានៃច្បាប់សារព័ត៌មាន "សន្តិសុខជាតិ និងស្ថិរភាពនយោបាយ" ដូចគ្នាដែរ។ ការរឹបអូសនេះគឺជាមធ្យោបាយមួយទៀតដែលមានប្រសិទ្ធិភាពសំរាប់បិទមាត់ប្រពន្ធ័ផ្សាយសារព័ត៌មានដែលខ្វែងយោបល់។

នៅឆ្នាំ២០០៥ និង ២០០៧ រដ្ឋាភិបាលបានរឹបអូសរបាយការណ៍របស់អង្គការឃ្លាំមើលបរិស្ថានក្លូបាលវិតណេស (Global Witness) ពីរដង ដែលនិយាយអំពីការកាប់ព្រៃឈើខុសច្បាប់។ ថ្វីត្បិតតែអង្គការឃ្លាំមើលបរិស្ថាន ក្លូបាលវិតណេស (Global Witness) មិនបានចុះបញ្ជីជាសារព័ត៌មានជាផ្លូវការនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏របាយការណ៍ក្លូបាលវិតណេស (Global Witness) បានបន្តផ្សព្វផ្សាយសព្វទិសទី នៅក្នុងសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ។ គ្មានហេតុផលច្បាប់ជាផ្លូវការណា សម្រាប់ហាមប្រាមមិនឱ្យផ្សព្វផ្សាយ និងរឹបអូសដូចពីការរឹបអូសរបាយការណ៍របស់ក្លូបាលវិតណេស (Global Witness) នៅឆ្នាំ២០០៧ នោះទេ ក៏ប៉ុន្តែក្រសួងព័ត៌មានបានអះអាងថា "ការផ្អាក និង ការរឹបអូសរបាយការណ៍នោះមិនពាក់ព័ន្ធទៅនឹងសេរីភាពក្នុងការចុះផ្សាយ និងផ្សព្វផ្សាយព័ត៌មានឡើយ ដែលរដ្ឋាភិបាលគាំទ្រយ៉ាងពេញទំហឹងនូវសេរីភាពក្នុងការចុះផ្សាយ និងផ្សព្វផ្សាយព័ត៌មាន"[១៣៨]។ ការរឹបអូសនេះត្រូវបានរិះគន់យ៉ាងខ្លាំងដោយក្រុមសិទ្ធិមនុស្ស និង "សេរីភាពសារព័ត៌មានអន្តរជាតិ"។

ករណីរឹបអូសមួយទៀតនៅឆ្នាំ២០០៧ គឺការបោះពុម្ពផ្សាយដែលជាការបង្ករហេតុមួយ ហៅថា *សេរីភាពសារព័ត៌មានទស្សនាវដ្តី* ដែលចេញផ្សាយដោយលោក លឹម ពិសិដ្ឋ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី

---

[១៣៧] សារព័ត៌មានមួយត្រូវផ្អាក ដោយការបដិសេធមិនព្រមចុះផ្សាយអត្ថបទព្រឹត្តិការណ៍របស់ក្រសួង-សេចក្តីប្រកាសអាសន្នរបស់សម្ព័ន្ធភាពសារព័ត៌មានអាស៊ីអាគ្នេយ៍ថ្ងៃទី៩ តុលា ២០០៧ ។

[១៣៨] រដ្ឋាភិបាលបានហាមរបាយការណ៍របស់ក្លូបាលវិតណេស (Global Witness) ដែលភ្ជាប់មន្ត្រីកំពូលៗទៅនឹងការកាប់ឈើខុសច្បាប់។ សេចក្តីអាសន្នរបស់សម្ព័ន្ធភាពសារព័ត៌មានអាស៊ីអាគ្នេយ៍ចុះថ្ងៃទី៦ មិថុនា ២០០៧។

ម្នាក់ ហើយដែលបានរត់ភាសខ្លួនពីការគំរាមកំហែងដល់អាយុជីវិតកាលពីដើមឆ្នាំ២០០៧នេះ។ ទស្សនាវដ្តីនោះរួមមានអត្ថបទ និងគំនូរនានាពិព័ណ៌នាអំពីបញ្ហាស្មុគស្មាញមួយចំនួន ដូចជាការកាប់ឈើខុសច្បាប់ ការសម្លាប់មេដឹកនាំសហជីពសេរីកម្មករ លោក ជា វិជ្ជា និងអ្នកចម្រៀង ពិសិដ្ឋ ពិលិកា ព្រមទាំងសាលាក្តីខ្មែរក្រហម។ ទស្សនាវដ្តីទាំង២០០០ ច្បាប់ត្រូវបានរឹបអូសដោយនគរបាល ហើយលោក លឹម ពិសិដ្ឋ និងអ្នកចែកចាយម្នាក់បានរត់ពួនដោយខ្លាចគេចាប់[១៣៩]។

ជាទូទៅ ការរឹបអូសបែបនេះត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃ (គឺនគរបាល) តាមការស្នើរបស់ក្រសួងព័ត៌មាន ។

បណ្ណាធិការម្នាក់មានប្រសាសន៍ថា "រឿងនេះមិនត្រឹមត្រូវទេ"។ "ក៏ប៉ុន្តែ ច្បាប់អនុញ្ញាតឱ្យមាន (រឹបអូសការផ្សព្វផ្សាយនេះ)"[១៤០]។

## *ករណីសិក្សា : ការបំភ្លេចរឿងចោល*

*សារព័ត៌មានសម្លេងយុវជនខ្មែរធ្លាប់មានឈ្មោះថាជាសារព័ត៌មានមួយជំទាស់ ហើយបច្ចុប្បន្ននេះមានទំនាក់ទំនងជាមួយនឹងគណបក្ស នរោត្តម រណឫទ្ធិ។ កាលពីខែមិថុនា ២០០៦ សារព័ត៌មាននេះបានចាប់ផ្តើមចុះផ្សាយនូវរឿងជាបន្តបន្ទាប់ដែលចោទប្រកាន់ លោកឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីរឿងដីធ្លី ។*

*បន្ទាប់ពីបានចេញផ្សាយ ៣ រឿងជាប់ៗគ្នា លោកបណ្ណាធិការ កែវ សុធា ចាប់ផ្តើមទទួលទូរស័ព្ទគំរាមកំហែង។ ប៉ុន្តែគាត់សម្រេចចិត្តបន្តចុះផ្សាយអត្ថបទនៅក្នុងខ្សែរឿងនោះបន្តទៀត ។*

*នៅពេលដែលភស្តុតាងបានបញ្ជូនដល់រោងពុម្ពភ្លាមៗ បណ្ណាធិការក៏បានទទួលទូរស័ព្ទថែមទៀតដោយនិយាយថា "ប្រសិនបើលោកចុះរឿងដដែលៗទៀត លោកអាចនឹងមានបញ្ហា"។*

*ព្រឹកស្អែកឡើង មានជនអនាមិកម្នាក់បានទិញសារព័ត៌មានទាំងអស់របស់សម្លេងយុវជនខ្មែរ ពីអ្នកចែកចាយសារព័ត៌មាន។ មានតែសារព័ត៌មានចំនួនតិចតួចតែប៉ុណ្ណោះ ដែលបានទៅដល់តូបលក់សារ-*

[១៣៩] រដ្ឋាភិបាលបានរឹបអូសទស្សនាវដ្តីព័ត៌មានដោយបានចុះផ្សាយអត្ថបទរិះគន់។ បណ្ណាធិការនាយក និងអ្នកចែកចាយ បានរត់គេចដោយខ្លាចប្រឈមមុខនឹងការចាប់ខ្លួន។ សម្ព័ន្ធភាពសារព័ត៌មានអាស៊ីអាគ្នេយ៍ ២០ វិច្ឆិកា ២០០៧។

[១៤០] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ថ្ងៃទី១២ កញ្ញា ២០០៧។

*ព័ត៌មាន ក៏ប៉ុន្តែសារព័ត៌មានត្រូវបានរឹបអូសដោយនគរបាល ។*

*លោក កែវ សុធា មានប្រសាសន៍ថា "ក្រោយពីនោះមក ខ្ញុំបានសម្រេចចិត្តឈប់សរសេររឿងនេះពីព្រោះខ្ញុំគិតថា ខ្ញុំនឹងប្រឈមមុខរឿងមិនល្អ ហើយគ្មាននរណាអាចជួយខ្ញុំបានទេ" ។*

## ការទទួលបានព័ត៌មាន

ការត្អូញត្អែរមួយដែលជួបច្រើនជាងគេក្នុងចំណោមពួកអ្នកសារព័ត៌មាន គឺការពិបាកក្នុងការរកព័ត៌មាននៅកម្ពុជា។ នេះគឺសំដៅលើការទទួលបានព័ត៌មានពីមេដឹកនាំនយោបាយធំៗ មន្ត្រីយោធា និងតុលាការជាដើម ។ ព័ត៌មានពីនគរបាលហាក់ដូចជាបែងចែកជាពីរស្មើគ្នារវាងក្រុម "ងាយស្រួល" និង "លំបាក" ប្រហែលជាអាស្រ័យទៅលើទំនាក់ទំនងផ្ទាល់ខ្លួន និងទំនោរនយោបាយរបស់ប្រពន្ធ័ផ្សាយព័ត៌មាន ។

គួរចងចាំថា សិទ្ធិក្នុងការទទួលបានព័ត៌មាន គឺពុំបានស្ថិតនៅក្នុងផ្នែកណាមួយនៃប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្នទេ។ ក្នុងរបបខ្មែរក្រហម ការសួរសំណួរទៅកាន់អាជ្ញាធរគឺត្រូវស្លាប់ ហើយក្នុងសម័យដែលកាន់កាប់ដោយវៀតណាមពីឆ្នាំ១៩៧៩ ដល់ ១៩៨៩ របបកុម្មុយនីស្ត បានគ្រប់គ្រងព័ត៌មានយ៉ាងតឹងតែងដោយអនុញ្ញាតឱ្យមានតែប្រពន្ធ័ផ្សាយព័ត៌មានរបស់រដ្ឋប៉ុណ្ណោះ ។

ដោយសារតែលំហូរនៃព័ត៌មានបានកើនឡើងចាប់តាំងពីសម័យខ្មៅងងឹតនោះមក ទង្វើរបៀបនេះនៅសេសសល់នៅឡើយ ។ នៅក្នុងក្រសួងរបស់រដ្ឋាភិបាលជាច្រើន មានតែមន្ត្រីអាជ្ញាធរជាន់ខ្ពស់បំផុត ត្រូវបានអនុញ្ញាតឱ្យនិយាយជាមួយសារព័ត៌មាន ហើយជួនកាលមន្ត្រីទាំងនោះសំរេចចិត្តថាមិននិយាយជាមួយសារព័ត៌មានទៀតផង ។ អ្នកសារព័ត៌មានធ្លាប់បានជួបជាមួយនឹងមន្ត្រីជាន់ខ្ពស់ដែលបិទទូរសព្ទ័ ហើយជួនកាល មន្ត្រីនោះបានបដិសេធថាពុំមែនជាម្ចាស់ទូរស័ព្ទទេ។ រឿងមួយទៀតគឺថា មន្ត្រីទាំងនោះច្រើនតែប្រាប់អ្នកសារព័ត៌មានថាសូមទាក់ទងនាយកដ្ឋាននេះ ឬ នាយកដ្ឋាននោះ "បញ្ជូនពីនាយកដ្ឋានមួយទៅនាយកដ្ឋានមួយទៀត" រហូតដល់ព័ត៌មាននោះចេះតែសាបទៅៗ ភ្លេចអស់ ។

រឿងជាក់ស្តែងមួយកើតឡើងបែបនេះ :

*នៅថ្ងៃអាទិត្យមួយមិនអាចទាក់ទងលោករដ្ឋមន្ត្រីក្រសួងបរិស្ថាន ម៉ុក ម៉ារេត បានឡើយ។ លោករដ្ឋលេខាធិការក្រសួងបរិស្ថាន ខៀវ មុត បញ្ជូនសំណួរឱ្យទៅសួរលោករដ្ឋលេខាធិការ យឹម គឹមស៊ាន ដែលមានប្រសាសន៍ថាតំបន់ជម្រកសត្វនោះមិនស្ថិតក្រោមឱវាទរបស់លោកទេ*[១៤១]។

ក្នុងចំណោមមន្ត្រីជាន់ខ្ពស់នានា តិចតួចណាស់ដែលដឹងពីការទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សាយព័ត៌មាន និងសាធារណជនទូទៅ មិនដូចនៅក្នុងប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដឡើយ។ រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ជាច្រើន កម្រវៀបចំសន្និសីទសារព័ត៌មានណាស់។ ភាគច្រើនមន្ត្រីទាំងនោះច្រើនតែធ្វើសន្ទរកថានៅក្នុងពិធីបុណ្យ ឬ ក្នុងពិធីសម្ភោធនានាដែលត្រូវបានប្រើប្រាស់សំរាប់ផ្សាយសារ។ ជាធម្មតាគ្មានឱកាសនឹងអាចសួរសំណួរបានឡើយ។

បណ្ណាធិការម្នាក់មានប្រសាសន៍ថា "យើងមានសេរីភាពសារព័ត៌មាន ប៉ុន្តែរដ្ឋាភិបាលនៅតែលាក់ព័ត៌មាន"[១៤២]។

ប្រព័ន្ធតុលាការជាទូទៅគឺជាកន្លែងដែលអ្នកសារព័ត៌មានជាច្រើនអាចដកស្រង់ព័ត៌មានបាន ក៏ប៉ុន្តែបែរជាកន្លែងមួយដែលពិបាកចូលទៅយកព័ត៌មានទៅវិញ។ នៅពេលដែលគេសួរអ្នកសារព័ត៌មានអំពីការទទួលព័ត៌មានពីប្រភពផ្សេងៗ ពួកគេឆ្លើយថាតុលាការគឺជាកន្លែងដែលពិបាកជាងគេបំផុត ដោយមានអ្នកឆ្លើយ ៧៥% និយាយថាវាជារឿង "ពិបាក" ឬ "ពិបាកណាស់" ក្នុងការសុំព័ត៌មានពីមន្ត្រីតុលាការ[១៤៣]។ តុលាការកម្ពុជា គឺជាតុលាការដែលមិនមានឈ្មោះល្អពីរឿងពុករលួយ និងលំអៀងខាងនយោបាយ ដូច្នេះបុគ្គលិកតុលាការប្រយ័ត្នបំផុតចំពោះការលាតត្រដាងនូវអំពើខុសច្បាប់ ឬ ខុសក្រមសីលធម៌។

នៅក្នុងចលនាមួយ ដែលចេះតែធ្វើឱ្យតុលាការឃ្លាតឆ្ងាយពីអ្នកសារព័ត៌មាន នៅក្នុងឆ្នាំ ២០០៥ តុលាការក្រុងភ្នំពេញបានហាមមិនឱ្យប្រើម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូ និងឧបករណ៍ថតសម្លេងនានានៅក្នុងទីធ្លាអគារតុលាការ។ ជាពិសេសនៅក្នុងបន្ទប់សវនាការ ឧបករណ៍ទាំងអស់នេះត្រូវបានហាមឃាត់ទាំង

---

[១៤១] អង្គការមិនមែនរដ្ឋាភិបាល ៖ ក្រសួងបានស្ទាបស្ទង់តួនាទីរបស់កងយោធពលខេមរភូមិន្ទ អំពីបញ្ហាជម្រកសត្វ។ សារព័ត៌មាន ឌឹ ឃែមបូឌា ដេលី ២៧ សីហា ២០០៧។

[១៤២] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ ថ្ងៃទី១៣ កញ្ញា ២០០៧ ។

[១៤៣] សូមអានការស្រាវជ្រាវអំពីប្រព័ន្ធផ្សាយព័ត៌មាន-សំណួរ ២៣។ កន្លែងដែលលំបាករកព័ត៌មានបន្ទាប់ពីនេះទៀតគឺតាមក្រសួងនានា។

ស្រុង ក៏ប៉ុន្តែការហាមឃាត់នេះបានធ្វើឱ្យអ្នកយកព័ត៌មានរបស់ប្រព័ន្ធផ្សាយព័ត៌មានស្ថិតនៅក្រៅរបង តុលាការ ដែលជាការលំបាកយ៉ាងខ្លាំងដល់អ្នកសារព័ត៌មានដើម្បីថតយកសម្លេង និងរូបភាព។

ការទទួលបានព័ត៌មាននៅតាមតំបន់នីមួយៗ គឺអាស្រ័យទៅលើអ្នកណាជាអ្នកចង់បានព័ត៌មាន នោះយកទៅធ្វើអ្វី។ អាជ្ញាធរអាចសហការជាមួយអ្នកសារព័ត៌មានណាដែលពួកគេ "ទុកចិត្ត" (ត្រូវធានាថា ព័ត៌មានដែលផ្តល់ឱ្យនឹងមិនត្រូវបានប្រើដើម្បីឆ្លុះបញ្ចាំងអំពើមិនល្អរបស់រដ្ឋាភិបាលឡើយ) ប៉ុន្តែមិនផ្តល់ឱ្យ អ្នកណាដែលពុំស្គាល់គ្នាជិតស្និទ្ធឡើយ។

ដោយសារតែការខ្វះខាតទទួលព័ត៌មានតាមផ្លូវការ ធ្វើឱ្យអ្នកដែលផ្តល់ព័ត៌មានជាច្រើនសុំមិន បញ្ចេញឈ្មោះពីប្រភព។ អ្នកសារព័ត៌មានទាំងឡាយ ជាពិសេសអ្នកយកព័ត៌មាននយោបាយ បង្កើតនូវ បណ្តាញមន្ត្រីថ្នាក់ក្រោម និងថ្នាក់កណ្តាលដែលពួកគេដកស្រង់សម្តីដោយមិនបញ្ចេញឈ្មោះឡើយ។ នៅ ពេលធ្វើការស្រាវជ្រាវសំរាប់របាយការណ៍នេះ ៥៥% នៃអ្នកសារព័ត៌មានបាននិយាយថាពួកគេបានប្រើ ប្រភពអនាមិក ហើយ ១៣% ប្រើប្រភពអនាមិកនៅក្នុង "គ្រប់រឿងទាំងអស់"[១៤៤] ។

ប្រភពអនាមិក គឺជាផ្នែកមួយដែលអាចទទួលយកបាននៅក្នុងវិស័យសារព័ត៌មានទូទាំងពិភពលោក ក៏ប៉ុន្តែអ្នកសារព័ត៌មានដែលមានការទទួលខុសត្រូវ ប្រើប្រាស់ប្រភពបែបនេះតិចតួចតែប៉ុណ្ណោះ ដូចជា ដើម្បីការពារអ្នកទម្លាយព័ត៌មានដែលពាក់ពន្ធ័ជាមួយការរំលោភ ឬ អំពើពុករលួយរបស់រដ្ឋាភិបាល។ នៅ ក្នុងបរិបទប្រពន្ធ័ផ្សាយព័ត៌មានកម្ពុជាដែលការឃោសនា និងការចោទប្រកាន់ដោយគ្មានភស្តុតាងគ្រប់គ្រាន់ គឺមានច្រើន ដូច្នេះការប្រើប្រាស់ប្រភពអនាមិកទូទៅ ក៏មិនអាចជួយបានច្រើនដែរ ដើម្បីកែលំអភាពមិន លំអៀង ឬ វិជ្ជាជីវៈនៃការបោះពុម្ពផ្សាយ ។

ច្បាប់ស្តីពីសារព័ត៌មានចែងថា ការស្នើសុំព័ត៌មានពីមន្ត្រីរដ្ឋាភិបាលអាចធ្វើជាលាយល័ក្ខអក្សរ ហើយមន្ត្រីត្រូវឆ្លើយតបក្នុងរយៈពេល ៣០ ថ្ងៃ ឬ បើមិនដូច្នេះត្រូវពន្យល់អំពីមូលហេតុ ដែលមិនអាចផ្តល់ ព័ត៌មាននោះបាន។ ២៨% នៃអ្នកសារព័ត៌មានដែលបានសម្ភាសន៍សំរាប់របាយការណ៍ បានឆ្លើយថា ពួកគេ បានប្រើប្រាស់យន្តការនេះ ប៉ុន្តែមិនបានច្បាស់ថាប៉ុន្មានដងដែលព័ត៌មានត្រូវបានផ្តល់ឱ្យ[១៤៥]។ និយាយឱ្យខ្លី អ្នកសារព័ត៌មាននិយាយថាពួកគេបានចៀសវាងក្នុងការសរសេរលិខិតស្នើសុំព័ត៌មាន ឬ សម្ភាសន៍ពីព្រោះ

---

[១៤៤] សូមអានការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ២២។

[១៤៥] សូមអានការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ២៤។

គេកម្រទទួលបានជោគជ័យណាស់ ហើយច្រើនតែត្រូវផ្តល់ប្រាក់កាសដល់មន្ត្រីថ្នាក់ក្រោមដើម្បីបញ្ជូនសំណើ ឬ ចំពោះ "ថ្លៃបោះពុម្ព" ឯកសារនោះ [១៤៦] ។

ច្បាប់ស្តីពីសេរីភាពក្នុងការទទួលព័ត៌មាន បច្ចុប្បន្នកំពុងត្រូវបានធ្វើសេក្តីព្រាងដោយមានជំនួយរបស់អង្គការមូលនិធិអន្តរជាតិ ប៉ុន្តែគេសង្កេតឃើញមានគំនិតយោបល់ចម្រុះគ្នា អំពីបញ្ហាថាតើច្បាប់ថ្មីនេះអាចធ្វើឱ្យមានការកែលំអការទទួលបានព័ត៌មានដែរឬទេ? ការភ័យខ្លាចរបស់សារព័ត៌មានជាច្រើន និងអ្នកធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន គឺថាច្បាប់នោះអាចត្រូវបានគេយកទៅប្រើដើម្បីឱ្យការហាមប្រាមក្នុងការទទួលបានព័ត៌មានរបស់រដ្ឋាភិបាល គឺជាប្រការស្របច្បាប់ទៅវិញ ។

[១៤៦] ដកស្រង់ពីការសម្ភាសន៍ជាមួយអ្នកសារព័ត៌មានជាន់ខ្ពស់ ថ្ងៃទី១២ កញ្ញា ២០០៧ ។ ព័ត៌មានខ្លីៗពីអ្នកសារព័ត៌មាននានា ។

# ភាគ ៣: ការវាយប្រហារ ការគំរាមកំហែង និងការភ័យខ្លាច

## ការវាយប្រហារលើរូបរាងកាយ

អ្នកសង្កេតការណ៍ជាច្រើនបានធូរស្បើយនៅក្នុងចិត្ត ដោយកត់សម្គាល់ឃើញថាមានការថយចុះនៃការសំលាប់ និងការវាយដំលើរូបរាងកាយទៅលើអ្នកសារព័ត៌មាននៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។

ប៉ុន្តែការរំលោភតិចតួចនៅតែបន្តកើតឡើង ហើយនៅតែមានការភ័យខ្លាចក្នុងចំណោមអ្នកសារព័ត៌មានដែលពួកគេអាចប្រឈមមុខនឹងបញ្ហាចំពោះការផ្សាយបញ្ហាស្មុកស្មាញ ជាពិសេសអំពើពុករលួយ ។

ចាប់តាំងពី អ៊ុនតាក់ បានព្យាយាមដាក់បញ្ចូលនូវសញ្ញាណនៃសេរីភាពសារព័ត៌មាននៅដើមឆ្នាំ ១៩៩០ មក តាមរបាយការណ៍បានឱ្យដឹងយ៉ាងតិចមានអ្នកសារព័ត៌មាន ៩ នាក់ ត្រូវបានធ្វើឃាដ ដោយសារតែការងាររបស់ពួកគេ។ ទោះបីជាមានការចាប់ខ្លួនឃាតករខ្លះក៏ដោយ ក៏មិនឃើញមានការផ្តន្ទាទោសឡើយ ។

អ្នកបម្រើការជាច្រើន ក្នុងប្រព័ន្ធផ្សាយព័ត៌មានមួយចំនួនបានរងរបួសនៅក្នុងការវាយប្រហារដូចជាការវាយដំបាញ់ វាយប្រហារដោយគ្រាប់បែក និងគ្រោះថ្នាក់ចរាចរគួរឱ្យសង្ស័យមួយចំនួន។

យ៉ាងតិចក៏មានអ្នកសារព័ត៌មានម្នាក់ដែរ ដែលបានបាត់ខ្លួននៅក្នុងកាលៈទេសៈមួយគួរឱ្យសង្ស័យ ។ លោក ជួន ពិនដារ៉ា អ្នកយកព័ត៌មានសារព័ត៌មាន អង្គបូរី បានបាត់ខ្លួននៅក្នុងខែកក្កដា ១៩៩៧ ក្រោយពីនគរបាលបានទៅដល់ផ្ទះរបស់លោកជាច្រើនដង ហើយការបាត់ខ្លួននេះនៅតែមិនទាន់បានដោះស្រាយនៅឡើយទេ[១៤៧] ។

និទណ្ឌភាពចំពោះការវាយប្រហារមកលើប្រព័ន្ធផ្សាយព័ត៌មាន គឺជាការបញ្ជូនសារយ៉ាងច្បាស់ថាអ្នកសារព័ត៌មាន គឺជាមនុស្សងាយរងគ្រោះ ហើយឃាតករគឺជាមនុស្សដែលមិនអាចប៉ះពាល់បានឡើយ ។

[១៤៧] កម្ពុជា : ការលេចឡើងនូវសង្គមស៊ីវិល ប្រឈមមុខនឹងអនាគតមិនជាក់លាក់ -សារ៉ា ខុម ១៩៩៧ ។

## ឃាតកម្ម[១៤៨]

**លោក ធូ ចាន់មង្គល** *ស្លាប់ថ្ងៃទី១១ មិថុនា ១៩៩៤*។

លោក ធូ ចាន់មង្គល ជានិពន្ធនាយកនៃសារព័ត៌មានអន្តរាគមន៍ ដែលចេញផ្សាយពីរសប្តាហ៍ម្តង បានស្លាប់មួយថ្ងៃក្រោយពីជួបប្រទះឃើញលោកសន្លប់ ដោយសាររបួសក្បាលនៅតាមផ្លូវមួយនៃទីក្រុងភ្នំពេញ។ ជាដំបូងនគរបាលបានអះអាងថា លោកជាជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរ ប៉ុន្តែគេពុំឃើញមានរបួសណាផ្សេងទៀតលើរូបរាងកាយរបស់លោកឡើយ ហើយម៉ូតូរបស់លោកក៏មិនឃើញមានស្នាមឆ្កូតដែរ។ មុននឹងលោក មង្គល ស្លាប់ សារព័ត៌មានអន្តរាគមន៍បានចុះផ្សាយអត្ថបទជាច្រើនចោទប្រកាន់រដ្ឋាភិបាល និងមន្ត្រីយោធាមួយចំនួនថាបានប្រព្រឹត្តអំពើពុករលួយ ហើយការិយាល័យសារព័ត៌មាននេះបានក្លាយជាគោលដៅនៃការវាយប្រហារដោយគ្រាប់បែក ក្នុងខែមិនា។

**លោក នន់ ចាន់** *ត្រូវបាញ់ស្លាប់ នៅថ្ងៃទី៧ កញ្ញា ១៩៩៤* ។

លោក នន់ ចាន់ ជាបណ្ណាធិការនៃសារព័ត៌មានសម្លេងយុវជនខ្មែរ ត្រូវបានជនមិនស្គាល់មុខបាញ់សម្លាប់នៅភ្នំពេញ។ លោក និងបុគ្គលិកសារព័ត៌មានមួយចំនួនទៀតបានរាយការណ៍ថា បានទទួលការគំរាមកំហែងដល់អាយុជីវិតមុននឹងឃាតកម្មនេះបានកើតឡើង។ សារព័ត៌មានរបស់លោកបានរិះគន់គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ីនប៉ិច ហើយធ្លាប់បានទទួលការព្រមានជាលាយល័ក្ខអក្សរពីក្រសួងព័ត៌មាន ។



មួយថ្ងៃក្រោយឃាតកម្មរបស់លោក នន់ ចាន់ លោករដ្ឋលេខាធិការក្រសួងព័ត៌មានបានមានប្រសាសន៍ថា : "ប្រសិនបើលោកមិនត្រូវបានធ្វើឃាតទេ យើងនឹងត្រូវប្តឹងលោក នន់ ចាន់"។

ជនសង្ស័យពីរនាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងឃាតកម្មនេះ ហើយតាមរបាយការណ៍ថា ជនទាំងពីរបានសារភាពទោសកំហុស ប៉ុន្តែក្រោយមកស្រាប់តែមានការលើកលែងការចោទប្រកាន់ទៅវិញ។ គ្មានព័ត៌មានអំពីអ្នកណាបញ្ជាឱ្យមានការសម្លាប់នេះត្រូវបានលាតត្រដាងឡើយ។

---

[១៤៨] ព័ត៌មាននេះត្រូវបានដកចេញពីប្រភពនានាជាច្រើនរួមមាន: គណៈកម្មការដើម្បីការពារអ្នកសារព័ត៌មាន ប្រព័ន្ធផ្សាយព័ត៌មានប្រជាធិបតេយ្យនៅកម្ពុជា ឡោ ចាន់ដារ៉ា អង្គការសហប្រជាជាតិរបាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សនៅកម្ពុជា១៩៩៨ ការតាំងជាប់របស់ Britt-Louise Edmanក្នុងអតីតកាលអង្គការលើកលែងទោសអន្តរជាតិ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ និងអង្គការលីកាដូ។

**លោក ចាន់ ដារ៉ា** *បាញ់ស្លាប់ នៅថ្ងៃទី ៨ ធ្នូ ១៩៩៤* ។

លោក ចាន់ ដារ៉ា គឺជាអ្នកឆ្លើយឆ្លងព័ត៌មានជាមួយសារព័ត៌មានកោះសន្តិភាព ហើយក៏រួមចំណែកជាមួយសារព័ត៌មានផ្សេងៗទៀតដែរ។ លោកបានចុះផ្សាយនូវអត្ថបទលាតត្រដាងអំពីអំពើពុករលួយប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល និងមន្ត្រីយោធាធំៗ ពាក់ព័ន្ធនឹងព្រៃឈើ និងកៅស៊ូក្នុងចំណោមពួកជន ដែលត្រូវបានចោទប្រកាន់ទាំងនោះ ដែលបានចុះផ្សាយដោយសារព័ត៌មានមួយឈ្មោះថា ព្រាបនាំសារបាន និយាយថាមានមន្ត្រីយោធាថ្នាក់វរសេនីយឯកដ៏ល្បីល្បាញម្នាក់ឈ្មោះ សាត សឿន។ លោក ចាន់ ដារ៉ា ត្រូវបានបាញ់សម្លាប់ក្រោយពីលោកត្រូវបានគេឃើញបានចាកចេញពីភោជនីយដ្ឋានមួយជាមួយ លោក សាត សឿន នៅខេត្តកំពង់ចាម។ នគរបាលក្រសួងមហាផ្ទៃបានចាប់ខ្លួន សាត សឿន ដែលក្រោយមកនៅតែបន្តគំរាមកំហែងដល់សារព័ត៌មានទាំងពីរព្រមទាំងប្រពន្ធរបស់លោក ចាន់ ដារ៉ា។ ក៏ប៉ុន្តែ វរសេនីយឯកនេះត្រូវបានលើកលែងការចោទប្រកាន់នៅក្នុងសវនាការ ហើយត្រូវបានដោះលែង។



ប៉ុន្មានឆ្នាំក្រោយមកទៀតលោក សាត សឿន បានជាប់ពាក់ព័ន្ធប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនទៀតរួមមានការសម្លាប់ និងការកាប់ព្រៃឈើខុសច្បាប់។ បច្ចុប្បន្នលោកស្ថិតនៅក្នុងពន្ធនាគារបន្ទាប់ពីត្រូវបានផ្តន្ទាទោសពីបទប៉ុនប៉ងធ្វើឃាតនៅឆ្នាំ ២០០៥ ។

**លោក ធន់ ប៊ុនលី** *បាញ់ស្លាប់នៅថ្ងៃទី ១៨ ឧសភា ១៩៩៦* ។

លោក ធន់ ប៊ុនលី ជាអ្នកនិពន្ធ និងបោះពុម្ពផ្សាយរបស់សារព័ត៌មានប្រឆាំងឈ្មោះថា ឧត្តគតិខ្មែរ ហើយក៏ជាសមាជិកគណៈកម្មការនាយកនៃគណបក្សជាតិខ្មែរ( ដែលក្រោយមកក្លាយជាគណបក្ស សម រង្ស៊ី)។ លោកត្រូវបានបាញ់សម្លាប់ពេលដែលលោកកំពុងជិះម៉ូតូនៅកណ្តាលទីក្រុងភ្នំពេញ។ អ្នកសារព័ត៌មានរូបនេះបានប្តឹងឧទ្ធរណ៍ជំទាស់នឹងការផ្តន្ទាទោសពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតពីរករណី ដោយបានរិះគន់រដ្ឋាភិបាលនៅក្នុងអត្ថបទ និងរូបថ្លុក។ លោក ធន់ ប៊ុនលី ព្រមទាំងបណ្តាធិការ នៃសារព័ត៌មានពីរទៀតសុទ្ធតែបានទទួលការព្រមានថា ជីវិតរបស់លោកកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់។ នៅពេលព្រឹកថ្ងៃដែលលោកស្លាប់ លោកបានចុះផ្សាយនូវអត្ថបទមួយនិយាយថា មានវរសេនីត្រីយ៍ មិនស្គាល់អត្តសញ្ញាណម្នាក់



នៅក្នុងកងកម្លាំងសន្តិសុខបានចេញមក និង "សំលាប់លោក"។ ប្រហែលជា ដោយសារអត្ថបទនោះហើយ មើលទៅបានជាមានការសម្លាប់លោក ពីព្រោះអត្ថបទនោះបានចម្អកឱ្យវរសេនីយត្រីយ៏នោះថាជាមនុស្សស្រវឹង និងគ្មានសមត្ថភាព ។

**លោក ជេត ជួនដារ៉ាវុធ** *ស្លាប់នៅក្នុងការវាយប្រហារដោយគ្រាប់បែកដៃ នៅថ្ងៃទី៣០ មិនា ១៩៩៧* ។



លោក ដារ៉ាវុធ គឺជាអ្នកយកព័ត៌មានសារព័ត៌មាន អ្នកប្រយុទ្ធ ដែលថ្មីៗនេះបានទទួលការ អនុញ្ញាតឱ្យបោះពុម្ពសារព័ត៌មានថ្មី។ លោកក៏ជាសមាជិកគណៈកម្មការនាយកនៃគណបក្សជាតិខ្មែរដែរ។ លោកបានស្លាប់ នៅក្នុងការវាយប្រហារដោយគ្រាប់បែកដៃមួយនៅខាងក្រៅរដ្ឋសភាជាតិនាទីក្រុងភ្នំពេញ ខណៈដែលលោកកំពុងយកព័ត៌មានអំពីការប្រជុំរបស់គណបក្សជាតិខ្មែរ ដែលលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងកំពុងតែថ្លែងសន្ទរកថា។ យ៉ាងតិចមានមនុស្ស ១៦ នាក់បានស្លាប់នៅក្នុងការវាយប្រហារនោះ ហើយអ្នកសារព័ត៌មានយ៉ាងតិចណាស់ ២២នាក់ បានរងរបួស និងខ្លះទៀតធ្ងន់ធ្ងរផង។

**លោក ពេជ្រ អែម** *បាញ់នៅថ្ងៃទី៤ ឧសភា ១៩៩៧ ស្លាប់ថ្ងៃទី៥ ឧសភា ១៩៩៧* ។

លោក ពេជ្រ អែម គឺជាអ្នកបច្ចេកទេស (ហើយតាមរបាយការណ៍ខ្លះ ក៏ជាអ្នកផ្សាយព័ត៌មានផងដែរ) នៅស្ថានីយ៏ទូរទស្សន៍ជាតិ **ឧឧភ** របស់រដ្ឋក្នុងក្រុងព្រះសីហនុ។ ជាច្រើនថ្ងៃមុននេះ មន្ត្រីនគរបាលជាន់ខ្ពស់ម្នាក់បានសុំស្នើឱ្យស្ថានីយ៏ចាក់ផ្សាយនូវសន្ទរកថានយោបាយរបស់ប្រធានគណបក្ស ហ៊្វុនស៊ីនប៉ិច។ ស្ថានីយ៏បានបដិសេធ។ នៅថ្ងៃទី៤ ឧសភា មានបុរស ៧ នាក់បានវាយប្រហារស្ថានីយ៏ដោយប្រើអាវុធអាកា៤៧ ហើយយ៉ាងតិចក៏មាន បេ ៤0 ពីរដើមដែរ។ លោក ពេជ្រ អែម ត្រូវគេបាញ់ត្រូវពោះពីរគ្រាប់ ហើយបានស្លាប់មួយថ្ងៃក្រោយមកនៅមន្ទីរពេទ្យ។ មនុស្សពីរនាក់ផ្សេងទៀត ត្រូវបានរងរបួសនៅក្នុងការវាយប្រហារនេះ ហើយឧបករណ៏នៅក្នុងស្ថានីយ៏ភាគច្រើនត្រូវបានខូចខាត ។

**លោក ម៉ៃឃីល សុខុន** (ឬ ម៉ៃឃីល ស៊ីនៀ) *ត្រូវគេបាញ់ស្លាប់ក្នុងខែកក្កដា ១៩៩៧* ។

លោក សុខុនគឺជាជនជាតិកាណាដាដែលមានដើមកំណើតខ្មែរ ដែលបានវិលត្រឡប់មកកម្ពុជាវិញ ហើយធ្វើការជាអ្នកអានព័ត៌មានទូរទស្សន៍ និងគ្រូបង្រៀនភាសាអង់គ្លេស។ លោកត្រូវបានបាញ់ស្លាប់ខណៈ

ដែលលោកកំពុងថតរូបសកម្មភាពលួចឆក់ប្លន់មួយប្រព្រឹត្តដោយពួកយោធានៅក្នុងផ្សារសាធារណៈមួយក្នុងព្រឹត្តការណ៍ឆ្នាំ១៩៩៧។ យោធាមួយក្រុមបានចូលមកជិតលោកហើយឃាត់លោក បន្ទាប់មកបានបាញ់លោកដំបូងត្រូវចំជង្គង់។ តាមរបាយការណ៍ថាខណៈដែលលោកដួលនៅលើផ្លូវ សុំអង្វរគេកុំឱ្យបាញ់ ពេលនោះគេបានបាញ់លោកម្តងទៀតនៅមុខប្រពន្ធ និងបងថ្លៃរបស់លោក។

**លោក អ៊ូ សារឿន** *បាញ់ស្លាប់នៅថ្ងៃទី១៤ តុលា ១៩៩៧* ។

លោក អ៊ូ សារឿន គឺជាអ្នកយកព័ត៌មាននៃសារព័ត៌មាន សម្លេងរាស្ត្រខ្មែរ ហើយជាកូនប្រុសរបស់អ្នកបោះពុម្ពផ្សាយសារព័ត៌មាននោះ។ ពួកសន្តិសុខផ្សារនៅទីក្រុងភ្នំពេញបានអូសលោកមកលើផ្លូវ ហើយបាញ់លោកស្លាប់ទៅ។ ឪពុករបស់លោកបានមានប្រសាសន៍ថា កូនប្រុសរបស់គាត់កំពុងស៊ើបអង្កេតក្នុងរឿងដែលពួកសន្តិសុខជម្រិតទារប្រាក់ពីអ្នកលក់ក្នុងផ្សារ។ របាយការណ៍ផ្លូវការនៃការស្លាប់របស់លោក អ៊ូ សារឿនបាននិយាយថាលោកកំពុងស្រវឹងហើយបានស្លាប់នៅក្នុងជម្លោះក្នុងវង់បៀ ប៉ុន្តែសមាគមអ្នកសារព័ត៌មានខ្មែរនៅតែអះអាងថា លោកត្រូវបានគេសម្លាប់ដោយសារតែការយកព័ត៌មានសំរាប់សារព័ត៌មាន។ នគរបាលបានចាប់ខ្លួនកងសន្តិសុខដែលបានបាញ់លោក អ៊ូ សារឿន ប៉ុន្តែក្រោយមកគេបានដោះលែងវិញ ហើយគ្មានការចោទប្រកាន់ទៅលើជនមុខសញ្ញានោះទៀតឡើយ។

**លោក ជូ ជេដ្ឋារីទ្ធ** *បាញ់ស្លាប់នៅថ្ងៃទី១៨ តុលា ២០០៣* ។

លោក ជេដ្ឋារីទ្ធ គឺជាបណ្ណាធិការរងនៃស្ថានីយ៍វិទ្យុតាព្រហ្ម ដែលជាវិទ្យុមានសម្ព័ន្ធភាពជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។ មនុស្សពីរនាក់ជិះម៉ូតូមួយគ្រឿងបានបាញ់លោកស្លាប់នៅមុខការិយាល័យរបស់លោកទាំងថ្ងៃ។ បួនថ្ងៃមុននេះ រដ្ឋាភិបាលបានចោទប្រកាន់វិទ្យុតាព្រហ្មថា បានប្រមាថមើលងាយការដឹកនាំរបស់រដ្ឋាភិបាល ហើយបានព្រមានស្ថានីយ៍ថា "ត្រូវតែត្រួតពិនិត្យកម្មវិធីរបស់ខ្លួនឡើងវិញ" ប្រសើរជាង។



ឃាតកម្មលើរូបលោក ជេដ្ឋារីទ្ធ កើតឡើងនៅមុនពេលការពិភាក្សាដែលបានគ្រោងទុករវាងភាគីទាំង៣ គឺគណបក្សប្រជាជនកម្ពុជា ហ៊្វុនស៊ិនប៉ិច និងសម រង្ស៊ី ដើម្បីបញ្ចប់នូវបញ្ហានយោបាយ ក្រោយពីគណបក្សប្រជាជនកម្ពុជាពុំមានទទួលសម្លេងគាំទ្រភាគច្រើន ពីរភាគបី នៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០០៣។ ការពិភាក្សានោះត្រូវបានលប់ចោលវិញ ក្រោយពីមានឃាតកម្មលើអ្នកសារព័ត៌មាន។ ប៉ុន្មានខែ

ក្រោយមកគណបក្សហ៊្វុនស៊ីនប៉ិច បានយល់ព្រមចូលរួមក្នុងរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជនកម្ពុជាជាថ្មីម្ដងទៀត។

ក្រោយពីមានអំពើឃាតកម្មរួចហើយ លោក ហេង ពៅ ដែលជាស្នងការនគរបាលរាជធានីភ្នំពេញកាលពីសម័យនោះ បានមានប្រសាសន៍ថា នគរបាលបានកំណត់អត្តសញ្ញាណជនសង្ស័យរួចហើយ ប៉ុន្តែពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីចាប់ជនណាមួយបាននៅឡើយទេ។

## *ការបង្ករបួសស្នាម*

ក្រៅពីអំពើឃាតកម្ម នៅមានករណីបង្ករបួសស្នាម និងប៉ុនប៉ងធ្វើឃាដលើអ្នកសារព័ត៌មានជាច្រើនទៀតក្នុងរយៈពេលជាង ១៥ ឆ្នាំកន្លងមកនេះ។ ការវាយប្រហារថ្មីៗរួមមាន:

នៅថ្ងៃទី២១ មិនា ២០០៦ ទាហានម្នាក់ដែលយាមនៅកសិដ្ឋានបង្កាត់ពូជស្វាដើម្បីនាំចេញ បានបង្ករបួសស្នាមលើអ្នកសារព័ត៌មានកោះសន្តិភាព នៅពេលដែលលោកបានព្យាយាមថតរូបកន្លែងបង្កាត់ពូជនៅខេត្តកំពង់ឆ្នាំង[១៤៩]។

អ្នកយកព័ត៌មានទស្សនាវដ្ដីម្នាក់ឈ្មោះ សាន ប៊ុនធឿន បានចោទប្រកាន់ថាកាលពីថ្ងៃទី៧ មេសា ២០០៧ លោក មួង ឃីម ជាមន្ត្រីនគរបាលជាន់ខ្ពស់ម្នាក់ និងជាស្វាមីតារាចម្រៀងប្រជាប្រិយឈ្មោះ ម៉េង កែវពេជ្រតា បានជះទឹកត្រីមកលើលោក ដោយសារតែអត្ថបទមួយបានចុះផ្សាយអំពីតារាចម្រៀងរូបនេះ។ ការប្រើប្រាស់ទឹកត្រីបែបនេះ ត្រូវបានចាត់ទុកជាអំពើធ្វើឱ្យអាមាស់មួយនៅក្នុងវប្បធម៌ខ្មែរ ហើយក៏ជាការគ្រាប់តាមការជះទឹកអាស៊ីដផងដែរ[១៥០]។

នៅថ្ងៃទី២១ មិថុនា ២០០៧ អ្នកយកព័ត៌មានពីរនាក់នៅខេត្តកំពង់ស្ពឺ ត្រូវកងរាជអាវុធហត្ថបង្ករឱ្យមានរបួសស្នាម ព្រមទាំងដកហូតម៉ាស៊ីនថតរូប ហ្វីល និងឧបករណ៍ថតសម្លេងទាំងអស់ ហើយបំផ្លាញចោល[១៥១]។

---

[១៤៩] អ្នកឃ្លាំមើលប្រព័ន្ធផ្សាយព័ត៌មាន លីកាដូ ។

[១៥០] អ្នកឃ្លាំមើលប្រព័ន្ធផ្សាយព័ត៌មាន លីកាដូ ។

[១៥១] អ្នកឃ្លាំមើលប្រព័ន្ធផ្សាយព័ត៌មាន លីកាដូ ។

ការវាយប្រហារលើរូបរាងកាយមកលើអ្នកសារព័ត៌មាន ជាធម្មតាកើតឡើងនៅតាមបណ្តាខេត្តនានា ហើយច្រើនប្រព្រឹត្តដោយពួកកម្លាំងប្រដាប់អាវុធ ដូចជាយោធា កងរាជអាវុធហត្ថ នគរបាល ឬ មន្ត្រីអាជ្ញាធរមូលដ្ឋានជាដើម។ ជនល្មើសទាំងអស់នោះកម្រត្រូវបានចោទប្រកាន់ ឬ ផ្តន្ទាទោសណាស់។ បញ្ហានេះ វាបានរួមចំណែកនៅក្នុងវប្បធម៌នៃនិទណ្ឌភាពសម្រាប់ជនល្មើស និងការភ័យខ្លាចសំរាប់អ្នកសារព័ត៌មាន ។

## ការវាយប្រហារផ្នែកច្បាប់

ចំនុចវិជ្ជមានបានមកពីការថយចុះ នៃការវាយប្រហារលើរូបរាងកាយទៅលើអ្នកធ្វើការក្នុងប្រព័ន្ធផ្សាយព័ត៌មាននានាត្រូវបានខូចខាត ដោយសារការបន្តវាយប្រហារតាមផ្លូវច្បាប់ទៅលើអ្នកសារព័ត៌មាន។ ប្រព័ន្ធតុលាការដែលមានឈ្មោះមិនល្អពីអំពើពុករលួយ និងលំអៀង បានបន្សល់ទុកអ្នកសារព័ត៌មាននូវកិច្ចការពារយ៉ាងតិចតួចជាទីបំផុត ជាពិសេសនៅពេលដែលអ្នកសារព័ត៌មាននោះត្រូវចោទប្រកាន់តាមបណ្តឹងរបស់មន្ត្រីជាន់ខ្ពស់នានា។

សិទ្ធិក្នុងការបោះពុម្ព និងផ្សាយ គឺជាការទទួលខុសត្រូវរបស់អ្នកសារព័ត៌មានក្នុងវិស័យច្បាប់ និងក្រមសីលធម៌។ នៅពេលដែលការទទួលខុសត្រូវនេះមានបញ្ហាត្រូវមានយន្តការច្បាប់ណាមួយដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ជួនកាលសារព័ត៌មានកម្ពុជាត្រូវបានពិពណ៌នាថាជា "ទំព័រអាស្រូវ" ដែលពោរពេញទៅដោយភាសាជេរប្រមាថ និងរូបភាពបន្ទុះបង្អាប់គ្នា។ បទដ្ឋានកំពុងតែកែលំអដោយសន្សឹម១ ក៏ប៉ុន្តែនៅប្រទេសឯទៀតដែលច្បាប់ស្តីពីសារព័ត៌មានរីកចម្រើន និងប្រព័ន្ធតុលាការត្រូវបានគេគោរពក៏ដោយ ក៏នៅតែមានការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ដែរ។

ប៉ុន្តែនៅកម្ពុជា ច្បាប់ចែងអំពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងបទញុះញង់ក៏ត្រូវបានប្រើដោយបំពានដើម្បីបំបិទមាត់ពួកប្រឆាំង ។ ច្បាប់ក្រមព្រហ្មទណ្ឌទាំងនេះ ត្រូវបានគេប្រើច្រើនជាងច្បាប់ស្តីពីសារព័ត៌មានដែលជាច្បាប់រដ្ឋប្បវេណី ការអនុវត្តរបៀបនេះត្រូវបានថ្កោលទោស ដោយអ្នកជំនាញការច្បាប់ និងអង្គការអន្តរជាតិស្តីពីសេរីភាពសារព័ត៌មានជាច្រើន។

ពេញមួយទសវត្សរ៍ ១៩៩០ អ្នកសារព័ត៌មាន និងសារព័ត៌មាននានា ត្រូវទទួលរងការវាយប្រហារដោយច្បាប់ជាប្រចាំ ហើយស្ថាប័នបោះពុម្ពផ្សាយជាច្រើនត្រូវបានផ្អាក ឬ បិទដោយរដ្ឋាភិបាល។

អ្នកសារព័ត៌មានទាំងឡាយដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះបានកត់សម្គាល់ឃើញថាការប្រព្រឹត្ត របៀបនេះនៅតែបន្តហើយអាចកើនជាងមុនផងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

នៅខែតុលា ២០០៥ បញ្ហាចម្រូងចម្រាសអំពីបញ្ហាសិទ្ធិសញ្ញាព្រំដែនកម្ពុជា វៀតណាម បាន បណ្តាលឱ្យមានការចោទប្រកាន់ លោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុសម្បុកឃ្មុំ ពីបទបរិហារកេរ្តិ៍ (ហើយក្រោយមកពីបទផ្សាយព័ត៌មានមិនពិត និងបទញុះញង់) ការចោទប្រកាន់នោះ គឺផ្អែកទៅលើពាក្យ បណ្តឹងរបស់រដ្ឋាភិបាល និងរដ្ឋសភាជាតិក្រោយពីមានការផ្សាយនូវបទសម្ភាសន៍តាមទូរស័ព្ទរវាងលោក ម៉ម សូណង់ដូ ជាមួយសកម្មជនម្នាក់នៅប្រទេសបារាំងដែលបានរិះគន់សន្ធិសញ្ញានោះ។ ក្នុងបទសម្ភាសន៍នោះ លោក ម៉ម សូណង់ដូ ពុំបានធ្វើការរិះគន់ដល់សន្ធិសញ្ញាត្រង់ចំណុចណាមួយទេ ហើយលោកមានតែប្រកែក នៅត្រង់ចំណុចខ្លះដែលសកម្មជននោះបានលើកឡើង។

លោក ម៉ម សូណង់ដូ ជាមួយនឹងមេដឹកនាំសង្គមស៊ីវិល ៤ នាក់ទៀត ដែលត្រូវបានផ្តន្ទាទោសពី បទចោទប្រកាន់ស្រដៀងគ្នានេះពាក់ព័ន្ធជាមួយនឹងបញ្ហាព្រំដែនក្រោយមកត្រូវបានដោះលែងវិញ។ ប៉ុន្តែ ការឃុំខ្លួននេះ បានបង្ហាញពីរបៀប ដែលច្បាប់កម្ពុជាអាចត្រូវបានប្រើខុសមកលើអ្នកណាដែលហ៊ានរិះគន់ រដ្ឋាភិបាល។

លោកស្រី អាញ៉េស កាឡាម៉ាដ នាយិកាប្រតិបត្តិ នៃអង្គការអន្តរជាតិស្តីពីសេរីភាព អ្នកសារ ព័ត៌មានមាត្រា១៩ មានប្រសាសន៍ថា "មាននិន្នាការមួយដែលអ្នកនយោបាយ និងពាណិជ្ជករ ដែលមាន អំណាចមួយចំនួននៅកម្ពុជា ផ្តើមប្តឹងអំពីបទបរិហារកេរ្តិ៍ទៅលើអ្នកណាដែលរិះគន់អ្នកទាំងនោះ"។ "បញ្ហា នេះបានបង្កើតនូវឥទ្ធិពលអវិជ្ជមានមួយមកលើសេរីភាពនៃការបញ្ចេញមតិ និងការបង្កើននូវបរិយាកាស នៃការភ័យខ្លាច"[១៥២]។

ចាប់តាំងពីមានករណីធំៗ នៅក្នុងឆ្នាំ២០០៥ ក៏បន្តឱ្យមាននូវចរន្តនៃខ្លាំងក្លានៃករណីវាយប្រហារ ដោយច្បាប់មកលើប្រព័ន្ធផ្សាយព័ត៌មានរួមមានឧទាហរណ៍បន្តបន្ទាប់ក្នុងឆ្នាំ២០០៧ ដូចខាងក្រោម:

ខែកុម្ភៈ ២០០៧ អ្នកបោះពុម្ពសារព័ត៌មានសម្លេងយុវជនខ្មែរ លោក កែវ សុធា ត្រូវបានចោទ ប្រកាន់ ពីបទបរិហារកេរ្តិ៍ ដោយបានរិះគន់លោក សាយ ហាក់ អភិបាលក្រុងព្រះសីហនុ។

---

[១៥២] ការឃុំខ្លួនសកម្មជន និងអ្នកសារព័ត៌មានកម្ពុជា គឺជាការរំលោភលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីថ្លែងការណ៍មាត្រា ១៩ និង ២០ ខែតុលា ២០០៥។

ខែកុម្ភៈ ២០០៧ លោក ថាច់ កេត នាយកសារព័ត៌មាន ស្រឡាញ់ខ្មែរ ត្រូវបានចោទប្រកាន់ពីបទបង្ខូចឈ្មោះ ដោយបានចុះផ្សាយអត្ថបទមួយ ដែលនិយាយពីការចោទប្រកាន់ជម្លោះរវាងមន្ត្រីនគរបាល និងចៅក្រមម្នាក់ ។

ខែមិថុនា ២០០៧ លោក យូ សារ៉ាវុធ នាយកសារព័ត៌មាន ស្រឡាញ់ខ្មែរ ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ដោយបានចុះផ្សាយនូវអត្ថបទមួយអំពីការរំលោភដីធ្លី ហើយចោទប្រកាន់ថាលោក ហ៊ុន តូ មានការពាក់ព័ន្ធនៅក្នុងបញ្ហានោះ។ លោក សារ៉ាវុធ បានភាសខ្លួនចេញពីកម្ពុជា ក្រោយពីទទួលការគំរាមកំហែងដល់អាយុជីវិត ហើយមិនបានប្រឈមមុខជាមួយតុលាការទេ ។

ខែកក្កដា ២០០៧ លោក កែវ សុធា អ្នកបោះពុម្ពផ្សាយសារព័ត៌មាន សម្លេងយុវជនខ្មែរ ត្រូវបានប្តឹងពីបទបង្ខូចកេរ្តិ៍ឈ្មោះ លោក កែប ជុតិមា អភិបាលរាជធានីភ្នំពេញ ដោយបានចុះផ្សាយអត្ថបទមួយចោទប្រកាន់លោកអភិបាលថាបានលក់អគារសាលាក្រុងភ្នំពេញ។

ខែសីហា ២០០៧ កងកម្លាំងនគរបាលបានវាយលុកចូលកន្លែងផលិតគ្រឿងញៀនមួយកន្លែងនៅខេត្តកំពង់ស្ពឺ ហើយបានរាលដាលនូវការចោទប្រកាន់ក្រោយមកក៏បណ្តាលឱ្យមានការវាយបកមកវិញតាមផ្លូវច្បាប់។ គូក្តីសំខាន់ម្ខាងទៀត គឺលោក ឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ។ លោក ឧបនាយករដ្ឋមន្ត្រីនេះបានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ប្តឹងលោក កែវ សុធា ដែលជាអ្នកបោះពុម្ពផ្សាយនៃសារព័ត៌មានសម្លេងយុវជនខ្មែរ និងប្តឹងលោក ប៊ុន ថា អ្នកបោះពុម្ពផ្សាយសារព័ត៌មាន ខ្មែរអមតៈ និងជានាយកកម្មវិធីផ្សាយសម្លេងរាជានិយម (គណបក្សនរោត្តម រណឫទ្ធិ) ដែលផ្សាយតាមវិទ្យុសម្បុកឃ្មុំ។

អ្នកសារព័ត៌មានដឹងច្បាស់ថា តុលាការនឹងអនុវត្តតាមគោលបំណងរបស់រដ្ឋាភិបាលក្នុងការផ្តន្ទា-ទោសដែលប្តឹងគ្រាន់តែគំរាមទៅតាមផ្លូវច្បាប់ គឺជាការគ្រប់គ្រាន់សំរាប់បំបិទមាត់របស់អ្នកសារព័ត៌មានប៉ុណ្ណោះ។

បណ្ណាធិការម្នាក់បាននិយាយថា "ខ្ញុំមិនចង់ឡើងតុលាការទេ ដូច្នេះ ជួនកាលខ្ញុំមិនប៉ះពាល់ឈ្មោះ (មនុស្សដែលចោទប្រកាន់ករណីស្មុកស្មាញទេ)"[១៥៣] ។

---

[១៥៣] សម្ភាសន៍ជាមួយបណ្ណាធិការម្នាក់ ថ្ងៃទី១៣ កញ្ញា ២០០៧។

ការគំរាមជាក់ស្តែងរបស់រដ្ឋាភិបាលក្នុងការប្រើច្បាប់កំឡុងពេលសន្និសញ្ញាព្រំដែន កម្ពុជា-វៀតណាម នៅឆ្នាំ២០០៥ ហើយម្តងទៀតនៅ ខែមិថុនា ឆ្នាំ២០០៧ ចំពោះរបាយការណ៍របស់ក្លូបាលវិតណេស (Global Witness) ដែលបានចោទប្រកាន់អំពើពុករលួយលើមន្ត្រីរដ្ឋាភិបាលធំៗមួយចំនួន វាប្រាកដជាបានធ្វើឱ្យមានការកាត់បន្ថយនូវការផ្សាយរបស់ប្រព័ន្ធផ្សាយព័ត៌មាន និងការពិភាក្សាសាធារណៈ ស្តីពីបញ្ហាទាំងនោះដោយគ្មានការសង្ស័យឡើយ។

បណ្តឹងផ្នែកច្បាប់ ឬ ការគំរាមបណ្តឹងផ្នែកច្បាប់ នៅតែជាអាវុធដ៏សំខាន់មួយដែលត្រូវបានគេប្រើដើម្បីបំបិទមាត់ និងបំភិតបំភ័យសារព័ត៌មានកម្ពុជា។ ដូចបានធ្វើការកត់សម្គាល់មកពីខាងដើមនៅក្នុងរបាយការណ៍នេះ (សូមអានផ្នែកស្តីពីប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា និងច្បាប់) ការដកទោសពន្ធធនាគារចេញពីបទបរិហារកេរ្តិ៍ មានលទ្ធផលតិចតួចបំផុតក្នុងការធានាថាអ្នកសារព័ត៌មានមិនអាច និងមិនបន្តប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ហើយនឹងអាចជាប់ពន្ធនាគារដោយសាររាយការណ៍អត្ថបទរិះគន់ និងការបញ្ចេញទស្សនៈអំពីរដ្ឋាភិបាលឡើយ។

## ការបំភិតបំភ័យ និងការភ័យខ្លាច

ការខ្វាយខ្វល់អំពីការវាយប្រហារមកលើរូបរាងកាយ និងតាមផ្លូវច្បាប់មានន័យថាអ្នកសារព័ត៌មានកម្ពុជាធ្វើប្រតិបត្តិការក្នុងបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យដែលជាលទ្ធផលត្រូវតែត្រួតពិនិត្យខ្លួនឯង។

នៅពេលដែលការសិក្សាក្នុងឆ្នាំ២០០២ បានសួរបណ្ណាធិការ និងអ្នកបោះពុម្ពផ្សាយសារព័ត៌មានថា តើអ្វីគឺជាបញ្ហាចំបងដែលអ្នកសារព័ត៌មានប្រឈមមុខខ្លាំងជាងគេបំផុត ? នោះយើងឃើញថា ក្នុងចំណោមសារព័ត៌មាន៣ធំជាងគេបង្អស់ ២បានឆ្លើយថា "សន្តិសុខផ្ទាល់ខ្លួន" (៣៦%) និង "ការបំភិតបំភ័យ" (២៧%)[១៥៤]។ ការសិក្សាមួយនៅឆ្នាំ២០០៧ ធ្វើឡើងសម្រាប់របាយការណ៍នេះ បានទទួលលទ្ធផលការឆ្លើយតបស្រដៀងគ្នា ជាមួយនឹងការឆ្លើយជាច្រើនដែលនិយាយថា "សន្តិសុខ" និង "ការគំរាមកំហែង" គឺជាបញ្ហាសំខាន់[១៥៥]។

---

[១៥៤] ការបោះពុម្ពនៅកម្ពុជា (ព័ត៌មានថ្មីៗ និងសរសេរឡើងវិញ) ២០០៦។

[១៥៥] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ២៦។ សំណួរបានសួរថា តើអ្វីខ្លះ គឺជាបញ្ហាធំជាងគេបំផុតដែលអ្នកប្រឈមមុខទាក់ទងនឹងការងាររបស់អ្នក ?

តាមការសិក្សាឆ្នាំ២០០៧ ឃើញថា ៦៥% នៃអ្នកដែលបានឆ្លើយការសម្ភាសន៍បាននិយាយថាអ្នកសារព័ត៌មានខ្លាចចំពោះការវាយប្រហារលើរូបរាងកាយ ហើយ៦២%ទៀតភ័យខ្លាចបណ្តឹងផ្នែកច្បាប់ [១៥៦]។ ប៉ុន្តែអ្វីដែលប្រាប់ឱ្យដឹងនោះគឺ ៥៤% បាននិយាយថាពួកគេធ្លាប់ទទួលរងការគំរាមកំហែងដោយសារការងាររបស់ពួកគេ [១៥៧]។ ប្រភេទនៃការគំរាមមាន "គំរាមអាយុជីវិត" (១៧%) "គំរាមបង្ករបួសស្នាម" (១៥%) ហើយ "គំរាមប្តឹងតាមផ្លូវច្បាប់" (៣០%) [១៥៨]។ ការគំរាមកំហែងជាទូទៅគឺតាមទូរស័ព្ទ ឬ ទល់មុខគ្នា [១៥៩]។

ចំណែកឯការគំរាមកំហែងខ្លះបានទុកជាការសម្ងាត់ ខ្លះទៀតយកមកធ្វើជាចំណងជើងធំៗ។

នៅខែមិថុនា ២០០៧ អ្នកយកព័ត៌មានគ្មានកិច្ចសន្យាការងារ ៣ នាក់ កំពុងថតរូបរថយន្តមួយគ្រឿង ដែលជាកម្មសិទ្ធិរបស់ព្រះរាជអាជ្ញាអមតុលាការ ដែលបានឈប់ក្បែររទេះគោដឹកឈើខុសច្បាប់មួយនៅខេត្តពោធិ៍សាត់។ លោកព្រះរាជអាជ្ញា និងអង្គរក្សមួយចំនួនបានរឹបអូស ម៉ាស៊ីនថតរូប និងទូរស័ព្ទដៃ ហើយអង្គរក្សទាំងនោះបានភ្ជង់កាំភ្លើងទៅអ្នកសារព័ត៌មានទាំងនោះ។ លោកព្រះរាជអាជ្ញាឈ្មោះ តុប ចាន់សេរីវុធ ក្រោយមកបានសារភាពថាបានដកហូតម៉ាស៊ីនថតរូប និងទូរស័ព្ទដៃទាំងនោះមែន ប៉ុន្តែបានបដិសេធថាមិនបានគំរាមបាញ់អ្នកយកព័ត៌មានទាំងនោះទេ [១៦០]។

ការដកហូតបែបនេះ គឺពុំមែនជារឿងប្លែកទេដែលអ្នកសារព័ត៌មាន និងបណ្ណាធិការដែលបានចូលរួមឆ្លើយក្នុងការស្រាវជ្រាវឆ្នាំ ២០០៧ ជាងមួយភាគបី និយាយថាពួកគេធ្លាប់ត្រូវបាន គេរឹបអូសយកឧបករណ៍ជាធម្មតាដោយនគរបាល ឬ យោធា [១៦១]។

នៅខេត្តបាត់ដំបង លោកឧត្តមសេនីយផ្កាយ ១ ម្នាក់ ត្រូវបានរាយការណ៍ថា បានភ្ជង់កាំភ្លើងចំក្បាលអ្នកយកព័ត៌មានសារព័ត៌មាន កម្ពុជាថ្មី ឈ្មោះ ជឹម ចិន្តា ពីព្រោះអ្នកសារព័ត៌មាននោះពុំបានហៅលោកតាមឋានន្តរស័ក្តិត្រឹមត្រូវរបស់លោក [១៦២]។

---

[១៥៦] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៣៨ និង ៤១ ។ មានតែ ២២% នៃអ្នកដែលបានចូលរួមក្នុងការឆ្លើយសំណួរស្រាវជ្រាវប៉ុណ្ណោះបាននិយាយថាពួកគេមិនខ្លាចការវាយប្រហារលើរូបរាងកាយទេ ហើយមានតែ ២៨% ប៉ុណ្ណោះដែលនិយាយថា មិនខ្លាចបណ្តឹងផ្នែកច្បាប់។

[១៥៧] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៣៦ ។

[១៥៨] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៣៦ ក ។

[១៥៩] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៣៦ ខ ។

[១៦០] អ្នកឃ្លាំមើលប្រព័ន្ធផ្សាយព័ត៌មាន លីកាដូ ។

[១៦១] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៤២ និង ៤២ ក។

អ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់បាននិយាយថា "អ្នកសារព័ត៌មាននៅភ្នំពេញហាក់ដូចជាមានសេរីភាពជាងអ្នកសារព័ត៌មាននៅតាមបណ្តាខេត្តនានា ដោយអ្នកសារព័ត៌មាននៅតាមខេត្តត្រូវបានរងការគំរាមកំហែងលើរូបរាងកាយ និងផ្នែកច្បាប់ច្រើនជាង" [១៦៣] ។

ប៉ុន្តែ ករណីមួយដែលមានការផ្សព្វផ្សាយទូទៅនៅភ្នំពេញគឺ កាលពីខែ ឧសភា ឆ្នាំ ២០០៧ សម្តេចនាយករដ្ឋមន្ត្រី មិនសប្បាយចិត្តនឹងសំណួរមួយរបស់ លោក អ៊ុំ សារិន អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី និងជាប្រធានសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មាន។ សម្តេចនាយករដ្ឋមន្ត្រីបានហៅលោក សារិន "ជាមនុស្សព្រហើន" ដោយហ៊ានសួរអំពីការរាតត្បាតនយោបាយ រវាងគណបក្សប្រជាជនកម្ពុជារបស់សម្តេច និងអតីតដៃគូរដ្ឋាភិបាលចម្រុះហ្វ៊ុនស៊ិនប៉ិច។ លោក សារិន បានភាសខ្លួនចេញពីកម្ពុជាអស់មួយរយៈបន្ទាប់ពីនោះ។

"អ្នកយកព័ត៌មានគ្មានព្រំដែន" បានរាយការណ៍ថាយ៉ាងតិចក៏មានការគំរាមកំហែងធ្ងន់ធ្ងរ ៥ ករណីមកលើអ្នកសារព័ត៌មាននៅឆ្នាំ ២០០៦ ។

ការគំរាមកំហែងនេះ ឥទ្ធិពលផ្ទាល់ និងធ្វើឱ្យខូចខាតដល់សេរីភាពប្រព័ន្ធផ្សាយព័ត៌មាន។ នៅក្នុងការស្រាវជ្រាវឆ្នាំ២០០៧ សំរាប់របាយការណ៍នេះ បានសួរអ្នកសារព័ត៌មានដែលធ្លាប់រងការគំរាមកំហែងថា តើការគំរាមកំហែងនេះមានឥទ្ធិពលអ្វីខ្លះមកលើការងាររបស់ពួកគេ ? ជាងមួយភាគបីបាននិយាយថាពួកគេមានអារម្មណ៍ភ័យខ្លាច ហើយ ១៨% និយាយថាពួកគេបានប្តូររឿងដោយសារការគំរាមកំហែង ១៣% សម្រេចចិត្តថាមិនចុះផ្សាយរឿង ១៣%និយាយថាពួកគេឈប់រាយការណ៍ទាំងស្រុងតែម្តងអំពីប្រធាបទនោះ ហើយជិត ៤% បាននិយាយថាពួកគេបានរត់ចេញពីប្រទេសដោយសារការគំរាមនេះ [១៦៤] ។

---

[១៦២] អ្នកឃ្លាំមើលប្រព័ន្ធផ្សាយព័ត៌មាន លីកាដូ។

[១៦៣] សម្ភាសន៍អ្នកសារព័ត៌មានម្នាក់ថ្ងៃទី១២ កញ្ញា ២០០៧។

[១៦៤] សូមអានការសិក្សាប្រព័ន្ធផ្សាយព័ត៌មាន សំណួរ ៣៦ង។

អ្នកសារព័ត៌មានជាន់ខ្ពស់ម្នាក់បានប្រសាសន៍ថា "អ្នកសារព័ត៌មានមួយចំនួនមិនដែលហ៊ានសួរសំណួរដែលស្មុកស្មាញទេ" អ្នកសារព័ត៌មានបានបន្ថែមថា ករណីដែលពាក់ព័ន្ធជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រីបានធ្វើឱ្យអ្នកយកព័ត៌មានប្រុងប្រយ័ត្ន។

**ករណីសិក្សា : ការគំរាមកំហែងដល់អាយុជីវិត**

*ការចេញផ្សាយរបាយការណ៍ស្តីពីការកាប់ព្រៃឈើខុសច្បាប់ ដោយអង្គការក្លូបាលវិតណេស (Global Witness) បានបង្កើតឱ្យមានការប្រឈមមុខដាក់គ្នាយ៉ាងខ្លាំងនៅពាក់កណ្តាលឆ្នាំ២០០៧។ របាយការណ៍បានចោទប្រកាន់ថា មានការពាក់ព័ន្ធរវាងក្រុមអ្នកកាប់ឈើខុសច្បាប់ និងមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលមួយចំនួន។ ក្រសួងព័ត៌មានបានចេញបញ្ជាឱ្យរឹបអូសរបាយការណ៍ទាំងអស់ ហើយព្រមានប្រព័ន្ធផ្សាយព័ត៌មាននានាមិនឱ្យបោះពុម្ពផ្សាយផ្នែកណាមួយដែលដកស្រង់ចេញពីរបាយការណ៍នោះទេ។*

*វិទ្យុអាស៊ីសេរី បានផ្សាយរបាយការណ៍នោះ និងរឿងពាក់ព័ន្ធមួយចំនួន។ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី លោក លឹម ពិសិដ្ឋ បានរៀបចំរឿងចំនួនបួនអំពីការកាប់បំផ្លាញព្រៃឈើនៅខេត្តកំពង់ធំដែលមាននៅក្នុងរបាយការណ៍នោះ។ យោងតាម "អ្នកយកព័ត៌មានគ្មានព្រំដែន" បាននិយាយថាមន្ត្រីនគរបាលម្នាក់បានចូលមកដល់ការិយាល័យវិទ្យុអាស៊ីសេរី ហើយបានព្រមានអ្នកសារព័តមានឱ្យឈប់រាយការណ៍បញ្ហានេះទៅ ។*

*លោក ពិសិដ្ឋ អាយុ ៣៨ ឆ្នាំ លោកនៅតាមផ្លូវធ្វើដំណើរទៅកំពង់ស្ពឺ ភាគខាងត្បូងកម្ពុជា នៅថ្ងៃទី១៦ មិថុនា ២០០៧ ដែលពេលនោះលោកបានទទួលទូរស័ព្ទគំរាមដែលគេហៅចូលមកទូរស័ព្ទដៃរបស់លោកពីលេខមួយដែលលោកមិនស្គាល់។ នៅពេលដែលលោកឆ្លើយទូរស័ព្ទ សម្លេងបុរសម្នាក់បាននិយាយ ទៅលោកថា:*

*បុរស: អ្នកឈ្មោះ លឹម ពិសិដ្ឋមែនទេ ?*

*ពិសិដ្ឋ : បាទ ខ្ញុំ! ហើយលោកជាអ្នកណា?*

*បុរស: អ្នកឯងព្រហើនណាស់ -អ្នកឯងចង់ស្លាប់ឬ?*

*ពិសិដ្ឋ: ហេតុអ្វីបានជាលោកមកប្រមាថខ្ញុំដូច្នេះ ?*

*បុរស: ពីព្រោះព័ត៌មានអំពីព្រៃឈើ អ្នកឯងដឹងហើយ ប្រយ័ត្នគ្មានដីសំរាប់កប់អ្នកឯងទេ ។*

*ការហៅទូរស័ព្ទនោះ គឺគេប្រើទូរស័ព្ទសាធារណៈតាមផ្លូវ ហើយគេមិនដឹងថាអ្នកណាជាអ្នកហៅទេ ។*

*លោក ពិសិដ្ឋ បានរត់គេចទៅប្រទេសថៃ បន្ទាប់ពីមានទូរស័ព្ទគំរាមបែបនេះ ។*

*នៅខែបន្ទាប់ពីលោកត្រឡប់មកវិញ លោកបានបោះផ្សាយនូវទស្សនាវដ្ដីដែលមានការចម្រូងចម្រាសមួយដែលត្រូវបានហាម និងដកហូត ។ ហើយលោកក៏រត់គេចខ្លួនម្ដងទៀត ។*

នៅក្នុងសៀវភៅផ្ទត់របស់លោក ស្ដីពីព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា លោក ពុយ គា បានមានប្រសាសន៍ថា "អ្នកសារព័ត៌មាន និងក្រុមហ៊ុនប្រព័ន្ធផ្សាយព័ត៌មាននានា មិនត្រឹមតែខ្លាចការគាបសង្កត់ពីរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខ្លាចគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចថែមទៀតផង" ។ "គណបក្សនយោបាយ តាមរយៈសមាជិករបស់គណបក្ស ប្រើប្រាស់ការគំរាមកំហែង និងការបំភិតបំភ័យទៅលើអ្នកសារព័ត៌មាន"[១៦៥] ។

ពុំមែនអ្នកសារព័ត៌មានទាំងអស់សុទ្ធតែចុះចាញ់ការគំរាម និងការបំភិតបំភ័យទេ។ អ្នកខ្លះចាត់ទុកថា នេះ គឺជាគ្រោះថ្នាក់នៅក្នុងមុខរបរ ហើយអាចដោះស្រាយបានតាមលទ្ធភាពដែលគេអាចធ្វើបាន។

បណ្ណាធិការម្នាក់បានមានប្រសាសន៍ថា "ការភ័យខ្លាចវាមានឥទ្ធិពល"។ យើងគ្រាន់តែដកថយមួយជំហ៊ានព្យាយាមស្វែងរកឯកសារ (ដើម្បីគាំទ្ររឿងដែលមានបញ្ហានេះ) ប៉ុន្តែយើងនៅតែព្យាយាមទៅមុខជានិច្ច" ។

---

[១៦៥] ពុយ គា ព័ត៌មានទូទៅអំពីវិទ្យុកម្ពុជា ២០០៧ ។







ប្រភព: ការស្ទង់មតិរបស់ អង្គការលីកាដូ

# អនុសាសន៍

អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិ ព្រមទាំងសហគមន៍ជាតិ និងអន្តរជាតិ (ដើម្បីតស៊ូមតិឱ្យមានការចាត់វិធានការដូចតទៅនេះ)៖

## កំណែទម្រង់ច្បាប់

- លប់បទព្រហ្មទណ្ឌបរិហារកេរ្តិ៍/បទបង្ខូចកេរ្តិ៍ឈ្មោះ និងផ្សាយព័ត៌មានមិនពិតចេញពីច្បាប់ព្រហ្មទណ្ឌ ច្បាប់កម្ពុជា ដើម្បីទុកអាទិភាពឱ្យមានការប្រើប្រាស់បទបញ្ញត្តិនៅក្នុងច្បាប់ស្តីពីច្បាប់សារព័ត៌មាន ដែលជាច្បាប់រដ្ឋប្បវេណី ដើម្បីដោះស្រាយបញ្ហាបរិហារកេរ្តិ៍ ឬផ្សាយព័ត៌មានមិនពិត។
- បកស្រាយឱ្យបានច្បាស់នូវភាពខុសគ្នារវាងច្បាប់ព្រហ្មទណ្ឌ និងច្បាប់ស្តីពីសារព័ត៌មាន (ជាពិសេស នៅក្នុងមាត្រា ២០ ក្រោយ) ដែលមានចែងយ៉ាងច្បាស់ថា មានតែច្បាប់ស្តីពីសារព័ត៌មានទេដែល ត្រូវប្រើក្នុងការដោះស្រាយការប្រកាន់ពីបទបរិហារកេរ្តិ៍ បទផ្សាយព័ត៌មានមិនពិត និងអំពើពាក់ព័ន្ធ។
- លប់ចោលមាត្រា ១២ នៃច្បាប់ស្តីពីសារព័ត៌មាន (ពាក់ព័ន្ធសន្តិសុខជាតិ និងស្ថេរភាពនយោបាយ) ដែលត្រូវបានប្រើខុសជាប្រចាំ។ ប្រសិនបើរដ្ឋាភិបាល និងរដ្ឋសភាជាតិមិនត្រៀមខ្លួនធ្វើបែបនេះ ទេ យ៉ាងតិចណាស់ក៏មាត្រានេះត្រូវធ្វើវិសោធនកម្មឱ្យបានច្រើនដើម្បីធានាឱ្យបាននូវ៖
    - ពាក្យ "ស្ថេរភាពនយោបាយ" ត្រូវលប់ចេញ ដោយវាកំហិតយ៉ាងខ្លាំងដល់សិទ្ធិប្រជាពលរដ្ឋ ខ្មែរ សេរីភាពក្នុងការបញ្ចេញមតិយោបល់ពីរដ្ឋាភិបាល និងគណបក្សនយោបាយនានា ។
    - "សន្តិសុខជាតិ" ត្រូវបានផ្តល់និយមន័យយ៉ាងច្បាស់លាស់ ពិសេស ដកចេញនូវបញ្ហាដែលពាក់ ព័ន្ធនយោបាយ និងការពិភាក្សាអំពីគោលនយោបាយ ឬសកម្មភាពរបស់រដ្ឋាភិបាល ។
    - ត្រូវលប់ចោលអំណាចរបស់ក្រសួងព័ត៌មានក្នុងការផ្អាកនិងរឹបអូសសារព័ត៌មានដោយអំណាច នេះបណ្តាលឱ្យមានការត្រួតពិនិត្យ។
    - ធ្វើយ៉ាងណាសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ត្រូវអនុវត្តទៅតាមបទដ្ឋានអន្តរជាតិឱ្យបានពេញ លេញ ដើម្បីការពារសេរីភាពក្នុងការបញ្ចេញមតិ និងជាពិសេស មិនត្រូវដាក់បទបរិហារកេរ្តិ៍ ឬការផ្សាយព័ត៌មានមិនពិតជាបទព្រហ្មទណ្ឌ ឬបទល្មើសស្រដៀងគ្នានៅក្នុងច្បាប់នេះទេ។

- ធ្វើយ៉ាងណាឱ្យសេចក្ដីព្រាងច្បាប់ថ្មីស្ដីពី "សេរីភាពក្នុងការទទួលសារព័ត៌មាន" ស្របតាមបទដ្ឋានអន្តរជាតិ ហើយកុំដាក់ការហាមប្រាមទាំងឡាយឱ្យទៅជាអំពើស្របច្បាប់ ឬធ្វើឱ្យការហាមប្រាមស្ដីពីការទទួលបានព័ត៌មាននៅកម្ពុជាបច្ចុប្បន្នកាន់តែតឹងតែងជាងមុនឡើយ ។

## សម្ពសិទ្ធិករ និងការផ្ដល់អាជ្ញាប័ណ្ណប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិច

- ត្រូវបង្កើតក្របខណ្ឌសមភាព និងសេរីក្នុងការផ្ដល់អាជ្ញាប័ណ្ណវិទ្យុ និងទូរទស្សន៍ស្របតាមបទដ្ឋានអន្តរជាតិចំពោះសេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធផ្សាយសារព័ត៌មាន។
- សូមធ្វើកិច្ចការខាងលើនេះបាន ត្រូវធ្វើការសិក្សាទូលំទូលាយ ឯករាជ្យមួយដើម្បីពិនិត្យមើលការអនុវត្តន៍ល្អៗនៅអន្តរជាតិក្នុងការផ្ដល់អាជ្ញាប័ណ្ណដល់ប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិច ព្រមទាំងបញ្ហាបច្ចេកទេសពាក់ព័ន្ធមួយចំនួន (ដូចជា រលកធាតុអាកាស) នៅកម្ពុជា និងធ្វើអនុសាសន៍ដល់ប្រព័ន្ធផ្ដល់អាជ្ញាប័ណ្ណកម្ពុជា ។
- សូមឱ្យក្រសួងព័ត៌មានឈប់គ្រប់គ្រងស្ថានីយទូរទស្សន៍ និងវិទ្យុជាតិ (**ទទក** AM 918 & FM96) ដើម្បីក្លាយជាសេវាសាធារណៈស្វ័យ័តមួយដោយរួមមាន:
  - មូលនិធិស្វ័យ័តសម្រាប់ស្ថានីយទាំងនោះ ដែលត្រូវបានយល់ព្រមដោយរដ្ឋសភាជាតិ។
  - តែងតាំងនាយកស្ថានីយនានាដែលជាមនុស្សឯករាជ្យ ដោយរដ្ឋសភាជាតិ (ពុំមែនជាមន្ត្រីរាជរដ្ឋាភិបាលដូចសព្វថ្ងៃនេះទេ) និងមានជំនាញចាំបាច់នានា។
  - សូមឱ្យមានការហាមប្រាមច្បាស់លាស់នូវការគ្រប់គ្រងដោយផ្ទាល់ពីក្រសួងព័ត៌មាន ឬស្ថានប័នណាមួយរបស់រដ្ឋ ។

## និទ្ទណ្ឌភាព ការប្រើប្រាស់ច្បាប់ខុសទិសដៅ និងការត្រួតពិនិត្យ

- សូមឱ្យ នគរបាល និងតុលាការ ធ្វើការស៊ើបអង្កេតជាថ្មីចំពោះរាល់ករណីឃាដកម្មលើអ្នកសារព័ត៌មាននៅកម្ពុជាដែលបានកើតឡើងតាំងពីឆ្នាំ២០០៣ មក ។
- សូមចាត់វិធានការយ៉ាងមានប្រសិទ្ធិភាព និងជាបន្ទាន់ដើម្បីស៊ើបអង្កេត និងដាក់ទណ្ឌកម្មដល់ករណីអំពើរំខានគំរាមកំហែង អំពើហិង្សា ឬការជ្រៀតជ្រែកដល់កិច្ចការអ្នកសារព័ត៌មានដែលត្រូវបានរាយការណ៍។

- ជាពិសេស សូមឱ្យការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងផ្តន្ទាទោសព្រហ្មទណ្ឌនូវរាល់ករណីហិង្សាមកលើអ្នកសារព័ត៌មាន។
- សូមឱ្យមន្ត្រី និងមន្ត្រីសាធារណៈសំខាន់ៗមួយចំនួនឯទៀតបង្ហាញនូវការអត់អោនចំពោះការរិះគន់ និងគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ហើយផ្អាកប្តឹងអ្នកសារព័ត៌មានបទព្រហ្មទណ្ឌ។
- (រហូតដល់ច្បាប់ស្តីពីសារព័ត៌មានត្រូវបានធ្វើវិសោធនកម្ម) សូមក្រសួងមហាផ្ទៃមេត្តាកុំផ្អាកអាជ្ញាប័ណ្ណសារព័ត៌មាន ឬសូមមេត្តាកុំរឹបអូសសម្ភារៈទាំងឡាយដែលបានបោះពុម្ព។
- សូមមេត្តាឈប់ត្រួតពិនិត្យនូវព័ត៌មានរបស់ **ឧឧភ** ។

*អនុសាសន៍ចំពោះនិយោជិក-និយោជករបស់ប្រព័ន្ធផ្សាយព័ត៌មានអ្នកតស៊ូមតិដើម្បីសេរីភាពនៃការបញ្ចេញមតិ និងអង្គការក្រៅរដ្ឋាភិបាលៈ*

- គ្រប់ប្រព័ន្ធផ្សាយព័ត៌មានទាំងអស់ (រួមទាំងប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក) គួរបង្កើត និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ។
- ម្ចាស់ប្រព័ន្ធផ្សាយព័ត៌មានម្នាក់ៗ អ្នកគ្រប់គ្រង ឬ អ្នកបោះពុម្ពផ្សាយគួរចាត់វិធានការដើម្បីលើកកំពស់បទដ្ឋានអ្នកសារព័ត៌មានល្អ ដូចជាផ្តល់ប្រាក់បៀវត្សរ៍ដែលអាចឱ្យអ្នកយកព័ត៌មាន និងបណ្ណាធិការដោះស្រាយជីវភាពបានល្អ ធានាយ៉ាងណាឱ្យបុគ្គលិក (អចិន្ត្រៃយ៍ ឬគ្មានកិច្ចសន្យា) មិនត្រូវបង់ប្រាក់ឱ្យបណ្ណាធិការដើម្បីបានចុះផ្សាយអត្ថបទរបស់ពួកគេទេ។ សូមឱ្យលើកទឹកចិត្តបុគ្គលិកឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌។ សូមធានាឱ្យមានឯករាជ្យក្នុងបទអត្ថាធិប្បាយនៅតាមច្រកចែកចាយរបស់ប្រព័ន្ធផ្សាយព័ត៌មានពីឥទ្ធិពលនយោបាយ ឬឥទ្ធិពលផ្សេងទៀត។ សូមបង្កើតឱ្យមានយន្តការសម្រាប់ប្តឹងសម្រាប់បុគ្គលិក និងអ្នកអាន/អ្នកមើល/អ្នកស្តាប់ ដើម្បីរាយការណ៍នូវការរំលោភលើក្រមសីលធម៌។
- អ្នកសារព័ត៌មានគួរតែដើរតួអ្នកនាំមុខគេ ក្នុងការតស៊ូមតិដើម្បីឱ្យមានសេរីភាពក្នុងប្រព័ន្ធផ្សាយព័ត៌មាន និងការពាររួមមាន តាមរយៈការផ្លាស់ប្តូរប្រព័ន្ធច្បាប់ កំណែទម្រង់ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណដល់ប្រព័ន្ធផ្សាយព័ត៌មានអេឡិចត្រូនិក ហើយដោយការដាក់និងថ្កោលទោសករណីគំរាមកំហែង និង រំលោភនីមួយៗមកលើអ្នកធ្វើការក្នុងប្រព័ន្ធផ្សាយព័ត៌មាននានា។

- ត្រូវតែខិតខំប្រឹងប្រែងដើម្បីឃ្លាំមើលនូវមាតិការបស់ប្រព័ន្ធផ្សាយព័ត៌មាន (ជាពិសេស ទូរទស្សន៍ និងវិទ្យុរបស់រដ្ឋ) ហើយត្រូវបញ្ជាក់ឱ្យច្បាស់នូវវិសមភាព និងកង្វះសមភាពនៅក្នុងការផ្សាយព័ត៌មាន។
- ពង្រឹងការរាយការណ៍ និងចងក្រងជាឯកសារនូវករណីវាយប្រហារ និងគំរាមកំហែងមកលើអ្នកសារព័ត៌មានម្នាក់ៗ ហើយផ្សព្វផ្សាយករណីទាំងនោះជាសាធារណៈនៅទីណាដែលអាចធ្វើបាន ដើម្បីបង្កើនការយល់ដឹងឱ្យបានកាន់តែខ្ពស់ជាងមុនចំពោះករណីគំរាមកំហែងមក លើសេរីភាពនៃប្រព័ន្ធផ្សាយព័ត៌មាន។
- ពង្រឹងការចងក្រង-ទំនាក់ទំនងរវាងសមាគមប្រព័ន្ធផ្សាយព័ត៌មានកម្ពុជា នឹងអ្នកសារព័ត៌មាននីមួយៗជាមួយក្រុមសេរីភាពនៃការបញ្ចេញមតិក្នុងតំបន់និងអន្តរជាតិ ដើម្បីធានាឱ្យមានការឆ្លើយតបកាន់តែធំឡើងចំពោះករណីវាយប្រហារ និងការគំរាមកំហែងជាក់លាក់នីមួយៗមកលើអ្នកសារព័ត៌មាន។
- ពង្រីកកម្មវិធីហ្វឹកហ្វឺនសារព័ត៌មាន ដោយដាក់បញ្ចូលនូវជំនាញពាណិជ្ជកម្មដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ដូចជា ជំនាញទីផ្សារ ការទិញ និងការផ្សាយពាណិជ្ជកម្ម លក់ជាដើម ។
- អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល (ដោយមិនគិតថាពួកគេធ្វើការលើបញ្ហាសេរីភាពនៃការបញ្ចេញមតិឬអត់ទេ) គួរលើកផ្សព្វផ្សាយយ៉ាងសកម្មនូវប្រព័ន្ធផ្សាយព័ត៌មានសេរី យុត្តិធម៌ និងមានការទទួលខុសត្រូវដោយរួមមានការៈ អនុម័តនូវគោលនយោបាយដែលមិនបង់ថវិការឱ្យអ្នកសារព័ត៌មានតាមវិធីណាមួយដើម្បីចុះផ្សាយព័ត៌មានឡើយ (រួមទាំងមិនបង់ថវិកាឱ្យពួកគេដើម្បីចូលរួមសន្និសីទសារព័ត៌មាន)។ ជៀសវាងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ (ដូចជាការផ្សាយពាណិជ្ជកម្មបង់ថ្លៃ) ប្រព័ន្ធចែកចាយសារព័ត៌មានដែលពាក់ព័ន្ធនឹងការឃោសនា។ យើងត្រូវបញ្ជាក់ឱ្យបានច្បាស់ចំពោះប្រព័ន្ធចែកចាយព័ត៌មាននានាថា ការសម្រេចចិត្តក្នុងការផ្សាយពាណិជ្ជកម្មឱ្យអង្គការមិនមែនរដ្ឋាភិបាល ។ល។ នឹងអាចធ្វើទៅបានលុះត្រាតែប្រព័ន្ធផ្សាយព័ត៌មាននោះមានទទួលខុសត្រូវនិងគោរពតាមក្រមសីលធម៌ ដែលមានក្នុងការផ្សព្វផ្សាយព័ត៌មាន និងមាតិកាផ្សេងៗ។

# ឧបសម្ព័ន្ធ ក: លទ្ធផលនៃការសិក្សាស្រាវជ្រាវ

ខាងក្រោមនេះ គឺជាលទ្ធផលរបស់ការសិក្សាស្រាវជ្រាវនៃអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សាយព័ត៌មាន នៅក្នុងខែកញ្ញា ២០០៧។ មានចំនួន១៤១នាក់ ក្នុងនោះមានបណ្ណាធិការ អ្នកថតរូប អ្នកថតវីដេអូ ប្រុស/ស្រី បានបំពេញទំរង់នៃការសិក្សាស្រាវជ្រាវនេះ។




សំណួរ២: តើអ្នកមានអាយុប៉ុន្មាន?
២០-២៤
២៥-២៩
៣០-៣៤
៣៥-៣៩
៤០-៤៤
៤៥-៤៩
៥០-៥៤
៥៥-៥៩
គ្មានចម្លើយ
១០
២៤
១៤
៣៨
២២
១៦
១១
៥
១
0 ៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០


សំណួរ៣: តើអ្នកបម្រើការងារឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប៉ុន្មានឆ្នាំហើយ?
តិចជាង១ ឆ្នាំ
១-៣ ឆ្នាំ
៣-១០ ឆ្នាំ
១០-២០ ឆ្នាំ
លើសពី២០ឆ្នាំ
គ្មានចម្លើយ
១២
២២
៥៧
៣៦
១០
៤
0 ១០ ២០ ៣០ ៤០ ៥០ ៦០


សំណួរ៤: តើកន្លែងធ្វើការរបស់អ្នកនៅទីណា?
ភ្នំពេញ
ខេត្ត
គ្មានចម្លើយ
៥៩
៧៩
៣
0 ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០


សំណួរ៥: តើអ្នកបោះពុម្ពផ្សព្វផ្សាយជាភាសាអ្វី?
ខ្មែរ
អង់គ្លេស
ខ្មែរ-អង់គ្លេស
ផ្សេងៗ
គ្មានចម្លើយ
១២០
៧
៨
១
៥
0 ២០ ៤០ ៦០ ៨០ ១០០ ១២០ ១៤០

## ១១៦ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ (របាយការណ៍លើកាដូ)



## សំណួរ៧: តើប្រធានបទពអ្វីខ្លះ ដែលអ្នកយកធ្វើជាព័ត៌មាន









ក្នុងចំណោម៤0នាក់ដែលឆ្លើយ ១២នាក់ជាសមាជិករបស់ក្លឹបសារព័ត៌មានកម្ពុជា ៨នាក់របស់ សមាគម កម្ពុជាដើម្បីការពារអ្នកសារព័ត៌មាន ៤នាក់ក្រុមប្រឹក្សាកម្ពុជាសំរាប់អ្នកសារព័ត៌មាន (ប្រហែលជាក្រុមប្រឹក្សាសារព័ត៌មានជាតិ)។ ជួនកាលអ្នកដែលបានឆ្លើយ មិនដឹងជាចង់និយាយថាសមាគមណាមួយទេ ? មានម្នាក់បានឆ្លើយថា "ក្រសួងព័ត៌មាន"។

សំណួរ៩ (ក): ប្រសិនបើជាសមាជិក តើសមាជិករបស់សមាគមណាមួយ ?

សមាជិក១២នាក់ បានឆ្លើយសំណួរ ក្នុងនោះ១0នាក់ជាសមាជិកគណបក្សប្រជាជនកម្ពុជា និង ២នាក់ ជាសមាជិកហ៊្វុនស៊ិនប៉ិច។




## ចំណូលរបស់អ្នកធ្វើការងារដោយអត់កិច្ចសន្យា

អ្នកដែលអត់មានកុងត្រាច្បាស់លាស់ ក៏មានសិទ្ធិឆ្លើយដែរ ហើយឆ្លើយថាបានទទួលប៉ុន្មានក្នុង១អត្ថបទ។ មាន១៣នាក់ឆ្លើយ ១១នាក់ឆ្លើយថាតិចជាង៦ដុល្លា/១អត្ថបទ ១នាក់ឆ្លើយថាពី៥០-១០០ដុល្លា/១អត្ថបទ ម្នាក់ទៀតឆ្លើយថា១៥០-២០០ដុល្លា/១អត្ថបទ។

## ចំណូលផ្សេងៗទៀត

មាន៧នាក់បានឆ្លើយថាបានចំណូលតិចជាង៦ដុល្លា/១អត្ថបទ ១នាក់ឆ្លើយថា១៥ដុល្លា/១អត្ថបទ ៥នាក់ ទៀតឆ្លើយថា មិនបានទទួលអ្វីទេពីអត្ថបទដែលបានសរសេរនោះ។

## ១២០ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ (របាយការណ៍លីកាដូ)





















សំណួរ១៧ (ក) : ប្រសិនជាបានចូលរួម សូមមេត្តាពន្យល់ពីវគ្គបណ្តុះបណ្តាលនោះ

៨៧នាក់ បានផ្តល់ចំលើយ ភាគច្រើនបានឆ្លើយថា ទទួលការវគ្គបណ្តុះបណ្តាលជាច្រើនដង មានអ្នកខ្លះចេញ0ទៅបរទេស ប្រធានបទដែលយកមកពិភាក្សាជាច្រើន គឺជំនាញមូលដ្ឋានវិជ្ជាជីវះខាងសារព័ត៌មានការស៊ើបអង្កេតក្នុងការយកព័ត៌មាន ក្រមសីលធម៌របស់វិជ្ជាជីវះខាងសារព័ត៌មានការបណ្តុះបណ្តាលពីប្រធាន ពិសេស។ដូចជា (ការបោះឆ្នោត ជំងឺអេដស៍ សិទ្ធិមនុស្ស សិទ្ធិកុមារ ច្បាប់សាលាក្តីខ្មែរក្រហម ការយក ព័ត៌មានពីតុលាការ និងការថតរូប)។

សំណួរ១៨: ប្រសិនបើអ្នកត្រូវផ្តល់យោបល់សំរាប់វគ្គបណ្តុះបណ្តាលទៅអនាគតសំរាប់អ្នកសារ ព័តិមាន តើអ្នករើសប្រធានបទអ្វីខ្លះ?

ចំលើយ: ៩៩នាក់ បានផ្តល់ចំលើយ ប្រធានបទដែលបានជ្រើសរើសច្រើនជាងគេគឺ អំពើពុករលួយ ការរំលោភសិទ្ធិមនុស្ស ការរំលោភយកដីធ្លី ធនធានធម្មជាតិ បរិស្ថាន វិជ្ជាជីវៈខាងស៊ើបអង្កេត វិជ្ជាជីវៈខាងសរសេរ/ខាងសំភាសន៍ ការអប់រំ កសិកម្ម អភិវឌ្ឍន៍ ក្រមសីលធម៌វិជ្ជាជីវៈខាងសារ ព័តិមាន។







## ការទទួលបានព័តិមាន

(ផ្នែកនេះសំរាប់អ្នកសារព័តិមាន និងបណ្ណាធិការ ដូច្នេះអ្នកថតរូប និងអ្នកថតវីដេអូ ទាំងបុរស និងស្ត្រី សូមអញ្ជើញមើលសំណួរទី២៥)

សំណួរ២០ (ក): អ្នកឆ្លើយជាច្រើននាក់បានសំអាងទៅលើហេតុផលថា: អ្នកទាំងអស់នោះជួយប្រជាពលរដ្ឋ រកយុត្តិធម៌ជូនជនរងគ្រោះ រកភាពអយុត្តិធម៌ឱ្យលេចចេញមក ប្រព្រឹត្តតាមគោលការណ៍ថាប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នា និងខិតខំជំរុញឱ្យមានការកែលំអរបស់តំរិយាបទរបស់រដ្ឋាភិបាល។

សំណួរ២១: តើអ្នកមានប្រភពព័ត៌មានសំខាន់ៗ៣អ្វីខ្លះ សំរាប់អត្ថបទរបស់អ្នក?












## ១២៤ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ (របាយការណ៍លើកាដូ)













ប្រភពពីក្រសួងព័ត៌មាន
ងាយស្រួលណាស់
ងាយស្រួល
ពិបាក
ពិបាកណាស់
គ្មានចម្លើយ
៨
៦៥
២៧
១២
២៩
០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០


ប្រភពពីមន្ត្រីតុលាការ (ចៅក្រម-ក្រឡាបញ្ជី និងមេធាវី)
ងាយស្រួលណាស់
ងាយស្រួល
ពិបាក
ពិបាកណាស់
គ្មានចម្លើយ
២
១០
៦១
៤៥
២៣
០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០


ប្រភពពីនគរបាល
ងាយស្រួលណាស់
ងាយស្រួល
ពិបាក
ពិបាកណាស់
គ្មានចម្លើយ
៤
៤៩
៥២
១៥
២១
០ ១០ ២០ ៣០ ៤០ ៥០ ៦០


ប្រភពពីយោធា
ងាយស្រួលណាស់
ងាយស្រួល
ពិបាក
ពិបាកណាស់
គ្មានចម្លើយ
៦
២២
៦៤
២៤
២៥
០ ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០

## ១២៦ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ (របាយការណ៍លើកាដូ)













ប្រភពពីសាក្សី
ងាយស្រួលណាស់ ១៩
ងាយស្រួល ៥១
ពិបាក ៤៣
ពិបាកណាស់ ៦
គ្មានចម្លើយ ២២
0 ១០ ២០ ៣០ ៤០ ៥០ ៦០


ប្រភពពីប្រជាពលរដ្ឋ
ងាយស្រួលណាស់ ៣៨
ងាយស្រួល ៧៦
ពិបាក ៥
ពិបាកណាស់ 0
គ្មានចម្លើយ ២២
0 ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០


ប្រភពពីអ្នកសារព័ត៌មានដទៃទៀត/ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
ងាយស្រួលណាស់ ២០
ងាយស្រួល ៧៣
ពិបាក ១១
ពិបាកណាស់ ២
គ្មានចម្លើយ ៣៥
0 ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០


ប្រភពពីអ៊ីនធឺណេត
ងាយស្រួលណាស់ ១៩
ងាយស្រួល ៤៤
ពិបាក ១៥
ពិបាកណាស់ ១០
គ្មានចម្លើយ ៥៣
0 ១០ ២០ ៣០ ៤០ ៥០ ៦០

**សំណួរ២៤: ច្បាប់សារព័ត៌មានកម្ពុជា (មាត្រា៥-ខ) និយាយថា ការស្នើសុំព័ត៌មានត្រូវសរសេរជាលាយលក្ខ័ ទៅកាន់មន្ត្រីរដ្ឋាភិបាល ហើយមន្ត្រីនោះត្រូវឆ្លើយតបក្នុងរយៈពេល៣០ថ្ងៃ ឬ ត្រូវពន្យល់ថាតើហេតុអ្វីបានជា ព័ត៌មានទាំងនោះមិនត្រូវបានផ្តល់ឱ្យ។ តើអ្នកធ្លាប់បានស្នើសុំសំរាប់យន្តការព័ត៌មានបែបនេះដែរឬទេ?**




**សំណួរ២៥: តើអ្នកពិពណ៌នាអំពីសេរីភាពនៃប្រព័ន្ធផ្សាយព័ត៌មាននៅកម្ពុជាដូចម្តេច?**




# សេរីភាពក្នុងការបញ្ចេញមតិ

សំណួរ២៦: តើបញ្ហាពាធំបំផុត ដែលអ្នកប្រឈមជាមួយនឹងការងាររបស់អ្នកគឺអ្វីខ្លះ? ចំលើយជាច្រើនទាក់ ទងទៅនឹងការទទួលព័ត៌មាន (ពិបាកក្នុងការទទួលព័ត៌មាន និងសំភាសន៍ជាមួយនឹងមន្ត្រីរដ្ឋាភិបាលព្រម ទាំងមន្ត្រីផ្សេងៗទៀត) បញ្ហាសន្តិសុខ (ការគំរាមកំហែង) និងកង្វះខាតថវិកា ឬធនធាន។


សំណួរ២៧: តើម្ចាស់ប្រព័ន្ធផ្សាយព័ត៌មាន មានឥទ្ធិពលមកលើព័ត៌មានដែរឬទេ?
អត់មានសោះ ២៣
កម្រ ១៤
ម្តងម្កាល ៤១
ញឹកញាប់ ១៦
ជានិច្ច ២៩
គ្មានចម្លើយ ១៨
០ ៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥


សំណួរ២៨: តើបណ្ណាធិការ/អ្នកផលិត បានសុំឱ្យអ្នកសរសេរអត្ថបទពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬ អ្នកនយោបាយណាមួយឬទេ?
មិនដែលសោះ ៩៦
កម្រ ១១
ម្តងម្កាល ១៨
ញឹកញាប់ ២
ជានិច្ច ១
គ្មានចម្លើយ ១៣
០ ២០ ៤០ ៦០ ៨០ ១០០ ១២០


សំណួរ២៩: តើអ្នកគាំទ្រផ្នែកហិរញ្ញវត្ថុនៃប្រព័ន្ធផ្សាយព័ត៌មាន ធ្លាប់បានសុំឱ្យអ្នកសរសេរអត្ថបទដើម្បីសរសើរ
គណបក្សនយោបាយ ឬ អ្នកនយោបាយណាមួយឬទេ?
មិនដែលសោះ ៩៨
កម្រ ៩
ម្តងម្កាល ១៥
ញឹកញាប់ ៤
គ្មានចម្លើយ ១៥
០ ២០ ៤០ ៦០ ៨០ ១០០ ១២០


សំណួរ៣១: តើអ្នកមានបានដឹងឮ ពីអ្នកសារព័ត៌មានដែលទទួលប្រាក់កាស ឬ រង្វាន់
ដើម្បីនឹងរាយការណ៍ឱ្យគេពេញចិត្តដែរឬទេ?
បាទ/ចាស ៣៥
ទេ ៣៨
មិនចង់និយាយ ៥០
គ្មានចម្លើយ ១៨
០ ១០ ២០ ៣០ ៤០ ៥០ ៦០

## ១៣០ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ (របាយការណ៍លីកាដូ)

សំណួរ៣២: តើអ្នកមានបានដឹងឮ ពីអ្នកសារព័ត៌មានដែលទទួលប្រាក់កាស ឬ រង្វាន់
ដើម្បីកុំអ្នករាយការណ៍ពីករណីណាមួយដែរឬទេ?




សំណួរ៣៣: តើអ្នកធ្លាប់ទទួលប្រាក់កាស ឬ រង្វាន់ ក្នុងការសរសេររឿងរ៉ាវឱ្យគេពេញចិត្ត ឬ
មិនសរសេរដែរឬទេ?




សំណួរ៣៤: តើអ្នកធ្លាប់ទទួលប្រាក់កាស ឬ រង្វាន់ (ប្រេងសាំង) សំរាប់ចូលរួមសន្និសីទដែរឬទេ?




សំណួរ៣៥: តើអ្នកមានដឹងឮផ្ទាល់
អំពីមិត្តភក្តិក្នុងការប្រព័ន្ធផ្សាយព័ត៌មានដែលទទួលនូវការគំរាមកំហែង ក្នុងការសរសេរអត្ថបទ ឬ
ការស៊ើបអង្កេតដែរឬទេ?









សំណួរ៣៦ (ខ): តើការគំរាមកំហែងនោះតាមរបៀបណា? មានចំលើយជាច្រើនតាមរយៈទូរស័ព្ទ (៣៧) គំរាមតាមរយៈកាយវិការ ឬក៏បញ្ចេញសកម្មភាពគំរាមផ្សេងៗទៀត (២៥) ទល់មុខជាមួយនឹងអ្នកគំរាម (២២) គំរាមទល់មុខគ្នាជាមួយអ្នកទី៣ដែលស្គាល់មុខ និងគំរាមទល់មុខគ្នាជាមួយនឹងអ្នកទី៣ដែលមិន ស្គាល់មុខ។



សំណួរ៣៦(គ): តើបញ្ហាអ្វីដែលបណ្ដាលឱ្យមានការគំរាមកំហែង?
នយោបាយ ២២
ការបោះឆ្នោត ៤
មុខជំនួញ ២០
វប្បធម៌ ៤
សិទ្ធិមនុស្ស ២១
ការអប់រំ ២
សុខភាព ១
ដីធ្លី ៤៤
កសិកម្ម ១
ធនធានធម្មជាតិ ២៩
គមនាគមន៍ ៤
កិច្ចការអន្តរជាតិ ៣
ព័ត៌មានអន្តរជាតិ ១
អំពើពុករលួយ ២
ផ្សេងៗ ១០
0 ៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥ ៥០




សំណួរ៣៦(ឃ): តើអ្នកបានស្គាល់ អ្នកដែលគំរាមកំហែងឬទេ?
បាទ/ចាស ៤៣
ទេ ២៥
គ្មានចម្លើយ ៧៣
0 ១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០




សំណួរ៣៦(ង): តើការគំរាមកំហែងនេះ មានឥទ្ធិពលអ្វីខ្លះ ដល់ការងាររបស់អ្នក? (អ្នកអាចឆ្លើយលើសពីមួយបាន)
គ្មានប៉ះពាល់ ១៤
ភ័យខ្លាច ៤៨
ផ្លាស់ប្ដូរអត្ថបទ ២៤
សម្រេចចិត្តមិនផ្សព្វផ្សាយ ១៨
បញ្ឈប់ការយកពត៌មាននោះទៀត ១៨
ផ្លាស់ប្ដូរការងារ ៣
ផ្លាស់ប្ដូរទីលំនៅ ២
ចាកចេញពីប្រទេស ៥
ផ្សេងៗ ៣
0 ១០ ២០ ៣០ ៤០ ៥០ ៦០




សំណួរ៣៧: តើអ្នកធ្លាប់ទទួលការវាយប្រហារលើរូបរាងកាយដោយសារអត្ថបទ ឬ
ការស៊ើបអង្កេតឬទេ?
បាទ/ចាស ៦
ទេ ១១៥
គ្មានចម្លើយ ២០
0 ២០ ៤០ ៦០ ៨០ ១០០ ១២០ ១៤០


សំណួរ៣៨: តើនៅពេលអនាគត អ្នកខ្លាចការវាយប្រហារលើរូបរាងកាយអ្នកឬទេ?
បាទ/ចាំស
៩១
ទេ
៣១
គ្មានចម្លើយ
១៩
០
២០
៤០
៦០
៨០
១០០


សំណួរ៣៩: តើអ្នកធ្លាប់មានការចោទប្រកាន់ ពីបទឧក្រិដ្ឋណាមួយក្នុងការសរសេរអត្ថបទ ឬ
ការស៊ើបអង្កេតដែរឬទេ?
បាទ/ចាំស
១៥
ទេ
១០៤
គ្មានចម្លើយ
២២
០
២០
៤០
៦០
៨០
១០០
១២០







សំណួរ៣៩(គ): ហេតុអ្វីបានជាអ្នកមិនមានមេធាវី?

៨នាក់ឆ្លើយថា គ្មានលទ្ធផលរកមេធាវី ២នាក់ឆ្លើយថា តុលាការមិនឱ្យគាត់យកមេធាវី ២នាក់ឆ្លើយថា ចង់ការពារដោយខ្លួនឯង ១នាក់បានឆ្លើយថា មេធាវីបដិសេធមិនព្រមការពារ និង១នាក់ទៀតឆ្លើយថា "តុលាការបើសវនាការដោយពុំមានសាក្សី "។


សំណួរ៤០: តើអ្នកមានដែលសុំឱ្យអង្គការជួយអ្នកដែរឬទេ?
សមាគម ឬ ក្លឹបប្រពន្ធ័ផ្សាយព័តិមានកម្ពុជា
៤៣
សមាគមប្រពន្ធ័ផ្សាយព័តិមានអន្តរជាតិ
១១
អង្គការមិនមែនរដ្ឋាភិបាល
២៦
នគរបាល
១០
០
១០
២០
៣០
៤០
៥០


សំណួរ៤១: តើនៅពេលអនាគម អ្នកខ្លាចទេពីការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ ព័តិមានមិនពិត ឬ ញុះញង់ ឬទេ?
បាទ/ចាស
៨៧
ទេ
៣៩
គ្មានចម្លើយ
១៥
០
២០
៤០
៦០
៨០
១០០


សំណួរ៤២: តើអ្នកធ្លាប់ត្រូវបានគេដកហូត ឧបករណ៍នៅពេលដែលអ្នកកំពុងធ្វើការ
(សៀវភៅកំណត់ហេតុ ស្លាបប៉ាកា កាមេរ៉ា ម៉ៃក្រូហ្វូន ម៉ាស៊ីនថតសំលេង) ឬទេ?
បាទ/ចាស
៣៩
ទេ
៧៥
គ្មានចម្លើយ
២៧
០
២០
៤០
៦០
៨០


សំណួរ៤២(ក): ប្រសិនបើមានការដកហូត តើអ្នកណាជាអ្នកដកហូតឧបករណ៍របស់អ្នក?
នគរបាល
២០
យោធា
១៦
មន្ត្រីថ្នាក់ក្រសួង
៧
មន្ត្រីថ្នាក់ស្រុក
៧
មន្ត្រីថ្នាក់ខេត្ត
៥
អ្នកប្រកបជំនួញ
៥
០
៥
១០
១៥
២០
២៥

# ឧបសម្ព័ន្ធ ខ: វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្ទង់មតិនេះត្រូវបានរៀបចំធ្វើឡើងដោយទីប្រឹក្សាសារព័ត៌មាន អ្នកជំនួយការ អ្នកសម្របសម្រួលខេត្ត បុគ្គលិកលីកាដូ និងការិយាល័យទាក់ទាញមិតិគាំទ្រ ឯកសារ និងធនធានព័ត៌មាននៃអង្គការលីកាដូ។

ទំរង់សំណួរនៃការស្ទង់មតិនេះត្រូវបានចងក្រងនៅក្នុងខែសីហា ឆ្នាំ២០០៧។ សេចក្តីព្រៀងលើកទី១ (ដែលត្រូវបានសរសេរជាភាសាអង់គ្លេស និងបកប្រែទៅជាភាសាខ្មែរ) ត្រូវបានធ្វើការសាកល្បងជាមួយក្រុមស្នូលនៃអ្នកកាសែត និងបណ្ណាធិការចំនួន៧នាក់ នៅចុងខែសីហា។ មតិកែលំអរដ៏មានតំលៃរបស់ពួកគេនាំឱ្យមានការកែតំរូវនូវទំរង់សំណួរ និងវិធីសាស្ត្រក្នុងការធ្វើការស្ទង់មតិ។

ក្រុមការងារបុគ្គលិកលីកាដូជាច្រើនអ្នកបានត្រួតពិនិត្យការបកប្រែនៃការស្ទង់មតិ ដើម្បីធានាថាទាំងភាសាខ្មែរ និងភាសាអង់គ្លេសគឺមានអត្ថន័យត្រូវគ្នាអាចទទួលយកបាន។

ការស្ទង់មតិនេះផ្តោតទៅលើអ្នកសារព័ត៌មាន បណ្ណាធិការ អ្នកថតរូប និងអ្នកថតវីដេអូ បុរស/ស្ត្រី។ គោលបំណងគឺដើម្បីឱ្យអ្នកសារព័ត៌មានគ្រប់រូបបំពេញនូវនៃទម្រង់ស្ទង់មតិនេះតាមតែអាចធ្វើទៅបាន។ រាល់ការផ្តល់ចម្លើយមិនត្រូវបានកត់ចំណាំ ឬលាតត្រដាងឡើយ។

នៅក្នុងខែកញ្ញា ទំរង់សំណួរសំរាប់ការស្ទង់មតិត្រូវបានប្រគល់ឱ្យទៅអ្នកសម្របសម្រួលលីកាដូទាំង១២ខេត្ត ដែលរួមមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ក្រុងព្រះសីហនុ និងខេត្តស្វាយរៀង។ អ្នកសម្របសម្រួលលីកាដូខេត្តនិមួយៗ បានបែងចែកទំរង់សំណួរសំរាប់ការស្ទង់មតិទៅឱ្យអ្នកសារព័ត៌មានតាមខេត្តនិមួយៗរបស់ពួកគេ និងប្រមូលយកមកវិញនៅមួយថ្ងៃបន្ទាប់។

ដោយឡែកនៅក្នុងទីក្រុងភ្នំពេញវិញ វាកាន់តែមានការពិបាកទៅទៀត ដើម្បីស្វែងរកអ្នកសារព័ត៌មាន និងបញ្ចុះបញ្ចូលឱ្យពួកគេជួញបំពេញនូវទំរង់សំណួរសំរាប់ការស្ទង់មតិ។ អ្នកសារព័ត៌មានខ្មែរជាច្រើននាក់មិននៅក្នុងការិយាល័យឱ្យទៀងទាត់ទេ ដូចនេះហើយ ក្រុមស្នូលបានស្នើឱ្យទៅកន្លែងដែលពួកគេជួបជុំគ្នានៅហាងកាហ្វេមួយកន្លែងទល់មុខរដ្ឋសភាចាស់ ដែលត្រូវបានគេស្គាល់ថា "ដើមអំពិល" ហើយនៅក្នុង

ហាងកាហ្វេស្ថិតនៅក្នុងទីធ្លាក្រសួងព័ត៌មាន។ នៅទីនោះ អ្នកសារព័ត៌មានទាំងអស់ប្រមូលផ្តុំគ្នារៀងរាល់ព្រឹកដើម្បីអានកាសែត ស្វែងប្រភពព័ត៌មាន និងជជែកជាមួយអ្នកសារព័ត៌មានផ្សេងទៀតពីអាហារពេលព្រឹក ឬកាហ្វេ។

ការណាត់ជួបមិនផ្លូវការនេះ មានគុណសម្បត្តិសំខាន់៧ពីរ។ ទីមួយគឺមានការងាយស្រួលដើម្បីជួបជាមួយនឹងក្រុមអ្នកសារព័ត៌មានចម្រុះ ដែលក្រុមចម្រុះនោះគឺអ្នកសារព័ត៌មានដើមអំពិល ជាពិសេសរួមមានអ្នកយកព័ត៌មានវិទ្យុ និងទូរទស្សន៍ កាសែតគាំទ្ររដ្ឋាភិបាល កាសែតប្រឆាំង និងកាសែតឯករាជ្យ។ ទីពីរគឺ អាចធ្វើឱ្យអ្នកសារព័ត៌មានទាំងអស់នៅឆ្ងាយពីការិយាល័យរបស់ពួកគេ ដើម្បីជៀសផុតពីការប្រើឥទ្ធិពលរបស់បណ្ណាធិការ ឬចាងហ្វាងសែត និងការភិតភ័យក្នុងការចូលរួមឆ្លើយនូវសំណួររសើបនេះ។

ជាមួយគ្នានេះផង គុណវិបត្តក៏មានដែរ។ ដើម្បីបានជួបជាមួយនឹងអ្នកសារព័ត៌មានធ្វើការនៅខាងក្រៅ យើងដកចេញនូវអ្នករាយការណ៍ ឬបណ្ណាធិការដែលធ្វើការទៀងទាត់នៅក្នុងបន្ទប់ព័ត៌មាន ឬស្ថានីយ៍វិទ្យុនោះទេ។ យើងក៏មិនរាប់បញ្ចូលអ្នកសារព័ត៌មានណា ដែលមិនបានទៅទីតាំងដែលបានជ្រើសរើសសំរាប់ធ្វើការស្ទង់មតិនោះដែរ។

ចំនួនសរុបនៃអ្នកសារព័ត៌មានដែលបានបំពេញនូវទម្រង់ស្ទង់មតិនោះ គឺមាន ១៤១នាក់ ដែល ៧៩ នាក់មកពីខេត្ត និង៥៩នៅភ្នំពេញ (មាន៣ចម្លើយមិនបានបញ្ជាក់ថាមកពីខេត្ត ឬទីក្រុង)។ នេះអាចរាប់ថាជាការស្ទង់មតិសារព័ត៌មានដ៏ទូលំទូលាយនៅកម្ពុជាមកដល់ពេលនេះ។

ចម្លើយដែលបានប្រមូលពីការស្ទង់មតិត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិភាគទិន្ន័យ SPSS។ ទិន្ន័យដំបូងនេះត្រូវបានរៀបចំដាក់តាមលំដាប់ ហើយលទ្ធផលនៃការឆ្លើយសំណួរបង្ហាញទិន្ន័យបានយ៉ាងងាយនៅក្នុងតារាង និងក្រាហ្វិក។

ការបំពេញទម្រង់ស្ទង់មតិជាភាសាអគ្លេសមានត្រឹមតែ២-៣នាក់ប៉ុណ្ណោះ ហើយភាគច្រើននៃអ្នកឆ្លើយគឺចង់បានជាភាសាខ្មែរ ដើម្បីងាយស្រួលយល់ក្នុងអាន និងសរសេរ។

អ្នកឆ្លើយខ្លះក៏មិនបានឆ្លើយគ្រប់សំណួរទាំងអស់ទេ។ សំណួរខ្លះនៃសំណួរទាំងនោះទាក់ទងនឹងអំពើពុករលួយ និន្នាការនយោបាយ ការប្រើឥទ្ធិពលរបស់បណ្ណាធិការ និងការគំរាមកំហែង។

ជាមួយគ្នានេះផងដែរ អ្នកសារព័ត៌មានខ្លះក៏ពុករលួយដែរក្នុងការសរសេរព័ត៌មានរបស់ពួកគេ (ជាពិសេស ព័ត៌មានទាក់ទងដល់ពួកគេ) និងសំណួរស៊ើបផ្សេងៗទៀត។ លទ្ធផលនៃការស្ទង់មតិនេះត្រូវបានយកមកប្រៀបធៀបជាមួយនឹងការសំភាសន៍យ៉ាងស៊ីជំរៅដែលមានអត្ថន័យ និងខ្លឹមសារដូចដែលមានលើកឡើងក្នុងនេះ។ ឧទាហរណ៍ ប្រភពព័ត៌មានជាច្រើននិយាយថាអ្នកសារព័ត៌មានស្ទើរតែទាំងអស់ដែលបម្រើការងារឱ្យសារព័ត៌មានភាសាខ្មែរគឺបានទទួលយកសំណូកបន្តិចបន្តួច ប៉ុន្តែការស្ទង់មតិមានត្រឹមតែ៣៣% ដែលឆ្លើយថា បានទទួលសំណូកនៅកំឡុងពេលចូលរួមសន្និសីទកាសែត។ ទោះបីជាមានដែនកំណត់ទាំងនេះក៏ដោយ ក៏ការពិត ១ភាគ៣របស់អ្នកឆ្លើយបានបញ្ជាក់ថាការទទួលយកសំណូកគឺជាការរកឃើញដ៏មានសារៈប្រយោជន៍បំផុត ហើយគាំទ្រនូវគំនិតដែលត្រូវបានអះអាងដោយគ្មានភស្តុតាងថាប្រព័ន្ធសារព័ត៌មាននៅកម្ពុជាមានការពុករលួយ។

# ឧបសម្ព័ន្ធ គ: ឯកសារយោង

## សៀវភៅ

Iarossie, Giuseppe. *The Power of Survey Design*, The International Bank for Reconstruction and Development / The World Bank, 2006

Mehta, Harish C., *Cambodia Silenced: The Press under Six Regimes*. Bangkok: White Lotus Press, 1997.

McCargo, Duncan, *Politics and the Press in Thailand: Media Machinations*, Garuda Press, 2002.

Puy, Kea, *Radio Profile in Cambodia*, Reahoo Publishing (sponsored by Konrad Adenauer Foundation), 2007

## របាយការណ៍

Article 19 / ADHOC / CLEC. *Freedom of Expression and the Media: baseline studies – Cambodia*, 27 June 2006, http://www.article19.org/publications/regions/asia/publications/reports.html

Aquino, Enrica G. & Tive Sarayeth, *Women and The Media In Cambodia National Survey*, December 2005, Women's Media Center of Cambodia

Chhay, Sohal & Steven Pak, *Safe Sex and the Media in Southeast Asia: Sex Without Substance*, 2004, AIDS Society of the Philippines.

Charney, Craig & Steve Hopkins, Charney Research. *Democracy in Cambodia – 2003: A Survey of the Cambodian Electorate*, The Asia Foundation, 16 May 2003 (draft)

Colm, Sara. *Cambodia: Emerging Civil Society Faces an Uncertain Future*, Cambodian Association for Human Rights and Development (ADHOC), September 1997

Committee to Protect Journalists (CPJ). *Attacks on the Press, 2003: Cambodia*, 2003. Online: http://www.cpj.org/attacks03/asia03/cambodia.html

Edman, Brittis. *Trapped in the Past, Seeking out a Future: A Study on the Cambodian Media Sector*. SIDA and Forum Syd, 2000.

Internews, *HIV/AIDS In Cambodia: Internews Assessment* [Annex – Snapshots of media], April 2005

Jarvis, Helen, and Peter Arfanis, et al (Revised and Updated Edition by Helen Jarvis, Christiane Lalobde and Nhean Lakhena). *Publishing in Cambodia*. Center for Khmer Studies, August 2006.

*KAF Democracy Report 2005: Media and Democracy*, Konrad Adenauer Foundation (http://www.kas.de/upload/Publikationen/KAF-dem-rep2005_3-4.pdf.

National Democratic Institute. *The 2002 Cambodian Commune Council Elections, March 20, 2002*. http://www.accessdemocracy.org/library/1390_kh_elec.pdf (pdf)

National Institute of Statistics & Directorate General for Health [Cambodia], and ORC Macro, *Cambodia Demographic and Health Survey 2000*

O'Keefe, Kathleen, *The Media and HIV/AIDS in Cambodia: A Country Assessment*, Internews/DFID, May 2005

Sharpe, Wayne. *Guiding the Development of Free and Responsible Election Coverage: A Canadian Perspective on Media Coverage of Elections in Cambodia*, Canadian Consortium on Human Security, Centre of International Relations, University of British Columbia.

United Nations Cambodia Office of the High Commissioner for Human Rights, *Continuing Patterns of Impunity in Cambodia*, October 2005.

United Nations, *Report of the Secretary General*, Agenda item 112 (b) of the Fiftieth Session of the General Assembly of the United Nations, 26 October 1995.

## អត្ថបទ

Huang, Bonnie. *Camera Shy Broadcasters*. KNIGHTline International: Knight International Press Fellowships News. (Winter 2004): 8-13. http://www.knight-international.org/i/knightlinewinter04.pdf.

Loo, Eric. *Cambodian journalism 'flying blind'*, 2007 in 'Media Development' a publication of the World Association for Christian Communication, http://www.wacc.org.uk/wacc/regional_associations/asia/asian_articles/cambodian_journalism_flying_blind

Lor, Chandara, *Media in Cambodia's Emerging Democracy*, paper presented at "Media and Democracy in Asia" held by the Asian Media Information and Communication Centre, Singapore, 2003. http://seamedia.org/cambodia.php?story_id=164.

Tenove, Chris. *Cambodian media: A 'mad dog' not a watchdog.* UBC Journalism Review. April 2001. http://www.journalism.ubc.ca/thunderbird/archives/2001.04/cambodia.html

Tive, Sarayeth. *Media Reform Experiences In Cambodia*, 2002. http://www.wacc.org.uk/wacc/publications/media_development/archive/2003_1/media_reform_experiences_in_cambodia

## ផ្សេងៗ

Cambodian People's Party, *The People's Magazine*

Club of Cambodian Journalists, list of attacks and threats 1994-2007

Ministry of Information, List of registered media in Cambodia, June 2007.

Press Law (1995), Cambodia. Available at http://www.cdpcambodia.org/press_law.asp.

ឧបត្ថម្ភគាំទ្រពីស្ថានទូតអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ
ដោយប្រើប្រាស់មូលនិធិកម្មវិធីយុទ្ធសាស្ត្ររបស់ FCO